# ថ្ងៃទី០១ ខែ មីនា ឆ្នាំ២០២២

## កម្ពុជា បញ្ជូនពលករ MOU ២៥០នាក់បន្ថែមទៀត ទៅធ្វើការនៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៨ កុម្ភៈ ២០២២ដោយ vann sokunthea

កម្ពុជា បានបញ្ជូនពលករ MOU ប្រមាណ២៥០នាក់ បន្ថែមទៀតទៅធ្វើការនៅប្រទេសថៃនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២នេះ បន្ទាប់ពីបានបញ្ជូនជិត១ពាន់នាក់រួចហើយកាលពីពេលថ្មីៗនេះ។ លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានឱ្យដឹងនៅព្រឹកថ្ងៃទី២៨ កុម្ភៈនេះថា ពលករ២៥០នាក់ ដែលត្រូវបញ្ជូនទៅថ្ងៃនេះ នឹងត្រូវទៅធ្វើការនៅរោងចក្រស៊ីភីជារោងចក្រចំណីអាហារ ធ្វើសាច់មាន់ សាច់ជ្រូកដោយពួកគេម្នាក់ៗទទួលបានប្រាក់ខែពី ៥០០ ទៅ ៧០០ ដុល្លារក្នុង១ខែ ។ លោកបានបន្តថា នេះជាលើកទី៤ហើយដែលកម្ពុជាបានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃក្រោយពីថៃបើកប្រទេសទទួលពលករបរទេសឡើងវិញ ហើយកម្ពុជាជាប្រទេសទី១ដែលថៃទទួលយកពលករមុនគេក្នុងចំណោមប្រទេសនៅអាស៊ាន ដូចជា ឡាវ ភូមា ដោយសារពលករកម្ពុជាបានចាក់វ៉ាក់សាំងបានគ្រប់ដូសរហូតដល់ដូសជំរុញ ឬដូសទី៣ដែលធ្វើឱ្យកម្រិតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ មានកម្រិតទាបបំផុត។

លោកបានបន្តទៀតថា លើកទី១កម្ពុជាបានបញ្ជូនពលករចំនួន ២២០នាក់កាលពីថ្ងៃទី ០១ខែ កុម្ភៈឆ្នាំ២០២២ធ្វើការនៅរោងចក្រសាច់មាន់ លើកទី២ បញ្ជូន៤០០នាក់កាលពីថ្ងៃទី១៥កុម្ភៈ លើកទី៣បញ្ជូន៣៥០នាក់កាលពីថ្ងៃទី២១កុម្ភៈនិងលើកទី៤បញ្ជូន២៥០នាក់នៅថ្ងៃទី២៨ កុម្ភៈដោយពួកគេទៅធ្វើការនៅរោងចក្រស៊ីភីទាំងអស់ ហើយពលករទាំងនោះទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីភាគីថៃទាំងកន្លែងធ្វើចត្តាឡីស័ក និងការផ្តល់ម្ហូបអាហារ។ លោក អន ប៊ុនហាក់ បានបន្ថែមថា ពលករ២៥០នាក់ នឹងត្រូវបញ្ជូនតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតទល់នឹងខេត្តស្រះកែវ។ពេលទៅដល់ព្រំដែនពលករត្រូវធ្វើតេស្ត ហើយបើលទ្ធផលតេស្តអវិជ្ជមានត្រូវបន្តធ្វើចត្តាឡីស័ករយៈពេល៧ថ្ងៃនិងថ្ងៃទី៧ត្រូវធ្វើតេស្តម្តងទៀតបើលទ្ធផលនៅអវិជ្ជមានទៀតទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។ ក្នុងករណីមានវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅកន្លែងព្យាបាល ហើយរាល់កាចំណាយទៅលើការព្យាបាលជាបន្ទុករបស់និយោជកថៃទាំងស្រុង ។ បើតាមលោក អន ប៊ុនហាក់ ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃ ត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា ត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ-១៩ រយៈពេល ៧២ ម៉ោង តាមម៉ាស៊ីន PCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញដើម្បីបញ្ជាក់វិញ្ញាបនបត្រថាមិនមានឆ្លងជំងឺកូវីដ-១៩។ របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថា បច្ចុប្បន្ននេះ កម្ពុជាមានពលករកំពុងធ្វើការងារនៅប្រទេសថៃមានចំនួន ១ ២២០ ១៩៧នាក់ដោយធ្វើលើផ្នែកសំណង់ កសិកម្ម នេសាទនិងរោងចក្រចំណីអាហារ៕ ដោយ៖ សំអឿន

## ស្ថាប័នរដ្ឋ និងវិស័យឯកជនសហការធ្វើយុទ្ធនាការគាំទ្រទិវាអន្តរជាតិ សុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ ២០២២ ដើម្បីរួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 27 February 2022 | 18:51 ICT

**ភ្នំពេញៈ** ស្ថាប័នរដ្ឋ និងវិស័យឯកជនសហការធ្វើយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២២ ដើម្បីរួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវនៅកម្ពុជាខណៈកុមារ និងយុវជនជិត ១០០០ នាក់ បានចូលរួម។ យុទ្ធនាការនេះត្រូវបានធ្វើឡើងជាបន្តបន្ទាប់ចាប់តាំងពីដើមខែកុម្ភៈ មកក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងយ៉ាងទូលំទូលាយអំពីសុវត្ថិ

ភាពអ៊ីនធឺណិតជាពិសេស លើកកម្ពស់ការចូលរួមធ្វើឱ្យបច្ចេកវិទ្យាអ៊ីនធឺណិតកាន់តែមានសុវត្ថិភាពសម្រាប់កុមារ និងការប្រើប្រាស់ ប្រកបដោយការទទួលខុសត្រូវ សេចក្តីគោរព ការគិតពិចារណា និងភាពច្នៃប្រឌិត។

សេចក្តីប្រកាសព័ត៌មានរួមចុះថ្ងៃទី២៥ ខែកុម្ភៈ បានឲ្យដឹងថាយុទ្ធនាការនេះមានគោលដៅដើម្បីផ្សព្វផ្សាយទៅដល់កុមារ និងយុវជនវ័យក្មេង ឪពុកម្តាយ និងអ្នកថែទាំកុមារ គ្រូបង្រៀន អ្នកអប់រំ បុគ្គលិកសង្គម ក្រុមហ៊ុនស៊ីនធឺណិត អ្នកធ្វើការសម្រេចចិត្ត និងអ្នកនយោបាយដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមចំណែកក្នុងការធ្វើឱ្យប្រព័ន្ធអ៊ីនធឺណិតកាន់តែល្អប្រសើរ និងមានសុវត្ថិភាព។

កាលពីថ្ងៃទី២៥ ខែកុម្ភៈ យុទ្ធនាការនេះត្រូវបានធ្វើឡើងតាមប្រព័ន្ធ Zoomដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) សហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) និងសាលាប៊ែលធីអន្តរជាតិ (BELTEI International School) ដែលមានអ្នកចូលរួមជាកុមារ យុវជន លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលាប្រមាណ ២៥០ នាក់។

មិនត្រឹមតែប៉ុណ្ណោះកាលពីថ្ងៃទី០៨ ខែកុម្ភៈ កន្លងទៅ នៅវិទ្យាស្ថានជាតិអប់រំ យុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បី សុវត្ថិភាពអ៊ីនធឺណិតឆ្នាំ២០២២ ក៏ត្រូវបានធ្វើឡើងដោយអង្គការសកម្មភាពដើម្បីកុមារ(APLE)និងស្ថាប័នរដ្ឋឯកជននិងអង្គការសង្គមជាច្រើនទៀតដើម្បីធ្វើការផ្សព្វផ្សាយទៅដល់អ្នកចូលរួមប្រមាណជិត ៤០០ នាក់ ដោយក្នុងនោះភាគច្រើនកុមារ យុវជន។

សេចក្តីប្រកាសព័ត៌មានរួមបានបញ្ជាក់ថា៖«យុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ ២០២២ ប្រារព្ធឡើងក្រោមប្រធានបទ រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ»។

សូមរំឭកថា យុទ្ធនាការសុវត្ថិភាពអ៊ីនធឺណិត ត្រូវបានប្រារព្ធឡើងដំបូងបំផុតនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០០៤ ដោយប្រទេសចំនួន១៤ (១៣ប្រទេសនៅអឺរ៉ុប និងប្រទេសអូស្ត្រាលី) តាមរយៈការសម្របសម្រួលពីបណ្តាញអង្គការជាដៃគូរបស់បណ្តាញសាលារៀននៅសហភាពអឺរ៉ុប (EUN Partnership) ហើយយុទ្ធនាការនេះបានពង្រីកវិសាលភាពរបស់ខ្លួននៅសហភាពអឺរ៉ុប ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់បណ្តាញជាសកលនៃគណៈកម្មាធិការទិវាសុវត្ថិភាពអ៊ីនធឺណិតនៅតាមបណ្តាប្រទេសនានា។ យុទ្ធនាការនេះទទួលការគាំទ្រកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយរហូតមកទល់បច្ចុប្បន្ន ទិវានេះបានក្លាយជា ព្រឹត្តិការណ៍សកលដ៏សំខាន់មួយ ដែលមានប្រទេស និងដែនដីប្រមាណជា២០០នៅទូទាំងពិភពលោកបានចូល រួមប្រារព្ធអបអរសាទរជារៀងរាល់ឆ្នាំ ដោយមានការចូលរួមពីមន្ត្រីរាជរដ្ឋាភិបាល អាជ្ញាធរ សិស្សានុសិស្ស គ្រូ បង្រៀន តំណាងវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ឪពុកម្តាយ និងជាពិសេសកុមារ និងយុវវ័យរាប់លាន នាក់។នេះបើតាមការអះអាងនៅក្នុងសេចក្តីប្រកាសព័ត៌មាន។

ដោយឡែកនៅប្រទេសកម្ពុជា យុទ្ធនាការសុវត្ថិភាពអ៊ីនធឺណិ ត្រូវបានផ្តួចផ្តើមប្រារព្ធឡើងដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ដែលជាអង្គការប្រយុទ្ធប្រឆាំងអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងជាដៃគូគាំទ្រមួយប្រចាំប្រទេសកម្ពុជា នៃគណៈកម្មាធិការរៀបចំទិវាសុវត្ថិភាពអ៊ីនធឺណិត ចាប់តាំងពីឆ្នាំ ២០១៩ មកម្ល៉េះ។ លោក ខឹម វ៉ាន់ដូ ប្រធានបច្ចេកទេសផ្នែកកិច្ចការពារកុមារនៃអង្គការសកម្មភាពដើម្បីកុមារបាននិយាយថាការចូលរួមប្រារព្ធទិវាសុវត្ថិភាពអ៊ិនធឺណិតនេះ បានសំដែងនូវការប្តេជ្ញាចិត្តដ៏មុះមុតរបស់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការការពារកុមារពីគ្រប់ទម្រង់ទាំងអស់នៃការរំលោភបំពានរួមទាំងការរំលោភបំពានតាមប្រព័ន្ធអនឡាញ។ លោកបន្តថាការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធក្នុងពេលនេះ ក៏បានក្លាយជាចំណែកដ៏ធំមួយនៃការផ្លាស់ប្តូរឥរិយាបទ និងការជំរុញលើកទឹកចិត្តឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាអ៊ីនធឺណិតប្រកបដោយការទទួលខុសត្រូវ ការ

គោរព ការចេះគិតពិចារណា និងភាពច្នៃប្រឌិត។ លោកបានបញ្ជាក់ថា៖«យើងសង្ឃឹមថា ទិវានេះនឹងក្លាយទៅជាទិវាជាតិមួយដែលត្រូវប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ»។

កាលពីឆ្នាំ ២០២១ កន្លងមកនេះ អង្គការសកម្មភាពដើម្បីកុមារដោយ ទទួលបានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរដ្ឋមួយចំនួនបានរៀបចំយុទ្ធនាការនេះ ឡើងដោយកំណត់ជាយុទ្ធនាការគាំទ្រ "ទិវាអន្តរជាតិដើម្បីសុវត្ថិភាពអីនធឺណិត និងលើកកម្ពស់សីលធម៌ដើម្បី សុវត្ថិភាពសង្គម" ក្រោមប្រធានបទ"រួមគ្នាធ្វើឱ្យអ៊ីនធឺណិតកាន់តែមានសុវត្ថិភាពសម្រាប់កុមារ" ជាមួយកុមារ យុវជន លោកគ្រូអ្នកគ្រូ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាល។ ជាងនេះទៅទៀត យុទ្ធនាការ ជាស៊េរីផ្សេងទៀត ក៏ត្រូវបានរៀបចំឡើងចាប់តាំងពីថ្ងៃទី០៣ រហូតដល់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ដែលជាយុទ្ធនាការធំចុងក្រោយ។ ជាលទ្ធផល អ្នកចូលរួមសរុបក្នុងយុទ្ធនាការនៅឆ្នាំ២០២១ មានប្រមាណ ៧៤០នាក់ (ស្រី៣៩២នាក់)៕

## ពលករចំណាកស្រុកប្រហែល៣ម៉ឺននាក់ត្រូវគេកេងប្រវ័ញ្ច

https://www.khmertimeskh.com/ ឈុន ស៊ុនលី / Khmer Times February 28, 2022

ក្រសួងមហាផ្ទៃបានសម្តែងការព្រួយបារម្ភថា ពលករចំណាកស្រុកប្រមាណ ៣0000 នាក់ដែលកំពុងធ្វើការនៅប្រទេសថៃកាលពីឆ្នាំមុន ត្រូវបានកេងប្រវ័ញ្ចឱ្យធ្វើការយូរម៉ោង ឬប្រាក់ខែរបស់ពួកគេមិនត្រូវបានផ្តល់ឱ្យពេញលេញដោយសារតែការរីករាលដាលនៃជំងឺកូវិត១៩ ។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស បានមានប្រសាសន៍កាលពីម្សិលមិញក្នុងវេទិកាប្រឆាំងការជួញដូរមនុស្សថា វាជាការប្រសើរសម្រាប់ប្រជាជនកម្ពុជាធ្វើការនៅក្នុងស្រុក ជាជាងការចេញទៅធ្វើការនៅក្រៅប្រទេស និងតស៊ូក្នុងជីវភាពរស់នៅនៅស្រុកគេក្នុងអំឡុងជំងឺរាតត្បាតកូវិត១៩។ អ្នកស្រីបាននិយាយថា រដ្ឋាភិបាលកំពុងមានការព្រួយបារម្ភយ៉ាងខ្លាំងក្នុងការបង់ប្រាក់ចំនួន៣0 ដុល្លារជារៀងរាល់ខែដល់កម្មករកាត់ដេររាប់ពាន់នាក់នៅទូទាំងប្រទេសក្នុងអំឡុងពេលជំងឺរាតត្បាតនេះ ខណៈដែលពួកគេទទួលបានត្រឹមតែ 50% នៃប្រាក់ខែពីនិយោជករបស់ពួកគេ។ លោកស្រីបានបន្តថា៖ «សូម្បីតែការបង់ប្រាក់ ៣០ ដុល្លារសម្រាប់កម្មករម្នាក់ជាចំនួនដ៏ច្រើនសម្រាប់រដ្ឋាភិបាល។ គួរតែគិតឱ្យបានហ្មត់ចត់ថាមួយណាមានប្រយោជន៍ជាង មិនថាស្នាក់នៅក្នុងប្រទេស ឬចំណាកស្រុកទៅធ្វើការនៅប្រទេសផ្សេង»។ អ្នកស្រីបន្ថែមថា មិនមែនលុយតែមួយមុខទេ ព្រោះពួកគេក៏ត្រូវគិតពីគ្រួសារ សុភមង្គលរបស់ពួកគេ ជាពិសេសកូនៗដែលត្រូវការ ការលួងលោម និងភាពកក់ក្តៅរបស់ឪពុកម្តាយរបស់ពួកគេ ក្នុងពេលដែលពិភពលោកកំពុងព្យាយាមប្រយុទ្ធប្រឆាំងនឹងមេរោគឆ្លង។ ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ លោកស្រីថា សូម្បីតែរដ្ឋាភិបាលក៏ប្រឈមនឹងបញ្ហាសេដ្ឋកិច្ចដែរ ប៉ុន្តែនៅតែបន្តជួយប្រជាពលរដ្ឋ ជាពិសេសកម្លាំងពលកម្ម ហើយពួកគេក៏ត្រូវតែជួយខ្លួនឯងដោយធ្វើការងារផ្សេងទៀតដូចជា ធ្វើស្រែចម្ការ ដាំបន្លែ ឬចិញ្ចឹមសត្វជាដើម។ លោកស្រីក៏បានព្រមានប្រជាជនឱ្យប្រុងប្រយ័ត្នចំពោះរបៀបដែលអ្នកជួញដូរមនុស្សប្រើអ៊ីនធឺណិតដើម្បីជ្រើសរើសពួកគេដោយផ្តល់ការងារក្លែងក្លាយ និងការសន្យាហើយបន្ទាប់មកកេងប្រវ័ញ្ចពួកគេដើម្បីប្រាក់ចំណេញ ឬប្រើប្រាស់ពួកគេសម្រាប់សកម្មភាពឧក្រិដ្ឋរបស់ពួកគេ។

លោកស្រី យឹម ស្រីសោភា ដែលធ្វើការជាពលករតាមផ្ទះនៅប្រទេសចិន និងថៃអស់រយៈពេលជិតពីរឆ្នាំមកនេះ បាននិយាយថា នាងបានផ្ញើប្រាក់ដើម្បីផ្គត់ផ្គង់គ្រួសាររបស់នាងជារៀងរាល់ខែ ហើយមនុស្សនៅតែមើលងាយនាងនៅពេលនាងត្រលប់មកផ្ទះវិញ។ ស្ត្រីរូបនេះនិយាយថា៖ « ខ្ញុំមិនគួរទៅបរទេសទេ។ ខ្ញុំគួរតែស្នាក់នៅប្រទេស

របស់ខ្ញុំ ហើយធ្វើអ្វីដែលប្រកបដោយភាពច្នៃប្រឌិត ដើម្បីរកប្រាក់ចំណូលបន្ថែម»។ លោកស្រីបាននិយាយថា អ្វីដែលលោកស្រីនឹកបំផុតពេលទៅធ្វើការនៅបរទេសគឺប្តី និងកូនរបស់លោកស្រី។

អ្នកស្រី ទ្រី សុភា មកពីមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស បានថ្លែងថា ពលករដែលចាញ់បោកនៅក្រៅប្រទេសភាគច្រើនជាស្ត្រី ដោយសារពួកគេងាយរងគ្រោះ ហើយពួកគេផ្តោតលើការជួយគ្រួសាររបស់ពួកគេក្នុងអំឡុងពេលបិទប្រទេស ហើយពួកគេឆ្លងកាត់ប្រទេសថៃតាមព្រំដែនខុសច្បាប់។ អ្នកស្រីថា មាននិយោជកដែលមិនបានបើកប្រាក់ខែកម្មករតាមផ្ទះអស់រយៈពេលជាច្រើនខែក្រោមលេសនៃជំងឺកូវីដ-១៩ ហើយពេលខ្លះពួកគាត់ត្រូវបានគេទម្លាក់នៅតាមព្រំដែនដើម្បីសន្យាផ្តល់ការងារ។ *ប្រែសម្រួលដោយ៖ សុ ជាតា*

## ខេត្តបន្ទាយមានជ័យរកឃើញអ្នកឆ្លងកូវីដបំប្លែងថ្មី(អូមីក្រុង)លើពលករមកពីថៃ១៤១នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១០:៣៤

ខេត្តបន្ទាយមានជ័យ ៖ ខេត្តបន្ទាយមានជ័យមានអ្នកឆ្លងកូវីដ.១៩បំប្លែងថ្មីអូមីក្រុងចំនួន២១៦ករណី ទៅលើពលករមកពីប្រទេសថៃចំនួន១៤១នាក់ នេះគិតត្រឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២ ។

លោកវេជ្ជៈបណ្ឌិត រឿន សុធី អនុប្រធានមន្ទីសុខាភិបាលខេត្តបន្ទាយមានជ័យបានឱ្យដឹងថា ខេត្តបន្ទាយមានជ័យមានអ្នកឆ្លងកូវីដប្រភេទបំប្លែងថ្មី «អូមីក្រុង» មានចំនួន២១៦នាក់ (ស្រី១១៥នាក់) ។ ក្នុងនោះ មានពលករខ្មែរត្រឡប់ពីប្រទេសថៃមានចំនួន១៤១នាក់ (ស្រី៨៤នាក់) ឆ្លងក្នុងសហគមន៍មានចំនួន៧៥នាក់ (ស្រី៣១នាក់) ។

លោកវរសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅបានប្រាប់ថា នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២នេះក្រុមការងារទទួលពលករត្រឡប់ពីប្រទេសថៃ ចូលតាមច្រកអូរបីជាន់ស្រុកអូរជ្រៅ មានចំនួន១៤៧នាក់ (ស្រី៧១នាក់) កុមារ២៤នាក់ (ស្រី១១នាក់) អ្នកវិជ្ជមានកូវីដ.១៩ចំនួន៤នាក់ (ស្រី១នាក់ កុមារ១នាក់) ហើយពលករដែលបានចាក់វ៉ាក់សាំងដូសទី២ និងដូសទី៣ មានចំនួន១១៨នាក់ (ស្រី៥៩នាក់) ។

## ឆ្នាំ២០២១អាជ្ញាធរថៃ បញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ តាមច្រកប៉ោយប៉ែត ជាង៤ពាន់នាក់

https://news.btv.com.kh/ 02/28/2022 11:02 AM

ភ្នំពេញ៖ កាលពីឆ្នាំ២០២១កន្លងទៅ យ៉ាងហោចណាស់ពលករខ្មែរជាង ៤០០០នាក់ បានឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ហើយត្រូវបានអាជ្ញាធរថៃ ចាប់បញ្ជូនមកវិញតាមច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ យោងតាមរបាយការណ៍ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ បានបង្ហាញក្នុងសន្និបាតបូកសរុបលទ្ធផលការងាឆ្នាំ២០២១ និងលើកទិសដៅបន្តឆ្នាំ២០២២ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ បានបង្ហាញថា នៅឆ្នាំ២០២១ សម្រាប់ខេត្តបន្ទាយមានជ័យ មានពលរដ្ឋបានធ្វើការចំណាកស្រុកចំនួនជាង ៦៣ ០០០នាក់ ក្នុងនោះ មានកុមារចំនួនជាង ៧០០០នាក់ និងព្រះសង្ឃចំនួន ៩អង្គ ។ របាយការណ៍ បានបន្តថា នៅឆ្នាំដដែលនេះ អាជ្ញាធរថៃបានចាប់បញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ តាមច្រកអន្តរជាតិប៉ោយប៉ែត ចំនួន៣៤១លើក សរុបចំនួន ៤ ៦៩២នាក់ ក្នុងនោះស្ត្រីចំនួន ២ ១៩៨នាក់ និងកុមារចំនួន ៤៥៩នាក់ ដោយពិនិត្យឃើញវិជ្ជមានកូវីដ១៩ ចំនួន៤៩នាក់ ស្រី ១៩នាក់ ។

ពាក់ព័ន្ធនឹងបញ្ហាឆ្លងដែននេះលោក លី សុវណ្ណារិទ្ធ អភិបាលរងខេត្តបន្ទាយមានជ័យ កាលពីពេលថ្មីៗនេះ បានឲ្យដឹងថា នារយៈពេលចុងក្រោយនេះ សកម្មភាពនៃការឆ្លងដែនរបស់ពលករ មកពីប្រទេសថៃ តាមច្រកនានាជាប់ខេត្តបន្ទាយមានជ័យ នៅតែមានចំនួនច្រើន ដោយ ក្នុងមួយថ្ងៃចាប់ពី ៣០០ ទៅ៥០០នាក់ ។ លោក បានបញ្ជាក់ថា ទន្ទឹមនឹងការវិលត្រឡប់មកនេះ អាជ្ញាធរខេត្ត និងមន្ត្រីជំនាញ បានពិនិត្យសុខភាពយ៉ាងយកចិត្តទុកដាក់

រួមទាំងអ្នកមិនទាន់បានចាក់វ៉ាក់សាំងកូវីដ១៩ ត្រូវបានបញ្ជូនទៅចាក់វ៉ាក់សាំងឲ្យបានគ្រប់គ្នា រួមទាំងការឲ្យធ្វើចត្តាឡីស័កឲ្យបានត្រឹមត្រូវ ខណៈអ្នកមានវិជ្ជមានកូវីដ១៩ ត្រូវបញ្ជូនទៅព្យាបាល ។

គួរបញ្ជាក់ថា នៅខេត្តបន្ទាយមានជ័យនេះ កាលពីឆ្នាំ២០២១កន្លងទៅ តាមច្រកមួយចំនួន ជាប់ខេត្ត ដូចជាច្រកបឹងត្រកួន ច្រកប៉ោយប៉ែត ច្រកអូរបីជាន់ និងច្រកស្រុកម៉ាឡៃជាដើម មានសកម្មភាពពលករឆ្លងដែន មកពីប្រទេសថៃរាល់ថ្ងៃ ធ្វើឲ្យអាជ្ញាធរខេត្ត បានពង្រីកនូវមណ្ឌលចត្តាឡីស័ក ឬមណ្ឌលព្យាបាលអ្នកជំងឺកូវីដ១៩ ហើយអំឡុងនៃការឆ្លងរាលដាលនៃជំងឺនេះ ក៏មានសកម្មភាពលួចឆ្លងដែនខុសច្បាប់ ត្រូវបានអាជ្ញាធរទាំងខ្មែរ និងថៃចាប់បញ្ជូនមកវិញ ខណៈមេខ្យល់ដែលជាអ្នកនាំផ្លូវមួយចំនួន ត្រូវបានឃាត់ខ្លួន បញ្ជូនទៅតុលាការផងដែរ ៕ សុខរិទ្ធ

## ជនជាតិចិនធ្វើជាទាសករលក់ឈាម» នៅខេត្តព្រះសីហនុ

https://kohsantepheapdaily.com.kh/ ភ្នំពេញ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ម៉ោង ១៤:៣០

រាជធានីភ្នំពេញ ៖ អគ្គស្នងការដ្ឋាននគរបាលជាតិ នៅថ្ងៃទី២៨ ខែកុម្ភៈនេះ បានច្រានចោលនូវការផ្សព្វផ្សាយព័ត៌មាន កាលពីពេលថ្មីៗកន្លងទៅនេះដោយចោទប្រកាន់ថា មានការចាប់បង្ខាំងជនជាតិចិនធ្វើជាទាសករលក់ឈាម នៅតំបន់ឆៃណាថោន ខេត្តព្រះសីហនុ ដែលការផ្សព្វផ្សាយបែបនេះបានធ្វើឲ្យប៉ះពាល់បរិយាកាស និងចិត្តសាស្រ្តសង្គម ព្រមទាំងធ្វើឲ្យមានការភ័ន្តច្រឡំពីសំណាក់សាធារណៈមតិជាតិ អន្តរជាតិជាច្រើន ។

អ្នកនាំពាក្យនៃអគ្គស្នងការដ្ឋាននគរបាលជាតិបានបញ្ជាក់ថា ពាក់ព័ន្ធករណីនេះ អ្នកនាំពាក្យនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សូមបញ្ជាក់ជូនថា ៖ បន្ទាប់ពីទទួលបានព័ត៌មានអកុសលខាងលើ អគ្គស្នងការដ្ឋាននគរបាលជាតិបានចង្អុលដឹកនាំ អង្គភាពជំនាញឲ្យចុះធ្វើការស្រាវជ្រាវ ស៊ើបអង្កេតជាបន្ទាន់ ដោយធ្វើការត្រួតពិនិត្យទីតាំងពាក់ព័ន្ធជាច្រើនកន្លែង និងប្រមូលចម្លើយសាក្សីមួយចំនួន ព្រមទាំងបានរកឃើញថា ព័ត៌មានខាងលើជាព័ត៌មានប្រឌិត ដែលរៀបចំដោយឈ្មោះ LYA YUAN LUN ភេទប្រុស ជនជាតិចិន អាយុ៣១ឆ្នាំ (ស្នាក់នៅព្យាបាលនៅមន្ទីរពេទ្យ បឹងធនកម្ពុជា-ចិន រាជធានីភ្នំពេញ) និងអ្នកពាក់ព័ន្ធចំនួន០៣នាក់ ដែលក្នុងនោះ ៖

១.ឈ្មោះ LI YA YUAN LUN ដែលអះអាងថា ជាជនរងគ្រោះ ជាតុពិតជនរូបនេះបានលួចឆ្លងដែនចូលប្រទេសកម្ពុជាដោយខុសច្បាប់ ប៉ុន្តែអាស្រ័យដោយមានជំងឺប្រចាំកាយក៏បានទាក់ទងមនុស្សមួយក្រុម ដើម្បីជួយរកវិធីដោះស្រាយបញ្ហារបស់ខ្លួន ។

២.អ្នកពាក់ព័ន្ធចំនួន ០៣នាក់ គឺជាអ្នកជួយដល់ឈ្មោះ L YA YUAN LUN ក្នុងការរៀបចំគម្រោង ប្រឌិតព័ត៌មានក្លែងក្លាយអំពីការបង្ខាំងមនុស្សធ្វើទារុណកម្ម និងធ្វើជាទាសករលក់ឈាម ដើម្បីជាលេសជួយដល់ឈ្មោះ LI YA YUAN LUN គេចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់នៅកម្ពុជា ។

សមត្ថកិច្ចប៉ូលិសបានបន្តថា បច្ចុប្បន្នឈ្មោះ LYAYUANLUN និងអ្នកពាក់ព័ន្ធចំនួន០៣នាក់ ស្រី០១នាក់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមផ្លូវច្បាប់ ។

ក្នុងនាមអ្នកនាំពាក្យនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សូមអំពាវនាវដល់គ្រប់មជ្ឈដ្ឋាន សារព័ត៌មាន និងប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមទាំងអស់ធ្វើការកែសម្រួលឡើងវិញនូវការផ្សព្វផ្សាយព័ត៌មានប្រឌិតខាងលើ ដើម្បីចៀសវាងការភ័ន្តច្រឡំពីសាធារណៈមតិជាតិ អន្តរជាតិ។ អ្នកនាំពាក្យនៃអគ្គស្នងការដ្ឋាននគរបាលជាតិបានបន្តថា «ទន្ទឹមគ្នានេះ យើងខ្ញុំក៏មានសំណូមពរដល់អ្នក សារព័ត៌មាន និងអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមទាំងអស់គប្បីគោរពឲ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌ វិជ្ជាជីវៈ ដោយមិនត្រូវផ្សព្វផ្សាយព័ត៌មានដែលគ្មានប្រភពច្បាស់លាស់ ជាពិសេសចៀសវាងធ្វើការសន្និដ្ឋាន ហេតុការណ៍ណាមួយដោយអត្តនោម័ត ពុំមានភស្តុតាងច្បាស់លាស់ នាំឲ្យប៉ះ

ពាល់ដល់បរិយាកាសសង្គម និង បង្កឲ្យមានភាពភ័យខ្លាចដល់ទេសចរណ៍ជាតិ អន្តរជាតិ និងអ្នកវិនិយោគបរទេស នៅកម្ពុជា» ៕

# ថ្ងៃទី០២ ខែ មីនា ឆ្នាំ២០២២

## អ្នកនាំពាក្យស្ថានទូតចិន អំពាវនាវពលរដ្ឋខ្លួន នៅកម្ពុជា គោរពច្បាប់ ក្រោយនគរបាលខ្មែរ រកឃើញករណី «ទាសករលក់ឈាម» ជាការប្រឌិត

https://dap-news.com/ ByDR103Posted on March 1, 2022

**ភ្នំពេញ ៖ អ្នកនាំពាក្យស្ថានទូតចិនប្រចាំកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍ នៅថ្ងៃទី២៨ កុម្ភៈ ស្តីពីក្រុមប៉ូលិសកម្ពុជា បានស្រាវជ្រាវរកឃើញថា សំណុំរឿង «ទាសករលក់ឈាមជនជាតិចិន» ថាជាការប្រឌិត ។ ក្រោយមានករណីនេះ អ្នកនាំទូតចិន ក៏បានអំពាវនាឲ្យពលរដ្ឋខ្លួន កំពុងរស់នៅកម្ពុជា គោរពច្បាប់របស់កម្ពុជា-ចិន ។ នេះបើតាមការចេញផ្សាយ នៅក្នុងផេកហ្វេសប៊ុកលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌ មាននៅថ្ងៃ១ មីនា ។**

ថ្មីៗនេះមានការផ្សាយថា មានករណីចាប់បង្ខាំង ជនជាតិចិនធ្វើជាទាសករលក់ឈាមនៅតំបន់ឆៃណាថោន ក្នុងខេត្តព្រះសីហនុទេ ។ អ្នកនាំពាក្យគូសបញ្ជាក់ថា ស្ថានទូតមានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះករណី «ទាសករលក់ឈាម» ដែលបានផ្សាយតៗគ្នា តាមប្រព័ន្ធអ៊ីនធឺណិត បន្ទាប់ពីបានជំរុញឲ្យប៉ូលិសកម្ពុជា បើកសំណុំរឿងនេះ ដោយចាប់ផ្តើមស៊ើបអង្កេត នៅថ្ងៃ១៥ កុម្ភៈមក ស្ថានទូតចិនបន្តតាមដានដំណើរការ ស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់។ កាលពីថ្ងៃ២៨ កុម្ភៈ ប៉ូលីសកម្ពុជាបានជូនដំណឹង ទៅស្ថានទូតចិន អំពីលទ្ធផលស៊ើបអង្កេតបឋម និងបានចេញសេចក្តីប្រកាសថា សំណុំរឿងទាសករលក់ឈាម គឺជារឿងប្រឌិតសុទ្ធសាធ។ អ្នកនាំពាក្យបញ្ជាក់ទៀតថា យោងតាមរបាយការណ៍ផ្ទៃក្នុង និងសេចក្តីប្រកាសរបស់នគរបាលកម្ពុជា បានឲ្យដឹងថា លោក Li Yayuanlun ជនជាតិចិន បានចូលមកកម្ពុជា ដោយខុសច្បាប់ ហើយក្រោយមកបានមាន ជំងឺថ្លើមធ្ងន់ធ្ងរ ក៏បានទាក់ទងសមាគមមួយ ដើម្បីសុំជំនួយ។ ដោយគោលបំណងផ្សេងៗគ្នា មានមនុស្ស៣នាក់ជាជួយ Li Yayuanlun ប្រឌិតរឿងនេះឡើង និងផ្សព្វផ្សាយព័ត៌មានក្លែងក្លាយថា"គាត់ត្រូវបានឃុំខ្លួនដោយខុសច្បាប់ រំលោភបំពាន និងធ្វើបាបដូចទាសករលក់ឈាម" ទង្វើនេះបំភ័ន្តមតិសាធារណៈ និងធ្វើឲ្យប៉ះពាល់ ដល់សណ្តាប់ធ្នាប់សង្គមយ៉ាងធ្ងន់ធ្ងរ។ ជំហានបន្ទាប់ពួកគេនឹងត្រូវ បញ្ជូនទៅស្ថាប័នតុលាការកម្ពុជា ដើម្បីកាត់ទោស។

អ្នកនាំពាក្យមានប្រសាសន៍បន្តថា "ស្ថានទូតរបស់យើងសូមអំពាវនាវ ដល់ពលរដ្ឋចិននៅកម្ពុជា គោរពតាមច្បាប់របស់ប្រទេសចិន និងកម្ពុជា ការពារសិទ្ធិរបស់ពួកគេ ដោយសមហេតុផល និងមិនត្រូវប្រឌិតពាក្យចចាមអារ៉ាម និងបោកបញ្ឆោតសាធារណជនឡើយ ។ យើងសូមអំពាវនាវ ដល់សាធារណជនទូទៅ មេត្តាបើកភ្នែកឲ្យធំៗ ចេះបែងចែកខុសត្រូវ មិនត្រូវឲ្យជនខិលខូច បោកប្រើឲ្យសោះ"។ អ្នកនាំពាក្យគូសបញ្ជាក់បន្ថែមថា នៅជំហានបន្ទាប់ ស្ថានទូតចិននឹងបន្តតាមដានការសវការ លើករណីនេះ នឹងនៅតែបន្តការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ របស់ភាគីពាក់ព័ន្ធ ក្រោមក្របខណ្ឌច្បាប់របស់ចិន-កម្ពុជា ។ បើតាមអ្នកនាំពាក្យដដែល ស្ថានទូតចិននឹងបន្តគាំទ្រ សហការជាមួយភ្នាក់ងារអនុវត្តច្បាប់កម្ពុជា និងបន្តពង្រឹងការបង្ក្រាបបទល្មើសបោកប្រាស់ និងបទល្មើសល្បែងស៊ីសង តាមប្រព័ន្ធអ៊ីនធឺណេត និងបទល្មើសពាក់ព័ន្ធ ការឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយពលរដ្ឋចិន ដើម្បីធានាឲ្យមានប្រសិទ្ធភាព នូវសុវត្ថិភាពអាយុជីវិត និងទ្រព្យសម្បត្តិរបស់ពលរដ្ឋចិន នៅកម្ពុជា៕

## ចំនួនពលករខ្មែរវិលមកពីថៃ
## តាមច្រកខេត្តបាត់ដំបងថយចុះ ខណៈមួយចំនួនវិជ្ជមានកូវីដ-១៩

https://btv.com.kh/ 03/01/2022 01:03 PM

បាត់ដំបង៖ ចំនួនពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ ចូលតាមច្រកខេត្តបាត់ដំបង ក្នុងមួយរយៈពេលចុងក្រោយនេះ មានការថយចុះជាបន្តបន្ទាប់ ខណៈពលករមួយចំនួនតូច ត្រូវបានរកឃើញឆ្លងជំងឺកូវីដ-១៩។

លោក ណាត ចាន់រ៉េត ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន ស្ទឹងស្ទឹងសុ (អូរអន្លក់) ស្រុកកំរៀង បានឱ្យដឹងថា ពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃទាំងអស់ ត្រូវបានយកសំណាកធ្វើ តេស្តរហ័សរកជំងឺកូវីដ-១៩ នៅច្រកព្រំដែន ហើយចំពោះអ្នកវិជ្ជមាន ក្រុមគ្រូពេទ្យ នឹងបញ្ជូនទៅព្យាបាល អ្នកអវិជ្ជមានគ្មានកាតចាក់វ៉ាក់សាំង ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ក ហើយអ្នកអវិជ្ជមាន មានកាតចាក់វ៉ាក់ សាំងពីរដូស ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន។ ប្រធានច្រកព្រំដែនរូបនេះ បានបញ្ជាក់ថា មួយរយៈពេលចុងក្រោយនេះ លំហូរពលករថយចុះ ប៉ុន្តែ ក្នុងចំណោមពលករចូលមកជាង ១០០នាក់ ក្នុងមួយថ្ងៃ មានចន្លោះពី១ទៅ៥នាក់ ត្រូវបានធ្វើតេស្តរហ័ស រកឃើញឆ្លងជំងឺកូវីដ-១៩ ខណៈពេលមុនលំហូរពលករកើនឡើង តែចំនួនរកឃើញឆ្លងមេរោគកូវីដ-១៩ មានតិចតួច ឬស្ទើរតែគ្មាន។

លោក បានបញ្ជាក់ថា ដើម្បីទប់ស្កាត់ការចម្លងមេរោគកូវីដ-១៩ បំប្លែងថ្មីប្រភេទអូមីក្រុង វិធានការ សុខាភិបាលនៅច្រកព្រំដែន ត្រូវបានរឹតបន្តឹងដោយគ្មានការធ្វេសប្រហែសឡើយ ទោះបីលំហូរពលករខ្មែរ វិលត្រឡប់មកពីប្រទេសថៃ មានការថយចុះ ហើយពលករភាគច្រើនមានកាតចាក់វ៉ាក់សាំងចាប់ពីពីរដូស ឡើងទៅក៏ដោយ។ ក្នុងមួយរយៈពេលចុងក្រោយនេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងខេត្តបាត់ដំបង មានការ ហាក់ឡើងបន្តិចវិញ ក្រោយមានការស្ងប់ស្ងាត់មួយរយៈពេលធំ។ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលឆ្លង ជំងឺកូវីដ-១៩ កងកម្លាំងចម្រុះការពារព្រំដែនក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើការទំនាក់ទំនង និងសហការយ៉ាងជិតស្និទជាមួយភាគីថៃ ដើម្បីទប់ស្កាត់មិនឲ្យប្រជាពលរដ្ឋខ្មែរលបលួចឆ្លងដែនចូលទៅក្នុង ទឹកដីថៃដោយមិនស្របច្បាប់ នឿត សុភក្រ្ត

## ១ ខែកុម្ភៈ ពលករខ្មែរជាង ១ ពាន់នាក់ ត្រូវបានបញ្ជូនទៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១ មីនា ២០២២ដោយ KC Virak

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២២នេះ កម្ពុជាបានបញ្ជូនពលករ MOU ប្រមាណជាង ១ ពាន់នាក់ទៅធ្វើការនៅប្រទេសថៃ ក្រោយពីប្រទេសថៃបានបើកប្រទេសឡើងវិញ។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានឱ្យដឹងថា ក្នុងខែកុម្ភៈ ឆ្នាំ២០២២នេះ កម្ពុជាបានបញ្ជូនពលករចំនួន ១១២០ នាក់ទៅធ្វើការនៅប្រទេសថៃ ចែកជា៤លើក។ ក្នុងនោះលើកទី១ បានបញ្ជូនពលករចំនួន ២២០ នាក់ កាលពីថ្ងៃទី០១ ខែកុម្ភៈ ទៅធ្វើការនៅរោងចក្រសាច់មាន់ លើកទី២ បញ្ជូន ៤០០ នាក់ កាលពីថ្ងៃទី១៥ កុម្ភៈ លើកទី៣បញ្ជូន ៣៥០ នាក់ កាលពីថ្ងៃទី២១ កុម្ភៈ និងលើកទី៤បញ្ជូន ២៥០ នាក់នៅថ្ងៃទី២៨ កុម្ភៈ ដោយពួកគេទៅធ្វើការនៅរោងចក្រស៊ីភីទាំងអស់ ហើយពលករទាំងនោះទទួលបានការយកចិត្តទុកដាក់ពីភាគីថៃទាំងកន្លែងធ្វើចត្តាឡីស័ក និងការផ្តល់ម្ហូបអាហារ។ លោក អន ប៊ុនហាក់ មានប្រសាសន៍ថា កម្ពុជាបានចាប់ផ្តើមបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃឡើងវិញ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២២នេះ បន្ទាប់ពីប្រទេសថៃបានបើកទទួលពលករបរទេសឡើងវិញពិសេសប្រទេសមួយចំនួននៅតាមតំបន់អាស៊ានដូចជា ឡាវ ភូមា និងកម្ពុជា។ លោក បានបន្តថា ក្នុងចំណោមពលករទាំងនោះ ពលករកម្ពុជាត្រូវបានភាគីថៃទទួលយកមុនគេ ដោយសារ

ពលករកម្ពុជាបានចាក់វ៉ាក់សាំងបានគ្រប់ដូសរហូតដល់ដូសជំរុញ ឬដូសទី៣ ដែលធ្វើឱ្យកម្រិតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ មានកម្រិតទាបបំផុត។

ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា រូបនេះបានបន្តទៀតថា សម្រាប់នៅខែមីនា ឆ្នាំ២០២២នេះ កម្ពុជាគ្រោងនឹងបន្តបញ្ជូនពលករជាបន្តបន្ទាប់ទៀតដោយសារភាគីថៃមានតម្រូវការកម្លាំងពលកម្មច្រើន ហើយចំពោះតួលេខពលករដែលត្រូវបញ្ជូននៅមិនទាន់បានដឹងនៅឡើយទេ។ លោកបានបន្ថែមថា ពលករទៅធ្វើការនៅប្រទេសថៃទទួលបានប្រាក់ខែចាប់ពី ៥០០ ទៅ ៧០០ ដុល្លារក្នុង ១ខែ។ លោក អន ប៊ុនហាក់ បានបញ្ជាក់ទៀតថា ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា ត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ-១៩ រយៈពេល ៧២ ម៉ោង តាមម៉ាស៊ីន PCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញដើម្បីបញ្ជាក់វិញ្ញាបនបត្រថាមិនមានឆ្លងជំងឺកូវីដ-១៩។ ពលករទាំងនោះត្រូវបញ្ជូនតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតទល់នឹងខេត្តស្រះកែវ។ ពេលទៅដល់ព្រំដែនពលករត្រូវធ្វើតេស្ត ហើយបើលទ្ធផលតេស្តអវិជ្ជមានត្រូវបន្តធ្វើចត្តាឡីស័ករយៈពេល ៧ថ្ងៃ និងថ្ងៃទី៧ ត្រូវធ្វើតេស្តម្តងទៀត បើលទ្ធផលនៅអវិជ្ជមានទៀត ទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។ ក្នុងករណីមានវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនទៅកន្លែងព្យាបាល ហើយរាល់ការចំណាយទៅលើការព្យាបាលជាបន្ទុករបស់និយោជកថៃទាំងស្រុង។

យោងតាមរបាយការណ៍របស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា បច្ចុប្បន្នកម្ពុជាមានពលករកំពុងធ្វើការងារនៅប្រទេសថៃមានចំនួន ១ ២២០ ១៩៧ នាក់ ដោយធ្វើលើផ្នែកសំណង់ កសិកម្ម នេសាទ និងរោងចក្រចំណីអាហារ៕ អត្ថបទ៖ សំអឿន

## នគរបាលជាតិ កម្ពុជា និងអូស្ត្រាលី
## ប្តេជ្ញាគៀកស្មា ដើម្បីប្រយុទ្ធប្រឆាំងជាមួយបទឧក្រិដ្ឋ ដែលមានអង្គការចាត់តាំង

https://cen.com.kh/ Posted ByPen Srey NeatMarch 1, 2022

ភ្នំពេញ ៖ ព្រឹកថ្ងៃអង្គារ ទី០១ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអញ្ជើញជួបប្រជុំទ្វេភាគីជាមួយអគ្គស្នងការនគរបាលសហពន្ធ័អូស្ត្រាលីដឹកនាំដោយ ឯកឧត្តម Reece Philip Kershaw នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានចាត់ទុកដំណើរទស្សនកិច្ចរបស់ ឯកឧត្តមអគ្គស្នងការនគរបាលសហព័ន្ធអូស្ត្រាលី នៅពេលនេះ គឺជាដំណើរទស្សនកិច្ច ដ៏ពិសេសមួយដែលបានចូលរួមប្រជុំជាទ្វេភាគីជាមួយនគរបាលជាតិកម្ពុជាផង និងក្នុងនាមជាដៃគូរបស់អាស៊ានណាប៉ូលផង។ ក្នុងឱកាសនោះដែរ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក៏បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការ រវាងនគរបាលប្រទេសទាំងពីរ ជាពិសេសការអនុវត្ត MOU ដែលភាគីទាំងពីរបានចុះហត្ថលេខានៅពេលកន្លងមក។ ក្រៅពីនោះភាគីអូស្ត្រាលី ក៏បានជួយគាំទ្រទាំងឧបករណ៍ និងសម្ភារៈព្រមទាំងជួយដល់ការបណ្តុះបណ្តាល រួមទាំងពង្រឹងក្រុមការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានការិយាល័យនៅក្នុងទីតាំងអគ្គស្នងការដ្ឋាននគរបាលជាតិនេះផ្ទាល់ហើយ ការិយាល័យនេះ ក៏បានក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាលកងកម្លាំងនគរបាលកម្ពុជា ពាក់ព័ន្ធនិងការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនទៀតផង។

ក្រៅពីនោះភាគីទាំងពីរក៏បានផ្លាស់ប្តូរព័តមានពីគ្នាទៅវិញទៅមកជាច្រើនរួមមាន៖ សកម្មភាពបទល្មើសគ្រឿងញៀន និងការជួញដូរមនុស្ស ដែលក្នុងខណៈនោះ ឯកឧត្តម នេត សាវឿន ក៏បានរំលឹកឡើងវិញពីជំនួយរបស់ភាគីអូស្ត្រាលី ក្នុងការពង្រឹងនគរបាលសហគមនៅកម្ពុជា ដែលបច្ចុប្បន្ននេះ បើទោះបីជានគរបាលអូស្ត្រាលីបានបញ្ចប់គម្រោងនិងដកមន្ត្រីជំនាញ ព្រមទាំងថវិកាក្នុងការជួយក្តី ក៏នគរបាលកម្ពុជានៅតែបន្តស្មារតីនេះ ដើម្បី

ជានានិរន្តភាព នៃការអនុវត្តគម្រោងនេះ។ ក្រៅពីនោះកម្ពុជា និងអូស្ត្រាលី ក៏បានសហការគ្នាក្នុងការបង្ក្រាបអង្គការចាត់តាំងម៉ូតូធំ មិនឲ្យកើតមាននៅកម្ពុជា ទៀតផង។

ជាកិច្ចឆ្លើយតបក្នុងជំនួប ឯកឧត្តម Reece Philip Kershaw អគ្គស្នងការនគរបាលសហព័ន្ធអូស្ត្រាលី បានថ្លែងអំណរគុណ ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគី របស់នគរបាលប្រទេសទាំងពីរ។ ឯកឧត្តម Reece Philip Kershaw បានបញ្ជាក់ថា ក្នុងកិច្ចសហប្រតិបត្តការជាង២០ឆ្នាំ រវាងនគរបាលកម្ពុជា និងអូស្ត្រាលី ដែលបន្សល់ទុកនៅសមិទ្ធិផលជាច្រើន ព្រមទាំងបានធ្វើឲ្យចំណងមិត្តភាពនេះ ក្លាយទៅជាមិត្តភាពជាប្រពៃណី។ ក្នុងឱកាសនោះ ឯកឧត្តមអគ្គស្នងការនគរបាលសហព័ន្ធអូស្ត្រាលី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះកិច្ចសហការរបស់នគរបាលកម្ពុជា ពាក់ព័ន្ធនិងការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការបង្ការទប់ស្កាត់ពីចំងាយគ្រឿងញៀនទៅអូស្ត្រលី ក៏ដូចជាក្រុមម៉ូតូធំ។ ពាក់ព័ន្ធកិច្ចនេះ ឯកឧត្តម បានប្តេជ្ញាគៀកស្មា ជាមួយកម្លាំងនគរបាលជាតិកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងជាមួយបទឧក្រិដ្ឋ ដែលមានអង្គការចាត់តាំងឲ្យបានជោគជ័យ។

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិបាន ក៏បានឯកភាពចំពោះការប្តេជ្ញាចិត្តរបស់ ឯកឧត្តមអគ្គស្នងការនគរបាលសហព័ន្ធអូស្ត្រាលី និងបានលើកសំណូមពរមួយចំនួនដើម្បីឲ្យភាគីអូស្ត្រាលី ធ្វើការពិចារណាៈ ទី១-ស្នើសុំអោយមានការគាំទ្រពាក់ព័ន្ធនិងការផ្លាស់ប្តូរព័តមាននានា ដែលពាក់ព័ន្ធដល់ព្រឹត្តិការណ៍នយោបាល ក៏ដូចជាព្រឹត្តិការណ៍តំបន់ដែលពាក់ព័ន្ធជាមួយកម្ពុជា ដែលឆ្នាំ២០២២-២០២៣នេះ កម្ពុជានឹងមានការបោះឆ្នោតឃុំ សង្កាត់ ការបោះឆ្នោតសភាជាតិ ដោយឡែកកម្ពុជានឹងធ្វើជាម្ចាស់ នៃកិច្ចប្រជុំកំពូលអាស៊ាន និងវេទិកាសំខាន់មួយទៀតគឺការប្រកួតកីឡាស៊ីហ្គេម ដែលជាព្រឹត្តការណ៍ទី១ សម្រាប់កម្ពុជា ដែលត្រូវទទួលរ៉ាប់រងជាម្ចាស់ផ្ទះ ជាពិសេសគឺការផ្តល់ជាបទពិសោធន៍មកដល់នគរបាលកម្ពុជា ចំពោះកិច្ចការពារព្រឹត្តការណ៍ទាំងអស់នេះ តាមរយៈការប្រជុំតាមវីដេអូពីចម្ងាយ រឺក៏អាចចាត់បញ្ជូនផ្លាស់ប្តូរគណៈប្រតិភូ ក្នុងក្របខណ្ឌពាក់ព័ន្ធនិងកិច្ចការពារនេះ។

ក្រៅពីនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក៏បានស្នើសុំឲ្យភាគីអូស្ត្រាលី ជួយពង្រឹងធនធានមនុស្ស ពាក់ព័ន្ធបទល្មើសសម្អាតប្រាក់ បទល្មើសសេដ្ឋកិច្ច បទល្មើសពាក់ព័ន្ធបច្ចេកវិទ្យា ដែលចាត់ទុកជាបញ្ហាថ្មីសម្រាប់កម្ពុជា។ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក្នុងជំនួបក៏បានថ្លែងគាំទ្រខ្ពស់ ចំពោះការលើកឡើងរបស់ភាគីអូស្ត្រាលី អំពីលទ្ធផលដ៏ល្អប្រសើរ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ រយៈពេល២០ឆ្នាំ ជាលក្ខណប្រពៃណីនេះ ហើយបានឯកភាពដើរទៅមុខរួមគ្នា ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសគ្រប់ប្រភេទ គ្រប់ទម្រង់ ដើម្បីជានាសន្តិសុខ សុវត្ថិភាពក្នុងប្រទេសក៏ដូចជា ក្នុងតំបន់ផងដែរ ។ បន្ថែមពីនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន ក៏បានបញ្ជាក់អំពីបញ្ហាប្រឈម ជាសត្យានុម័តមួយចំនួន ពាក់ព័ន្ធដល់និន្នាការគ្រឿងញៀននៅកម្ពុជា រួមទាំងការគ្រប់គ្រងសារធាតុគីមីផ្សំ សម្រាប់សំយោគកែច្នៃផលិតគ្រឿងញៀនផងដែរ ដែលបញ្ហានេះបានផ្លាស់ប្តូរយោបល់ និងពិសោធន៍ទៅវិញទៅមក និងប្តេជ្ញារួមគ្នាផ្លាស់ប្តូរព័ត៌មាន ក្នុងន័យពង្រឹងកិច្ចសហប្រតិបត្តការ ការបណ្តុះបណ្តាល ដើម្បីទប់ស្កាត់នូវបទឧក្រិដ្ឋ ពិសេសទប់ស្កាត់គ្រឿងញៀនអោយបានពីចម្ងាយ។ ជាការឆ្លើយតប ភាគីអូស្ត្រាលី ពេញចិត្តក្នុងការធ្វើកិច្ចសហប្រតិបត្តិការ ដែលជាសំណូមពររបស់ភាគីកម្ពុជា និងសន្យាជួយជ្រោមជ្រែងដល់ភាគីកម្ពុជា ទាំងពិសោធន៍ និងកិច្ចការផ្សេងៗទៀតដែលអាចធ្វើទៅបាន៕ សុទ្ធ លី

## រកឃើញពលករខ្មែរ ០២ នាក់ វិជ្ជមានជំងឺកូវីដ-១៩ ក្នុងចំណោមពលករ ៧១នាក់ ដែលភាគីថៃចាប់បញ្ជូនមកស្រុកកំណើត

https://gntimes.com/ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២

បាត់ដំបង៖ ពលករខ្មែរ ០២នាក់ ត្រូវបានក្រុមគ្រូពេទ្យតេស្តរហ័សរកឃើញផ្ទុកជំងឺកូវីដ-១៩ ក្នុងចំណោមពលករខ្មែរ ៧១នាក់ ដែលភាគីថៃចាប់បញ្ជូនមកកាន់ស្រុកកំណើតនាព្រឹកថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០២២ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសេរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ បានឲ្យដឹងថា ករណីរកឃើញវិជ្ជមានជំងឺកូវីដ-១៩ លើស្ត្រីពលករខ្មែរ ០២នាក់ នេះ បានកើតឡើងបន្ទាប់ពីកម្លាំងប៉ុស្តិ៍គីឡូ ១៣ សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន និងកម្លាំងយោធាវរសេនាតូច ៥៣៣ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកគីឡូ ១៣ ស្រុកសំពៅលូន ។ បន្ទាប់ពីសាកសួរកត់ឈ្មោះ ចុះកំណត់ហេតុរួចឃើញថា ពលករខ្មែរសរុបទាំងអស់ ៧១នាក់ ស្រី ៣០នាក់ និងក្មេង ២នាក់ ហើយត្រូវបានក្រុមគ្រូពេទ្យធ្វើតេស្តរហ័សចេញលទ្ធផល វិជ្ជមានជំងឺកូវីដ-១៩ ០២នាក់ (ស្រី) បន្ទាប់មកក្រុមគ្រូពេទ្យបញ្ជូនទៅកាន់មណ្ឌលព្យាបាលកូវីដ-១៩ ស្ថិតក្នុងភូមិអូរកណ្តោល ឃុំសន្តិភាព ស្រុកសំពៅលូន ហើយចំពោះពលករខ្មែរ ៤០នាក់ (ស្រី ១៧នាក់) ត្រូវបានក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតវិញរៀងៗខ្លួន ដោយឡែក អ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្លែនអត់ចេញ មាន ២៩នាក់ ស្រី ១១នាក់ និងក្មេង ០២នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ៕

## ថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង ផ្តល់អនុសាសន៍ចំនួន០៥ ដល់សន្និសីទអាស៊ានណាប៉ូល លើកទី៤០ ដើម្បីបន្តពង្រឹងទំនាក់ទំនងសហប្រតិបត្តិការអាស៊ានឱ្យកាន់តែប្រសើរឡើង

https://www.gntimes.com/ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២

ភ្នំពេញ ៖ ក្នុងស្មារតីបន្តពង្រឹងទំនាក់ទំនងសហប្រតិបត្តិការអាស៊ានឱ្យកាន់តែប្រសើរឡើង ក៏ដូចជាការគាំទ្រលើកទឹកចិត្តដល់កិច្ចខិតខំប្រឹងប្រែងនានា ស្របតាមខ្លឹមសារ នៃប្រធានបទរបស់អាស៊ានណាប៉ូល លើកទី៤០ ក្នុងឱកាសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុពិធីបើកសន្និបាតអាស៊ានណាប៉ូល លើកទី៤០ នាព្រឹកថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានផ្តល់នូវអនុសាសន៍សំខាន់ៗចំនួន០៥ ដល់សន្និសីទអាស៊ានណាប៉ូល លើកទី៤០ ដែលរួមមាន ៖

ទី១-អនុវត្តសេចក្តីថ្លែងការណ៍រួម នៃសន្និសីទអាស៊ានណាប៉ូល លើកទី៣៩ គ្រប់គណៈកម្មការជំនាញ A B C នឹងពិនិត្យឡើងវិញនូវសកម្មភាពទាំងឡាយដែលសម្រេចបាន ក្នុងរយៈពេល ០២ឆ្នាំកន្លងទៅ ព្រមទាំងបន្តពិភាក្សារិះរកនូវវិធានការគន្លឹះនានា ដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍រួមរបស់សន្និសីទអាស៊ានណាប៉ូលលើកទី៤០ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់រួមគ្នាប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ និងគ្រប់ទម្រង់ថ្មីៗ សំដៅរួមចំណែករក្សាស្ថិរភាពសន្តិសុខ និងសុវត្ថិភាពក្នុងសហគមន៍អាស៊ាន និងលើសកលលោក។

ទី២-អាស៊ានណាប៉ូល បានបង្កើតឡើងនូវក្របខ័ណ្ឌការងារ និងពិធីសារមួយចំនួន ដើម្បីពង្រីក និងលើកកម្ពស់ប្រសិទ្ធភាពសហប្រតិបត្តិការក្នុងក្របខ័ណ្ឌ តំបន់ និងអន្តរជាតិ។ កត្តាគន្លឹះសំខាន់នោះគឺ ត្រូវតែធ្វើឱ្យពិធីសារទាំងនោះ ក្លាយជាឯកសារដែលមានចលនាផ្តល់ប្រយោជន៍ទៅវិញទៅមក តាមរយៈការរៀបចំយន្តការ និង

ផែនការសកម្មភាពជាក់ស្តែង ឆ្លើយតបយ៉ាងសមស្របទៅតាមគោលបំណង និងសំណូមពរ ព្រមទាំងខ្លឹមសារ នៃពិធីសារសហប្រតិបត្តិការដែលបានឯកភាពគ្នាបង្កើតឡើង។

ទី៣-គិតចាប់ពីឆ្នាំ១៩៨៨ រហូតដល់ពេលនេះ អាស៊ានណាប៉ូលមានដៃគូសន្ទនាចំនួន ១១ប្រទេស/ស្ថាប័ន ដែលវឌ្ឍនភាពនេះ បានឆ្លើយតបយ៉ាងពេញលេញ ស្របតាមចក្ខុវិស័យនៃសហគមន៍អាស៊ាន ក្នុងការធ្វើការឱ្យកាន់តែស៊ីជម្រៅ នៃតំណរភ្ជាប់អន្តរតំបន់ ដោយលើកស្ទួយភាពជាដៃគូ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។ សម្តេចក្រឡាហោម សូមលើកទឹកចិត្តក្នុងការបន្តពង្រីកទំនាក់ទំនង បង្កើតបន្ថែមទៀតនូវដៃគូសន្ទនា សំដៅប្រមូលផ្តុំនូវថាមពលគាំទ្រធ្វើឱ្យសហគមន៍អាស៊ាន កាន់តែរឹងមាំ និងលេចធ្លោប្រកបដោយកិត្យានុភាព។

ទី៤-គោលដៅអាទិភាពរបស់អាស៊ាននាពេលខាងមុខគឺ អាស៊ានរួមគ្នាធ្វើ ការដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា ដោយដាក់ចេញនូវគោលដៅពង្រឹងសសរស្តម្ភទាំង០៣ ដែលក្នុងនោះ បណ្តាចំណុចអាទិភាពនៃសហគមន៍នយោបាយ សន្តិសុខ គឺជាស្នូល និងជាបង្អែកសម្រាប់បម្រើឱ្យប្រយោជន៍ និងវឌ្ឍនភាពនៃសហគមន៍និងសេដ្ឋកិច្ច និងសហគមន៍សង្គមវប្បធម៌អាស៊ាន។ ដូច្នេះកិច្ចប្រជុំនៃគណៈកម្មការជំនាញនីមួយៗ គប្បីរិះរកនូវមធ្យោបាយ ឬវិធីសាស្ត្រគន្លឹះសំដៅ លើកកម្ពស់ប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ តាមគ្រប់ទម្រង់ និងគ្រប់រូបភាព ដើម្បីរក្សាស្ថិរភាព សន្តិសុខ និងសុវត្ថិភាពសង្គម នាំមកនូវវិបុលភាពសម្រាប់សហគមន៍ ពិសេសការបង្កើតបរិយាកាសអំណោយ ផលគាប់ប្រសើរសម្រាប់គាំទ្រដល់ការស្ទុះងើបឡើងនៃប្រទេសនីមួយៗ ក៏ដូចជាតំបន់ទាំងមូល បន្ទាប់ពីការញាំញីដោយជំងឺកូវីដ-១៩។

ទី៥-រហូតមកដល់ពេលនេះ យើងក៏ពិនិត្យឃើញដែរថា សមត្ថភាព ជំនាញវិជ្ជាជីវៈ រវាងកងកម្លាំងអនុវត្តនៃបណ្តាប្រទេសជាសមាជិកអាស៊ានណាប៉ូល នៅតែមិនទាន់មានតុល្យភាព ដែលធ្វើឱ្យលទ្ធផលនៃកិច្ចសហប្រតិបត្តិការក្នុង ចំណោមប្រទេសជាសមាជិកនៅមានកម្រិត ដែលបញ្ហានេះក៏ជាការផ្តល់ឱកាសដល់ពួកឧក្រិដ្ឋជនពង្រីកសកម្មភាព នៅតាមគោលដៅដែលមិនទាន់រឹងមាំ។ ក្នុងន័យនេះ កត្តាចម្បងបំផុតរបស់អាស៊ានណាប៉ូលនាពេលខាងមុខ គឺត្រូវយកចិត្តទុកដាក់ខ្ពស់ ក្នុងកិច្ចសហការជាមួយដៃគូពិភាក្សា ជួយគាំទ្រគ្នាទៅវិញទៅមក ក្នុងការកសាងធនធានមនុស្សបង្កើតឱ្យបាននូវតុល្យភាពរវាងដៃគូសហប្រតិបត្តិការ អនុវត្តច្បាប់ ទាំងក្នុង និងក្រៅតំបន់ ដោយមានផែនការបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈ និងការផ្លាស់ប្តូរបទពិសោធន៍ល្អៗ រវាងកងកម្លាំងអនុវត្តច្បាប់៕

## កម្លាំងសមត្ថកិច្ចចម្រុះសន្តិសុខការពារខ្សែបន្ទាត់ព្រំដែនស្រុកសំពៅលូនកម្ពុជា-ថៃ បានទទួលពលករខ្មែរ វិលត្រឡប់មកកម្ពុជាវិញមានចំនួន៧១នាក់តាមចំណុចពោធិ៍ជ្រៃ

http://nokorwatnews.com/ 02/03/2022

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៦និង០០នាទី នាព្រឹកថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹង ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ដោយមានអនុវត្តតាមបទបញ្ជារបស់ លោក សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោក ហាត ឡៃឡេ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោក ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោក ពៅ ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូល

មកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្ត បាត់ដំបង ចំនួន៧១នាក់ ស្រី៣០នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារហាមឃាត់(ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) ជាលទ្ធផល÷ ដកហូតបានកាំបិត០៣ដើម រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល÷ វិជ្ជមានចំនួន០២នាក់ បន្ទាប់មកក្រុមគ្រូពេទ្យបានបញ្ជូនអ្នកវិជ្ជមានចំនួន០២នាក់(ស្រី) ទៅកាន់មណ្ឌលព្យាបាលកូវីដ-១៩ ស្ថិតក្នុងភូមិអូរកណ្ដាល ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ហើយក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនចំនួន៤០នាក់ ស្រី១៧នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្តែនអត់ចេញ ចំនួន២៩នាក់ ស្រី១១នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## អង្គការសិទ្ធិមនុស្សថា កម្ពុជានៅតែមានពលកម្មកុមារកម្រិតខ្ពស់

https://www.rfa.org/ ដោយ មួង ណារ៉េត2022-02-27

អង្គការសង្គមស៊ីវិលផ្នែកសិទ្ធិមនុស្សពិនិត្យឃើញថា កម្ពុជានៅតែមានពលកម្មកុមារកម្រិតខ្ពស់នៅឡើយ ដែលទាមទារឱ្យរដ្ឋាភិបាលត្រូវខិតខំបន្ថែមទៀតដើម្បីដោះស្រាយបញ្ហានេះ។ ប៉ុន្តែមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលអះអាងថា ពលកម្មកុមារត្រូវបានកាត់បន្ថយច្រើនមកហើយ និងថារដ្ឋាភិបាលកំពុងបន្តដោះស្រាយបញ្ហានេះថែមទៀត។ ក្រុមអង្គការសង្គមស៊ីវិល អំពាវនាវដល់រដ្ឋាភិបាលឱ្យយកចិត្តទុកដាក់ខ្ពស់លើរឿងពលកម្មកុមារ ដោយសារបញ្ហានេះ នៅតែកើតមានច្រើន និងកំពុងគំរាមកំហែងដល់អនាគតកុមារកម្ពុជាជាច្រើនរូប។

នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការសិទ្ធិមនុស្សលីកាដូ (LICADHO) លោក អំ សំអាត ទទួលស្គាល់ថា រដ្ឋាភិបាលតាមរយៈក្រសួងការងារ បានចុះអប់រំផ្សព្វផ្សាយអំពីពលកម្មកុមារ ក៏ប៉ុន្តែចំណាត់ការនេះមិនទាន់អាចដោះស្រាយបញ្ហាពលកម្មកុមារ ឱ្យមានប្រសិទ្ធភាពនៅឡើយទេ។ លោកបន្តថា ការប្រើប្រាស់ពលកម្មកុមារនៅតែបន្តកើតមានតាមសិប្បកម្មឡឥដ្ឋ រោងចក្រសហគ្រាសខ្នាតតូច និងមធ្យម ព្រមទាំងការងារតាមផ្ទះ។ លោកយល់ថា ក្រសួងការងារគួរតែចាត់ទុកការលុបបំបាត់ពលកម្មកុមារ ជាបញ្ហាអាទិភាពមួយដែលត្រូវដោះស្រាយសម្រាប់ឆ្នាំ ២០២២ និងសម្រាប់ពេលអនាគត៖ «ពលកម្មលើកុមារនេះ ក៏វាជារឿងមួយដែលធ្ងន់ធ្ងរដែរ ហើយកន្លងមក យើងក៏ឃើញមានសហរដ្ឋអាមេរិក និងប្រទេសមួយចំនួនទៀត មានការចាប់អារម្មណ៍ដែរ។ ហើយក្នុងហ្នឹងរឿង GSP (ការអនុគ្រោះពន្ធទូទៅ) និងរឿងផ្សេងៗទៀត ក៏គេភ្ជាប់ជាមួយនឹងទម្រង់នៃពលកម្មអាក្រក់របស់កុមារហ្នឹងផងដែរ។ ខ្ញុំមើលទៅ វានៅតែជាអាទិភាពរបស់ក្រសួងការងារក្នុងការដាក់ទិសដៅក្នុងការទប់ស្កាត់ទម្រង់ពលកម្មអាក្រក់លើកុមារបន្តទៀត»។

ការលើកឡើងរបស់តំណាងអង្គការសិទ្ធិមនុស្សនេះ កើតមានឡើងក្រោយពីក្រសួងការងារបានបិទបញ្ចប់សន្និបាតបូកសរុបលទ្ធផលការងាររបស់ខ្លួនសម្រាប់ឆ្នាំ ២០២១ និងលើកទិសដៅការងារបន្តសម្រាប់ឆ្នាំ២០២២ កាលពីពេលថ្មីៗនេះ។ ក្រសួងការងារឱ្យដឹងតាមសេចក្ដីជូនដំណឹងថា ក្នុងឆ្នាំ២០២១ កន្លងទៅ ក្រសួងបានចុះផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ ហើយបានដកហូត និងទប់ស្កាត់ពលកម្មកុមារចំនួន ៣៥០ នាក់។ ក្រសួងបានដាក់ទិសដៅការងារចំនួន ១៤ ចំណុចដែលត្រូវអនុវត្តបន្តនៅឆ្នាំ២០២២ ក៏ប៉ុន្តែមិនមានចំណុចណាមួយនិយាយអំពីការទប់ស្កាត់ពលកម្មកុមារឡើយ។ វិទ្យុអាស៊ីសេរីមិន

អាចទាក់ទងអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ ដើម្បីបកស្រាយរឿងនេះបានទេ ប៉ុន្តែតំណាងស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាលអះអាងថា ពលកម្មកុមារនៅកម្ពុជាមិនមានកម្រិតធ្ងន់ធ្ងរដូចពីមុននោះទេ។

សមាជិក និងជាអ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាលោក កត្តា អ៊ន ថ្លែងថា យោងតាមរបាយការណ៍ចុងក្រោយឆ្នាំ២០២២ របស់ក្រសួងការងារ ករណីពលកម្មកុមារមានការកាត់បន្ថយច្រើន។ ជាពិសេសលោកអះអាងថា ពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋលែងមានតទៅទៀតហើយ ហើយពលកម្មកុមារដែលនៅមានខ្លះៗនោះ គឺការងារតាមផ្ទះ។ លោកបញ្ជាក់ថា រដ្ឋាភិបាលនៅតែយកចិត្តទុកដាក់ខ្ពស់ក្នុងការទប់ស្កាត់ពលកម្មកុមារ និងស្វាគមន៍កិច្ចសហការជាមួយភាគីពាក់ព័ន្ធ រួមទាំងអង្គការសង្គមស៊ីវិលផងដែរ៖ «របាយការណ៍ទូទាំងប្រទេសចំពោះសិប្បកម្មឡឥដ្ឋ យើងលែងមានបញ្ហាពលកម្មកុមារទៀតហើយ ប៉ុន្តែនៅមានភាពមិនប្រក្រតីមួយចំនួន ដូចជា បញ្ហាពលកម្មកុមារនៅតាមផ្ទះ ដែលជាបញ្ហាមួយ ដែលយើងត្រូវមានកិច្ចសហប្រតិបត្តិការគ្នាទាំងស្ថាប័នរដ្ឋ ទាំងស្ថាប័នឯកជន ជាពិសេសអង្គការសង្គមស៊ីវិល ពីព្រោះបញ្ហាកុមារនេះ ជាបញ្ហាសិទ្ធិមនុស្ស ជាបញ្ហាសំខាន់ដែលយើងទាំងអស់គ្នាត្រូវតែលុបបំបាត់»។ ផ្ទុយពីការបកស្រាយរបស់មន្ត្រីរដ្ឋាភិបាលនេះ របាយការណ៍នានាសុទ្ធតែបង្ហាញថា ពលកម្មកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា ស្របពេលព័ត៌មានស្ដីពីគ្រោះថ្នាក់ការងារកើតលើកុមារបានលេចចេញជាហូរហែ។

សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC) បានស្រាវជ្រាវនៅតាមសិប្បកម្មឡឥដ្ឋប្រមាណ ៣០កន្លែងនៅខេត្តជុំវិញរាជធានីភ្នំពេញ កាលពីឆ្នាំ ២០១៨ ដោយរកឃើញថា កុមារអាយុក្រោម ១៨ឆ្នាំជាង ៦រយនាក់ (៦០០) ធ្វើការជាមួយឪពុកម្ដាយក្នុងសិប្បកម្មឡឥដ្ឋ ហើយករណីបែបនេះនៅតែបន្តកើតមានដដែលមកដល់ពេលបច្ចុប្បន្ន។

ស្របគ្នានេះដែរ របាយការណ៍ស្ដីពីពលកម្មកុមារ និងពលកម្មដោយបង្ខំ ចេញផ្សាយដោយក្រសួងការងារសហរដ្ឋអាមេរិកកាលពីខែកញ្ញា ឆ្នាំ២០២១ បង្ហាញថា កម្ពុជាមានការវិវត្តន៍តិចតួចស្ដួចស្ដើងបំផុតក្នុងការដោះស្រាយបញ្ហាពលកម្មកុមារ។ ក្រសួងការងារសហរដ្ឋអាមេរិកគូសបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាខកខានមិនបានចាត់វិធានការឱ្យសកម្ម ដើម្បីស៊ើបអង្កេត ចោទប្រកាន់ និងផ្ដន្ទាទោសលើមន្ត្រីសាធារណៈទាំងឡាយណា ដែលចូលរួម ឬជួយសម្រួលដល់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ រួមទាំង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងពលកម្មដោយបង្ខំដើម្បីដោះបំណុលនៅសិប្បកម្មឡឥដ្ឋនោះឡើយ។ បន្ថែមពីលើនេះ ចៅក្រមមួយចំនួនត្រូវបានគេរាយការណ៍ថាទទួលសំណូកជាថ្នូរនឹងការមិនចោទប្រកាន់ ការទម្លាក់ចោលបទចោទប្រកាន់ និងការបន្ធូរបន្ថយទោសចំពោះបុគ្គលដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ។ ជាមួយគ្នានេះ ធនធានមិនគ្រប់គ្រាន់បានធ្វើឱ្យរាំងស្ទះដល់សមត្ថភាពការងាររបស់អាជ្ញាធរ ជាពិសេសនៅតាមទីជនបទ ដែលជាកន្លែងសម្បូរដោយពលករជាកុមារ។ ក្រៅពីនេះ កង្វះការអប់រំជាមូលដ្ឋាន និងការមិនកំណត់លក្ខខណ្ឌតម្រូវក្នុងការអប់រំ ក៏បង្កើនភាពងាយរងគ្រោះសម្រាប់កុមារក្នុងការធ្លាក់ចូលអន្លង់នៃពលកម្មកុមារធ្ងន់ធ្ងរផងដែរ។

អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក (ADHOC) លោក ស៊ឹង សែនករុណា សង្កេតឃើញថាពលកម្មកុមារនៅតែកើតមានច្រើននៅឡើយ មិនដូចការអះអាងរបស់មន្ត្រីរដ្ឋាភិបាលនោះទេ។ លោកទទួលស្គាល់កិច្ចខិតខំរបស់ស្ថាប័នពាក់ព័ន្ធក្នុងការទប់ស្កាត់បញ្ហានេះ ប៉ុន្តែលោកថា ស្ថាប័នទាំងនោះក៏គួរទទួលយក និងហ៊ានធ្វើរបាយការណ៍ផ្អែកលើការពិតផងដែរ ទើបករណីពលកម្មកុមារអាចដោះស្រាយបានប្រកបដោយប្រសិទ្ធភាព៖ « បញ្ហាពលកម្មកុមារនេះ អត់ទាន់បានបញ្ចប់នៅក្នុងប្រទេសកម្ពុជាយើងនៅឡើយទេ អ៊ីចឹងគប្បីមានការដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្របន្តទៀត។ ហើយ(រដ្ឋាភិបាល)គួរតែមានយន្តការ ឬវិធីសាស្ត្របែបណា ដើម្បីទប់ស្កាត់

ហើយនិងជួយឱ្យកុមារដែលទទួលរងការប្រើប្រាស់អំពើពលកម្មកុមារហ្នឹង ឱ្យពួកគេទទួលបានឱកាសទាំងការសិក្សា ទាំងជីវភាពរស់នៅរបស់ក្រុមគ្រួសារគេហ្នឹង គឺឱ្យមានភាពល្អប្រសើរ»។

បើតាមក្រុមអង្គការសង្គមស៊ីវិលក្នុងស្រុក ពលកម្មកុមារនៅកម្ពុជាផ្ដើមចេញពីកត្តាមួយចំនួន មានជាអាទិ៍ ភាពក្រីក្រ បំណុល ភាពអត់ការងារធ្វើ និងការបាត់បង់ដីធ្លី។ ពួកគេស្នើយ៉ាងទទូចដល់រដ្ឋាភិបាលឱ្យបង្កើតការងារកាន់តែច្រើនសម្រាប់ពលរដ្ឋ ដាក់ចេញយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រឱ្យមានប្រសិទ្ធភាព និងដោះស្រាយវិវាទដីធ្លីរបស់ពលរដ្ឋឱ្យបានត្រឹមត្រូវជាដើម។

ជាមួយគ្នានេះ ក្រសួងការងារសហរដ្ឋអាមេរិកបានផ្ដល់អនុសាសន៍ជាច្រើនចំណុចដល់រដ្ឋាភិបាលកម្ពុជាដើម្បីដោះស្រាយបញ្ហាពលកម្មកុមារ។ អនុសាសន៍ទាំងនោះ មានជាអាទិ៍ ធានាឱ្យបាននូវក្របខណ្ឌច្បាប់សម្រាប់គាំពារកុមារ ពង្រឹងការអនុវត្តច្បាប់ និងមុខងាររបស់មន្ត្រីជំនាញ ការពារជនរងគ្រោះពីការបំភិតបំភ័យ ផ្សព្វផ្សាយសកម្មភាព គោលនយោបាយ និងក្របខ័ណ្ឌច្បាប់នានាពាក់ព័ន្ធនឹងកិច្ចគាំពារកុមារ បង្កើតកម្មវិធីសង្គមនានាដើម្បីធានាថា កុមារទទួលបានសេវាព្យាបាល ថែទាំ និងអប់រំត្រឹមត្រូវ ព្រមទាំងពង្រីកសំណាញ់សុវត្ថិភាពគាំពារសង្គមនៅតំបន់ជនបទ ជាដើម។

ក្រុមអង្គការសិទ្ធិមនុស្សសង្កត់ធ្ងន់ថា ពលកម្មកុមារបង្កផលប៉ះពាល់ជាច្រើនដល់អនាគតរបស់ពួកគេ ដូចជា ធ្វើឱ្យកុមារបាត់បង់ឱកាសក្នុងការសិក្សា ប៉ះពាល់ការលូតលាស់ផ្នែករាងកាយ និងប្រាជ្ញាស្មារតី ហើយបើធ្ងន់ធ្ងរខ្លាំងអាចបណ្ដាលឱ្យកុមារធ្លាក់ខ្លួនពិការ ឬបាត់បង់ជីវិតផងក៏មាន ហេតុនេះ ការទប់ស្កាត់ពលកម្មកុមារប្រៀបបាននឹងការជួយដល់ពួកគេឱ្យទទួលបានការលូតលាស់ ឱកាស និងអនាគតភ្លឺស្វាងយ៉ាងដូច្នេះដែរ៕

## កម្ពុជា ស្នើប្រទេសសមាជិកអាស៊ាន ណាប៉ូលរួមគ្នាប្រយុទ្ធ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ

https://www.kampucheathmey.com/ ថ្ងៃពុធ ២ មីនា ២០២២ដោយ Sophal Tuon

សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបាន ស្នើដល់ប្រទេស សមាជិកអាស៊ានណាប៉ូល ត្រូវបង្កើនកិច្ចសហប្រតិបត្តិការ និងរួមគ្នាប្រយុទ្ធ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ សំដៅរួមចំណែករក្សាស្ថិរភាពសន្តិសុខ និងសុវត្ថិភាពក្នុងសហគមន៍អាស៊ាន និងលើសកលលោក។

ថ្លែងនៅក្នុងពិធីបើកសន្និសីទអាស៊ានណាប៉ូលលើកទី៤០ នៅព្រឹកថ្ងៃ ០២ មីនា នៅសណ្ឋាគារសុខាភ្នំពេញ ក្នុងនាមជាម្ចាស់ផ្ទះ សម្ដេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា ប្រទេសសមាជិកអាស៊ានណាប៉ូលទាំងអស់ ត្រូវរិះរកនូវវិធានការគន្លឹះនានា ដាក់បញ្ចូលក្នុងសេចក្ដីថ្លែងការណ៍រួមរបស់សន្និសីទ អាស៊ានណាប៉ូលលើកទី៤០ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់រួមគ្នាប្រយុទ្ធ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ និងគ្រប់ទម្រង់ថ្មីៗ ដើម្បីរក្សាស្ថិរភាព សន្តិសុខ និងសុវត្ថិភាពសង្គម នាំមកនូវវិបុលភាពសម្រាប់សហគមន៍ ពិសេសការការបង្កើតបរិយាកាសអំណោយផលគាប់ប្រសើរសម្រាប់គាំទ្រដល់ការស្ទុះងើបឡើងនៃប្រទេសនីមួយៗ ក៏ដូចជា តំបន់អាស៊ានទាំងមូល។

លើសពីនេះទៀត សម្ដេចក្រឡាហោម ស ខេង បានជំរុញឱ្យប្រទេសសមាជិកអាស៊ានណាប៉ូលទាំងអស់ត្រូវពង្រឹង និងជំរុញសកម្មភាពនៃយន្តការ និងប្រព័ន្ធផ្លាស់ប្ដូរព័ត៌មានដែលមានស្រាប់ឱ្យដំណើរការកាន់តែស៊ីសង្វាក់ និងមានប្រសិទ្ធភាពខ្ពស់ ពិសេសការបន្តប្រើប្រាស់នូវប្រព័ន្ធ e-ADS-2.0 ឱ្យអស់ពីសក្ដានុពល ដោយបន្តធ្វើការអភិវឌ្ឍប្រព័ន្ធនេះឱ្យកាន់តែទំនើប ព្រមទាំងបន្តពង្រីក និងរក្សានិរន្តភាពសហប្រតិបត្តិការតាមរយៈប្រព័ន្ធ 1-

24/7 ដើម្បីជាប្រយោជន៍បម្រើដល់កិច្ចការជំនាញស្រាវជ្រាវ ស៊ើបអង្កេត និងតាមចាប់ខ្លួនពួក ឧក្រិដ្ឋជនយកមកផ្តន្ទាទោសតាមផ្លូវច្បាប់។

ទន្ទឹមនឹងនេះ សម្តេចក្រឡាហោម ក៏បានលើកឡើងពីសមត្ថភាព ជំនាញវិជ្ជាជីវៈ រវាងកងកម្លាំងអនុវត្តនៃបណ្តាប្រទេសជាសមាជិកអាស៊ានណាប៉ូល នៅតែមិនទាន់មានតុល្យភាព ដែលធ្វើឱ្យលទ្ធផលនៃកិច្ចសហប្រតិបត្តិការ ក្នុងចំណោមប្រទេសជាសមាជិកនៅមានកម្រិត ដែលបញ្ហានេះ ក៏ជាការផ្តល់ឱកាស ដល់ពួកឧក្រិដ្ឋជនពង្រីកសកម្មភាព នៅតាមគោលដៅដែលមិនទាន់រឹងមាំ។

សម្តេចក្រឡាហោម បានបន្ថែមថា ក្នុងន័យនេះ កត្តាចម្បងបំផុតរបស់អាស៊ានណាប៉ូលនាពេលខាងមុខ គឺត្រូវយកចិត្ត ទុកដាក់ខ្ពស់ក្នុងកិច្ចសហការជាមួយដៃគូពិភាក្សា ជួយគាំទ្រគ្នាទៅវិញទៅមកក្នុង ការកសាងធនធានមនុស្ស បង្កើតឱ្យបាននូវតុល្យភាពរវាងដៃគូសហប្រតិបត្តិការ អនុវត្តច្បាប់ ទាំងក្នុង និងក្រៅតំបន់ ដោយមានផែនការបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈ និងការផ្លាស់ប្តូរបទពិសោធន៍ល្អៗ រវាងកងកម្លាំងអនុវត្តច្បាប់។

នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិបានថ្លែងបញ្ជាក់ថា សន្និសីទអាស៊ានណាប៉ូល គឺជាវេទិកាដ៏សំខាន់មួយក្នុងការភ្ជាប់ទំនាក់ទំនង និង ការលើកកម្ពស់ភាពជាដៃគូ ភាពខ្លាំងរបស់យើងគឺកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញ ទៅមក ហេតុនេះក្នុងសភាពការណ៍បច្ចុប្បន្នយើងត្រូវបន្តពង្រឹង និងប្រតិបត្តិគោលការណ៍នេះ ឱ្យកាន់តែខ្លាំងថែមទៀត អាស្រ័យដោយយើងកំពុងជួបបញ្ហាប្រឈមជាច្រើន ដែលទាមទារ ឱ្យមានកិច្ចប្រឹងប្រែង និងឆ្លើយតបរួមគ្នា។ នាយឧត្តមសេនីយ៍ បានបង្ហាញក្តីសង្ឃឹមយ៉ាងមុតមាំក្នុងការរួមចំណែកស្វែងរកយុទ្ធសាស្ត្រ វិធីសាស្ត្រ និងវិធីដែលមានសក្តានុពល ដើម្បីការពារផលប្រយោជន៍ និងសុខដុមរមនាជានាស្ថិរភាព សុវត្ថិភាពសង្គម ក្នុងតំបន់ ពិសេសជួយគ្នាក្នុងការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម ក្នុងបរិបទកូវីដ១៩៕ សំអឿន

## ថ្ងៃទី០៤ ខែ មីនា ឆ្នាំ២០២២

## ដោយសារកូវីដផងនិងនឹកផ្ទះផង ពលករជាច្រើននាំគ្នាវិលត្រឡប់មកស្រុកកំណើតវិញ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៣ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ១៥:៥២

ខេត្តបន្ទាយមានជ័យ ៖ រយៈពេលត្រឹមតែ៣ថ្ងៃដើមខែមីនា ២០២២ ភាគីថៃបានបញ្ជូនពលករខ្មែរត្រឡប់តាមច្រកតំបន់ និងអន្តរជាតិក្នុងខេត្តបន្ទាយមានជ័យ ហាក់ច្រើនខុសសព្វមួយដង គឺមានចំនួនជាង១០០០នាក់ ។ នេះបើតាមការឱ្យដឹងពីមន្ត្រីជំនាញ ។ របាយការណ៍ពលករបញ្ជូនត្រឡប់ពីថៃនៅថ្ងៃទី៣នេះ ដ្បិតក្រុមមន្ត្រីជំនាញមិនទាន់បង្ហើបឲ្យដឹង ព្រោះកំពុងធ្វើការនៅឡើយ ប៉ុន្តែសម្រាប់ថ្ងៃទី១ និងទី២ មីនា មានពលករជិត ១០០០នាក់ (ស្រី៣៨០នាក់, កុមា១៣២នាក់) បានគេបញ្ជូនដល់ទឹកដីកំណើតវិញហើយ។

ប្រភពពីមន្ត្រីប្រាប់ថា កាលពីថ្ងៃទី១ មីនា មានពលករចំនួន២៨២នាក់ (ស្រី១០៤នាក់,កុមា៤៧នាក់) ។ ក្នុងចំណោមនេះ ពលករចំនួន១៧៧នាក់ត្រូវភាគីថៃបញ្ជូនតាមច្រករបៀងអូរបីជាន់ ក្នុងស្រុកអូរជ្រៅជាច្រកកិច្ចព្រមព្រៀង(MOU) រវាងខេត្តបន្ទាយមានជ័យកម្ពុជានិងស្រះកែវថៃ៨៧នាក់ តាមច្រកតំបន់ម៉ាឡៃ១៥នាក់ តាមច្រកតំបន់បឹងត្រកួន និង៣នាក់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត។

ថ្ងៃទី២ មីនា ចំនួន៦៨៧នាក់ (ស្រី២៧៦ កុមា៨៥នាក់) ដោយ៣១៨នាក់ និងតាមច្រករបៀងអូរបីជាន់, ច្រកតំបន់ម៉ាឡៃ១៥៣នាក់, ច្រកតំបន់បឹងត្រកួន២៤នាក់ និង១៩២តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត។ មន្ត្រីដដែលគូសបញ្ជាក់ថា រយៈពេល៣ថ្ងៃចុងក្រោយនៃដើមខែមីនានេះ មានពលករជាច្រើនត្រូវបានភាគីថៃបញ្ជូនមក

ឲ្យភាគីកម្ពុជាតាមច្រកអន្តរជាតិ,ច្រកតំបន់ និងច្រកកិច្ចព្រមព្រៀងMOU(ច្រករបៀងអូរបីជាន់)ក្នុងខេត្តបន្ទាយមានជ័យ។

សាកសួរករណីភាគីថៃបញ្ជូនពលករត្រឡប់នេះ មន្ត្រីខាងលើប្រាប់ថា យោងការសួរនាំក្រុមពលករប្រាប់ថាពួកគេមិនបានវិលចូលស្រុកកំណើត២ឆ្នាំមកហើយ ដោយសារមេរោគកូវីដ ។ ម្យ៉ាងទៀតក៏នឹកក្រុមគ្រួសារទើបនាំគ្នាជួលរថយន្តជិះបម្រុងមកព្រំដែនដោយខ្លួនឯង តែត្រូវសមត្ថកិច្ចថៃឃាត់សួរនាំនិងដឹកបញ្ជូនវិញ ខណៈមួយចំនួនទៀត ត្រូវសមត្ថកិច្ចថៃចាប់តាមដងផ្លូវពេលកំពុងធ្វើដំណើរត្រឡប់។ មន្ត្រីជំនាញបន្តថា ពលករទាំងអស់ក្រោយទទួលពីភាគីថៃត្រូវដឹកទៅកាន់មណ្ឌលសំចតរបស់ក្រសួងសង្គមកិច្ច ដែលមានការិយាល័យនៅក្រុងប៉ោយប៉ែត ដើម្បីធ្វើតេស្តិរហ័ស ។មន្ត្រីបន្តទៀតថា ពលករដែលបានចាក់វ៉ាក់សាំង២ដូស ឬ៣ដូសរួចហើយ គឺអនុញ្ញាតឲ្យវិលត្រឡប់ទៅស្រុកកំណើត។ ដោយឡែក អ្នកទើបបានចាក់ដុសទី១ ឬមិនទាន់បានចាក់សោះ នឹងបញ្ជូនទៅធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កកូបជំក្នុងសង្កាត់និមិត្តក្រុងប៉ោយប៉ែត។ ចំពោះអ្នកដែលធ្វើតេស្តិរហ័សរកឃើញមានវិជ្ជមាន គឺបញ្ជូនទៅព្យាបាលនៅមណ្ឌលចត្តាឡីស័កកងវ៉ាក្នុងក្រុងសិរីសោភ័ណ។ យ៉ាងណាក៏ដោយ មន្ត្រីដដែលលើកឡើងថា រាល់ពលករបញ្ជូនពីថៃអ្នកមិនទាន់ចាក់វ៉ាក់សាំងឬអ្នកធ្វើតេស្តិវិជ្ជមានមានតិចតួចណាស់៕

## កម្លាំងនគរបាលការពារព្រំដែន
## កម្ពុជា-ថៃ ទទួលបញ្ជូនពលករខ្មែរ១១៨ នាក់វិលត្រឡប់ចូលកម្ពុជាវិញ

http://nokorwatnews.com/ 02/04/2022

ខេត្តបាត់ដំបង ៖ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ កាលពីរសៀលថ្ងៃទី ២ ខែមីនាឆ្នាំ ២០២២ នេះ បានដឹកនាំកម្លាំងចុះទៅសហការជាមួយកម្លាំងប៉ុស្តិ៍គីឡូ១៣ កម្លាំងយោធាផ្នែកសឹករងសំពៅលូន និងកម្លាំងយោធាវរសេនាតូច៥៣៣ ដើម្បីទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពី ប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ នៅត្រង់ភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន ១១៨នាក់ (ស្រី ៣១នាក់) ក្មេង ១៤នាក់ (ក្មេងស្រី ០៥នាក់) ។

ប្រភពពីមន្ត្រីនគរបាលការពារព្រំដែនកម្ពុជា- ថៃ ឈរជើងនៅចំណុចខាងលើបានឲ្យដឹងថា បងប្អូនទាំងអស់នេះបានទៅស៊ីឈ្នួលធ្វើពលកម្មនៅប្រទេសថៃជាច្រើនខែមកហើយ ហើយដោយពេលនេះអាជ្ញាធរថៃបានរឹតបន្តឹងការស្នាក់នៅក៏ដូចជាខ្លាចឆ្លងជំងឺកូវីដ-១៩ បំប្លែងថ្មី ទើបអាជ្ញាធរថៃចាត់បញ្ជូនបងប្អូនវិលត្រឡប់មកកម្ពុជាវិញ។ ក្រោយពីទទួលបានបងប្អូនទាំងនេះ កម្លាំងចម្រុះបានកត់ឈ្មោះ ធ្វើកំណត់ហេតុនិងបានអប់រំណែនាំ ហើយសំណូមពរសុំបងប្អូនសហការដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់។ ជាមួយនេះក៏ត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ដោយជាលទ្ធផល ៖ ដកហូតបានកាំបិត០៨ដើម រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យ នៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។

ជាលទ្ធផលរកឃើញ វិជ្ជមានចំនួន ០៦នាក់ (ស្រី ០៣នាក់) បន្ទាប់មកក្រុមគ្រូពេទ្យបានបញ្ជូនអ្នកវិជ្ជមានចំនួន ០៦នាក់ នោះទៅកាន់មណ្ឌលព្យាបាលកូវីដ-១៩ ស្ថិតក្នុងភូមិអូរកណ្ដាល ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ហើយក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន ៦២នាក់ (ស្រី ១៥នាក់) ក្មេង ០៧នាក់ (ក្មេងស្រី ០២នាក់) ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ ។ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ដែនអត់ចេញ ចំនួន ៥០នាក់ (ស្រី ១៣នាក់) ក្មេង ០៧នាក់ (ក្មេងស្រី ០៣នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កត្រង់ចំណុចរោងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្ងៀ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ដើម្បីពិនិត្យសុខភាពបន្ត ៕

# ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០២២

## ថៃគ្រើនរំលឹកនិយោជកឲ្យបន្តការចុះបញ្ជីពលករខ្មែរជាថ្មីអោយបាននៅត្រឹមចុងខែមីនា

https://www.khmertimeskh.com/ Khmer Times March 4, 2022

ក្រសួងការងារថៃកាលពីថ្ងៃព្រហស្បតិ៍បានគ្រើនរំលឹកនិយោជករបស់កម្មករមកពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ឱ្យបន្តការចុះឈ្មោះរបស់ពួកគេឡើងវិញអោយបាននៅចុងខែនេះ។ រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បាននិយាយថា និយោជកថៃត្រូវបានអនុញ្ញាតឱ្យជួលកម្មករមកពីប្រទេសជិតខាងទាំងបីក្រោមសេចក្តីសម្រេចចិត្តចំនួនបី ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១៩ ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២០ និងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០។ បន្ទាប់មកគណៈរដ្ឋមន្ត្រីបានចេញសេចក្តីសម្រេចមួយទៀតនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ដើម្បីបន្តសុពលភាពនៃសេចក្តីសម្រេចចិត្តមុនទាំងបី។ លោក Suchart បាននិយាយថា ពលករមកពីប្រទេសទាំងបីដែលត្រូវបានផ្តល់ការងារនៅក្រោមសេចក្តីសម្រេចចិត្តទាំងបីនេះ ត្រូវតែបំពេញផ្លូវច្បាប់សម្រាប់ការបន្តចុះឈ្មោះរបស់ពួកគេនៅចុងខែនេះ ដើម្បីអោយពួកគេមានសិទ្ធិធ្វើការក្នុងប្រទេសថៃរហូតដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣។ លោក Suchart បានបន្ថែមថា និយោជករបស់ពលករចំណាកស្រុកដែលត្រូវបានជួលនៅក្រោមសេចក្តីសម្រេចចិត្តថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ ត្រូវតែជូនដំណឹងទៅអាជ្ញាធរដើម្បីធ្វើបច្ចុប្បន្នភាពស្ថានភាពរបស់កម្មកររបស់ពួកគេ និងដើម្បីបានអត្តសញ្ញាណប័ណ្ណអន្តោប្រវេសន៍របស់ពួកគេត្រឹមថ្ងៃទី៣១ ខែមីនា។

លោក Pairoj Chotikasathien អគ្គនាយកនៃអគ្គនាយកដ្ឋានការងារបាននិយាយថា មានពលករចំណាកស្រុកប្រមាណ ១១,០០០នាក់ ដែលត្រូវការធ្វើបច្ចុប្បន្នភាពការចុះឈ្មោះ និងទទួលបានអត្តសញ្ញាណប័ណ្ណអន្តោប្រវេសន៍។ លោក Pairoj បាននិយាយថា យើងមានការព្រួយបារម្ភច្រើនចំពោះក្រុមនេះ ពីព្រោះប្រសិនបើការចុះឈ្មោះរបស់ពួកគេមិនត្រូវបានធ្វើបច្ចុប្បន្នភាព អោយបានត្រឹមថ្ងៃទី ៣១ ខែមីនា ពួកគេនឹងមិនមានសិទ្ធិស្នាក់នៅក្នុងប្រទេសថៃឡើយ។ លោក Pairoj បាននិយាយថា និយោជកដែលជួលពលករចំណាកស្រុកដែលមិនបានចុះបញ្ជីអាចនឹងត្រូវពិន័យជាប្រាក់ពី ១០,០០០ បាត ទៅ ១០០,០០០ បាតក្នុងម្នាក់សម្រាប់ពលករខុសច្បាប់។ ប្រសិនបើនិយោជកត្រូវបានគេចាប់បានថាធ្វើខុសដដែលៗ ការផាកពិន័យនឹងត្រូវកើនឡើងទ្វេដង ហើយពួកគេនឹងត្រូវជាប់ពន្ធនាគារយ៉ាងតិចចំនួនបីឆ្នាំ។ ជនអន្តោប្រវេសន៍ខុសច្បាប់នឹងត្រូវរងការផាកពិន័យពី ៥,០០០ បាតទៅ ៥០,០០០ បាតប្រសិនបើពួកគេត្រូវបានចាប់ខ្លួនធ្វើការនៅក្នុងប្រទេសថៃដោយមិនបានចុះឈ្មោះ និងមានអត្តសញ្ញាណប័ណ្ណអន្តោប្រវេសន៍ ហើយនឹងប្រឈមនឹងការនិរទេសផងដែរ។ *First published in The Nation*

## ក្រសួងការងារ៖ ជប៉ុនសម្រេចអនុញ្ញាតឱ្យកម្មសិក្សាការី-ពលករជំនាញខ្មែរ ចូលប្រទេសជប៉ុនឡើងវិញ ចាប់ពីថ្ងៃទី០១ ខែមីនាតទៅ ដោយត្រូវអនុវត្តទៅតាមនីតិវិធីមួយចំនួន

http://freshnewsasia.com/ 2022-03-04 12:52pm

**(ភ្នំពេញ)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអះអាងថា រដ្ឋាភិបាលជប៉ុន ពេលនេះ បានសម្រេចអនុញ្ញាតឱ្យជនបរទេស រួមទាំងកម្មសិក្សាការី-ពលករជំនាញកម្ពុជា ចូលប្រទេសជប៉ុនឡើងវិញ ដោយអនុវត្តចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ នេះតទៅ ដោយត្រូវអនុវត្តទៅតាមនីតិវិធីមួយចំនួន។

**នីតិវិធីនោះដូចខាងក្រោម៖**

*** ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវ៖**

១៖ សហការជាមួយក្រុមហ៊ុនទទួល ឬសមាគមនៅប្រទេសជប៉ុន ដើម្បីស្នើសុំលិខិតអនុញ្ញាតបន្ថែម សម្រាប់កម្មសិក្សាការី-ពលករជំនាញចូលប្រទេសជប៉ុន តាមរយៈប្រព័ន្ធ Entrants, Returnees Follow-up System របស់ប្រទេសជប៉ុន។

២៖ បន្ទាប់មក ត្រូវភ្ជាប់បន្ថែមនូវលិខិតអនុញ្ញាតនេះសម្រាប់កម្មសិក្សាការី-ពលករជំនាញ នៅពេលស្នើសុំទិដ្ឋាការជូនកម្មសិក្សាការី-ពលករជំនាញ នៅស្ថានទូតជប៉ុនប្រចាំកម្ពុជា។

*** កម្មសិក្សាការី-ពលករជំនាញត្រូវ៖**

១៖ ត្រូវមានវិញ្ញាបនបត្របញ្ជាក់ថាគ្មានមេរោគកូវីដ-១៩ រយៈពេល៧២ម៉ោង មុនចេញដំណើរ។

២៖ បំពេញកិច្ចសន្យាអនុវត្តវិធានការចត្តាឡីស័ក ដែលតម្រូវដោយរាជរដ្ឋាភិបាលនៃប្រទេសជប៉ុន មុនពេលចាកចេញទៅប្រទេសជប៉ុន។

៣៖ ទាញយកកម្មវិធី Covid-19 Contact-Confirming Application ទៅក្នុងទូរស័ព្ទដៃ និងចុះឈ្មោះក្នុងកម្មវិធី មុនពេលចាកចេញទៅប្រទេសជប៉ុន។

៤៖ ផ្តល់កិច្ចសន្យាអនុវត្តវិធានការចត្តាឡីស័ក ជូនការិយាល័យទទួលបន្ទុកអនុវត្តចត្តាឡីស័កនៅអាកាសយានដ្ឋានប្រទេសជប៉ុន។

៥៖ អនុវត្តវិធានការរបស់រដ្ឋាភិបាលជប៉ុនដូចខាងក្រោម៖

-អ្នកបានចាក់វ៉ាក់សាំងដែលទទួលស្គាល់ដោយប្រទេសជប៉ុនចំនួន៣ដូស៖ ត្រូវធ្វើចត្តាឡីស័កចំនួន៣ថ្ងៃនៅកន្លែងខ្លួនឯង និងធ្វើតេស្តរកមេរោគកូវីដ១៩នៅថ្ងៃទី៣។

-អ្នកមិនបានចាក់វ៉ាក់សាំងដែលទទួលស្គាល់ដោយប្រទេសជប៉ុនចំនួន៣ដូស៖ ត្រូវធ្វើចត្តាឡីស័កចំនួន៣ថ្ងៃនៅកន្លែងដែលកំណត់ដោយការិយាល័យចត្តាឡីស័ក មិនអនុញ្ញាតឱ្យប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ និងធ្វើតេស្តរកមេរោគកូវីដ១៩នៅថ្ងៃទី៣។

ក្រសួងការងារបានបញ្ជាក់ថា ក្នុងករណីដែលកម្មសិក្សាការី-ពលករជំនាញ មិនអនុវត្តតាមគោលការណ៍ណែនាំនៅប្រទេសជប៉ុន អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសជប៉ុន នឹងចាត់វិធានការតាមផ្លូវច្បាប់៕

## ការសង្គ្រោះជនជាតិថៃពីអ្នកបោកប្រាស់នៅក្នុងប្រទេសកម្ពុជានៅតែបន្តដោយមាន ៥៦នាក់ផ្សេងទៀតត្រូវបានគេជួយសង្គ្រោះ

https://www.khmertimeskh.com/ Khmer Times March 4, 2022

ប៉ូលីសបានអោយដឹងថា ជនជាតិថៃចំនួន៥៦នាក់ផ្សេងទៀត បានត្រឡប់ពីប្រទេសកម្ពុជាវិញដោយសុវត្ថិភាព ដែលពួកគេត្រូវបានគេបោកបញ្ឆោតឱ្យទៅធ្វើការនៅមជ្ឈមណ្ឌលហៅទូរស័ព្ទរបស់ក្រុមខិលខូច និងត្រូវបានឃុំខ្លួនដើម្បីជំរិតទាលុយ។ ជនជាតិថៃមួយក្រុមចុងក្រោយបង្អស់ ដែលជាជនរងគ្រោះត្រូវបានបោកបញ្ឆោតបានធ្វើដំណើរដោយឆ្លងកាត់ស្ពានមិត្តភាពកម្ពុជា-ថៃ ត្រង់ចំណុចត្រួតពិនិត្យខ្លងលឹក ក្នុងខេត្តស្រះកែវ បន្ទាប់ពីអាជ្ញាធរកម្ពុជាប្រគល់ពួកគេអោយទៅវិញកាលពីរសៀលថ្ងៃពុធ។

ជំនួយការអគ្គស្នងការនគរបាលជាតិថៃ ឧត្តមសេនីយ៍ទោ Surachate Hakparn ដែលមានតួនាទីជានាយករងនៃនាយកដ្ឋានការពារស្ត្រី និងកុមារ និងមជ្ឈមណ្ឌលប្រឆាំងការជួញដូរមនុស្សនៃប៉ូលីសថៃ បានមកជួបពួកគេ។ អ្នកដែលត្រឡប់មកវិញត្រូវបានគេនាំទៅពិនិត្យសុខភាពមុនពេលចូលទៅដាក់ឲ្យនៅដាច់ដោយឡែកនៅមណ្ឌលមួយក្នុងស្រុកអារញ្ញ។ ឧត្តមសេនីយ៍ទោ Surachat បាននិយាយថា ប៉ូលីសបានដឹងអំពីស្ថានភាពរបស់ពួកគេ បន្ទាប់ពីពួកគេបានស្វែងរកជំនួយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ ប៉ូលិសបានជូនដំណឹងទៅស្ថានទូតថៃនៅ

ភ្នំពេញដែលប្រាប់ប៉ូលិសកម្ពុជា។ អាជ្ញាធរមូលដ្ឋានបានផ្ទក់ចូលមជ្ឈមណ្ឌលហៅទូរស័ព្ទក្នុងក្រុងរីសតខេត្តព្រះសីហនុ ហើយបានធ្វើប្រតិបត្តិការសង្គ្រោះ។

ជនរងគ្រោះបាននិយាយថា ពួកគេបានឮអំពីការងារដែលមានប្រាក់ខែល្អនៅក្នុងប្រទេសកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយក៏សម្រេចចិត្តសាកល្បងមកធ្វើការ។ ជនរងគ្រោះម្នាក់ដែលសុំមិនបញ្ចេញឈ្មោះបាននិយាយថាពួកគេបានដើរឆ្លងកាត់ព្រំដែនហើយត្រូវបានក្រុមខិលខូចមកយក។ ពួកគេត្រូវបានគេនាំទៅខេត្តព្រះសីហនុ និងបង្ខំឲ្យបោកប្រាស់ប្រជាជននៅប្រទេសថៃតាមទូរស័ព្ទ។ ក្រោយមកពួកគេបានទាមទារសុំសេរីភាព ប៉ុន្តែក្រុមជនពាលមិនព្រម។ ពួកគេត្រូវបានគេចាប់ដាក់ចំណាប់ខ្នាំង ហើយបានប្រាប់ថា គ្រួសាររបស់ពួកគេនៅប្រទេសថៃត្រូវបង់ប្រាក់ចំនួន ១០០,០០បាតក្នុងមួយនាក់ដើម្បីឱ្យពួកគេដោះលែង។ ជនជាតិថៃត្រូវបានឃុំខ្លួននៅក្នុងបន្ទប់តូចៗ និងផ្តល់អាហារមិនគ្រប់គ្រាន់។ ប៉ូលិសបានឲ្យដឹងថា អ្នកខ្លះត្រូវបានគេវាយដំ ហើយប្រាប់ថា ពួកគេនឹងត្រូវលក់ទៅឲ្យថៅកែផ្សេងទៀត៕ ប្រភព: Bangkokpost

## អ្នកបោកប្រាស់ជនជាតិចិនកាន់តែច្រើន ស្វែងរកទីជម្រកនៅក្នុងប្រទេសកម្ពុជា ដែលនាំឱ្យមានជនរងគ្រោះជាជនជាតិចិនកាន់តែច្រើន

https://www.khmertimeskh.com/ Khmer Times March 5, 2022

ក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ ករណីជនជាតិចិនម្នាក់ ដែលត្រូវបានចាប់ពង្រត់ និងបង្ខំឱ្យធ្វើការជា "ទាសករឈាម" ដោយក្រុមអ្នកឆបោកតាមអ៊ីនធឺណិតនៅកម្ពុជា បានធ្វើឱ្យប្រទេសចិនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ នៅក្នុងរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយជាច្រើន Li Yayuanlun ដែលត្រូវបានគេកំណត់ថាជាជនរងគ្រោះក្នុងសំណុំរឿងនេះមានឈាមចំនួន ៣៥០ មីលីលីត្រ នៃឈាមដែលត្រូវបានបូមចេញពីគាត់ចំនួន៧ ដងក្នុងរយៈពេល ៦ ខែដែលគាត់ត្រូវបានគេឃុំឃាំងនៅកន្លែងលាក់ខ្លួនរបស់ក្រុមខិលខូចក្នុងខេត្តព្រះសីហនុ។ ថ្វីបើលោក Li អាចគេចខ្លួនបាន ប៉ុន្តែគាត់ស្ថិតក្នុងសេចក្តីស្លាប់ នៅពេលដែលគាត់បានទទួលការព្យាបាល នេះបើយោងតាមសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី១៦ ខែកុម្ភៈ ដែលចុះផ្សាយដោយស្ថានទូតចិនប្រចាំប្រចាំកម្ពុជា ដោយមានមន្ទីរពេទ្យ Bethune Cambodia China First ទទួលយកគាត់។ រឿងរ៉ាវរបស់ Li បានធ្វើឱ្យមានការរំជើបរំជួលនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមចិន ដោយមានមនុស្សជាច្រើនបានបង្ហាញពីការអាណិតអាសូរចំពោះទុក្ខលំបាករបស់គាត់។ ទោះជាយ៉ាងណាក៏ដោយ ភាពពិតនៃរឿងនេះបានឈានដល់ការចោទសួរកាលពីថ្ងៃច័ន្ទ នៅពេលដែលប៉ូលីសកម្ពុជាបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថារឿងរបស់លោក Li គឺជា "ការប្រឌិតសុទ្ធសាធ" ដែលជាការសន្និដ្ឋានបញ្ចប់បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេលមួយសប្តាហ៍។

ប៉ូលិសកម្ពុជាបាននិយាយថា ពួកគេបានឃុំខ្លួន Li និងបីនាក់ផ្សេងទៀត។ អ្នកដែលត្រូវបានឃុំខ្លួននោះរួមមាន Chen Baorong ជាមេដឹកនាំក្រុមអ្នកស្ម័គ្រចិត្តក្នុងតំបន់ដែលធ្លាប់បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយចិន Caixin ថាគាត់បានជួយយក Li ទៅមន្ទីរពេទ្យ។ មិនថារឿងរបស់លោក Li ពិត ឬមិនពិតនោះទេ វាឆ្លុះបញ្ចាំងពីបញ្ហាគំរាមកំហែងអាយុជីវិត ដែលជនជាតិចិនប្រឈមនៅក្នុងប្រទេសកម្ពុជា ដោយគ្មាននរណាក្រៅពីខ្លួនពួកគេ ចំនួនករណីឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងពួកគេ រួមទាំងការចាប់ជំរិត និងការជួញដូរមនុស្ស បានកើនឡើងបន្ទាប់ពីក្រុមក្មេងខិលខូចអ្នកលេងល្បែងស៊ីសង និងបោកប្រាស់តាមទូរស័ព្ទកាន់តែច្រើនរបស់ចិនបានផ្លាស់ទៅទីនោះ បន្ទាប់ពីមានការបង្ក្រាបកាន់តែខ្លាំងនៅប្រទេសចិន។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនវិនិយោគអនឡាញមួយចំនួនធំបានក្លាយទៅជាក្រុមឧក្រិដ្ឋជនក្លែងខ្លួនជាក្រុមហ៊ុន ដែលបានតាំងខ្លួនជាក្រុមហ៊ុនឯកជនដើម្បីគេចពីការបង្ក្រាបរបស់រដ្ឋាភិបាល។

ស្ថិតនៅតំបន់ឆ្នេរភាគនិរតីរបស់ប្រទេសកម្ពុជា ខេត្តព្រះសីហនុ គឺជាទីក្រុងកំពង់ផែ គោលដៅទេសចរណ៍ និងមជ្ឈមណ្ឌលពាណិជ្ជកម្មបរទេសដ៏ធំបំផុតរបស់ប្រទេស។ ចាប់តាំងពីការរីកដុះដាលនៃវិស័យអចលនទ្រព្យក្នុងឆ្នាំ២០១៦ មក ទីក្រុងនេះបានទាក់ទាញវិនិយោគិនចិនយ៉ាងឆាប់រហ័ស រួមទាំងអ្នកដែលចូលរួមលេងល្បែងអនឡាញ និងការបោកប្រាស់តាមទូរសព័ទ្ធដែលនាំឱ្យមានការកើនឡើងនូវសកម្មភាពឧក្រិដ្ឋកម្ម ដូចជាការចាប់ជំរិត និងជំរិតអ្នកលេងល្បែងជាដើម។ ក្នុងឆ្នាំ២០១៩ សកម្មភាពមួយបានកើតឡើងនៅពេលដែលប្រទេសចិន និងកម្ពុជាបានបង្កើតក្រុមការងាររួមគ្នាមួយ ហើយបានបើកការបង្ក្រាបលើសកម្មភាពឧក្រិដ្ឋកម្មបែបនេះ។ គិតត្រឹមខែសីហា ឆ្នាំនោះមានជិត ១ ពាន់នាក់។ ជនជាតិចិនត្រូវបានចាប់ខ្លួន រួមទាំងជនសង្ស័យចំនួន១១៥ នាក់ពីបទឆបោកតាមទូរស័ព្ទ និង ៣៣៥ នាក់សង្ស័យថាបានចូលរួមក្នុងប្រតិបត្តិការល្បែងស៊ីសងខុសច្បាប់តាមអ៊ីនធឺណិត។ កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ កម្ពុជាបានហាមឃាត់ការលេងល្បែងស៊ីសងតាមអ៊ីនធឺណិតទាំងស្រុង។ ក្រោយពីការបង្ក្រាប សកម្មភាពឧក្រិដ្ឋកម្មបានធ្លាក់ចុះយ៉ាងខ្លាំង។ ប៉ុន្តែនៅពេលដែលឥទ្ធិពលនៃជំងឺរាតត្បាតកូវីដ-១៩ បានចាប់ផ្តើមស្រាកស្រាន្តក្នុងប្រទេសក្នុងឆ្នាំ២០២០ ឧក្រិដ្ឋជនជាច្រើនបានត្រឡប់ទៅទីក្រុងកំពង់ផែវិញ ក្រោមរូបភាពជាក្រុមហ៊ុនឯកជននៅក្នុងតំបន់វិនិយោគតាមអ៊ីនធឺណិត។

ប៉ុន្តែ ដោយសារប្រទេសចិនបានរឹតបន្តឹងការគ្រប់គ្រងព្រំដែន និងបន្តការបង្ក្រាបលើការឆបោកទូរស័ព្ទឆ្លងដែន និងការលេងល្បែងស៊ីសងខុសច្បាប់ ក្រុមហ៊ុនក្លែងបន្លំទាំងនេះមានការលំបាកកាន់តែខ្លាំងឡើងក្នុងការរត់ពន្ធជ្រើសរើសបុគ្គលិកថ្មី ដូច្នេះពួកគេបានបង្កើតយុទ្ធសាស្ត្រថ្មីដើម្បីចាប់ជំរិត ឬចាប់ជនជាតិចិននៅកម្ពុជាអោយធ្វើអាជីវកម្មខុសច្បាប់។ ការស៊ើបអង្កេតផ្ទាល់ដោយ Khmer Times ក្នុងខែសីហា ដល់ខែវិច្ឆិកា ឆ្នាំ២០២១ បានបង្ហាញថា តំបន់វិនិយោគតាមអ៊ីនធឺណិតទាំងនោះ ស្ថិតនៅទីតាំងដែលត្រូវបានបិទទ្វា។ ការការពារសន្តិសុខនៅកន្លែងនេះត្រូវបានអោយដឹងថាបានបង្កការលំបាកសម្រាប់ប៉ូលិសក្នុងតំបន់ធ្វើការស្រាវជ្រាវឬស៊ើបអង្កេតខាងក្នុង។ តំបន់វិនិយោគតាមអ៊ីនធឺណិតបែបនេះមាននៅកន្លែងផ្សេងទៀតក្នុងប្រទេសកម្ពុជា រួមទាំងរាជធានីភ្នំពេញផងដែរ និងស្ទើរតែនៅទូទាំងប្រទេស។ លោក Li Xi'an មកពីខេត្ត Guizhou ភាគនិរតីនៃប្រទេសចិន បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយចិន Caixin ថានៅក្នុងខែមីនា ឆ្នាំ២០២១ គាត់ត្រូវបានសន្យាថានឹងផ្តល់ប្រាក់ខែខ្ពស់នៅពេលដែលគាត់ត្រូវបានគេរត់ពន្ធចូលទៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ ហើយលក់ទៅឱ្យក្រុមហ៊ុនវិនិយោគតាមអ៊ីនធឺណិតនៅក្រុងព្រះសីហនុ។

ដោយសារតែគាត់បដិសេធមិនចូលរួមក្នុងការបោកប្រាស់នៅក្រុមហ៊ុនទីមួយ គាត់បាននិយាយថាគាត់ត្រូវបានលក់ទៅឱ្យបន្ទប់មួយទៀតដែលដំណើរការចេញពីអគារពីរដែលព័ទ្ធជុំវិញដោយជញ្ជាំងកម្ពស់ពីរម៉ែត្រ។ Li Xi'an បាននិយាយថា ក្រុមខិលខូចបានធ្វើទារុណកម្មគាត់ដោយដំបងធក់ ហើយគាត់បានត្រឹមតែរត់គេចខ្លួនដោយលោតពីលើជញ្ជាំងពីជាន់ទីពីរប៉ុណ្ណោះ។ គាត់បានរងរបួសនៅពេលដែលធ្លាក់ចុះ ប៉ុន្តែបានបញ្ជូនទៅមន្ទីរពេទ្យដោយសុវត្ថិភាព។ មិនដូចលោក Li Xi'an ទេ Li Liya មិនត្រូវបានគេចាប់ពង្រត់ ឬរត់ពន្ធចូលប្រទេសកម្ពុជាឡើយ។ នាងបាននិយាយថា នាងកំពុងធ្វើការជាគណនេយ្យករនៅរោងចក្រមួយក្នុងខេត្តព្រះសីហនុ ពេលនាងបានស្គាល់មនុស្សម្នាក់ឈ្មោះ Aqiang តាមអ៊ីនធឺណិត។ នាងបានប្រាប់ Caixin ថាសុបិន្តអាក្រក់របស់នាងបានចាប់ផ្តើមនៅថ្ងៃទី២៨ ខែធ្នូ នៅពេលដែលនាងបានជួប Aqiang តែម្នាក់ឯងជាលើកដំបូង។ ពេលនាងមកដល់កន្លែងជួបមួយនៅពេលថ្ងៃ នាងបានឃើញថា Aqiang បាននាំមនុស្សម្នាក់ទៀតមក។ បន្ទាប់មកអ្នកទាំងពីរបានចាប់នាង។ នាងត្រូវបានចាប់ខ្លួនដោយក្រុមខិលខូចដែលកំពុងធ្វើអាជីវកម្មក្នុងតំបន់វិនិយោគតាមអ៊ីនធឺណិត។

មនុស្សម្នាក់បានគំរាមនាងដោយដំបងធក់ ដកយកទូរស័ព្ទដៃរបស់នាង ហើយបង្ខំនាងឱ្យបង្ហាញពាក្យសម្ងាត់របស់នាង ដើម្បីពួកគេអាចលុបព័ត៌មានទំនាក់ទំនងរបស់នាងជាមួយ Aqiang ។ li ជឿថា ការចាប់ពង្រត់

ត្រូវបានគ្រោងទុកជាមុន។ គេបានដឹងផងដែរថា កាលពីពាក់កណ្តាលខែធ្នូ ស្ត្រីជនជាតិចិនម្នាក់ទៀតឈ្មោះ Xiaolian ត្រូវបានគេចាប់ពង្រត់ទៅលក់ឱ្យនៅបន្ទប់ជាមួយ Li Liya ។ នាងត្រូវបានគេឃុំខ្លួនក្នុងតម្លៃលោះចំនួន ៣០០,០០០ យន់ (៤៧,៥០០ ដុល្លារ) មុនពេលត្រូវបានគេលក់បន្តទៅកន្លែងផ្សេងទៀតនៃប្រទេស។ ស្ត្រីទាំងពីរនាក់ក្រោយមកបានរត់គេចខ្លួនកាលពីខែមករា។

យោងតាមសេចក្តីរាយការណ៍ព័ត៌មានក្នុងស្រុក ប៉ូលិសបានចាប់ខ្លួនជនសង្ស័យជនជាតិចិនចំនួន ១១នាក់ពាក់ព័ន្ធករណីឧក្រិដ្ឋកម្មស្រដៀងគ្នានៅខេត្តព្រះសីហនុ កាលពីចុងខែមករា ក្នុងនោះ ៦នាក់ ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាតដោយចេតនា ពាក់ព័ន្ធនឹងការស្លាប់របស់ជនជាតិចិនពីរនាក់។ ប៉ូលីសក៏បានជួយសង្គ្រោះជនជាតិចិនបីនាក់ដែលត្រូវបានគេឃុំខ្លួនដោយខុសច្បាប់។ ក្នុងករណីរបស់ Li Liya នាងបាននិយាយថាទីបំផុតនាងបានរួចគេចខ្លួនដោយសារ Chen ដែលជាប្រធានក្រុមសប្បុរសធម៌កម្ពុជា-ចិន។ Chen មានដើមកំណើតនៅខេត្ត Hubei ភាគកណ្តាលប្រទេសចិន ហើយបានរកស៊ីនៅក្នុងកម្ពុជាអស់រយៈពេលជាង២០ ឆ្នាំមកហើយ។ គាត់បានចាប់ផ្តើមជួយសង្គ្រោះជនរួមជាតិចិនដែលត្រូវបានចាប់ខ្លួនដោយក្រុមឧក្រិដ្ឋជនកាលពីប៉ុន្មានឆ្នាំមុន។ នាងបាននិយាយថានៅថ្ងៃទី៨ ខែមករា Li បានទាក់ទង Chen ដោយមានមិត្តរបស់នាងជួយ។ បន្ទាប់ពី Li បានផ្តល់រូបថតលិខិតឆ្លងដែន និងរៀបរាប់ពីរបៀបដែលនាងត្រូវបានគេចាប់ជំរិត Chen បានរាយការណ៍ករណីនេះភ្លាមៗទៅកាន់មន្ត្រីប៉ូលីសក្នុងតំបន់ដែលគាត់ទុកចិត្ត។

ការជួយសង្គ្រោះមិនងាយស្រួលទេ ខណៈឧក្រិដ្ឋជនកំពុងតាមដានLi យ៉ាងជិតស្និទ្ធ។ មួយថ្ងៃបន្ទាប់ពីនាងទាក់ទងជាមួយ Chen ប៉ូលីសពីរនាក់បានមកសួរថាតើ Li បានទូរស័ព្ទទៅពួកគេដើម្បីសុំជំនួយឬអត់ Li បាននិយាយថា នាងមិនបានទូស័ព្ទទៅទេដោយសារតែមានការព្រួយបារម្ភច្រើន ដោយសារនាងនៅតែស្ថិតក្នុងក្រុមហ៊ុនដែលគ្រប់គ្រងដោយក្រុមខិលខូច។ ទោះបីជានាងបដិសេធក៏ដោយ សមាក្រុមខិលខូចបានបង្ខំនាងឱ្យថតវីដេអូដែលនិយាយថានាង "មិនត្រូវបានបង្ខិតបង្ខំ" និង "សុខចិត្តធ្វើការនៅទីនោះ" ដើម្បីបញ្ចុះបញ្ចូលប៉ូលីសថាមិនមានបញ្ហាអ្វីនោះទេ។ ទោះយ៉ាងណាក៏ដោយ Li នៅតែទាក់ទងជាមួយ Chen ។ ក្រោយមក ប៉ូលិសមូលដ្ឋានបានសុំឱ្យនាងមកដាក់ពាក្យបណ្តឹងជាផ្លូវការនៅប៉ុស្តិ៍ប៉ូលីស ជាកន្លែងដែលនាងត្រូវបានជួបដោយអ្នកស្ម័គ្រចិត្តមកពីក្រុមសប្បុរសធម៌កម្ពុជា-ចិន Chen ។ ក្រោយមក នាងត្រូវបានអនុញ្ញាតឱ្យចេញពីក្រុមខិលខូច។ ដោយសារមានមនុស្សច្រើនសុំគាត់ជួយនៅក្នុងប្រទេសកម្ពុជា Chen បាននិយាយថា គាត់ភាគច្រើនប្រកាន់ខ្ជាប់នឹងការជួយអនីតិជន ឬអ្នកដែលត្រូវគេវាយដំ ឬរបួស។

កាលពីខែធ្នូ អ្នកស្ម័គ្រចិត្តជនជាតិចិនម្នាក់ពីក្រុមរបស់គាត់ត្រូវបានចាប់ពង្រត់ និងវាយដំដោយក្រុមខិលខូចបានទាមទារប្រាក់ដើម្បីដោះលែងគាត់។ អ្នកស្ម័គ្រចិត្តត្រូវបានជួយសង្គ្រោះ បន្ទាប់ពីសមាគមធុរកិច្ចចិននៅកម្ពុជា និងក្រុមសប្បុរសធម៌កម្ពុជា-ចិនបានរាយការណ៍ករណីនេះជូនអគ្គស្នងការនគរបាលជាតិ និងជូនដំណឹងដល់ភ្នាក់ងាររដ្ឋាភិបាលចិនដែលមានមូលដ្ឋាននៅកម្ពុជា រួមទាំងស្ថានទូតផងដែរ។ Chen បាននិយាយថា អ្នកស្ម័គ្រចិត្តត្រូវបានល្បួងដោយក្រុមខិលខូចតាមរយៈការផ្សាយពាណិជ្ជកម្មការងារមិនពិត។ Li Yayuanlun ក៏បាននិយាយដែរថា គាត់ត្រូវបានបោកបញ្ឆោតតាមរយៈការផ្សាយពាណិជ្ជកម្មការងារមិនពិត។ ប៉ូលីសកម្ពុជាបានចោទប្រកាន់លោក Li ថាបានប្រឌិតរឿងនៃការចាប់ជំរិតរបស់គាត់។ ពួកគេបានឃាត់ខ្លួន Li និង Chen នេះបើយោងតាមប៉ូលីស និងមនុស្សដែលដឹងពីករណីនេះ។

Caixin បានដឹងថា ការចូលរួមរបស់ Chen បានជំរុញឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងក្នុងចំណោមសហគមន៍ចិនរបស់កម្ពុជា ដោយមនុស្សជាច្រើនជឿថាគាត់គឺជាជនរងគ្រោះ ឬត្រូវបាន Li Yayuanlun បោកបញ្ឆោត។

នាពេលកន្លងមក Chen ត្រូវបានគេរាយការណ៍ថា គាត់ធ្លាប់ត្រូវបានគម្រាមកំហែងម្តងរួចមកហើយ បន្ទាប់ពីបានជួយសង្គ្រោះជនជាតិចិនម្នាក់ ដែលឃុំខ្លួននៅកន្លែងលាក់ខ្លួនឧក្រិដ្ឋជននៅកម្ពុជា។ គាត់ហាក់ដូចជាព្រួយបារម្ភអំពីសុវត្ថិភាពរបស់គាត់។ គាត់បាននិយាយនៅក្នុងបទសម្ភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយចិនថា "ប្រសិនបើមានអ្វីកើតឡើងចំពោះខ្ញុំ ខ្ញុំសង្ឃឹមថារដ្ឋ (ចិន) នឹងរកយុត្តិធម៌ឱ្យខ្ញុំ" ។ "ខ្ញុំស្រលាញ់ និងស្អប់កម្ពុជា។ ខ្ញុំស្រឡាញ់មនុស្សល្អនៅទីនេះ ប៉ុន្តែស្អប់មន្ត្រីពុករលួយ និងថៅកែក្រុមហ៊ុនវិនិយោគតាមអ៊ីនធឺណិត»។ ក្រុមការងារសប្បុរសធម៌កម្ពុជា-ចិន បាននិយាយថា ខ្លួនបានជួលមេធាវីការពារលោក Chen ដោយប្តេជ្ញាធានាថាគាត់នឹងទទួលបានយុត្តិធម៌ នេះបើយោងតាមសេចក្តីថ្លែងការណ៍កាលពីថ្ងៃចន្ទ។ គិតត្រឹមរសៀលថ្ងៃសុក្រ គណនី WeChat ផ្លូវការរបស់ក្រុមអ្នកស្ម័គ្រចិត្តត្រូវបានបិទ ហើយមិនមានសេចក្តីថ្លែងការណ៍ពីមុននៅលើគណនីនេះទេ។

ស្ថានទូតចិនបាននិយាយថា ខ្លួននឹងបន្តតាមដានករណីនេះ និងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីបង្ក្រាបល្បែងស៊ីសងតាមអ៊ីនធឺណិត និងការឆបោកតាមទូរសព្ទ័នៅកម្ពុជា។ ការកើនឡើងនៃករណីឧក្រិដ្ឋកម្មនៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានជាសអារម្មណ៍ពាណិជ្ជករចិន ដែលកំពុងធ្វើការនៅកម្ពុជា។ កាលពីខែវិច្ឆិកា សភាពាណិជ្ជកម្មចិនជាច្រើនក្នុងប្រទេសបានចេញសេចក្តីថ្លែងការណ៍រួមមួយ ដែលក្នុងនោះពួកគេបានថ្កោលទោសចំពោះជនល្មើសនៃអំពើឧក្រិដ្ឋកម្មទាំងអស់ ជាពិសេសឧក្រិដ្ឋកម្មហិង្សា ដូចជាការចាប់ជំរិតជាដើម។ ពួកគេក៏បានសន្យាថានឹងធ្វើការជាមួយនគរបាលមូលដ្ឋាន និងភ្នាក់ងារអនុវត្តច្បាប់ផ្សេងទៀត ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ក្រាបបទល្មើសគ្រប់ប្រភេទ។

កាលពីខែមិថុនា មន្ត្រីជាន់ខ្ពស់នៃក្រសួងសន្តិសុខសាធារណៈចិនបាននិយាយថា ចិន និងកម្ពុជានឹងបន្តរួមគ្នាប្រយុទ្ធប្រឆាំងនឹងសកម្មភាពខុសច្បាប់ ដូចជាការឆបោកតាមទូរស័ព្ទ និងការរត់ពន្ធ ក៏ដូចជាការរឹបអូស និងធ្វើមាតុភូមិនិវត្តន៍ឧក្រិដ្ឋជនដែលត្រូវបានចាប់ខ្លួន។ សម្រាប់ឧក្រិដ្ឋជនដែលបានចូលសញ្ជាតិកម្ពុជា ប្រទេសទាំងពីរនឹងបន្តជំរុញឱ្យមានការដកហូតសញ្ជាតិក្នុងករណីមានការក្លែងបន្លំនេះ បើយោងតាមរបាយការណ៍កាសែត ខ្មែរថាមស៍ ដែលធ្លាប់ បានសហការជាមួយក្រុមរបស់លោក Wu ជាច្រើនលើក។ លោក Wu បាននិយាយថា៖ «កម្ពុជានឹងមិនក្លាយជាជម្រកសុវត្ថិភាពសម្រាប់ពួកគេឡើយ»។ ឈ្មោះ Li Xi'an, Li Liya និង Xiaolian នៅក្នុងអត្ថបទនេះគឺជាឈ្មោះក្លែងក្លាយ។ ភាគធំនៃរឿងនេះត្រូវបានរាយការណ៍ជាលើកដំបូងនៅក្នុងកាសែតខ្មែរថាមស៍ក្នុងប្រទេសកម្ពុជា ដែលបាននាំយករឿងនេះជាលើកដំបូងចាប់តាំងពីខែសីហា ឆ្នាំ២០២១ ហើយរឿងរ៉ាវនីមួយៗបានបណ្តាលឱ្យមានសកម្មភាពមួយចំនួនពីប៉ូលីសក្នុងតំបន់ ជាមួយនឹងរបាយការណ៍ស៊ើបអង្កេត ការឃ្លាំមើល និងព័ត៌មានដែលផ្តល់ដោយការិយាល័យសម្របសម្រួលកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់កម្ពុជា-ចិន។

## ឃាត់ខ្លួនជនជាតិចិនជាង ២០ នាក់ ពាក់ព័ន្ធនឹងបទល្មើស ជួញដូរផ្លូវភេទ

https://cen.com.kh/ Posted ByPen Srey NeatMarch 6, 2022

ភ្នំពេញ ៖ កម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថរាជធានីភ្នំពេញ សហការជាមួយកម្លាំងអាវុធហត្ថខណ្ឌដូនពេញ បានបើកការចុះបង្ក្រាបទីតាំងសណ្ឋាគារមួយកន្លែង ដែលមានស្លាកយីហោជាអក្សរចិន ដែលប្រែខ្មែរមកថា ឈូងសមុទ្រក្រអូប ។ ដោយនៅក្នុងនោះបង្កប់លួចបើកនៅសេវាផ្លូវភេទ។ ទីតាំងចុះបង្ក្រាបនេះដែរ បានធ្វើឡើងកាលពីវេលាម៉ោង ៩និង១០នាទីយប់ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២ ស្ថិតតាមបណ្តោយផ្លូវលេខ១៧២ កែងនឹងផ្លូវ៥១ (បាស្ទ័រ ) ក្នុងសង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការចុះបង្ក្រាបនេះដែរ ដោយមានការចង្អុលបង្ហាញដោយផ្ទាល់ ពីសំណាក់លោកឧត្តមសេនីយ៍ឯក រ័ត្ន ស្រ៊ាង មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ នឹងមានការដឹកនាំកម្លាំងចុះផ្ទាល់ ពីលោកឧត្តមសេនីយ៍ មេបញ្ជាការទទួលជំនាញ ផងដែរ ។

តាមប្រភពពីមន្ត្រីកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានឲ្យដឹងថា ការចុះបង្រ្កាប គឺធ្វើឡើង ដោយពាក់ព័ន្ធនឹងបទល្មើសរកស៊ីផ្លូវភេទ ហើយនៅពេលដែលកម្លាំងសមត្ថកិច្ចចុះដល់ទីតាំងខាងលើ ឃើញថា ពិតជាមានប្រាកដមែន បន្ទាប់ពីសមត្ថកិច្ច បានបើកការស្រាវជ្រាវកន្លងមក ។ ប្រភពដដែល បន្តថា ក្នុងនោះដែរកម្លាំងជំនាញ ក៏បានរកឃើញមានថ្នាំញៀន និងឧបករណ៍ប្រើប្រាស់មួយចំនួន ដែលក្រុមជនសង្ស័យ បានធ្វើសកម្មភាពប្រើប្រាស់ ។ វង្វង់ប្រតិបត្តិការជាង៣ម៉ោង កម្លាំងសមត្ថកិច្ច បានធ្វើការឃាត់មនុស្សប្រុសស្រីជាជនជាតិចិន សរុបជាង២០នាក់ និង បានដកហូតបានវត្ថុតាងមួយចំនួនធំផងដែរ ពាក់ព័ន្ធនឹងបទល្មើសរកស៊ី និងជួញដូរផ្លូវភេទ ក៏ដូចជាគ្រឿងញៀនផងដែរ ។ យ៉ាងណាមិញ ក្រោយការឃាត់ខ្លួន ជនសង្ស័យជាង២០នាក់ ត្រូវបានបញ្ជូនឡើងរថយន្ត ដឹកយកទៅកាន់ ទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ដើម្បីសាកសួរនាំ និងចាត់ការទៅតាមនីតិវិធីច្បាប់នៅពេលក្រោយផងដែរ ៕ រក្សាសិទ្ធិដោយ ៖ សា មេត

## ជនជាតិឥណ្ឌូណេស៊ីជាង៣០នាក់ ត្រូវបានសង្គ្រោះ ពីក្រុមល្បែងស៊ីសងតាមប្រព័ន្ធអនឡាញនៅខេត្តកណ្តាល លក់ចេញពីក្រុងព្រះសីហនុ

https://www.khmertimeskh.com/ Khmer Times March 6, 2022

ខ្មែរថាមស៍ បាន និងកំពុងរាយការណ៍យ៉ាងសកម្ម នូវករណីជាច្រើន នៃការសង្គ្រោះជនជាតិផ្សេងៗពីក្រុមជួញដូរមនុស្ស ដែលបានជួញដូរមនុស្សដែលត្រូវបានគេល្បួងឱ្យចូលធ្វើការក្នុងលេងល្បែងអនឡាញទូទាំងប្រទេសនៅខេត្តព្រះសីហនុ កោះកុង រាជធានីភ្នំពេញ និងខេត្តជាប់ព្រំដែនថៃ។

ឥឡូវនេះខេត្តកណ្តាលបានក្លាយជាខេត្តចុងក្រោយបំផុត ដែលត្រូវបានអូសចូលទៅក្នុងកន្លែងភក់ជ្រាំនេះ នៅពេលដែលជនជាតិឥណ្ឌូនេស៊ីចំនួន ៤៤ នាក់ ត្រូវបានជួយសង្គ្រោះពីក្រុមល្បែងស៊ីសងតាមប្រព័ន្ធអ៊ីនធឺណេតក្នុងស្រុកជ្រៃធំខេត្តកាលពីថ្ងៃទី២៦ ខែកុម្ភៈ បន្ទាប់ពីមានការចរចារជាច្រើនថ្ងៃ និងរៀបចំផែនការ និងសម្របសម្រួលយ៉ាងយកចិត្តទុកដាក់ជាមួយភ្នាក់ងារអនុវត្តច្បាប់កម្ពុជា និងស្ថានទូតឥណ្ឌូនេស៊ីប្រចាំនៅទីក្រុងភ្នំពេញ។ ខណៈពេលដែលការជួយសង្គ្រោះអ្នកទាំង ៤៤នាក់ មិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលនោះទេ ដោយសារតែហេតុការណ៍បែបនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងកាសែតខ្មែរថាមស៍ និងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកផ្សេងទៀត ដោយការលាតត្រដាងដែលអ្នកត្រូវបានជួយសង្គ្រោះជាង ៣០ នាក់ក្នុងចំណោម ៤៤នាក់ បានឆ្លងកាត់ពេលវេលាដ៏អាក្រក់នៅពេលដែលពួកគេត្រូវបានជួញដូរដូចសត្វធាតុ ដោយក្រុមល្បែងស៊ីសងតាមប្រព័ន្ធអ៊ីនធឺណិតពីខេត្តព្រះសីហនុ ទៅកាន់ជ្រៃធំ ហើយបោះទីតាំងទៅទីនោះ។

ដូចបញ្ហាភាគច្រើនដែលជនបរទេសបានជួបប្រទះ ពេលធ្វើការឱ្យក្រុមហ៊ុនចិនបោកប្រាស់ ជនជាតិឥណ្ឌូនេស៊ីទាំងនេះត្រូវបានបង្ខំឱ្យធ្វើការ១២ម៉ោងក្នុងមួយថ្ងៃ ឬច្រើនជាងនេះ។ ពួកគេក៏បានប្រឈមមុខនឹងការគំរាមកំហែងពីក្រុមហ៊ុនដើម្បីឈានដល់ចំនួនជាក់លាក់នៃជនរងគ្រោះដែលត្រូវបានបោកប្រាស់ជារៀងរាល់ថ្ងៃ។ ប្រសិនបើកម្មករដែលត្រូវបានជ្រើសរើសមិនបានដល់កម្រិតទាបបំផុតនោះ ជីវិតរបស់ពួកគេនឹងរស់នៅក្នុងនរក។ ដើម្បីចាកចេញពីក្រុមហ៊ុន ប្រតិបត្តិករក្រុមហ៊ុនបានទាមទារឲ្យកម្មករ ឬគ្រួសាររបស់ពួកគេបង់ប្រាក់ចន្លោះពី ៣០០០ ទៅ ៥០០០ ដុល្លារជាប្រាក់សំណងដើម្បីដោះលែង។

# អាស៊ានណាប៉ូលលើកទី៤០ ផ្តោតសំខាន់
# លើបទល្មើសឆ្លងដែនចំនួន១០ ការជួញដូរគ្រឿងញៀន សកម្មភាព
# ភេរវកម្ម ការជួញដូរអាវុធ បទល្មើសពាណិជ្ជកម្មធនាគារ បណ្ណឥណទានក្លែងក្លាយ

https://cen.com.kh/ Posted ByPen Srey NeatMarch 6, 2022

ភ្នំពេញ ៖ សន្និសីទអាស៊ានណាប៉ូលលើកទី៤០ បានផ្លាស់ប្តូរនូវសភាពការណ៍ លទ្ធផលការងារ និងបទពិសោធន៍ល្អៗឲ្យគ្នា ទៅវិញទៅមក ទាក់ទងនឹងបទល្មើសឆ្លងដែន និងបទល្មើសមិនប្រពៃណីមួយចំនួន ក្នុងនោះបានផ្តោតសំខាន់លើបទល្មើសដែនចំនួន១០ រួមមាន ការជួញដូរគ្រឿងញៀនខុសច្បាប់ សកម្មភាពភេរវកម្ម ការជួញដូរអាវុធខុសច្បាប់ ការជួញដូរមនុស្ស បទល្មើសសត្វព្រៃ បទល្មើសផ្ទៃសមុទ្រ បទល្មើសពាណិជ្ជកម្មធនាគារ និងបណ្ណឥណទានក្លែងក្លាយ បទល្មើសបច្ចេកវិទ្យា ឯកសារធ្វើដំណើរក្លែងក្លាយ និងបទល្មើសឆ្លងដែន។

សន្និសីទអាស៊ានណាប៉ូលលើកទី៤០ បានប្រព្រឹត្តទៅនៅសណ្ឋាគារសុខាភ្នំពេញ កាលពីថ្ងៃទី០១-០៥ ខែមីនា ឆ្នាំ២០២២ ដោយមានការចូលរួមពីគណៈប្រតិភូជាតំណាងកងកម្លាំងនគរបាលនៃប្រទេសជាសមាជិកអាស៊ានទាំង១០ ប្រទេស/ស្ថាប័នជាដៃគូពិភាក្សាចំនួន០៩ (ចិន ជប៉ុន កូរ៉េ អូស្ត្រាលី ញូហ្សីលែន តួគី រុស្ស៊ី Interpol ភ្នាក់ងារឧក្រិដ្ឋកម្មអង់គ្លេស) និងប្រទេស/ស្ថាប័នអ្នកសង្កេតការណ៍ ចំនួន០៤ (បារាំង កាណាដា FBI និងIACP) សរុបប្រមាណ២៥០រូប ។ ពិធីបើកសន្និសីទ បានប្រព្រឹត្តទៅនៅសណ្ឋាគារសុខាភ្នំពេញ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានការចូលរួមពីឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសអាស៊ានប្រចាំនៅកម្ពុជា។ នាឱកាសនោះ សម្តេចក្រឡាហោម ស ខេង បានថ្លែងសន្ទរកថាបើកអង្គសន្និសីទ និងប្រកាសប្រធានបទ «លើកកម្ពស់សុខដុមនីយកម្ម តំបន់មានសន្តិភាព និងស្ថិរភាពជានិរន្តរ»។

បន្ទាប់ពីសេចក្តីរាយការណ៍ ស្តីពី វឌ្ឍនភាពនៃការអនុវត្តសេចក្តីថ្លែងការណ៍រួម នៃសន្និសីទអាស៊ានណាប៉ូលលើកទី៣៩ របស់ប្រធានប្រតិភូនគរបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមរួចមក នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ត្រូវបានជ្រើសរើសតែងតាំងជាប្រធាន ដើម្បីដឹកនាំសន្និសីទអាស៊ានណាប៉ូលលើកទី៤០។ សន្និសីទអាស៊ានណាប៉ូលលើកទី៤០ បានដំណើរការទៅដោយរលូនតាមកម្មវិធីដែលបានគ្រោងទុក ក្នុងស្មារតីមិត្តភាព ស្និទស្នាល គោរពគ្នាទៅវិញទៅមក និងទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា។ អង្គសន្និសីទ បានផ្លាស់ប្តូរនូវសភាពការណ៍ លទ្ធផលការងារ និងបទពិសោធន៍ល្អៗឲ្យគ្នាទៅវិញទៅមក ទាក់ទងនឹងបទល្មើសឆ្លងដែន និងបទល្មើសមិនប្រពៃណីមួយចំនួន ក្នុងនោះបានផ្តោតសំខាន់លើបទល្មើសដែនចំនួន១០ រួមមាន ការជួញដូរគ្រឿងញៀនខុសច្បាប់ សកម្មភាពភេរវកម្ម ការជួញដូរអាវុធខុសច្បាប់ ការជួញដូរមនុស្ស បទល្មើសសត្វព្រៃ បទល្មើសផ្ទៃសមុទ្រ បទល្មើសពាណិជ្ជកម្មធនាគារ និងបណ្ណឥណទានក្លែងក្លាយ បទល្មើសបច្ចេកវិទ្យា ឯកសារធ្វើដំណើរក្លែងក្លាយ និងបទល្មើសឆ្លងដែន។

អង្គសន្និសីទ ក៏បានពិភាក្សាផងដែរអំពីកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមកពេលមានគ្រាអាសន្ន ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពកងកម្លាំងនគរបាលក្នុងប្រទេសអាស៊ាន ការបន្តអភិវឌ្ឍន៍ប្រព័ន្ធទិន្នន័យអាស៊ានណាប៉ូល e-ADS 2.0 វិទ្យុនគរបាលអាស៊ាន។ ជាមួយនោះ សន្និសីទក៏បានឯកភាពទទួលយកសំណូមពររបស់ប្រទេសស្ថាប័នចំនួន ០៤ (នគរបាល Bangladesh នាយកដ្ឋានសន្តិសុខសាធារណៈអ៊ីតាលី ក្រសួងមហាផ្ទៃ អារ៉ាប់រួម និងនគរបាលសហព័ន្ធ Argentine) ធ្វើជាអ្នកសង្កេតការណ៍របស់អាស៊ានណាប៉ូល ព្រមទាំងបានឯកភាពគ្នាលើកិច្ចការមួយចំនួន ទាក់ទងនឹងការរៀបចំពង្រឹងដំណើរការលេខាធិការដ្ឋានអាស៊ានណាប៉ូល។

អង្គសន្និសីទបានបញ្ចប់ដោយការឯកភាព និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួម នៃសន្និសីទអាស៊ានណាប៉ូលលើកទី៤០ ដែលជាផែនទីបង្ហាញផ្លូវដល់កងកម្លាំងនគរបាលប្រទេសសមាជិកអាស៊ាន ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ចន្លោះពីពេលនេះរហូតដល់សន្និសីទអាស៊ានណាប៉ូលលើកទី៤១ ដែលបានកំណត់ប្រគល់ជូនក្រសួងសន្តិសុខសាធារណៈ នៃសាធារណៈប្រជាធិបតេយ្យប្រជាមានិតឡាវ ទទួលរ៉ាប់រងធ្វើជាម្ចាស់ផ្ទះ។

ក្នុងឱកាសអញ្ជើញបិទសន្និសីទអាស៊ានណាប៉ូល លើកទី៤០ នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងជាប្រធាននៃសន្និសីទនេះ បានលើកឡើងថា សន្និសីទនេះបានបម្រើដល់កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំង ទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់ និងគ្រប់ប្រភេទ ជាពិសេសប្រភេទឧក្រិដ្ឋកម្មថ្មីៗ ក្នុងគោលបំណងរួមចំណែកដោយផ្ទាល់ ដើម្បីធ្វើឲ្យសម្រេចចក្ខុវិស័យរបស់អាស៊ាន ក្នុងការអភិវឌ្ឍលើគ្រប់វិស័យ ខណៈដែលពិភពលោកកំពុងតែខិតខំរំកិលខ្លួន ចេញពីការគំរាមកំហែងនៃជំងឺកូវីដ-១៩។ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានបញ្ជាក់ថា តាមរយៈខ្លឹមសារនៃសេចក្តីថ្លែងការណ៍រួម ដែលបានអនុម័ត និងការដាក់ចេញផែនការសកម្មភាពនានា គួបផ្សំជាមួយទំនាក់ទំនងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធប្រកបដោយទស្សនៈសុទិដ្ឋិនិយម រវាងប្រទេសជាសមាជិក និងបណ្តាតំបន់ផ្សេងៗទៀតនៅលើសកលលោក សង្ឃឹមថា កងកម្លាំងនគរបាលអាស៊ាន នឹងបន្តកសាងស្នាដៃយ៉ាងធំធេង បង្កើតនូវសមិទ្ធផលថ្មីៗបន្ថែមទៀត ជាពិសេសការបង្កើតនូវបរិយាកាសសុខដុមនីយកម្ម ធ្វើឲ្យអាស៊ានធ្វើដំណើរឆ្ពោះទៅរកសន្តិភាព ស្ថិរភាព សុវត្ថិភាព ក្នុងស្មារតីសាមគ្គីភាព ឯកភាព មានកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## ថ្ងៃទី០៩ ខែ មីនា ឆ្នាំ២០២២

### នៅព្រឹកថ្ងៃអាទិត្យ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/06/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង០០នាទី នាថ្ងៃអាទិត្យ ៤កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី6 ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ-ប៊ុណ្ណា (មេបញ្ជាការរងកងអនុសេនាធំ) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៨នាក់ (ស្រី០៣នាក់ ក្មេងស្រីម្នាក់)។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមាន បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## នៅយប់ថ្ងៃព្រហស្បតិ៍ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/04/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង២១និង០០នាទី នាថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន៥៦នាក់ (ស្រី១៨នាក់ ក្មេង០៨នាក់ ក្មេងស្រី០២នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសំភារៈហាមឃាត់(ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) ក្នុងនោះដកហូតបានកាំបិត០៣ដើម រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺវិជ្ជមាន ចំនួន០៤នាក់ ស្រី០២នាក់ ក្រុមគ្រូពេទ្យបានបញ្ជូនអ្នកវិជ្ជមានទៅកាន់មណ្ឌលព្យាបាលកូវីដ-១៩ ស្ថិតក្នុងភូមិកណ្តាលឃុំសន្តិភាព ស្រុកសំពៅលូនខេត្តបាត់ដំបង។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន៤០នាក់ ស្រី១១នាក់ ក្មេងស្រី០១នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្តែនអត់ចេញ ចំនួន១២នាក់ ស្រី០៥នាក់ ក្មេង០៣នាក់ ក្មេងស្រី០១នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ជប៉ុនចាប់ផ្តើមជ្រើសរើសពលករខ្មែរ និងអ្នកហាត់ការឡើងវិញ

https://www.khmertimeskh.com/ ទិន សុខាវុធ / Khmer Times March 7, 2022

ក្រសួងការងារបានឱ្យដឹងថា ប្រទេសជប៉ុនបានបន្តជ្រើសរើសកម្មករជំនាញ និងកម្មសិក្សាការពីកម្ពុជាឡើងវិញ ចាប់ពីថ្ងៃទី១ ខែមីនា។ អ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ បាននិយាយកាលពីម្សិលមិញថា ដើម្បីធ្វើការនៅប្រទេសជប៉ុន កម្មសិក្សា និងកម្មករជំនាញត្រូវតែមានវិញ្ញាបនបត្រអវិជ្ជមានជំងឺកូវីត១៩។ លោកបានបន្ថែមថា កម្មករក៏ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងដាក់ឱ្យនៅដាច់ពីគេមុនពេលធ្វើដំណើរ។ លោកបានមានប្រសាសន៍ថា៖ « លើសពីនេះ កម្មករត្រូវដំឡើង និងចុះឈ្មោះជាមួយ « កម្មវិធីបញ្ជាក់ទំនាក់ទំនងជំងឺកូវីត១៩» នៅលើទូរស័ព្ទដៃរបស់ពួកគេ មុនពេលធ្វើដំណើរទៅប្រទេសជប៉ុន។ លោកបន្ថែមថា បន្ទាប់ពីទៅដល់ប្រទេសជប៉ុន កម្មករត្រូវផ្តល់កិច្ចសន្យាឱ្យនៅដាច់ពីគេដល់មន្ត្រីទទួលបន្ទុកនៅអាកាសយានដ្ឋាន។ លោកថា៖ « នៅក្នុងប្រទេសជប៉ុន កម្មករដែលត្រូវបានសម្គាល់ដោយរដ្ឋាភិបាលសម្រាប់ការចាក់វ៉ាក់សាំងចំនួនបី ចាំបាច់ត្រូវដាក់ឱ្យនៅដាច់ដោយ

ឡែករយៈពេលបីថ្ងៃនៅក្នុងកន្លែងស្នាក់នៅរបស់ពួកគេ។ ពួកគេក៏ត្រូវឆ្លងកាត់ការធ្វើតេស្តកូវិត១៩ បន្ទាប់ពីរយៈពេលបីថ្ងៃ»។

បើតាមលោក សួរ សម្រាប់កម្មករដែលមិនត្រូវបានគេស្គាល់អត្តសញ្ញាណសម្រាប់ការចាក់វ៉ាក់សាំងចំនួនបីដង ពួកគេត្រូវដាក់ឱ្យនៅដាច់ដោយឡែករយៈពេលបីថ្ងៃនៅកន្លែងដែលកំណត់ដោយអាជ្ញាធរ។ ពួកគេនឹងមិនត្រូវបានអនុញ្ញាតឱ្យប្រើមធ្យោបាយដឹកជញ្ជូនសាធារណៈឡើយ ហើយពួកគេត្រូវឆ្លងកាត់ការធ្វើតេស្តជំងឺកូវិត១៩ បន្ទាប់ពីបីថ្ងៃ។ លោកបានបន្តថា៖ «ចំពោះក្រុមហ៊ុនដែលជ្រើសរើសកម្មករ ពួកគេត្រូវសុំលិខិតអនុញ្ញាតការងារសម្រាប់អ្នកហាត់ការ និងកម្មករជំនាញតាមរយៈប្រព័ន្ធតាមដានអ្នកត្រឡប់មកវិញនៅប្រទេសជប៉ុន»។ លោកក៏បាននិយាយដែរថា ក្រុមហ៊ុនត្រូវដាក់ឯកសារអនុញ្ញាតការងារជាមួយនឹងពាក្យសុំទិដ្ឋាការនៅស្ថានទូតជប៉ុននៅភ្នំពេញ។ លោកបន្តថា៖ «រហូតមកដល់ពេលនេះ ក្រុមហ៊ុនឯកជនយ៉ាងហោចណាស់ចំនួន ១០៥ ត្រូវបានក្រសួងអនុញ្ញាតឱ្យជ្រើសរើស និងបណ្តុះបណ្តាលកម្មសិក្សាការី និងកម្មករជំនាញកម្ពុជាសម្រាប់មុខតំណែងនៅប្រទេសជប៉ុន»។ លោកបានបន្តថា រហូតមកដល់ពេលនេះ កម្មករខ្មែរយ៉ាងហោចណាស់ ៩ ១៩៥ នាក់បានឱកាសទទួលបានបទពិសោធជាភាសាជប៉ុនជាញឹកញាប់ជាមួយនឹងប្រាក់ខែរហូតដល់ ១៥០០ ដុល្លារក្នុងមួយខែ។ *សុ ជាតា*

## ថៃចាប់ពលករខ្មែរខុសច្បាប់បញ្ជូនមកស្រុក មានចំនួនច្រើនជាង ពលករទៅធ្វើការស្របច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៧ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ១៦:៥១

បន្ទាយមានជ័យ ៖ ពលករទៅមកលើទឹកដីថៃស្របច្បាប់ និងមិនស្របច្បាប់ គេឃើញកើតមានជាបន្តបន្ទាប់ ប៉ុន្តែការបញ្ជូនត្រឡប់មកវិញចំពោះពលករខុសច្បាប់ច្រើនជាងពលករស្របច្បាប់ ដែលក្រុមហ៊ុនបញ្ជូនទៅធ្វើការលើទឹកដីថៃ ។ ចំនួនពលករបញ្ជូនពីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត,ច្រកតំបន់ម៉ាឡៃ,ច្រកតំបន់បឹងត្រកួនក៏ដូចជាច្រកកិច្ចព្រមព្រៀង MOU បន្ទាយមានជ័យកម្ពុជា និងស្រះកែវថៃ គឺច្រករបៀងអូរបីជាន់ ក្នុងស្រុកអូរជ្រៅប៉ុន្មានថ្ងៃចុងក្រោយនៃខែមីនា ២០២២នេះ ហាក់មានច្រើនជាងពេលមុនៗ ខណៈពលករស្របច្បាប់ តាមរយៈក្រុមហ៊ុនផ្សេងៗបញ្ជូនចេញពីកម្ពុជាទៅធ្វើការងារលើទឹកដីថៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត កើតមានជាបន្តបន្ទាប់ ចាប់តាំងពីដើមខែកុម្ភៈ២០២២មក ។

តាមរបាយការណ៍ដែលកោះសន្តិភាពទទួលបានពីមន្ត្រីជំនាញរយៈពេល៤ថ្ងៃចុងក្រោយនេះ ពលករដែលភាគីថៃបញ្ជូនត្រឡប់តាមច្រករបៀង,តំបន់ និងអន្តរជាតិក្នុងខេត្តបន្ទាយមានជ័យ ក្នុងមួយថ្ងៃមិនក្រោម៦០០នាក់ និងមានថ្ងៃខ្លះរហូតជាង៨០០នាក់ក៏មានដែរ ។ ជាក់ស្តែងថ្ងៃទី៣ មីនា មានពលករបញ្ជូនពីថៃចំនួន៨៦២នាក់ ស្រី៣៥៣នាក់ កុមារ៩៦នាក់,ថ្ងៃទី៤ ចំនួន៦២១នាក់ ស្រី២៥០នាក់កុមារ៧១នាក់ ថ្ងៃទី៥ ចំនួន៧០១នាក់ ស្រី២៧៩នាក់ កុមារ៩៧នាក់ ថ្ងៃទី៦ ចំនួន៦៤០នាក់ ស្រី២៥៧នាក់ និងកុមារ៦៤នាក់ និងថ្ងៃទី៧នេះ នៅមិនទាន់ទទួលបានព័ត៌មានលម្អិតពីមន្ត្រី និងសមត្ថកិច្ចជំនាញនៅឡើយ ព្រោះការងារកំពុងដំណើរការមិនទាន់ដល់ម៉ោងបិទបញ្ចប់ ។

ចំពោះពលករស្របច្បាប់តាមរយៈក្រុមហ៊ុនបញ្ជូនចេញពីកម្ពុជាទៅធ្វើការលើទឹកដីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅថ្ងៃទី៧ មីនា២០២២ មានចំនួន១៥៩នាក់ ។ បើតាមកាឲ្យដឹងពីតំណាងក្រុមហ៊ុនសឹកសេសមេនផៅវ័រសឺវីសហៅកាត់ថា (SMS) ប្រាប់ថា ពលករទាំងនេះ និងទៅធ្វើការក្នុងរោងចក្រសាច់មាន់ នៅខេត្តឡបបូរីប្រទេសថៃ ។

ចំពោះករណីបញ្ជូនអន្តោប្រវេសន៍ខុសច្បាប់ឆ្លងដែនទៅប្រទេសកំណើតវិញ មានកាកត់សំគាល់ថា ខុសគ្នាដូចមេឃ និងដី បើប្រៀបធៀបអន្តោប្រវេសន៍ខ្មែរ និងអន្តោប្រវេសន៍ថៃ ។

ដាក់ស្តែងអន្តោប្រវេសន៍ថៃចូលមកធ្វើការ និងស្នាក់នៅខុសច្បាប់លើទឹកដីខ្មែរពេលបញ្ជូនត្រឡប់ម្តងៗជិះសុទ្ធតែរថយន្តទំនើបមានទាំងស៊ីរ៉ែននាំមុខដូចក្បួនប្រតិភូអ្នកធំ ខណៈអន្តោប្រវេសន៍ខ្មែរគេដឹកមកវិញតាមរថយន្តទ្រុង និងប្រជ្រៀតគ្នាណែន សូម្បីកុមារតូចៗក៏មិនលើកលែងមើលទៅពិតជាគួរឲ្យសង្វេគណាស់ ៕

## សហព័ន្ធឧស្សាហកម្មថៃជំរុញរដ្ឋ
## ឱ្យមានវិធានការឱ្យបានលឿន ចំពោះបញ្ហាកង្វះកម្លាំងពលកម្ម

https://www.khmertimeskh.com/ Khmer Times March 8, 2022

សហព័ន្ធឧស្សាហកម្មថៃ (FTI) កំពុងទាមទារឱ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីដោះស្រាយកង្វះខាតធ្ងន់ធ្ងរនៃកម្លាំងពលកម្មចំនួន ៧០០,០០០នាក់ បើទោះបីជារដ្ឋាភិបាលកំពុងធ្វើការដើម្បីនាំយកពលករចំណាកស្រុកមកពីប្រទេសជិតខាងក៏ដោយ។ លោក Suchart Chantaranakaracha អនុប្រធាន FTI ទទួលបន្ទុកកិច្ចការការងារបាននិយាយថា កាលពីខែមុន សហព័ន្ធបានអំពាវនាវឱ្យអាជ្ញាធរពន្លឿនការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MoUs) ជាមួយមន្ត្រីក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដើម្បីនាំចូលកម្លាំងពលកម្ម។ លោកបាននិយាយថា "យើងចង់ឱ្យរដ្ឋាភិបាលដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មជាបន្ទាន់ ព្រោះបញ្ហានេះកំពុងគំរាមកំហែងប៉ះពាល់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចថៃ"។ លោក Suchart បាននិយាយថា រដ្ឋាភិបាលបានព្យាយាមនាំចូលពលករពីប្រទេសទាំងបី ប៉ុន្តែចាំបាច់ត្រូវធ្វើបន្ថែមទៀត។ ចំនួនពលករមកពីកម្ពុជាមានចំនួនលើសប្រទេសមីយ៉ាន់ម៉ា ដែលជាធម្មតាជាប្រភពកម្លាំងពលកម្មបរទេសដ៏សំខាន់ក្នុងប្រទេសថៃ។

FTI បានស្នើឱ្យរដ្ឋមន្ត្រីក្រសួងការងារថៃពិភាក្សាដោយផ្ទាល់ជាមួយរដ្ឋមន្ត្រីការងារនៃប្រទេសទាំងបី ដើម្បីពន្លឿនដំណើរការចុះហត្ថលេខាលើ MoU ។ លោកបាននិយាយថា "រដ្ឋមន្ត្រីថៃគួរតែជួបពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងការងារក្នុងប្រទេសមីយ៉ាន់ម៉ា ពីព្រោះការសម្រេចចិត្តក្នុងកម្រិតនេះនឹងត្រូវបានធ្វើឡើងលឿនជាងកិច្ចប្រជុំផ្លូវការ" ។ លោក Suchart បាននិយាយថា រដ្ឋាភិបាលថៃក៏គួរតែសម្របសម្រួលដំណើរការនាំចូលកម្លាំងពលកម្មដោយកាត់បន្ថយការចំណាយ និងបទប្បញ្ញត្តិដែលមិនចាំបាច់។ លោកបាននិយាយថា មន្ត្រីអាចពិនិត្យពលករចំណាកស្រុកដែលឆ្លង Covid-19 ដោយប្រើឧបករណ៍តេស្តអង់ទីហ្សែនរហ័ស ជាជាងការធ្វើតេស្ត PCR ហើយគួរតែអនុវត្តគម្រោង Test & Go ដោយមិនចាំបាច់ធ្វើចត្តាឡីស័កនៅពេលមកដល់ក្នុងរយៈពេលពី ៧ ទៅ ១៤ ថ្ងៃ។

លោក Suchart ក៏បានស្នើឱ្យរដ្ឋាភិបាលពិចារណាផ្តល់ការលើកលែងទោសដល់ពលករចំណាកស្រុកដែលចូលប្រទេសថៃដោយខុសច្បាប់ និងដល់និយោជករបស់ពួកគេដែលបានបំពានច្បាប់ការងារ ព្រោះនេះធ្វើឱ្យបទប្បញ្ញត្តិកាន់តែងាយស្រួលសម្រាប់ពលករ។ លោកបានបន្តថា៖ «វិធីសាស្ត្រនេះអាចកាត់បន្ថយចំនួនពលករចំណាកស្រុកខុសច្បាប់ ហើយអាចជួយប្រទេសថៃក្នុងការដោះស្រាយបញ្ហាពុំរ៉ៃនេះបានកាន់តែប្រសើរ»។ ប្រទេសថៃត្រូវការកម្មករ ដើម្បីបម្រើក្នុងរោងចក្រ និងអាជីវកម្មទាក់ទងនឹងវិស័យទេសចរណ៍ និងសេវាកម្ម។ វិស័យនាំចេញកើនឡើង ធ្វើអោយមានតម្រូវការកម្លាំងពលកម្ម។

មានពលករចំណាកស្រុកជាង ២ លាននាក់នៅក្នុងប្រទេសថៃ ប៉ុន្តែ ៥០០,០០០ ទៅ ៦០០,០០០នាក់បានត្រឡប់ទៅប្រទេសរបស់ពួកគេវិញ បន្ទាប់ពីជំងឺរាតត្បាតបានវាយប្រហារនៅដើម ឆ្នាំ២០២០ ដោយសារសកម្មភាពអាជីវកម្មជាច្រើនត្រូវបានផ្អាក ដែលបណ្តាលឱ្យពួកគេបាត់បង់ការងារ។ ភាគច្រើននៅមិនទាន់ត្រឡប់ទៅប្រទេសថៃវិញទេ៕ ប្រភព: Bangkokpost

# ឆ្នាំ ២០២១ CPU ចូលរួមស៊ើបអង្កេត
# និងចាប់ខ្លួនជនប្រព្រឹត្តល្មើសលើកុមារបានជាង ៣០០ ករណី

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 08 March 2022 | 08:50 ICT

**ភ្នំពេញៈ** នៅក្នុងឆ្នាំ ២០២១ អង្គភាពការពារកុមារ (CPU) បានចូលរួមស៊ើបអង្កេត និងចាប់ខ្លួនជនដែលបានប្រព្រឹត្តបទល្មើសលើកុមារបានជាង ៣០០ ករណី ដែលមានជនសង្ស័យជិត ៣០០ នាក់។ នេះបើតាមរបាយការណ៍សង្ខេបប្រចាំឆ្នាំ ២០២១ របស់ អង្គភាព CPU។ របាយការណ៍បានឱ្យដឹងថា ក្នុងឆ្នាំ ២០២១ CPU បានចូលរួមក្នុងប្រតិបត្តិការស៊ើបអង្កេតបទល្មើសឧក្រិដ្ឋប្រឆាំងនឹងកុមារចំនួន ៣១៣ ករណី ដោយបានឈានទៅចាប់ខ្លួនជនសង្ស័យចំនួន ២៦៨ នាក់ ឬស្មើ ៨៥ ភាគរយ។ ក្នុងប្រតិបត្តិការរបស់ CPU ពេញ ១ ឆ្នាំ ក្នុងការចូលរួមបង្ក្រាប និងស៊ើបអង្កេតបទល្មើសប្រឆាំងនឹងកុមារនេះ គឺ CPU បានចំណាយទឹកប្រាក់ប្រមាណ ១ ១២១ ៣៥៣ ដុល្លារ។ របាយការណ៍បញ្ជាក់ថាៈ «ទីតាំងនៃការប្រព្រឹត្តបទល្មើស មាននៅភ្នំពេញ និងខេត្តកំពង់ឆ្នាំងមាន ៥ ទីតាំង។ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម មាន ២ ទីតាំង និងក្រៅពីហ្នឹង ១ ទីតាំងដូចជាខេត្តកណ្ដាល សៀមរាប កំពង់ធំ ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ ហើយទំនាក់ទំនងដែលកើតឡើង ទៅលើជនរងគ្រោះ គឺភាគច្រើនជនសង្ស័យជាអ្នកជិតខាង»។

លោក James McCabe នាយកប្រតិបត្តិអង្គភាពការពារកុមារបាននិយាយថា ឆ្នាំ ២០២១ គឺជាឆ្នាំមួយដែលពោរពេញដោយភាពលំបាក និងឧបសគ្គ។ ប៉ុន្តែលោកនៅតែលើកយកឱកាសនេះ ដើម្បីថ្លែងអំណរគុណ ទៅដល់អ្នកពាក់ព័ន្ធដែលបានផ្តល់ការគាំទ្រ ជាពិសេសក្រុមការងាររបស់អង្គភាពការពារកុមារ (CPU) នគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននគរបាលអន្តរជាតិ ដែលជាដៃគូ ដែលបានផ្តល់យោបល់ជំនាញ និងការណែនាំមួយចំនួន ចំពោះកិច្ចការស៊ើបអង្កេតដ៏ហត់នឿយខ្លះៗ ដែលមានភាពលំបាក និងទាមទាររយៈពេលយូរ។ លោក James McCabe បញ្ជាក់ថាៈ «CPU និងនគរបាលជាតិកម្ពុជា បានបំពេញកិច្ចការល្អៗជាច្រើននៅក្នុងឆ្នាំ ២០២១ ដើម្បីប្រឆាំង និងផ្តន្ទាទោសទៅលើរាល់ជនល្មើស ដែលបានប្រព្រឹត្តបទល្មើសទៅលើកុមារ»។

របាយការណ៍ប្រចាំឆ្នាំរបស់ CPU នឹងត្រូវប្រគល់ជូនរាជរដ្ឋាភិបាលក្រសួងមហាផ្ទៃអគ្គស្នងការនគរបាលជាតិកម្ពុជាក្រសួងជាដៃគូនានា និងស្នងការដ្ឋាននគរបាល តាមបណ្តាខេត្ត-ក្រុង ដោយរបាយការណ៍នេះ រៀបរាប់អំពីរាល់កិច្ចការស៊ើបអង្កេត ការផ្តន្ទាទោស សេវាកម្មដែលបានផ្តល់ជូនជនរងគ្រោះភាពជោគជ័យ សមិទ្ធផល និងភាពបរាជ័យដែលមាននៅក្នុងឆ្នាំ ២០២១។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ៧ មីនាថា CPU គឺជាអង្គភាពមួយ ដែលធ្វើការសហការជាមួយក្រសួងមហាផ្ទៃដែលអាចជឿទុកចិត្តបាន និងជួយគ្នាទៅវិញទៅមក ក្នុងការងារស៊ើបអង្កេត រាល់បទល្មើសដែលកើតឡើងទៅលើកុមារកម្ពុជា។ លោកស្រីបន្តថា ការសហការនេះ គឺមានភាពជោគជ័យខ្លាំង ដែលបានឈានទៅរកការចាប់ខ្លួន និងវែកមុខជនសង្ស័យយកមកផ្តន្ទាទោស បើទោះបទល្មើសទាំងនោះបានកើតឡើងយ៉ាងណាក្តី ប៉ុន្តែរាល់សកម្មភាពដែលប្រឆាំងទៅលើកុមារ ដែលមានការចូលរួមពីអង្គការនេះត្រូវបានធានាថា ជនសង្ស័យមិនអាចគេចផុតពីសំណាញ់ច្បាប់បាននោះទេ។

លោកស្រីបានរៀបរាប់ថាៈ «រហូតមកដល់ពេលនេះ ករណីរំលោភបំពានលើកុមារ គឺមានចំនួនច្រើនជាងមុន និងកាន់តែសាហាវ។ ប៉ុន្តែទោះបីច្រើនប៉ុណ្ណឹង ក៏យើងមើលឃើញថា យើងនៅតែអាចតាមបង្ក្រាបបានជាង ៩០ ភាគរយមានន័យថា បទល្មើសស្ទើរតែទាំងស្រុង ត្រូវបានបង្ក្រាបប្រកបដោយប្រសិទ្ធភាព»។ លោកស្រី ជូ ប៊ុន

អេង បានបញ្ជាក់ពីការតាំងចិត្តខ្ពស់ ជាមួយដៃគូពាក់ព័ន្ធ ជាពិសេសអង្គភាព CPU នេះ ដោយមិនត្រឹមតែមានមហិច្ឆតាក្នុងការកាត់បន្ថយអំពើល្មើសទៅលើកុមារប៉ុណ្ណោះទេ គឺក្រសួងមហាផ្ទៃ មានមហិច្ឆតាក្នុងការលុបបំបាត់អំពើនានាប្រឆាំងទៅលើកុមារកម្ពុជា ដែលលោកស្រីចាត់ទុកថា ការឈានទៅរកមុខជនប្រព្រឹត្តបទល្មើសទាំងនោះ ដើម្បីយកមកទទួលទោសតាមច្បាប់ គឺជាជំហានមួយដែលត្រូវរួមគ្នាបន្តទៀត ដើម្បីធ្វើយ៉ាងណា ជានានូវយុត្តិធម៌ដល់កុមាររងគ្រោះ៕

## ថ្ងៃទី១០ ខែ មីនា ឆ្នាំ២០២២

### រកឃើញពលករខ្មែរ ៩នាក់ វិជ្ជមាន
### ជំងឺកូវីដ-១៩ ក្នុងចំណោមពលករជាង ៣០០នាក់ ដែលភាគីថៃបញ្ជូនមកកម្ពុជា

https://gntimes.com/ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២

បាត់ដំបង៖ ពលករខ្មែរ ប្រុស-ស្រី ជាង ៣០០នាក់ ត្រូវបានភាគីថៃចាប់បញ្ជូនមកកម្ពុជាតាមច្រកព្រំដែនស្ថិតក្នុងស្រុកកំរៀង ក្នុងចំណោមពលករទាំងជាង ៣០០នាក់ មាន ៩នាក់ វិជ្ជមានកូវីដ-១៩ ។ នគរបាលការពារនៅតាមបន្ទាត់បានឲ្យដឹងថា នៅព្រឹកថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០២២ នេះ កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងឃោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ សមត្ថកិច្ចបន្តថា បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួចឃើញថា ពលករសរុបមាន ៣២១នាក់ ស្រី ១៣០នាក់ ក្មេង ៤០នាក់ បន្ទាប់មកក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស ជាលទ្ធផលវិជ្ជមានកូវីដ ៩នាក់ ស្រី ៤នាក់ ។

សមត្ថកិច្ចបន្តទៀតថា បន្ទាប់ពីធ្វើតេស្តសំណាកហើយ ពលករ ១១៧នាក់ ស្រី ៤៣នាក់ និងក្មេង ១៤នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្តបាតដំបង ចំណែកពលករដែលមានកាតចាក់វ៉ាក់សាំងសរុប ១៩៥នាក់ ស្រី ៨៣នាក់ និងក្មេង ២៦នាក់ ក្នុងនោះ បានចាក់វ៉ាក់សាំងឱ្យក្មេងចាប់ពីអាយុ ៥ ឆ្នាំ ដល់ ១៨ឆ្នាំ ១៦នាក់ ស្រី ៦នាក់ ត្រូវបានក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕

### អាជ្ញាធរស្រុកសំពៅលូន នៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពី ប្រទេសថៃ និងប្រគល់នៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/03/08/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១១និង៣០នាទី នាថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡែ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនចក្រី ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ឆាង-ធៀន (នាយរងប៉ុស្តិ៍) សហការជាមួយកម្លាំងឃោជាកងអនុសេនាធំទី២ វរសេនាតូចលេខ១ចំនួន០៤នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី ណន-វន្នី (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចភូមិសាស្រ្ត ភូមិកោះតូច ឃុំសំពៅលូន ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២០នាក់ ស្រី០៨នាក់ ក្មេងប្រុស០២នាក់។ ក្រោយពី

ទទួលបាន កម្លាំងយើងធ្វើការសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចប្រគល់បងប្អូនឲ្យក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## នៅព្រឹកថ្ងៃអង្គារ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ព្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/08/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែមីនា ឆ្នាំ ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន០៨នាក់ (ស្រី០៣នាក់ ក្មេងប្រុស០២នាក់)។

ក្រោយពីទទួលបានកម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចប្រគល់បងប្អូនចំនួន ០៣នាក់ (ស្រីម្នាក់) ទៅឲ្យក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារអន្តរជាតិគីឡូ១៣ និងបងប្អូនចំនួន០៥នាក់ ស្រី០២នាក់ ក្មេងប្រុស០២នាក់ ទៅឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្តនិងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺអវិជ្ជមាន។ បន្ទាប់មកក្រុមពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ។

## ថ្ងៃទី១១ ខែ មីនា ឆ្នាំ២០២២

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពី ប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/03/10/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៥និង៣០នាទី នាថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនកូនភ្នំចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ខៀវ-រ៉ាត់ (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី១,វរសេនាតូចលេខ១ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឡៃ-លឿន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាកងអនុសេនាធំគាំទ្រ,វរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ភួង-រ៉េ (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន

០៥នាក់ (ស្រីម្នាក់)។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ និងអប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឲ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/03/10/ Seng Chanmonirith ខេត្តបាត់ដំបង

នៅថ្ងៃព្រហស្បតិ៍ ៨ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២២ ដោយអនុវត្តនតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនគរបាលខេត្តបាត់ដំបង និង លោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្រ្ត ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១៤៧នាក់, ស្រី៥៧នាក់ និងក្មេង៣នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ ៦នាក់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ១២០នាក់ (ស្រី៤៧នាក់, ក្មេង២៤នាក់) ចំណែកពលករចំនួន២៤នាក់, ស្រី៩នាក់ និងក្មេង៥នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួន១៦នាក់ (ស្រី១០នាក់) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## នៅព្រឹកថ្ងៃពុធ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/09/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង៣០នាទី នាថ្ងៃពុធ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្ត បាត់ដំបង ចំនួន៥៨នាក់ (ស្រី២៤នាក់ ក្មេង០៤នាក់ ក្មេងស្រីម្នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសំភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក)។ ដោយដកហូតបានកាំបិត០១ដើម រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យ នៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្ដិ៍។ ជាលទ្ធផល គឺវិជ្ជមាន ចំនួន០៤នាក់ ស្រី០២នាក់ ក្មេងស្រីម្នាក់ (រួមនឹងម្ដាយម្នាក់អវិជ្ជមាន) ក្រុមគ្រូពេទ្យបានបញ្ជូនអ្នកវិជ្ជមានទៅកាន់មណ្ឌលព្យាបាលកូវីដ-១៩ ស្ថិតក្នុងភូមិកណ្ដាល ឃុំសន្តិភាព ស្រុកសំពៅលូនខេត្តបាត់ដំបង។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន៣៧នាក់ ស្រី១៤នាក់ ក្មេងប្រុស០៣នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ដែនអត់ចេញ ចំនួន១៦នាក់ ស្រី០៧នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ពលករមកពីថៃ
## តាមច្រកខេត្តបន្ទាយមានជ័យ មានច្រើនរាល់ថ្ងៃ និងរកឃើញវិជ្ជមាន ២០ទៅ៣០នាក់

https://news.btv.com.kh/ 03/10/2022 11:03 AM

បន្ទាយមានជ័យ៖ នៅមុនបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ពលករខ្មែរត្រឡប់មកពីប្រទេសថៃ ឆ្លងដែនតាមច្រកជាប់ ក្នុងបន្ទាយមានជ័យ មានចំនួនច្រើនរាល់ថ្ងៃ ហើយក្នុងចំណោមពលករទាំងនោះ ត្រូវបានរកឃើញមានវិជ្ជមានកូវីដ-១៩ ប្រមាណពី២០ ទៅ៣០នាក់ ជាប្រភេទបំប្លែងថ្មី អូមីក្រុង ហើយបានបញ្ជូនទៅព្យាបាល នៅតាមមណ្ឌល ឬមន្ទីរពេទ្យ ដែលបានរៀបចំទុកជាស្រេច ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១០ ខែមីនា នេះ បានឱ្យដឹងថា នារយៈពេលចុងក្រោយនេះ ពលករខ្មែរ មកពីប្រទេសថៃ ដែលឆ្លងតាមច្រកនានាជាប់ខេត្តបន្ទាយមានជ័យ គឺមានចន្លោះពី៤០០ ទៅ៥០០នាក់ ហើយនៅថ្ងៃខ្លះ ក៏មានចំនួនលើសនោះផងដែរ។ ឯកឧត្តម បានបន្តថា ពលករទាំងអស់ ដែលឆ្លងដែនមក ត្រូវបានអាជ្ញាធរ និងមន្ត្រីសុខាភិបាលពិនិត្យសុខភាព និងធ្វើតេស្តសំណាកគ្រប់គ្នា ដើម្បីរកមេរោគកូវីដ-១៩ រួមទាំងអ្នកមិនទាន់បានចាក់វ៉ាក់សាំង ក៏ត្រូវបានជំរុញ និងណែនាំពួកគេឲ្យទៅចាក់ ឲ្យបានគ្រប់គ្នា។ ឯកឧត្តម អ៊ុំ រាត្រី បានបញ្ជាក់ថា សម្រាប់ពលករខ្មែរ ដែលឆ្លងដែនមកពីប្រទេសថៃ តាមចំនួននៃ ខេត្តបន្ទាយមានជ័យ ក្នុងនោះមានច្រកបឹងត្រកួន ច្រកអូរបីជាន់ និងច្រកស្រុកម៉ាឡៃជាដើម៕ អត្ថបទ៖ បាន សុខរិទ្ធ

## អាជ្ញាធរថៃ បញ្ជូនប្រជាពលរដ្ឋ
## ចំនួន ១៤៧នាក់ ចូលប្រទេសកម្ពុជាវិញ តាមច្រកតំបន់អូរអន្លក់

https://cen.com.kh/ Posted ByPen Srey NeatMarch 10, 2022

បាត់ដំបង ៖ នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តនតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ដាប់ជាប្រចាំស្ដីពីការការពារសន្តិសុខ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញ ដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រក្រោមការបញ្ជាផ្ទាល់ របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ ទទួលពលករវិលត្រឡប់មកស្រុកវិញ នៅច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។

ប្រជាពលរដ្ឋសរុបចំនួន ១៤៧នាក់ ស្រី ៥៧នាក់ ក្មេង ៣០នាក់ ក្មេងស្រី ១៣នាក់ ត្រូវបានសមត្ថកិច្ចសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួច ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស ជាលទ្ធផល ៖ វិជ្ជមានកូវីដ-១៩ ចំនួន ៣នាក់ ស្រី ១នាក់ ក្មេង ១នាក់ ដោយឡែកពលករចំនួន ២៤នាក់ ស្រី ៩នាក់ ក្មេង ៥នាក់ ក្មេងស្រី ១នាក់ បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្តបាត់ដំបង ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ១២០នាក់ ស្រី ៤៧នាក់ ក្មេង ២៤នាក់ ក្មេងស្រី ១២នាក់ ។ ក្នុងនោះបានចាក់វ៉ាក់សាំងឲ្យក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន ១៦នាក់ ស្រី ១០នាក់ ក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## ថ្ងៃទី១៤ ខែ មីនា ឆ្នាំ២០២២

### ក្រុមអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ ស្នើសុំឲ្យបំបាត់អំពើទាសភាពនៅកម្ពុជា

https://www.rfa.org/ ដោយ ខែ សុណាង 2022-03-10

ក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ស្នើសុំឲ្យអាជ្ញាធរចាត់វិធានការរួមគ្នា ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស និងទាសភាព នៅក្នុងប្រទេសកម្ពុជា។ សេចក្តីថ្លែងការណ៍រួមរបស់អង្គការ សមាគម ជាតិនិងអន្តរជាតិ នៅថ្ងៃទី១០ ខែមីនានេះ ឲ្យដឹងថា ពួកគេមានការព្រួយបារម្ភជាខ្លាំង ចំពោះការកើនឡើង នៃការជួញដូរមនុស្ស ការចាប់បង្ខំឲ្យធ្វើពលកម្ម អំពើទាសភាព និងទារុណកម្ម នៅតាមបរិវេណអគារនានា នៅកម្ពុជា។ ក្រុមអង្គការក្នុងស្រុក និងអន្តរជាតិ បានចងក្រងការរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ និងគណនីបណ្តាញសង្គមរបស់ជនរងគ្រោះរកឃើញថា មានមនុស្សរាប់ពាន់នាក់ ដែលភាគច្រើនជាជនបរទេស ត្រូវបានទទួលរងគ្រោះ នៃការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរទាំងនេះ។

នាយកផ្នែកកិច្ចការទូទៅនៃអង្គការលីកាដូលោក អំ សំអាត មានប្រសាសន៍ប្រាប់វិទ្យុអាស៊ីសេរី មុនការផ្សាយនេះបន្តិចថា សមត្ថកិច្ចត្រូវសហការជាមួយសហគ្រាស ដែលប្រព្រឹត្តបទល្មើសទាំងនេះ ដើម្បីស៊ើបអង្កេតឲ្យបានច្បាស់លាស់ ក្នុងការលុបបំបាត់អំពើជួញដូរនិងទាសភាព ឲ្យមានប្រសិទ្ធភាព នៅក្នុងប្រទេសកម្ពុជា៖ «នៅក្នុងសេចក្តីថ្លែងការណ៍រួម ដើម្បីលុបបំបាត់អំពើទាសភាពនៅក្នុងប្រទេសកម្ពុជានេះ ព្រោះរយៈពេលកន្លងមកយើងឃើញ មានការកើនឡើងនៃការជួញដូរ ការប្រព្រឹត្តបទល្មើស តាមប្រព័ន្ធអ៊ីនធឺណិត ការធ្វើទារុណកម្មផ្សេងៗ សរុបមកមានជាង ១០០ករណីហើយ ដែលប្រទេសថៃ វៀតណាម ប្រទេសឥណ្ឌូនេស៊ី ដែលបានជួយរំដោះជនរងគ្រោះត្រឡប់ទៅវិញ»។

សេចក្តីថ្លែងការណ៍ដដែល ក៏បានបញ្ជាក់ថា ការរំលោភបំពានពាក់ព័ន្ធនឹងជនបរទេស ដែលត្រូវបានចាប់ជំរិត លក់ ជួញដូរ ឬត្រូវបោកបញ្ឆោត ឲ្យទទួលការងារនៅក្នុងខេត្តមួយចំនួន រួមមាន ខេត្តព្រះសីហនុ ភ្នំពេញ ពោធិ៍សាត់ កោះកុង ជាដើម។ បន្ទាប់មកពួកគេត្រូវបានឃុំខ្លួន ក្នុងបរិវេណអគារធំៗ និងត្រូវបង្ខំឲ្យធ្វើការលើសម៉ោង គ្មានពេលសំរាកជាដើម។ ជនរងគ្រោះដែលបានរត់គេចខ្លួនរួច បានរាយការណ៍ថា ពួកគេត្រូវបានធ្វើបាបទាំងរាងកាយ ផ្លូវចិត្ត រងអំពើហិង្សាពីសំណាក់ក្រុមដែលបង្ខាំងពួកគេ៕

# អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិចំនួន
# ៣៦ស្ថាប័ន ស្នើឱ្យអាជ្ញាធរខ្មែរត្រូវដោះស្រាយ និងលុបបំបាត់ទាសភាពនៅកម្ពុជា

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 11/03/2022 - 07:08

បណ្ដាអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិចំនួន៣៦ស្ថាប័ន នៅថ្ងៃទី១០ មីនា ម្សិលមិញ បានចេញសេចក្តីថ្លែងការណ៍រួមមួយ ដោយទទូចឱ្យអាជ្ញាធរកម្ពុជាត្រូវចាត់វិធានការ និងដាក់ចេញនូវសកម្មភាពលុបបំបាត់ទាសភាពនៅកម្ពុជា។ ក្នុងសេចក្ដីថ្លែងការណ៍នោះ អង្គការសង្គមស៊ីវិលបានអះអាងថា សកម្មភាពជួញដូរមនុស្សចូលមកកម្ពុជាមានការកើនឡើងខ្លាំងដែលបានបង្កឱ្យកើតមានការធ្វើពលកម្មដោយបង្ខំនិងរំលោភសិទ្ធមនុស្សយ៉ាងធ្ងន់ធ្ងរ។ ក្នុងសេចក្ដីថ្លែងការណ៍រួមរបស់បណ្ដាអង្គការសង្គមស៊ីវិល និងសិទ្ធិមនុស្សទាំងជាតិនិងអន្តរជាតិចំនួន៣៦ស្ថាប័ន បានចេញមកសម្ដែងការព្រួយបារម្ភកាន់តែខ្លាំង ជុំវិញស្ថានភាពជួញដូរមនុស្សចូលប្រទេសកម្ពុជា។ របាយការណ៍ជាច្រើនបានបង្ហាញថា កម្រិតជួយដូរមនុស្សចូលមកកម្ពុជាយ៉ាងសំបើប បានបង្កឱ្យមានសកម្មភាពធ្វើពលកម្មដោយបង្ខំ អំពើទាសភាព និងទារុណកម្មនៅតាមបរិវេណអគារនានា នៅក្នុងប្រទេសកម្ពុជា។ របាយការណ៍មួយចំនួនបានបង្ហាញថា ភាគច្រើននៃបរិវេណអគារទាំងនោះ គឺស្ថិតនៅក្នុងខេត្តព្រះសីហនុ។ ប៉ុន្តែក៏មានដែរ ការរំលោភបំពានស្រដៀងគ្នានេះ ត្រូវបានអង្គការជាតិនិងអន្តរជាតិរកឃើញថា កំពុងកើតមានឡើង នៅក្នុងរាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តមួយចំនួនទៀត។

បើតាម កាសែតបាងកកប៉ុស្ដិ៍ចុះផ្សាយថ្ងៃទី១១ ខែ មីនា ឆ្នាំ២០២២ សកម្មភាពជួយដូរ និងការរំលោភបំពានដែលកើតមានឡើងក្នុងប្រទេសកម្ពុជា ភាគច្រើនគឺជាប់ពាក់ព័ន្ធនឹងជនបរទេសដែលត្រូវបានចាប់ជំរិត លក់ជួយដូរ ឬត្រូវបានបោកបញ្ឆោតឱ្យទទួលបានការងារនៅស្រុកខ្មែរ។ ជនបរទេសរាប់ពាន់នាក់ ត្រូវបានចាប់ឃុំខ្លួនក្នុងបរិវេណអគារធំៗ និងបង្ខំឱ្យធ្វើការដែលពាក់ព័ន្ធនឹងប្រតិបត្តិការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេត ដែលដាក់គោលដៅលើជនបរទេសរស់នៅខាងក្រៅប្រទេសកម្ពុជា។ ជារួមមានការទទូចស្នើឱ្យរដ្ឋាភិបាលកម្ពុជាឆ្លើយតបទៅនឹងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនេះ ធ្វើឡើងបន្ទាប់ពី បណ្ដាស្ថានទូតប្រទេសចំនួន៥ ក្នុងនោះរួមមាន៖ ប្រទេសឥណ្ឌូនេស៊ី ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសប៉ាគីស្ថាន និងប្រទេសចិន បានចេញសេចក្ដីថ្លែការណ៍ព្រមានអំពីស្ថានភាពជួញដូរមនុស្សយ៉ាងច្រើនចូលមកក្នុងកម្ពុជា ដើម្បីចាប់ជំរិតតាមប្រព័ន្ធអ៊ីនធឺណេត។ជាក់ស្ដែងអាជ្ញាធរថៃ ទើបតែទទួលបានពលរដ្ឋខ្លួនចំនួន៨នាក់វិលពីប្រទេសកម្ពុជា។ ពួកគេបានបញ្ជាក់មកកាន់កាសែតបាងកកប៉ុស្ដិ៍ថា ជនចាប់ជំរិតបានវាយដំ និងបង្អត់អាហារពួកគេ ក្រោយបដិសេធមិនចូលរួមការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេត។ លើសពីនេះទៅ ជនរងទារុណកម្មទាំងអស់នោះ គឺត្រូវបូមឈាមលក់ថែមទៀតផងដែរ ខណៈពួកគេប្រឈមមុខនឹងការគំរាមកំហែងដល់អាយុជីវិត។

ជុំវិញរឿងនេះ លោក ខៀវ សុភ័ក្រ្ត អ្នកនាំពាក្យក្រសួងមហាផ្ទៃបានបញ្ជាក់មកវិទ្យុបារាំងអន្តរជាតិថា កម្ពុជាពិតជាមានករណីនេះកើតឡើងមែន ក៏ប៉ុន្តែអាជ្ញាធរបានបង្ក្រាបស្ទើតែទាំងស្រុង ពោលគឺសម្រេចបាន៩៣%នៃលទ្ធផលដែលបានអនុវត្ត ខណៈសកម្មភាពជួយដូរមនុស្ស៧%ទៀតនៅបន្តកើតមាន។ លោកខៀវ សុភ័ក្រ្តបញ្ជាក់យ៉ាងខ្លីថា អាជ្ញាធរកំពុងបន្តដុតដៃដុតជើងធ្វើយ៉ាងណា ឱ្យសកម្មភាពសេះសល់៧%ទៀតនេះត្រូវបានបង្ក្រាប។ ដោយឡែកពាក់ព័ន្ធនឹងករណីបូមឈាមលក់អ្នកនាំពាក្យក្រសួងមហាផ្ទៃរូបនេះបានច្រាលចោលថា ជាព័ត៌មានមិនពិត។

ទោះបីរដ្ឋាភិបាលកម្ពុជា បានអះអាងថា កំពុងបន្តដោះស្រាយលើករណីទាំងអស់នេះ ប៉ុន្តែអង្គការសង្គមស៊ីវិលបន្តស្នើឱ្យអាជ្ញាធរកម្ពុជា បំពេញការទទួលខុសត្រូវរាល់ការរំលោភបំពាន និងការបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធឺណេត ព្រមទាំងលុបបំបាត់រាល់ទីតាំងដែលជាប់នឹងល្បែងស៊ីសងខុសច្បាប់ទាំងអស់បន្ថែមទៀត។

សូមបញ្ជាក់ថា បើតាមកាសែតThe Nation ប្រទេសថៃ មជ្ឈមណ្ឌលស៊ើបអង្កេតឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ក្រោមនាយកដ្ឋានស៊ើបអង្កេតពិសេស (DSI)បានរកឃើញថា ស៊ីមកាតខុសច្បាប់ជាង១ម៉ឺនត្រូវបានរឹបអូសនៅក្នុងការបង្ក្រាប ខណៈស៊ីមកាតជាង ៨,៥០០ ត្រូវបានរកឃើញថា បានចុះឈ្មោះដោយប្រើប្រាស់អត្តសញ្ញាណប័ណ្ណរបស់ប្រទេសមីយ៉ាន់ម៉ា និងប្រទេសកម្ពុជា៕

## វរៈនគរបាលព្រំដែនគោក ៨១៧ធ្វើការឃាត់ខ្លួនពលករចំនួន ៣ នាក់ដែលកំពុងចំរុង

https://www.facebook.com/cpnnnews/ 10/03/2022

បាត់ដំបង: នៅវេលាម៉ោង១៦និង០០នាទី នាថ្ងៃសុក្រ ៩កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹង ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្ត បាត់ដំបង ចំនួន៣៥នាក់ ស្រី១៤នាក់ ក្មេងស្រី០៤នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសំភារៈហាមឃាត់(ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) ជាលទ្ធផល÷ ដកហូតបានកាំបិត០២ដើម រួចបានប្រគល់បងប្អូនទាំងអស់ឱយទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល÷ អវិជ្ជមាន បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន២២នាក់ ស្រី១០នាក់ ក្មេងស្រី០៣នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ដែនអត់ចេញ ចំនួន១៣នាក់ ស្រី០៤នាក់ ក្មេងស្រី០១នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ដោយ: ហង្សទេព

## កាសែតថៃ៖
## ស្ត្រីថៃម្នាក់រូបបានគេចខ្លួនរួចពីការប៉ុនប៉ងយកសរីរាង្គដោយជនជាតិចិននៅកម្ពុជា

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 12/03/2022 - 07:08

កាសែតអនឡាញថៃបានចុះផ្សាយថា ស្ត្រីជនជាតិថៃមួយរូប ដែលត្រូវបានគេល្បួងមកធ្វើការងារខុសច្បាប់នៅប្រទេសកម្ពុជា ក្នុងខេត្តព្រះសីហនុ ប្រុងនឹងក្លាយជាជនរងគ្រោះដោយសារការវះយកសរីរាង្គ ដោយក្រុមបងតូចបងធំជាជនជាតិចិន ប៉ុន្តែនាងត្រូវបានរត់គេចខ្លួនដោយត្រដាបត្រដួស។ បើតាមប្រភពជាមន្ត្រីនគរបាលជាតិថៃសមត្ថកិច្ចបានធ្វើការស្រាវជ្រាវនិងត្រួតពិនិត្យឃើញថា ជនជាតិចិននៅកម្ពុជាទាំងនោះ បានគ្រោងចាប់ជនរងគ្រោះប្រមាញ់យកសរីរាង្គ សម្រាប់លក់នៅក្នុងទីផ្សារងងឹត។

រដ្ឋលេខាធិកានៃនគរបាលជាតិ លោក Surachate Hakparn បានគូសបញ្ជាក់ប្រាប់កាសែតអនឡាញរដ្ឋថៃជាភាសាអង់គ្លេសឈ្មោះ Thai PBS World ថាជនរងគ្រោះពីការប៉ុនប៉ងយកសរីរាង្គដោយជនទុច្ចរិតជនជាតិចិនកំពុងស្នាក់នៅកម្ពុជា គឺជាស្ត្រីជនជាតិថៃមកពីទីក្រុងបាំងកក មានវ័យ២៥ឆ្នាំ។ បើតាមលោកមន្ត្រីនគរបាលថៃ នាងត្រូវបានគេល្បួងមកធ្វើការខុសច្បាប់ ក្នុងក្រុមហ៊ុនហៅទូរស័ព្ទមួយនៅក្នុងខេត្តព្រះសីហនុ ដែលដំណើរការដោយជនជាតិចិន។ នៅពេលនាងធ្វើដំណើរពីថៃដល់កំពង់ផែក្រុងព្រះសីហនុ នាងត្រូវបានប្រាប់ឱ្យទៅធ្វើការភ្លាម។ ពេលនាងមិនព្រម នាងក៏ត្រូវគេវាយដំឃុំខ្លួនទុកឱ្យស្រេកឃ្លាន ហើយប្រាប់ឱ្យទាក់ទងទៅគ្រួសារនាងនៅប្រទេសថៃ ដើម្បីជម្រិតទារយកប្រាក់ជាថ្នូរនឹងការដោះលែងនាង។ នៅក្នុងអំឡុងពេលនៃការឃុំខ្លួននោះនាងថា នាងត្រូវចរន្តអគ្គិសនីឆក់ និងមានអ្នកបូមយកឈាមនាងដែរ។ ធ្ងន់ធ្ងរជាងនេះ នាងក៏បិះនឹងត្រូវគេវះយកសរីរាង្គរបស់នាងដែរ។ ក្រោយមក នាងបានស្វែងរកផ្លូវរត់គេចខ្លួនមកដល់មន្ទីរពេទ្យក្រុងប៉ោយប៉ែត ព្រំដែនថៃ រហូតបាត់បង់ស្មារតី និងនាងក៏ត្រូវបានអាជ្ញាធរថៃនៅព្រំដែនជួយសង្គ្រោះ នៅថ្ងៃទីពុធទី៩ មិនា កន្លងទៅនេះ។ នេះបើតាមការចុះផ្សាយរបស់កាសែតអនឡាញ Thai PBS World។

គិតត្រឹមម៉ោងផ្សាយនេះ វិទ្យុបារាំងអន្តរជាតិមិនទាន់បានការបញ្ជាក់ពីអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក ជុំ សុន្ទរី និងអ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ នៅឡើយទេ។

មកដល់ពេលនេះ មានជនជាតិថៃប្រមាណ ៣០០០នាក់ ដែលធ្វើការដោយខុសច្បាប់នៅក្នុងប្រទេសកម្ពុជា។ នេះបើតាមលោករដ្ឋលេខាធិកានៃនគរបាលជាតិ និងបន្ថែមថាប៉ូលីសថៃ និងស្ថានទូតថៃប្រចាំទីក្រុងភ្នំពេញនឹងស្នើឱ្យមន្ត្រីសន្តិសុខកម្ពុជា ដោះស្រាយជាមួយក្រុមទុច្ចរិតនៅខេត្តព្រះសីហនុនេះផងដែរ។

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានជម្រុញឱ្យអាជ្ញាធរខេត្តឆ្នេរសមុទ្រមួយនេះ បញ្ចប់ឲ្យបានជាអតិប្បរមានូវបទល្មើសឧក្រិដ្ឋនានា ឱ្យបានមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ នេះ។ ការថ្លែងរបស់លោក ស ខេង ដូច្នេះ គឺបន្ទាប់ពីលោកទទួលបានរបាយការណ៍ពីស្នងការប៉ូលីសខេត្តព្រះសីហនុ ដែលបង្ហាញពីបទល្មើសសាហាវៗកន្លងមក។ លោកថារូបភាពសាហាវឃោរឃៅនៅខេត្តព្រះសីហនុ វានឹងប៉ះពាល់ដល់កេរឈ្មោះកម្ពុជាទាំងមូល នៅពេលដែលមានការផ្សព្វផ្សាយនៅទូទាំងពិភពលោក៕

## ពលករខ្មែរ មកពីថៃ ៨នាក់ រកឃើញវិជ្ជមានកូវីដ-១៩

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ១២ មីនា ២០២២ដោយ Sophal Tuon

ពលករខ្មែរទើបត្រឡប់មកពីប្រទេសថៃចំនួន ៨នាក់ ក្នុងចំណោមពលករចំនួន ១៣៤នាក់ ត្រូវបានរកឃើញវិជ្ជមានកូវីដ១៩ ហើយបានបញ្ជូនទៅព្យាបាលរួចរាល់ហើយ។ យោងតាមផេកហ្វេប៊ុកផ្លូវការរបស់អគ្គស្នងការដ្ឋាននគរបានលជាតិ ចុះផ្សាយនៅថ្ងៃនេះបានឱ្យដឹងថា កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យបានទៅទទួលពលករចំនួន ១៣៤នាក់ (ស្រី៥១នាក់) ក្មេង២៣នាក់(ស្រី១២នាក់) វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ បន្ទាប់ពី កម្លាំងប៉ុស្តិ៍អូរអន្លក់ និងក្រុមគ្រូពេទ្យ សាកសួរកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួចក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័សរកជំងឺកូវីដ១៩ ហើយជាលទ្ធផលមានពលករចំនួន៨នាក់ស្រី៤នាក់ កុមា១នាក់មានវិជ្ជមានកូវីដ-១៩ ។ ដោយឡែកពលករចំនួន ៤៤នាក់ ស្រី១៧នាក់ ក្មេង៦នាក់ ស្រី១នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្តបាត់ដំបង។រីឯពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន៨២នាក់ ស្រី៣០នាក់ ក្មេង១៦នាក់ ស្រី១១នាក់ក្នុងនោះបាន

ចាក់វ៉ាក់សាំងឱ្យក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន៧នាក់ ស្រី៤នាក់ត្រូវបានក្រុមគ្រូពេទ្យអនុញ្ញាតឱ្យវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕ សំអឿន

## អភិបាលរងខេត្តព្រះសីហនុៈ
## រឿងឧក្រិដ្ឋកម្មនៅខេត្តភាគច្រើនត្រូវបានបំប៉ោងនិងប្រឌិត ដើម្បីបង្កភាពចលាចល

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 12/03/2022 - 12:26

លោក ឡុង ឌីម៉ង់ អភិបាលរងខេត្តព្រះសីហនុ តាមរយៈវិទ្យុបារាំងអន្តរជាតិRfi នៅរសៀលថ្ងៃទី១២មិនានេះ បានប្រានចោលទាំងស្រុងនូវការចុះផ្សាយព័ត៌មានរបស់កាសែតអនឡាញថៃដែលថាមានស្ត្រីជនជាតិថៃមួយរូបដែលមកធ្វើការខុសច្បាប់នៅកម្ពុជាក្នុងខេត្តព្រះសីហនុ ត្រូវបានឧក្រិដ្ឋជនជាជនជាតិចិនប៉ុនប៉ងប្រមាញ់យកសរីរាង្គសម្រាប់ជួញដូរក្នុងទីផ្សារងងឹត។ លោកអភិបាលរងខេត្តព្រះសីហនុរូបនេះ បានគូសបញ្ជាក់ថា ករណីឧក្រិដ្ឋកម្មនៅខេត្តព្រះសីហនុភាគច្រើនក្នុងពេលបច្ចុប្បន្ននេះ ត្រូវបានបំប៉ោងនិងប្រឌិតឡើងដោយបុគ្គលតាំងនាមជាជនរងគ្រោះ និងជនទុច្ចរិតមួយចំនួនទៀតដើម្បីបង្កភាពចលាចលនៅក្នុងសង្គម៕

## អ្នកនាំពាក្យក្រសួងការបរទេសបំភ្លឺថា មកដល់ពេលនេះ ពុំទាន់មានការបញ្ជាក់ណាមួយថា ករណីស្ត្រីជនជាតិថៃដែលរងការជួញដូរសរីរាង្គ កើតមានឡើងនៅកម្ពុជាទេ

http://freshnewsasia.com/ 2022-03-13 11:21am

**(ភ្នំពេញ)៖** លោក ជុំ សន្ទរី អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២នេះ បានចេញសេចក្តីបំភ្លឺមួយ ដោយអះអាងថា រហូតមកទល់ពេលនេះ ពុំទាន់មានការបញ្ជាក់ណាមួយថា ករណីជនជាតិថៃថាខ្លួនរងការជួញដូរសរីរាង្គ កើតឡើងនៅក្នុងប្រទេសកម្ពុជាទេ។ ការបញ្ជាក់របស់អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា បានធ្វើឡើងបន្ទាប់ពីកាសែតអនឡាញថៃ បានចុះផ្សាយថា មានស្ត្រីជនជាតិថៃមួយរូបដែល ត្រូវបាន គេល្បួងមកធ្វើការងារខុសច្បាប់នៅប្រទេសកម្ពុជា ក្នុងខេត្តព្រះសីហនុ ប្រុងនឹងក្លាយជាជនរងគ្រោះដោយសារការវះយកសរីរាង្គ ដោយក្រុមបងតូចបងធំជាជនជាតិចិន ប៉ុន្តែ នាងបានរត់គេចខ្លួនរួចដោយ ត្រជាបត្រដួស។

**ពាក់ព័ន្ធនឹងព័ត៌មានចុះផ្សាយក្នុង សារព័ត៌មានថៃ Thai Examiner កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ នោះ លោកជុំមសុន្ទរី បានបំភ្លឺ ២ចំណុចដូចតទៅ៖**

**១៖** អាជ្ញាធរមានសមត្ថកិច្ចខេត្តព្រះសីហនុ បានប្រកាសបដិសេធរួចហើយថានោះគឺជាការលើកឡើងដោយគ្មានមូលដ្ឋានត្រឹមត្រូវពិតប្រាកដ។

**២៖** ទន្ទឹមនឹងនេះ ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ ក៏បានទាក់ទងជាមួយអាជ្ញាធរមានសមត្ថកិច្ចថៃ ស្វែងរកការបញ្ជាក់លើព័ត៌មាននេះ តែរហូតមកដល់ ពេលនេះ (ព្រឹកថ្ងៃទី១៣ ខែមិនា) ពុំទាន់ទទួលបានការបញ្ជាក់ណាមួយ ថានេះជាករណីដែលបានកើតមានឡើងនៅកម្ពុជា ដូចព័ត៌មានដែលបានផ្សាយនោះឡើយ ។ ស្ថានទូតកំពុងបន្តទាក់ទងជាមួយអាជ្ញាធរមានសមត្ថកិច្ចថៃ រកព័ត៌មានបន្ថែមទៀត៕

# ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០២២

## ពលករខ្មែរ វិលពីថៃ កើនចំនួន ហើយអ្នកវិជ្ជមានកូវីដ-១៩ ក៏កើនឡើង

https://www.rasmeinews.com/ MARCH 13, 2022

**ដោយ: ប.ជ័យ / ព្រំដែនកម្ពុជា ថៃ:** *ក្នុងអំឡុងខែកុម្ភៈ និងមីនា ឆ្នាំ២០២២ ពលករខ្មែរ វិលពីថៃ មកកម្ពុជាវិញ តាមច្រកព្រំដែន ក្នុងភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ បានកើនចំនួន ហើយអ្នកវិជ្ជមានកូវីដ-១៩ ក៏កើនឡើង គួរអោយកត់សម្គាល់ និងក៏គួរអោយបារម្ភ ។* នេះបើយោងមន្ត្រីអាជ្ញាធរដែនដី មន្ត្រីសមត្ថកិច្ចនគរបាល និងមន្ត្រីសុខាភិបាល នៅស្ថានីយ៍ទទួលពលករខ្មែរ ច្រកអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ និងច្រកព្រំដែនអន្តរជាតិ អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ប្រាប់រស្មីកម្ពុជា នៅថ្ងៃអាទិត្យ ទី១៣ ខែមីនា ឆ្នាំ២០២២ ។

សម្រាប់នៅច្រកព្រំដែនអូរបីជាន់ តួលេខចំនួនពលករខ្មែរ ដែលអាជ្ញាធរមាន សមត្ថកិច្ចថៃ ចាប់បញ្ជូន និងដែលសាម៉ីខ្លួន ពលករវិលវិញខ្លួនឯង គិតក្នុងខែកុម្ភៈ និង មីនា នេះ មានពី ១៥០ នាក់ ទៅ ៣៥០ នាក់ ក្នុង១ថ្ងៃៗ ហើយ អ្នកវិជ្ជមាន កូវីដ-១៩ ដែលគ្រូពេទ្យប្រចាំការ ធ្វើតេស្តរហ័សរកឃើញ មានពី ៥ ទៅ ២០ នាក់ ក្នុងនោះ អ្នកវិជ្ជមាន មានទាំងស្ត្រី កុមារ ផងដែរ។ ពោលគឺ តាមធម្មតា ពលករវិលវិញ មានតែពី ៨០ ទៅ ២០០ នាក់ ក្នុង១ថ្ងៃៗ។ ឯអ្នកវិជ្ជមានកូវីដ១៩ មានពី ១ ទៅ ៥ នាក់ ក្នុង១ថ្ងៃៗ។ ក្នុងចំណោមពលករ ដែលវិជ្ជមាន គឺភាគតិច បានកើតលើ អ្នកបានចាក់វ៉ាក់សាំង ។ តែកើតច្រើនលើអ្នកអត់បាន ចាក់វ៉ាក់សាំង ដោយអ្នកអត់បាន ចាក់វ៉ាក់សាំង មានពី ១៥ ទៅ ២០ ភាគរយ នៃចំនួនពលករ សរុបវិលវិញ ក្នុង១ថ្ងៃៗ ។

ចំណែកមន្ត្រីដូចខាងលើ នៅច្រកព្រំដែនអន្តរជាតិ អូរស្មាច់ ខេត្តឧត្តរមានជ័យ បានអោយដឹងថាៈ ក្នុងអំឡុងខែមីនា និងរយៈពេល ឆ្ពោះទៅបុណ្យចូលឆ្នាំខ្មែរ ខាងមុខ បរិមាណពលករខ្មែរ វិលវិញ តាមច្រកនេះ ក៏កើនឡើងខ្ពស់ គឺមានពី ២៥០ ទៅជិត ៥០០ នាក់ ក្នុង១ថ្ងៃៗ ។ ហើយអ្នកវិជ្ជមានកូវីដ-១៩ មានពី ២០ ទៅ ៤០ នាក់ ក្នុង១ថ្ងៃៗ ពោលគឺ កើនឡើងពី ២ ទៅ ៣ ដង បើប្រៀបធៀបនឹងចំនួន ធម្មតា ពលករខ្មែរឆ្លងដែន ពីថៃ មកកម្ពុជាវិញ៕/V-PC

## ការជួបពិភាក្សារវាងកម្លាំងកម្ពុជា-ថៃ នៅចំណុចTA( 68137-46930 )

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៤ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ០៨:៣៨

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងឈរជើងតាមបន្ទាត់ព្រំដែនបានជួបពិភាក្សាជាមួយ និងទាហានថៃ ដើម្បីបង្រឹងកិច្ចសហប្រតិបត្តិការល្អនិងទប់ស្កាត់បទល្មើសឆ្លងដែន កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ស្ថិតនៅចំណុចច្រកបឹងត្រកួន ស្រុកថ្មពួក ។

លោកវរសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧ បានប្រាប់ថា កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧ និងកម្លាំងយោធាចំនួន១០នាក់ ជួបពិភាក្សាជាមួយទាហានភាគីថៃចំនួន១០នាក់ នៅចំណុចប៉ុស្តិ៍ច្រកទ្វារព្រំដែនតំបន់បឹងត្រកួន ស្ថិតភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ឈមភូមិខ្លងផែង ឃុំថាប់ស្តេត ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ។ លោកបានបញ្ជាក់ថា ការជួបពិភាក្សារវាងកម្លាំងកម្ពុជា និងកម្លាំងយោធាថៃ នៅចំណុច TA (68137-46930) ដើម្បីពិភាក្សា បង្រឹងកិច្ចសហប្រតិបត្តិការល្អ ការទប់ស្កាត់ពលករឆ្លងដែនល្មើសច្បាប់ ទំនិញគេចពន្ធ បទល្មើសលួចឆ្លងដែនផ្សេងៗត្រូវទប់ស្កាត់អោយបាន។ លោកវរសេនីយ៍ឯក ឡុង សំណាង បានបញ្ជាក់ថា រយៈពេលកន្លងមកកម្លាំងនគរបាលការពារព្រំដែន

គោកបានខិតខំយកចិត្តទុកដាក់ការពារបូរណៈភាពទឹកដីនិងការពារប្រជាពលរដ្ឋ និងប្រទេសជាតិអោយមានសុខសន្តិភាព៕

## នៅព្រឹកថ្ងៃសៅរ៍ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ព្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/12/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃសៅរ៍ ១០កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន១៤នាក់ ស្រី០៥នាក់ ក្មេងស្រី០២នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចប្រគល់បងប្អូនចំនួន ០៩នាក់ ស្រី០៣នាក់ ក្មេងស្រី០២នាក់ ទៅឲ្យក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារអន្តរជាតិគីឡូ១៣ និងបងប្អូនចំនួន០៥នាក់ ស្រី០២នាក់ ទៅឲ្យក្រុមគ្រូពេទ្យ នៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺអវិជ្ជមាន។ បន្ទាប់មកក្រុមពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ ចំនួន០៤នាក់ ស្រីម្នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានបានចាក់វ៉ាក់សាំងតែស្គាល់អត់ចេញចំនួនម្នាក់ (ស្រី) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## អាជ្ញាធរថៃ បញ្ជូនប្រជាពលរដ្ឋ កម្ពុជាចំនួន ១២៣នាក់ មកស្រុកកំណើតវិញ តាមច្រកស្រុកកំរៀង

https://cen.com.kh/ Posted ByPen Srey NeatMarch 14, 2022

បាត់ដំបង ៖ នៅថ្ងៃ១៤ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជា របស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរង ផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ ទទួលប្រជាពលរដ្ឋត្រឡប់ចូលប្រទេសកម្ពុជាវិញ តាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។

ប្រជាពលរដ្ឋចំនួន ១២៣នាក់ ស្រី ៤៨នាក់ ក្មេង ១៩នាក់ ក្មេងស្រី ១០នាក់ ត្រូវបានសមត្ថកិច្ចសាកសួរកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ អំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួចក្រុមគ្រូពេទ្យធ្វើតេស្តរហ័ស

ជាលទ្ធផល អវិជ្ជមានទាំងអស់ ដោយឡែកពលករចំនួន ១៨នាក់ ស្រី ១នាក់ ក្មេង ១នាក់ ក្មេងស្រី ១នាក់ បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ១០៥នាក់ ស្រី ៤២នាក់ ក្មេង ១៨នាក់ ក្មេងស្រី ៩នាក់ ។ ក្នុងនោះបានចាក់វ៉ាក់សាំងឲ្យក្មេងចាប់ពីអាយុ៥ឆ្នាំដល់ ១៨ឆ្នាំ ចំនួន ៤នាក់ ស្រី ២នាក់ ក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕ សុទ្ធ លី

## ពលករនាំគ្នាសម្រុកមកស្រុកកំណើតវិញ ត្រឹមមួយថ្ងៃមិនតិចជាង២០០នាក់នោះទេ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៤ ខែ មីនា ឆ្នាំ ២០២២

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរធ្វើការនៅប្រទេសថៃ បានកំពុងនាំគ្នាសម្រុកចូលមកស្រុកខ្មែរវិញ ត្រឹមតែ១ថ្ងៃប៉ុណ្ណោះមិនតិចជាង២០០នាក់ឡើយ តាមច្រកអូរបីជាន់ ដើម្បីមកជួបជុំគ្រួសារនៅថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ នៅក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។

ដោយយោងតាមរបាយការណ៍ក្រុមការងារទទួលពលករខ្មែរ ច្រកអូរបីជាន់ ស្រុកអូរជ្រៅ ថា រយៈពេល៣ថ្ងៃមកនេះ ឃើញមានពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃ ចូលតាមច្រកអូរបីជាន់ ក្នុងឃុំអូរបីជាន់ ស្រុកអូរជ្រៅ បន្តចូលច្រើនខុសពីធម្មតា ដោយពួកគាត់ម្នាក់ៗបាននិយាយឱ្យដឹងថា ឆ្នាំ២០២២នេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសចូលឆ្នាំថ្មីប្រពៃណីខ្មែរឆ្នាំ២០២២ ទើបពួកគាត់សម្រេចមកលេងស្រុកកំណើត ដើម្បីជួបជុំគ្រួសារ។

លោកវរសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងក្រុមការងារទទួលពលករខ្មែរត្រឡប់ពីថៃ ច្រកអូរបីជាន់ បានប្រាប់ថា ៖ រយៈពេល៣ថ្ងៃនេះ គេឃើញមានពលករខ្មែរបានសម្រុកត្រឡប់មកស្រុកកំណើតវិញខុសពីធម្មតា ដែលក្រុមការងារច្រកអូរបីជាន់ ស្រុកអូរជ្រៅ បានទទួល គឺមាននៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២នេះ មានចំនួន២៣៤នាក់ ក្នុងនោះស្រី១១៧នាក់ កុមារ២៦នាក់ ស្រី១៦នាក់ មានវិជ្ជមានកូវីដ១៩ ចំនួន៥នាក់ (ស្រី៣នាក់) ។ ចំណែកនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២វិញ គឺមានចំនួន២៥៥នាក់ ក្នុងនោះស្រី១២១នាក់ កុមារ៣៦នាក់ ស្រី១៦នាក់ វិជ្ជមានកូវីដ១៩ ចំនួន១១នាក់ (ស្រី៦នាក់ កុមារ២នាក់)។ រីឯនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២នេះ ក៏មានពលករខ្មែរចំនួន២១៥នាក់ ក្នុងនោះស្រី១០៤នាក់ កុមារចំនួន៣០នាក់ ស្រី១១នាក់ មានវិជ្ជមានកូវីដ១៩ ចំនួន១៥នាក់ (ស្រី៩នាក់ កុមារ២នាក់)។ លោកបានបញ្ជាក់ថា ចំពោះពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ដែលរកឃើញមានវិជ្ជមានកូវីដ១៩ ត្រូវបានបញ្ជូនទៅព្យាបាលនៅមណ្ឌល និងអ្នកដែលមានឯកសារចាក់វ៉ាក់សាំងដូសទី២ និងទី៣ ត្រូវបានអោយបន្តទៅស្រុកកំណើតវិញ៕

# ថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០២២

## នៅថ្ងៃចន្ទនេះពលករខ្មែរ ជាង១០០នាក់ បានសំរុកចាកចេញពីប្រទេសថៃ ចូលកម្ពុជាតាមច្រកព្រំដែនស្រុកកំរៀង

http://nokorwatnews.com/ 15/03/2022

ខេត្តបាត់ដំបង ៖ នៅថ្ងៃ១៤ ខែមីនា ឆ្នាំ២០២២ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ ទទួលប្រជាពលរដ្ឋ១២៣នាក់ត្រឡប់ចូលប្រទេសកម្ពុជាវិញ តាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ ប្រជាពលរដ្ឋចំនួន ១២៣នាក់ ក្នុង

នោះមានស្រី ៤៨ នាក់ ក្មេង ១៩នាក់ ក្មេងស្រី ១០នាក់ ត្រូវបានសមត្ថកិច្ចសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវីដ-១៩ រួចក្រុមគ្រូពេទ្យធ្វើតេស្តរហ័ស ជាលទ្ធផល អវិជ្ជមានទាំងអស់ ។ ដោយឡែកពលករចំនួន ១៨នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន ខេត្ត បាត់ដំបង និង ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ១០៥នាក់ ក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕

## បុរសពលករខ្មែរម្នាក់បានធ្លាក់ ពីលើអគារសំណង់ស្លា.ប់នៅថៃត្រូវបានបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៥ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ០៩:៣៧

បន្ទាយមានជ័យ ៖ បុរសពលករខ្មែរបានធ្លាក់ពីលើអគារសំណង់ស្លា.ប់ត្រូវបានបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅវេលាម៉ោង៨ និង៣០នាទី ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ក្រុងប៉ោយប៉ែត ។

មន្ត្រីស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ បានប្រាប់ថា ៖ ជនរងគ្រោះមានឈ្មោះ ព្រឿត ឈាត ភេទប្រុស អាយុ៤២ឆ្នាំ (កម្មករសំណង់)មានស្រុកកំណើតភូមិពង្រ ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ មន្ត្រីស្ថានអគ្គកុងស៊ុលកម្ពុជាបានបញ្ជាក់ថា ៖ ក្រោយពេលមានពលករខ្មែរម្នាក់បានរងគ្រោះធ្លាក់អគារសំណង់ស្លា.ប់ នៅទីក្រុងបាងកក ប្រទេសថៃ ហើយស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានទំនាក់ទំនងជាមួយអាជ្ញាធរភាគីថៃបានទៅទទួលយកសាកសពពលករខ្មែរ ដើម្បីសម្របសម្រួលការងារដឹកជញ្ជូនសាកសពជូនសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមកទទួលយកទៅធ្វើបុណ្យតាមប្រពៃណី ៕

## លំហូរពលករខ្មែរមកពីថៃ តាមច្រកខេត្តបាត់ដំបងថយចុះ ប៉ុន្តែមានកំណើនករណីកូវីដ-១៩

https://btv.com.kh/ 03/15/2022 02:03 PM

បាត់ដំបង៖ លំហូរពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ ចូលតាមច្រកខេត្តបាត់ដំបង មានការថយចុះជាបន្តបន្ទាប់ ប៉ុន្តែចំនួនពលករដែលត្រូវបានរកឃើញឆ្លងកូវីដ-១៩ មានការកើនឡើង ខណៈវិធានការសុខាភិបាលនៅច្រកព្រំដែន ត្រូវបានរឹតបន្តឹង។

លោក ណាត ចាន់រ៉េត ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន ស៊ួនស៊ុ (អូរអន្លក់) ស្រុកកំរៀង បានឱ្យដឹងថា ដើម្បីទប់ស្កាត់ការចម្លងមេរោគកូវីដ-១៩ បំប្លែងថ្មី ប្រភេទអូមីក្រុង វិធានការសុខាភិបាលនៅច្រកព្រំដែន ត្រូវបានរឹតបន្តឹងដោយគ្មានការធ្វេសប្រហែសឡើយ ទោះបីវំហូរពលករខ្មែរវិល ត្រឡប់មកពីប្រទេសថៃ មានការថយចុះ ហើយពលករភាគច្រើន មានកាតចាក់វ៉ាក់សាំងចាប់ពី២ដូសឡើងទៅ។ លោក បានឱ្យដឹងបន្ថែមថា ពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃទាំងអស់ ត្រូវបានយកសំណាកធ្វើតេស្តរហ័សរកជំងឺកូវីដ-១៩ នៅច្រកព្រំដែន ហើយចំពោះអ្នកវិជ្ជមាន ក្រុមគ្រូពេទ្យនឹងបញ្ជូនទៅព្យាបាលអ្នកអវិជ្ជមានគ្មានកាតចាក់វ៉ាក់សាំង ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ក ហើយអ្នកអវិជ្ជមានមានកាតចាក់វ៉ាក់សាំងគ្រប់២ដូស ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន។

ប្រធានច្រកព្រំដែនរូបនេះ បានបញ្ជាក់ថា មួយរយៈពេលចុងក្រោយនេះ វំហូរពលករថយចុះ ប៉ុន្តែ ក្នុងចំណោមពលករចូលមកជាង ១០០នាក់ក្នុងមួយថ្ងៃ មានចន្លោះពី ៣ទៅ ៥នាក់ ត្រូវបានធ្វើតេស្តរហ័ស រកឃើញឆ្លងជំងឺកូវីដ-១៩ ខណៈពេលមុន វំហូរពលករកើនឡើង ក្នុងចំនួនចន្លោះពីជាង ២០០នាក់ទៅជិត ៣០០នាក់ តែការរកឃើញឆ្លងកូវីដ-១៩ មានតិចតួច ឬស្ទើរតែគ្មាន។

គួរកត់សម្គាល់ថា ក្នុងមួយរយៈពេលចុងក្រោយនេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងខេត្តបាត់ដំបង មានការហក់ឡើងបន្តិចវិញ ក្រោយមានការស្ងប់ស្ងាត់មួយរយៈពេលធំ។ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ-១៩ កងកម្លាំងចម្រុះការពារព្រំដែន ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើការទំនាក់ទំនង និងសហការយ៉ាងជិតស្និទជាមួយភាគីថៃ ដើម្បីទប់ស្កាត់មិនឲ្យប្រជាពលរដ្ឋខ្មែរលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដោយមិនស្របច្បាប់៕អត្ថបទ៖ នឿត សុកក្រ្គ

## លំហូរចូលនៃពលករចំណាកស្រុកដែលត្រឡប់មកពីប្រទេសថៃមុនពិធីបុណ្យចូលឆ្នាំខ្មែរបង្កើនការព្រួយបារម្ភលើករណីឆ្លងវីរុស Omicron

https://www.khmertimeskh.com/ ឃឹម ស្រីលីន /ខ្មែរថាមស៍ 15/03/2022

នាពេលជិតចូលឆ្នាំខ្មែរនេះ មានចលនាពលករចំណាកស្រុកច្រើនកុះករនៅតាមខេត្តមួយចំនួនជាប់ព្រំដែនជាមួយប្រទេសជិតខាង ដូចជាប្រទេសថៃជាដើម។ ប្រការនេះកំពុងបង្កការព្រួយបារម្មណ៍យ៉ាងខ្លាំងដល់អាជ្ញាធរខេត្ត ខណៈពួកគេក៏កំពុងមើលឃើញការកើនឡើងនៃករណីឆ្លងជំងឺកូវីដ-១៩ ប្រសិនបើមិនបានដោះស្រាយ និងគ្រប់គ្រងឲ្យបានត្រឹមត្រូវនឹងអាចនាំឲ្យមានការផ្ទុះឡើងនៃសហគមន៍មួយទៀត។ ចាប់តាំងពីដើមខែនេះ ពលករចំណាកស្រុកជាង ១,៣០០នាក់ បានចាប់ផ្តើមត្រឡប់ទៅខេត្តបន្ទាយមានជ័យវិញ ខណៈជាង ១.០០០ ទៅ ១.៥០០នាក់ទៀតទៅខេត្តឧត្តរមានជ័យពីប្រទេសថៃ។

កាលពីម្សិលមិញលោក ង៉ោ ម៉េងជ្រួន អភិបាលរងខេត្តបន្ទាយមានជ័យ និយាយថា មានការកើនឡើងគួរឲ្យកត់សម្គាល់ នៃពលករចំណាកស្រុកដែលវិលត្រឡប់មកចូលរួមពិធីបុណ្យចូលឆ្នាំខ្មែរ។ លោកបន្តថាក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំនេះ ពលករចំណាកស្រុកមិនតិចជាង ២០០ នាក់បានឆ្លងព្រំដែនពីប្រទេសថៃ ហើយជាមួយនឹងការប្រារព្ធពិធីក្នុងរយៈពេលមួយខែទៀត មនុស្សជាច្រើនគ្រោងនឹងត្រលប់មកវិញ ហើយការគ្រប់គ្រងលំហូរនៃពលករចំណាកស្រុកនឹងក្លាយជាបញ្ហាប្រឈមសម្រាប់ មន្ត្រីពាក់ព័ន្ធ។ លោកថា៖ «អ្វីដែលយើងបានរកឃើញនោះគឺថា មានតែពលករមួយចំនួនដែលបានត្រលប់មកវិញតាំងពីដើមខែនេះ ត្រូវបានចាក់វ៉ាក់សាំងពេញលេញ ខណៈពលករជាច្រើនមិនបានចាក់វ៉ាក់សាំង។ យើងក៏ត្រូវធ្វើឲ្យប្រាកដថាពួកគេមិនមានឆ្លងជំងឺកូវីដដែរ»។

ដោយលើកឡើងពីអ្វីដែលបានកើតឡើងកាលពីចុងសប្តាហ៍ លោកថានៅកាលពីថ្ងៃសុក្រ ពលករចំណាកស្រុកចំនួន ៥៣៦ នាក់បានត្រឡប់ទៅខេត្តវិញ ខណៈថ្ងៃសៅរ៍មាន ៤៦៣ នាក់ និងថ្ងៃអាទិត្យ ៣៦៥ នាក់ ហើយក្នុងចំណោមចំនួនសរុបមាន ២០ ភាគរយនៃពលករដែលបានឆ្លងវីរុសនេះ។ លោកបន្ថែមថា៖ «អ្វីដែលយើងបារម្ភនោះគឺថា ក្នុងចំណោមពលករចំណាកស្រុកក៏មានអ្នកឆ្លងកូវីដច្រើនដែរ ហើយពួកគេភាគច្រើនជាអ្នកដែលមិនបានចាក់វ៉ាក់សាំង។ យើងរំពឹងថានឹងឃើញលំហូរនៃពលករចំណាកស្រុកត្រឡប់មកវិញដូចក្នុងខែសីហាឆ្នាំមុនដែរ»។ លោកថានៅតាមព្រំដែន ការធ្វើតេស្តរហ័សគឺធ្វើឡើងលើពលករចំណាកស្រុកទាំងអស់ ដោយមិនថាចាក់វ៉ាក់សាំង ឬមិនទាន់ចាក់វ៉ាក់សាំងទេ ហើយអ្នកដែលរកឃើញថាវិជ្ជមាន នឹងត្រូវបញ្ជូនទៅកាន់មណ្ឌលព្យាបាលមួយក្នុងចំណោមមណ្ឌលចត្តាឡីស័កកងវ៉ា និងកូបធំភ្លាមៗ ដែលបច្ចុប្បន្នមានអ្នកជំងឺចំនួន ៦៨០នាក់។ លោកថា៖ «អ្នកដែលត្រូវបានចាក់វ៉ាក់សាំងនឹងតម្រូវឲ្យធ្វើចត្តាឡីស័ករយៈពេល ៧ ថ្ងៃខណៈអ្នកដែលមិនបានចាក់វ៉ាក់សាំងត្រូវធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ»។

ជាមួយគ្នានេះ លោកឌី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យបាននិយាយកាលពីម្សិលមិញថា ពលករចំណាកស្រុកទាំងអស់ ដែលមកពីប្រទេសថៃ អាចចូលខេត្តបានតែតាមច្រកទ្វារអន្តរជាតិអូរស្មាច់ចាប់តាំងពីដើមឆ្នាំខែនេះ រហូតដល់ចូលឆ្នាំខ្មែរ។ លោកបន្តថា៖ «ឥឡូវនេះ ពលករចំណាកស្រុកត្រឡប់មកវិញបានកើនពី ២៥០ នាក់ក្នុង

មួយថ្ងៃដល់ជិត ៥០០ នាក់ក្នុងមួយថ្ងៃ។ ក្នុងរយៈពេលពីរខែចុងក្រោយនេះ ពលករមិនតិចជាង ២០០នាក់ ដែលត្រឡប់មកពីប្រទេសថៃវិញទេ ប៉ុន្តែតួលេខពេលនេះកើនឡើងទ្វេដង និងអាចកើនឡើងបីដង ដោយយ៉ាងហោចណាស់ ១៥ ភាគរយនៃពួកគេបានឆ្លងជំងឺកូវីដ-១៩»។ នៅខេត្តឧត្តរមានជ័យ ពលករចំណាកស្រុកដែលបានចាក់វ៉ាក់សាំងពេញលេញទាំងអស់ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ ខណៈអ្នកមិនបានចាក់វ៉ាក់សាំងតម្រូវឲ្យធ្វើចត្តាឡីស័ក។ លោកបន្ថែមថា៖ «ឥឡូវនេះមិនមានកម្មករចំណាកស្រុកច្រើនជាង ២០០ នាក់ទេដែលស្ថិតក្រោមការធ្វើចត្តាឡីស័កនៅក្នុងខេត្តនេះ ប៉ុន្តែយើងមានអ្នកជំងឺជាង ៣០០ នាក់ដែលកំពុងទទួលការព្យាបាលនៅមជ្ឈមណ្ឌល»៕

## ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០២២

### ពលករខ្មែរនៅប្រទេសថៃចំនួន ២៦.៨៤០នាក់ មានលិខិតអនុញ្ញាតឲ្យបន្តការងាររយៈពេលពីរឆ្នាំទៀត

https://www.khmertimeskh.com/ Khmer Times March 16, 2022

គណៈរដ្ឋមន្ត្រីថៃ កាលពីថ្ងៃអង្គារ បានអនុម័តពន្យាសុពលភាពការងាររបស់ជនចំណាកស្រុកពីប្រទេសកម្ពុជា និងពីរផ្សេងទៀតសម្រាប់រយៈពេលពីរឆ្នាំ។

អ្នកនាំពាក្យរដ្ឋាភិបាលលោក Thanakorn Wangboonkongchana បាននិយាយថា ការពន្យារពេលនេះគឺសម្រាប់ពលករចំណាកស្រុកកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលបានចូលប្រទេសក្រោមអនុស្សរណៈ នៃការយោគយល់គ្នា ស្តីពីការងារ ហើយកិច្ចសន្យាការងាររយៈពេល ៤ឆ្នាំនឹងត្រូវផុតកំណត់នៅឆ្នាំនេះ។ លិខិតអនុញ្ញាតអោយធ្វើការងារ និងទិដ្ឋាការរបស់ពួកគេនឹងត្រូវបន្តរហូតដល់ពីរឆ្នាំ ដើម្បីកុំឱ្យពួកគេចាកចេញពីប្រទេស ខណៈដែលស្ថានភាពកូវីដ-១៩ កំពុងធ្វើឱ្យការធ្វើដំណើរមានការពិបាក។ លោក Thanakorn បាននិយាយថា ការពន្យារពេលនេះក៏នឹងបំពេញតម្រូវការរបស់និយោជកផងដែរ។ អ្នកនាំពាក្យរូបនេះបាននិយាយថា កិច្ចសន្យាការងាររបស់ពលករចំណាកស្រុកចំនួន ១០៦.៥៨០នាក់ មកពីប្រទេសឡាវ កម្ពុជា និងមីយ៉ាន់ម៉ា នឹងផុតកំណត់នៅឆ្នាំនេះ។ វានឹងប៉ះពាល់ដល់ប្រជាជនកម្ពុជាចំនួន ២៦,៨៤០ នាក់ ជនជាតិឡាវ ២៥,៥០៤ នាក់ និងមីយ៉ាន់ម៉ាចំនួន ៥៤,២៣៦ នាក់។ ប្រទេសរបស់ពួកគេក៏បានយល់ព្រមជាមួយនឹងការពន្យារប័ណ្ណអនុញ្ញាតអោយធ្វើការងារ៕ Bangkokpost

### ពលករខ្មែរមកពីប្រទេសថៃ តាមច្រកព្រំដែនបាត់ដំបងថយចុះព្រោះត្រូវឆ្លងកាត់វិធានការសុខាភិបាល

http://nokorwatnews.com/ 15/03/2022

ខេត្តបាត់ដំបង៖ ចរន្តនៃការវិលត្រឡប់របស់ពលករខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃចូលស្រុកវិញតាមព្រំដែនខេត្តបាត់ដំបងមានការថយចុះគួរឲ្យកត់សម្គាល់។ ការថយចុះនេះមួយផ្នែកក៏ដោយសារការរឹតបន្តឹងរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងជំងឺកូវីដ-១៩។ ប៉ុន្តែចំនួនពលករដែលត្រូវបានរកឃើញឆ្លងកូវីដ-១៩ មានការកើនឡើង ខណៈវិធានការសុខាភិបាលនៅច្រកព្រំដែនត្រូវបានរឹតបន្តឹង។

បើតាមលោក ណាត ចាន់រ៉េត ប្រធានទីស្នាក់ការត្រួត ពិនិត្យច្រកទ្វារតំបន់ព្រំដែន ស្ទួនស៊ុ (អូរអន្លក់) ស្រុកកំរៀង បានឱ្យដឹងថា ដើម្បីទប់ស្កាត់ការចម្លងមេរោគកូវីដ-១៩ បំប្លែងថ្មី ប្រភេទអូមីក្រុង វិធានការសុខាភិបាលនៅច្រកព្រំដែន ត្រូវបានរឹតបន្តឹងដោយគ្មានការធ្វេសប្រហែសឡើយ ទោះបីរំហូរពលករខ្មែរវិល ត្រឡប់មកពីប្រទេសថៃ មានការថយចុះ ហើយពលករភាគច្រើន មានកាតចាក់វ៉ាក់សាំងចាប់ពី២ដូសឡើងទៅ។ វិធានការសុខាភិបាលត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនដោយមិនធ្វេសប្រហែសមួយវិនាទីណាឡើយ។ លោកប្រធានស្នាក់ការបានឱ្យ

ដឹងបន្ថែមថា ពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃទាំងអស់ ត្រូវបានយកសំណាកធ្វើតេស្តរហ័សរកជំងឺកូវីដ-១៩ នៅចំណុចច្រកព្រំដែន ហើយចំពោះអ្នកវិជ្ជមាន ក្រុមគ្រូពេទ្យនឹងបញ្ជូនទៅព្យាបាល ។ រីឯអ្នកអវិជ្ជមានគ្មានកាតចាក់វ៉ាក់សាំង ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ក ហើយអ្នកអវិជ្ជមានមានកាតចាក់វ៉ាក់សាំងគ្រប់២ដូស ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន។ ប្រធានច្រកព្រំដែនរូបនេះ បានបញ្ជាក់ថា មួយ រយៈពេលចុងក្រោយនេះ  រំហូរពលករថយចុះ ប៉ុន្តែ ក្នុងចំណោមពលករចូលមកជាង ១០០នាក់ក្នុង១ថ្ងៃ មានចន្លោះពី ៣ទៅ ៥នាក់ ត្រូវបានធ្វើតេស្តរហ័ស រកឃើញឆ្លងជំងឺកូវីដ-១៩ ខណៈមុននេះ រំហូរពលករកើនឡើង ក្នុងចំនួនចន្លោះពីជាង ២០០នាក់ទៅជិត ៣០០នាក់ តែការរកឃើញឆ្លងកូវីដ-១៩ មានតិចតួច ឬស្ទើរតែគ្មាន។

គួរកត់សម្គាល់ថា ក្នុងមួយរយៈពេលចុងក្រោយនេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងខេត្តបាត់ដំបងមាន ការហាក់ឡើងបន្តិចវិញ ក្រោយមានការស្ងប់ស្ងាត់មួយរយៈពេលធំ។ យ៉ាងណាក៏ដោយការកើនឡើងនៃជំងឺ covid-19 នៅខេត្តបាត់ដំបងមិនមែនសុទ្ធតែដោយ សារពាក់ព័ន្ធការវិលត្រឡប់របស់បងប្អូនពលករដែលមកពីប្រទេសថៃនោះឡើយ។ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ-១៩ កងកម្លាំងចម្រុះការពារព្រំដែនកម្ពុជា-ថៃក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើទំនាក់ទំនង និងសហការយ៉ាងជិតស្និទជាមួយភាគីថៃ ដើម្បីទប់ស្កាត់មិនឲ្យប្រជាពលរដ្ឋខ្មែរលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដោយមិនស្របច្បាប់។ ពោលគឺបណ្ដាជនដែលឆ្លងព្រំដែនទាំងអស់សុទ្ធតែត្រូវឆ្លងកាត់ការធ្វើតេស្ត៕

## រយៈពេល៩ថ្ងៃ ថៃបញ្ជូនពលករត្រឡប់មកវិញជិត៥០០០នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៦ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ១៣:១០

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរជិត៥០០០នាក់ ត្រូវបានភាគីថៃបញ្ជូនមកឲ្យកម្ពុជាវិញតាមច្រករបៀងកិច្ចព្រមព្រៀង (ច្រករបៀងអូរបីជាន់ ក្នុងស្រុកអូរជ្រៅ), ច្រកតំបន់(ម៉ាឡៃ និងបឹងត្រកួន) និងអន្តរជាតិប៉ោយប៉ែត ស្ថិតក្នុងខេត្តបន្ទាយមានជ័យ ។ នេះបើតាមកាឲ្យដឹងពីមន្ត្រីជំនាញផ្នែកទទួលពលករបញ្ជូនពីថៃ។ ពលករជិត៥០០០នាក់នេះ គេបញ្ជូនពីថៃចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១៥ មីនា ២០២២ ដោយកាលពីថ្ងៃទី៧ មីនា ពលករបញ្ជូនពីថៃមានចំនួន៦២៨នាក់ (ស្រី២៥៧នាក់ កុមា៧១នាក់) ។ ថ្ងៃទី៨ មីនា (ចំនួន៥៥៣នាក់ស្រី២១៦នាក់កុមា៨០នាក់) ។ ថ្ងៃទី៩ មីនា ចំនួន៥៩០នាក់ (ស្រី២៣០នាក់ កុមា៨៥នាក់) ។ ថ្ងៃទី១០ មីនា ចំនួន៤៩០នាក់ (ស្រី១៩៩នាក់កុមា៧៩នាក់) ថ្ងៃទី១១ មីនា (ចំនួន៦០១នាក់ ស្រី២៤៦នាក់ កុមា៦៥នាក់) ។ ថ្ងៃទី១២ មីនា (ចំនួន៣៥២នាក់ស្រី១៤៤នាក់កុមា៥២នាក់) ។ ថ្ងៃទី១៣ មីនា (ចំនួន៥១០នាក់ ស្រី២១៣នាក់ កុមា៦៨នាក់) ។ ថ្ងៃទី១៤ មីនា (ចំនួន៥០៧នាក់ស្រី២១០នាក់ កុមា៦១នាក់) និងថ្ងៃទី១៥ មីនា (ចំនួន៤៨៩នាក់ ស្រី២០៣នាក់កុមាចំនួន៤០នាក់ )។

យោងតាមការសាកសួរពីមន្ត្រីជំនាញបានឲ្យដឹងថា ពលករទាំងនេះស្ម័គ្រចិត្តវិលត្រឡប់មកផ្ទះដោយខ្លួនឯង ដើម្បីចូលរួមពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនាពេលខាងមុខ ព្រោះតែពួកគេខកខានមិនបានវិលត្រឡប់មកស្រុកជាង២ឆ្នាំមកហើយ លើទឹកដីថៃ ក្នុងសម័យកូវីដ ប៉ុន្តែត្រូវភាគីថៃឃាត់តាមដងផ្លូវដឹកបញ្ជូនត្រឡប់ឲ្យភាគីកម្ពុជា ហើយមួយរយៈចុងក្រោយនេះ ហាក់មានចំនួនច្រើនជាងពេលមុនៗ ៕

## មួយរយៈក្រោយនេះ ពលករខ្មែរមកថៃ
## ត្រូវបានរកឃើញផ្ទុកអូមីក្រុង ប្រមាណ២០នាក់ក្នុងមួយថ្ងៃ

https://btv.com.kh/ 03/16/2022 02:03 PM

ឧត្តរមានជ័យ៖ មួយរយៈពេលចុងក្រោយនេះ ដែលជិតដល់ពេលចូលឆ្នាំខ្មែរផងនោះ ពលករខ្មែររាប់រយនាក់ ក្នុងមួយថ្ងៃៗ បានវិលត្រឡប់មកពីប្រទេសថៃ ហើយត្រូវបានរកឃើញផ្ទុកជំងឺកូវីដ-១៩ ប្រភេទបំប្លែងថ្មី អូមីក្រុង ប្រមាណ២០នាក់ដែរ។ ការវិលត្រឡប់របស់ពលករខ្មែរនេះ គឺតាមច្រកព្រំដែនអន្តរជាតិអូរស្មាច់ ក្នុងខេត្តឧត្តរមានជ័យ។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានឲ្យដឹងថា កាលពី ម្សិលមិញ ពលករខ្មែរ ចំនួនជិត៣០០នាក់ បានវិលមកពីប្រទេសថៃ ដែលក្នុងចំនួននេះ ត្រូវបានរកឃើញ មានវិជ្ជមានកូវីដ-១៩ អូមីក្រុង ចំនួន២១នាក់ ខណៈកំពុងសម្រាកព្យាបាល ៣០០នាក់ និងធ្វើចត្តាឡីស័ក ៤០០នាក់។ លោកវេជ្ជបណ្ឌិត បានបញ្ជាក់ថា ខណៈពេលមានវំហូរពលករខ្មែរដូច្នេះ វិធានការសុខាភិបាល កាន់តែត្រូវបានរឹតបន្តឹងពិសេសគឺការធ្វើតេស្តរកជំងឺកូវីដ-១៩ ដើម្បីទប់ស្កាត់កុំឱ្យមានការនាំចូលមក ចម្លងក្នុងសហគមន៍បន្ថែមទៀត។ លោកវេជ្ជបណ្ឌិត បានបញ្ជាក់ថា ក្រុមការងារសុខាភិបាលជួរមុខ តែងតែពិនិត្យរកឃើញអ្នកវិជ្ជ មានកូវីដ-១៩ លើពលករមកពីថៃ ក្នុងរយៈពេលចុងក្រោយនេះ ហើយក្នុងចំណោមអ្នកទាំងអស់នោះ អ្នកខ្លះបានចាក់វ៉ាក់សាំងរួច ឯខ្លះទៀត ក៏ពុំទាន់បានចាក់វ៉ាក់សាំងនៅឡើយ។ ចំពោះអ្នកដែលពុំទាន់បានចាក់វ៉ាក់សាំង ក្រុមការងារ តម្រូវឲ្យស្នាក់នៅមណ្ឌលធ្វើចត្តាឡីស័កជាបណ្ដោះអាសន្នសិន ដើម្បីតាមដានសុខភាព ទោះបីជាពួកគេពុំមានវិជ្ជមានកូវីដ-១៩ យ៉ាងណាក្ដី។ លោកវេជ្ជបណ្ឌិត ឃ្លោក ហួត បានបញ្ជាក់ថា ការវិលត្រលប់ពលករខ្មែរមកពីថៃ មានការកើនឡើងច្រើនជារៀងរាល់ថ្ងៃយ៉ាងដូច្នេះ គឺដោយសារកត្តាភាគច្រើនពួកគេពុំសូវមានការងារធ្វើឲ្យបានទៀងទាត់ ព្រមជាមួយនឹងពិធីបុណ្យចូលឆ្នាំខ្មែរ ក៏បានខិតជិតមកដល់ផង៕អត្ថបទ៖ យិន សារិទ្ធ

## ក្រុមគ្រូពេទ្យរកឃើញពលករខ្មែរ៨នាក់
## ក្នុងចំណោម១៤០នាក់ វិជ្ជមានកូវីដ-១៩ បន្ទាប់ពីភាគីថៃចាប់បញ្ជូនមកវិញ

https://www.kampucheathmey.com/ ថ្ងៃពុធ ១៦ មីនា ២០២២ដោយ Sokhom Khon

ពលករខ្មែរ ដែលចូលក្នុងប្រទេសថៃករកការងារធ្វើ ដោយប្រថុយប្រថានខុសច្បាប់ ត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួនជាបន្តបន្ទាប់ហូតមានចំនួន១៤០នាក់ ហើយបានបញ្ជូនមកប្រគល់ឲ្យសមត្ថកិច្ចកម្ពុជាវិញ។

សមត្ថកិច្ចឲ្យដឹងថា ករណីខាងលើនេះ អាជ្ញាធររួមជាមួយកម្លាំងចម្រុះការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៅព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២នេះ បានសហការគ្នាដើម្បីទៅទទួលពលករខ្មែរពីសមត្ថកិច្ចថៃដែលបានបញ្ជូនឲ្យវិលត្រឡប់មកស្រុកវិញសរុបចំនួន១៤០នាក់ នៅចំណុចច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។ ចំពោះពលករទាំង១៤០នាក់ រួមមានបុរសចំនួន៦៥នាក់ ពលករស្ត្រី៥៦នាក់ និងក្មេងចំនួន១៩នាក់ផងដែរ ដោយក្នុងនោះក្រុមគ្រូពេទ្យក៏បានពិនិត្យរកឃើញពលករ៨នាក់ មានផ្ទុកជំងឺកូវីដ១៩ និងបានបញ្ជូនទៅសម្រាកព្យាបាលភ្លាមៗផងដែរ។

មន្ត្រីសុខាភិបាលបានឲ្យដឹងដែរថា ពលរដ្ឋដែលជាពលករទាំងអស់ខាងលើក្រោយការពិនិត្យឃើញចំនួន១១៣នាក់មានកាតចាក់វ៉ាក់សាំងត្រូវក្រុមគ្រូពេទ្យណែនាំអប់រំហើយអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ រីឯពលករដែលមិនទាន់បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ត្រូវគ្រូពេទ្យបានបញ្ជូនទៅមណ្ឌលដើម្បីសម្រាកព្យាបាលជំងឺ និងធ្វើចត្តាឡីស័កដើម្បីតាមដានសុខភាពនៅពេលក្រោយ៕ អត្ថបទ៖ សៅ សារិទ្ធ

## សេចក្តីជូនដំណឹងស្តីពីពលករ ពលការិនីទំនាក់ទំនងមិនបាន

https://www.facebook.com/mtosbcambodia 16/03/2022

គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស សូមជូនដំណឹងដល់ ពលករ ពលការនីដែលមានឈ្មោះដូចខាងក្រោម៖

១/ អ៊ូច ណៅ (OUCH NOV ) ភេទ ប្រុស អាសយដ្ឋាន ភូមិខ្វាវ ឃុំអំពក ស្រុកគិរីវង់ ខេត្តតាកែវ។

២/ ធូ ស្រីលីន (THOU SREYLIN) ភេទ ស្រី អាសយដ្ឋាន ភូមិកោះដាច់ ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

៣/ ឡុក ពុត (LOK PUTH) ភេទ ប្រុស អាសយដ្ឋាន ភូមិកន្ទួតប្រោង ឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

៤/ ស្វាយ សុខា (SVAY SOKHA) ភេទ ស្រី អាសយដ្ឋាន ភូមិតាលាក់ខាងជើង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។

៥/ ផាត សុវណ្ណី (PHAT SOVANNY) ភេទ ស្រី អាសយដ្ឋាន ភូមិកំពែង ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

៦/ ពុត សំអុន (PUT SAM UN) ភេទប្រុស អាសយដ្ឋាន ភូមិជាច ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង។

៧/ ចេន រ៉ាន់ (CHEN RANN) ភេទ ប្រុស អាសយដ្ឋាន ភូមិព្រៃកែស ឃុំដំណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត។

៨/ នួន សុម៉ាលី (NUON SOMALY) ភេទ ស្រី អាសយដ្ឋាន ភូមិថ្នា ឃុំបន្សាយត្រែង ស្រុកថ្មគោល ខេត្តបាត់ដំបង។

៩/ ឯក យ៉ា (EK YA) ភេទ ស្រី អាសយដ្ឋាន ភូមិពោធិដុះ ឃុំបឹងនិមល ស្រុកឈូក ខេត្តកំពត។

សូមរួសរាន់ទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ឱ្យបានមុនថ្ងៃសុក្រ ទី១៨ ខែមីនា ឆ្នាំ២០២២ ម៉ោង០៣:០០នាទីរសៀល តាមរយៈទូរស័ព្ទលេខ ០៨៨ ៣៩៩ ៨៨៨៨ / ០៧១ ៩០៧៩ ៧៧៧ និង ០២៣ ៦៤២៥ ៧៧៧នៅរៀងរាល់ម៉ោងធ្វើការ។ * បញ្ជាក់៖ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស មិនអាចទំនាក់ទំនង តាមរយៈលេខទូរស័ព្ទរបស់គាត់ និងគ្រួសាររបស់គាត់បានឡើយ។ អាស្រ័យហេតុនេះ សូមបងប្អូន និងសាធារណជនមេត្តាជួយផ្សព្វផ្សាយបន្ត។

# ថ្ងៃទី១៨ ខែ មីនា ឆ្នាំ២០២២

## ពលករខ្មែររាប់ពាន់នាក់ សម្រុកវិលត្រឡប់ពីថៃមកកម្ពុជាវិញតាមខេត្តឧត្តរមានជ័យ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 16 March 2022 | 11:10 ICT

**ឧត្តរមានជ័យៈ** ពលករខ្មែររាប់ពាន់នាក់បានសម្រុកវិលមកពីថៃ ដោយគ្រាន់តែចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ១៣ ខែមីនាឆ្នាំ ២០២២ មានពលករខ្មែរត្រឡប់មកពីថៃ តាមច្រកទ្វារព្រំដែនអន្តរជាតិខេត្តឧត្តរមានជ័យមានជិត ៥ ពាន់នាក់ក្នុងនោះវិជ្ជមានកូវីដ-១៩ប្រមាណ ៣០០ នាក់។

ជាទូទៅក្នុងមួយថ្ងៃៗមានពលករវិលត្រឡប់មកពីថៃតាមច្រកព្រំដែនក្នុងខេត្តនេះមានចន្លោះពី ២០០ ទៅ ៥០០ នាក់។ នេះបើតាមរបាយការណ៍បូកសរុបប្រចាំថ្ងៃរបស់ខេត្តឧត្តរមានជ័យ។ ក្នុងរបាយការណ៍ស្តីពីចំនួនពលករសំណាកស្រុក មកពីប្រទេសថៃ តាមច្រកព្រំដែនខេត្តឧត្តរមានជ័យ ដោយគិតចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០២២ មានពលករវិលចូលស្រុកវិញចំនួន ៤ ៧៥០ នាក់ក្នុងនោះ រកឃើញអ្នកវិជ្ជមានកូវីដ ១៩ ចំនួន

២៧៨ នាក់។ របាយការណ៍ដដែលបន្តថា ក្នុង ១ ថ្ងៃពលករដែលវិលចូលស្រុកមិនតិចក្រោម ២០០ នាក់នោះទេ ពោលគឺចន្លោះពីជាង ២០០ ទៅ ៥០០ នាក់។ បើតាមរបាយការណ៍នៅថ្ងៃទី ១ ខែមីនា មានពលករបានវិលត្រឡប់មកវិញចំនួន ៤៩២ នាក់ ថ្ងៃទី ២ ចំនួន ២៨៩ នាក់ ថ្ងៃទី ៣ ចំនួន ៤៨១ នាក់ ថ្ងៃទី ៤ មានចំនួន ២៣៦ នាក់ ថ្ងៃទី ៥ ចំនួន ៣០៤ នាក់ ថ្ងៃទី ៦ ចំនួន ៥៤៤ នាក់ ថ្ងៃទី ៧ ចំនួន ៥១២ នាក់ថ្ងៃទី ៨ ចំនួន ៣៥៣ នាក់ ថ្ងៃទី ៩ ចំនួន ៣២៣ នាក់ ថ្ងៃទី ១០ ចំនួន ៣១៤ នាក់ ថ្ងៃទី ១១ ចំនួន ៣៥៣ នាក់ ថ្ងៃទី ១២ ចំនួន ២៦២ នាក់ និងថ្ងៃទី ១៣ មីនាមានចំនួន ២៨៧ នាក់។

អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យ លោក ផល លឹម បានប្រាប់ភ្នំពេញប៉ុស្តិ៍បន្ថែមថា ក្នុងចំណោមពលករដែលវិលចូលស្រុកវិញនេះ មានអ្នកខ្លះមកចាក់វ៉ាក់សាំងដូសជំរុញ និងមួយចំនួនទៀតដោយសារអត់មានការងារធ្វើនៅប្រទេសថៃ។ លោកថា៖ «ក្នុងខែមីនានេះ ពលករវិលចូលស្រុកច្រើនក្នុងមួយថ្ងៃមានចាប់ពី ២០០ នាក់ ៣០០ នាក់ថ្ងៃខ្លះជាង ៥០០ នាក់ ភាគច្រើនជាអ្នកចាក់ដូសជំរុញ អ្នកខ្លះចាក់ដូសជំរុញទី ២ ទី ៣ ហើយខ្លះទៀតអត់ការងារគេបញ្ជូនមកវិញ»។ លោកបន្តថា ក្នុងចំណោមពលករដែលត្រឡប់មកវិញត្រូវបានកម្លាំងអាជ្ញាធរបញ្ជូនបន្តទៅតាមបណ្ដាខេត្តរបស់ពួកគេ ក្នុងករណីអវិជ្ជមានកូវីដ ១៩ ដោយមិនអនុញ្ញាតឱ្យត្រឡប់ទៅថៃវិញនោះទេ ស្របពេលដែលរដ្ឋាភិបាលទាំង ២ មិនទាន់សម្រេចបើកច្រកទ្វារព្រំដែនឡើងវិញ។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (Central) លោក មឿន តុលា មើលឃើញមូលហេតុចំនួន ៣ ដែលពលករនៅបន្តវិលចូលស្រុកវិញ ដោយមិនរាប់បញ្ចូលរឿងការចាក់វ៉ាក់សាំងកូវីដ ១៩។ លោកថ្លែងថា មូលហេតុទី ១ ដោយសារពលករចប់អាណត្តិការងារ ហើយមិនអាចបន្តការងារថ្មីនៅថៃបាន។ ទី ២ ក្រុមហ៊ុនដែលពលករខ្មែរកំពុងធ្វើការនោះ ត្រូវបានរំសាយ ឬបញ្ឈប់បុគ្គលិក ដោយសារនៅប្រទេសថៃ ផ្ទុះកូវីដខ្លាំង ។ ចំពោះមូលហេតុទី ៣ ផ្ដោតសំខាន់ទៅលើពលករខ្មែរមួយចំនួនទៅធ្វើការនៅថៃមិនមានឯកសារត្រឹមត្រូវ ហើយទទួលរងនូវការធ្វើទុក្ខបុកម្នេញ ឬមានការតាមចាប់ពីតម្រួតថៃ ទើបគាត់សម្រេចចិត្តត្រឡប់មកវិញ។

អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) លោកស្រី ជូ ប៊ុនអេង ធ្លាប់បានថ្លែងថា ចាប់តាំងពីផ្ទុះជំងឺរាតត្បាតកូវីដ ១៩ រហូតដល់ចុងឆ្នាំ ២០២១ មានពលករខ្មែរត្រឡប់មកពីក្រៅប្រទេសចូលស្រុកវិញជាង ២៦ ម៉ឺននាក់ ក្នុងនោះភាគច្រើនត្រឡប់មកពីប្រទេសថៃ។ លោកស្រីថ្លែងថា ក្នុងអំឡុងពេលជំងឺកូវីដ ១៩ បានចាប់ផ្ដើមរាតត្បាតដល់បណ្ដាប្រទេសក្នុងតំបន់បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ដល់ប្រព័ន្ធសេដ្ឋកិច្ច និងការងារពលករដែលតាមបណ្ដារោងចក្រ សហគ្រាស និងកសិដ្ឋាន ត្រូវបានបិទស្ទើរទាំងស្រុង ធ្វើឱ្យពលករបាត់បង់ការងារ និងប្រាក់ចំណូល ជាពិសេសពលករគ្មានជំនាញ និងចំណូលទាប។ លោកស្រីថា៖ « នាគ្រានោះដែរប្រទេសថៃបានប្រកាសបិទព្រំដែន ក្នុងអំឡុងខែមីនាឆ្នាំ ២០២០ ហើយបានជំរុញឱ្យពលករកម្ពុជាវិលត្រឡប់មកពីប្រទេសថៃវិញ យ៉ាងគគ្រឹកគគ្រេងតាមបណ្ដោយបន្ទាត់ព្រំដែន»៕

## កម្លាំងការពារព្រំដែនម៉ាឡៃ ឃាត់ខ្លួនពលករខ្មែរមកពីថៃ ១៣០ នាក់ធ្វើតេស្តអវិជ្ជមាន

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៧ មីនា ២០២២ដោយ deth leng

កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនលេខ៨១៥ ឈរជើងនៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី ១៦ ខែមីនា បានធ្វើការឃាត់ខ្លួន ពលករខ្មែរមកពីប្រទេសថៃចូលមកកម្ពុជាចំនួន ១៣០ នាក់ ដើម្បីយកទៅធ្វើសំណាករកមេរោគកូវីដ១៩។

ការឃាត់ខ្លួនពលករបានធ្វើឡើងចំនួន ២ លើក លើកទី១ នៅវេលាម៉ោង៩ ព្រឹកថ្ងៃទី ១៦ ខែមីនា ឃាត់ខ្លួនបានចំនួន ១៧ នាក់នៅចំណុច ពង់បងសល់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យពួកគាត់មានទីលំនៅក្នុងខេត្តចំនួន៤គឺ ១សៀមរាប ៤នាក់ ២បាត់ដំបង៨នាក់ ៣កំពង់ធំ ១នាក់ ៤បន្ទាយមានជ័យ៤នាក់។

ឃាត់ខ្លួនលើកទី២ នៅវេលាម៉ោង ៣ល្ងាច ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ មានពលករចំនួន ១១៣នាក់ ស្រី ៥០នាក់ កុមារ១១នាក់ វិលត្រឡប់ពីប្រទេសថៃ ចូលមកស្រុកខ្មែរ តាមភូមិសាស្ត្រប៉ុស្តិ៍ចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

ពលករខ្មែរទាំងនោះ ត្រូវបានយកទៅប្រគល់ជូនក្រុមគ្រូពេទ្យជំនាញជួរមុខ ដើម្បីយកសំណាកធ្វើតេស្តរហ័សរកមេរោគកូវី-១៩ លទ្ធផលពលករទាំង១៣០នាក់នោះអវិជ្ជមានទាំងអស់។ ពលករខ្មែរទាំង ១៣០នាក់ ក្រោយពីធ្វើកិច្ចសន្យារួចត្រូវបានអនុញ្ញាតិឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញរៀងៗខ្លួន៕

## សមត្ថកិច្ចឃាត់ខ្លួនតៃកុងឡានម្នាក់ ដឹកពលរដ្ឋ ១៣នាក់ បម្រុងឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ

https://gntimes.com/news/ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

បន្ទាយមានជ័យ៖ សមត្ថកិច្ចឈរជើងតាមបន្ទាត់ព្រំដែន ឃាត់ខ្លួនពលរដ្ឋ ១៣នាក់ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅទឹកដីប្រទេសថៃ រួមនិងតៃកុងឡានម្នាក់ នៅចំណុចផ្លូវលំក្នុងភូមិចំបក់ ឃុំបឹងបេង (ចម្ងាយពីផ្លូវជាតិលេខ ៥៩ ប្រហែល ១០០ម៉ែត្រ) កាលពីវេលម៉ោង ១២ យប់រំលងអធ្រាត្រឈានចូលថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២២ ។

បើតាមការបញ្ជាក់ពីសមត្ថកិច្ច វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៥ បានឲ្យដឹងថា៖ កម្លាំងសមត្ថកិច្ចប៉ុស្តិ៍ចំបក់ សហការជាមួយកម្លាំងកងរាជអាវុធហត្ថប្រចាំស្រុកម៉ាឡៃ បានទប់ស្កាត់ប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនខុសច្បាប់ ១៣នាក់ (ស្រី ០៥នាក់ កុមារម្នាក់) នៅចំណុចផ្លូវលំក្នុងភូមិចំបក់ ឃុំបឹងបេង (ចម្ងាយពីផ្លូវជាតិលេខ ៥៩ ប្រហែល ១០០ម៉ែត្រ) និងរថយន្ត ០១គ្រឿង មាកនីសាន់ ពណ៌ទឹកប្រាក់ ស្លាកលេខ ២B-៣៤៤៣ ដែលអ្នកបើកបររថយន្តឈ្មោះ លឿម បូរី ភេទប្រុស អាយុ ៤០ឆ្នាំ មានទីលំនៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

បច្ចុប្បន្ន សមត្ថកិច្ចបានបញ្ជូនពលរដ្ឋទាំង ១៣នាក់ ទៅមណ្ឌលចត្តាឡីស័ក ចំណែកតៃកុងរថយន្ត បានបញ្ជូនទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ដើម្បីចាត់វិធានការបន្តតាមនីតិវិធីច្បាប់ ៕ ចន្ទ្រា

## នៅព្រឹកថ្ងៃព្រហស្បតិ៍ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/17/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែ

បន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន០៦នាក់ ស្រី ០២នាក់ ក្មេងប្រុសម្នាក់។

ក្រោយពីទទួលបានកម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចប្រគល់បងប្អូនចំនួន ០៩នាក់ ស្រី០៣នាក់ ក្មេងស្រីម្នាក់ ក្មេងប្រុសម្នាក់ ទៅឲ្យក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារអន្តរជាតិគីឡូ១៣ និងបងប្អូនចំនួន០៣នាក់ ស្រីម្នាក់ ទៅឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ជាលទ្ធផល គឺអវិជ្ជមាន បន្ទាប់មកក្រុមពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ។

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែន គោកលេខ៨១៩ សហការនិងកម្លាំងយោធា ចុះល្បាតបង្ការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទ និងក្តាប់សភាពការណ៍តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/03/17/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នាថ្ងៃព្រហស្បតិ៍ ១៥កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក។ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេមេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់អោយនាយប៉ុស្តិ៍ប្រចាំការនៅជួរមុខចំនួន២ប៉ុស្តិ៍ ត្រៀមកម្លាំងចេញល្បាត រួមមាន៖

-កម្លាំងប៉ុស្តិ៍អូររំដួល ចំនួន ៥នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ផេង ណូរ៉ែលនាយរងប៉ុស្តិ៍

-កម្លាំងប៉ុស្តិ៍បឹងអាជាង ចំនួន ២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ជួប ជឹម មន្ត្រីប៉ុស្តិ៍ សហការជាមួយកងកម្លាំងវរៈចំណុះអោយកម្លាំងកងពលតូចថ្មើរជើងលេខ៥៣ កងល្បាតចំណុះកងការពារព្រំដែន៥០៤ និងកម្លាំងសឹករងស្រុក បានចុះល្បាតត្រួតពិនិត្យនៅព្រំដែន បង្ការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទ និងក្តាប់សភាពការណ៍តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្ររបស់ទទួលខុសត្រូវ ជាលទ្ធផល ពិនិត្យឃើញថាពុំមានសកម្មភាពអ្វីគួរឲ្យកត់សម្គាល់ឡើយ។

# ថ្ងៃទី២១ ខែ មីនា ឆ្នាំ២០២២

## រកឃើញពលករខ្មែរមកពីថៃ វិជ្ជមានកូវីដ ២៣ នាក់

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៨ មីនា ២០២២ដោយ Sorn Phanith

ពលករខ្មែរ ២២៨ នាក់ នៅថ្ងៃទី ១៨ ខែមីនានេះ ត្រូវបានភាគីសមត្ថកិច្ចថៃ ចាប់បញ្ជូនមកប្រគល់ឲ្យសមត្ថកិច្ចកម្ពុជាវិញ ក្រោយពួកគេលួចចូលទៅរកការងារធ្វើដោយខុសច្បាប់ ក្នុងប្រទេសថៃ។

លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ បានឲ្យដឹងថា ពលករខ្មែរដែលភាគីថៃបញ្ជូនមកនាពេលនេះ លោកបានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យទៅទទួលពួកគេ នៅចំណុចច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតា

សែន ស្រុកកំរៀង ខេត្តបាត់ដំបង។ លោកបន្តថា បន្ទាប់ពីសមត្ថកិច្ចធ្វើការសាកសួរកត់ឈ្មោះចុះកំណត់ហេតុ និង អប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវីដរួចមក សមត្ថកិច្ចបានប្រគល់ឲ្យក្រុមគ្រូពេទ្យ ដើម្បីពិនិត្យលើសុខភាព។

ក្រុមគ្រូពេទ្យបានបញ្ជាក់ឲ្យដឹងថា ពលករខ្មែរដែលមានសរុបចំនួន ២២៨ នាក់ ក្នុងនោះស្រី ៩៣ នាក់ ក្មេង ៤២ នាក់ ស្រី ២១ នាក់ ក្រោយពីក្រុមគ្រូពេទ្យធ្វើតេស្តរហ័សជាលទ្ធផលវិជ្ជមានកូវីដ ចំនួន ២៣នាក់ ស្រី ១១ នាក់ ក្មេង ២ នាក់ ស្រី ១ នាក់ បានបញ្ជូនទៅព្យាបាលនៅមណ្ឌលស្រុកសំពៅលូន។ ដោយឡែកពលករចំនួន ២៧ នាក់ ស្រី ១១ នាក់ ក្មេង ៥ នាក់ ស្រី ៣ នាក់ បញ្ជូនទៅធ្វើចត្តាឡីស័ក នៅមណ្ឌលគីឡូ ៩ ស្រុកសំពៅលូន ខេត្តបាតដំបង។

ចំណែកពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ១៧៨ នាក់ ស្រី ៧០ នាក់ ក្មេង ៣៥ នាក់ ស្រី ១៧ នាក់ ក្នុងនោះបានចាក់វ៉ាក់សាំងឲ្យក្មេងចាប់ពីអាយុ ៥ ឆ្នាំដល់ ១៨ ឆ្នាំ ចំនួន ៣០ នាក់ ស្រី ១៨ នាក់ ក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕ **អត្ថបទ៖ សៅ សារិទ្ធ**

## ឃាត់ខ្លួនមេខ្យល់ម្នាក់ នាំពលករ ទៅរកការងារធ្វើ នៅប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatMarch 18, 2022

បន្ទាយមានជ័យ : មេខ្យល់ម្នាក់ នាំពលករទៅរកការងារធ្វើនៅប្រទេសថៃ ដោយខុសច្បាប់ ត្រូវកម្លាំងអាវុធហត្ថឃាត់ខ្លួន នៅវេលាម៉ោង ៥ល្ងាច ថ្ងៃទី១៨ ឆ្នាំ ២០២២ ក្នុងកម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុក បានចុះល្បាតក្នុងភូមិសាស្ត្រភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ស្រាប់តែបានឃើញមានរថយន្ត១គ្រឿង ម៉ាក NISSANFROTIER ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ បន្ទាយមានជ័យ 2B-3443 ដឹកមនុស្សប្រុស ស្រីជាច្រើននាក់ ។

លោកវរសេនីយ៍ត្រី តាំង សុខហេង បានប្រាប់ឲ្យដឹងថា មនុស្សជិះក្នុងរថយន្តនោះមានគ្នាចំនួន១៤នាក់ ក្នុងស្ត្រីចំនួន៥នាក់ និងអ្នកបើករថយន្ត១នាក់ ជាមេខ្យល់ ។ ក្រោយពីកម្លាំងជំនាញសាកសួរពលករទាំង១៣នាក់នោះបានឲ្យដឹងថា ពួកខ្លួនមកពីបណ្ដាខេត្តផ្សេងៗគ្នាបានធ្វើការទំនាក់ទំនងនិងមេខ្យល់ ជាអ្នកបើករថយន្ត ដើម្បីឲ្យនាំពួកខ្លួនឆ្លងដែនទៅប្រទេសថៃរកការងារធ្វើ។ ចំណែកមេខ្យល់មានឈ្មោះ លឿម បូរី ភេទប្រុស អាយុ៤០ឆ្នាំ រស់នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ បានសារភាពថា ខ្លួនពិតជាបានដឹកពលករទាំងអស់បម្រុងឆ្លងដែន ទៅរកការងារនៅប្រទេសថៃមែន។ ពលករទាំង១៣នាក់ ត្រូវបានកម្លាំងអាវុធហត្ថដឹកតាមរថយន្តបញ្ជូនទៅធ្វើតេស្តរហ័ស នៅមណ្ឌលសុខភាពស្រុម៉ាឡៃដើម្បីរកមេរោគកូវីដ-១៩ បើសិនអវិជ្ជមានអនុញ្ញាតឲ្យវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ដោយឡែកបើវិជ្ជមាន ត្រូវនៅសម្រាកព្យាបាលសិន ។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ទទួលការងារស្រាវជ្រាវ និងបង្រ្កាបបទល្មើសបានឲ្យដឹងថា ដោយបានការអនុញ្ញាតពីលោកឧត្តមសេនីយ៍ត្រី បោន ប៊ិន មេបញ្ជាការកងរាជអាវុធហត្ថខេត្ត និងមានការសម្របសម្រួលនីតិវិធីពី ឯកឧត្តម កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត មេខ្យល់នឹងបញ្ជូនទៅតុលាការ ដើម្បីដាក់ទោសទៅតាមច្បាប់៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

# អាជ្ញាធរថៃ-កម្ពុជា អះអាងថា
# ព័ត៌មាននៃការចាប់ជំរិតដោយបង្ខំឱ្យបូមយកឈាមលក់មិនមែនជាការពិត

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ១៩ មីនា ២០២២ដោយ deth leng

ប្រភពព័ត៌មានបានឱ្យដឹងថា អាជ្ញាធរថៃ-កម្ពុជាបានបញ្ជាក់ថា ព័ត៌មានពីករណី នៃការចាប់ជំរិតដោយបង្ខំបូមយកឈាមលក់នោះមិនមែនជាការពិតទេ និងអះអាងថា ជនរងគ្រោះបានធ្វើដំណើរទៅកម្ពុជាដោយខុសច្បាប់។

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ លោកឧត្តមសេនីយ៍ឯក Roy Ingkapairote អគ្គស្នងការរងនគរបាលជាតិថៃ និងសមត្ថកិច្ចនគរបាលជាន់ខ្ពស់ នៃអគ្គស្នងការនគរបាលជាតិកម្ពុជា បានរួមគ្នាធ្វើសន្និសីទសារព័ត៌មានមួយ ដោយបានធ្វើការបំភ្លឺដើម្បីបញ្ជាក់ការពិតពីករណីការជួយសង្គ្រោះដល់ជនជាតិថៃ ដែលត្រូវបានគេជំរិតបង្ខំឱ្យធ្វើការ រហូតដល់អាចជួយសង្គ្រោះនាំត្រឡប់មកប្រទេសថៃវិញបានដោយជោគជ័យចំនួន ៨នាក់ កាលពីថ្ងៃទី៩ ខែមីនាកន្លង មក។ ហើយបន្ទាប់ពីជួយសង្គ្រោះត្រឡប់មកដល់ប្រទេសថៃវិញ មានជនរងគ្រោះម្នាក់បានប្រាប់ហេតុការណ៍ និង ផ្តល់ព័ត៌មានដល់សមត្ថកិច្ច អំពីហេតុការណ៍ដែលបានកើតឡើងនៅកម្ពុជាដោយអះអាងថា ក្នុងអំឡុងពេលពួកគេស្នាក់នៅប្រទេសកម្ពុជា ត្រូវបានក្រុមជនបង្កដែលជាជនជាតិចិននៅក្រុងព្រះសីហនុ(ប្រទេសកម្ពុជា) នាំទៅ និងបង្ខំបូមយកឈាមចំនួន ៣ប្លោក និងបានប្រើអំពើហិង្សាលើរាងកាយ ព្រមទាំងចាក់ថ្នាំសន្លប់ទៀតផង។ លោកឧត្តមសេនីយ៍ឯក Roy Ingkapairote ថ្លែងថា បន្ទាប់ពីបានដឹងរឿងរ៉ាវពីការអះអាងនេះ សមត្ថកិច្ចថៃបានសហការជាមួយសមត្ថកិច្ចកម្ពុជា ដើម្បីស៊ើបអង្កេតឱ្យដឹងការពិត រហូតបានដឹងថា៖ បញ្ហាដែលបានអះអាងថា ចាប់បង្ខំបូមយកឈាមនោះ មិនមែនជាការពិតឡើយ។

ជាមួយគ្នានេះដែរ លោកឧត្តមសេនីយ៍ទោ Surachet Hakphan ជំនួយការអគ្គស្នងការនគរបាលជាតិថៃ បានលើកឡើងពីសកម្មភាពរបស់ជនរងគ្រោះនេះថា៖ ដើមឡើយស្ត្រីជាជនរងគ្រោះនេះ បានឆ្លងដែនដោយខុសច្បាប់ទៅធ្វើការនៅកម្ពុជាជាមួយនឹងមិត្តប្រុសរបស់ខ្លួន ហើយបានសុំជំនួយសង្គ្រោះមកអាជ្ញាធរថៃ ទើបសមត្ថកិច្ចបានត្រួតពិនិត្យព័ត៌មាន និងបានទំនាក់ទំនងជាមួយអាជ្ញាធរកម្ពុជា រហូតដល់ជំនួយសង្គ្រោះបានត្រឡប់មកថៃវិញដោយជោគជ័យ ប៉ុន្តែមិត្តប្រុសរបស់នាងបានត្រឡប់មកវិញមុន ធ្វើឱ្យនាងមានការបារម្ភថា នឹងមិនបានទទួលការជួយសង្គ្រោះភ្លាមៗ ទើបបានជានាងបង្កើតរឿងនេះឡើង ក្នុងគោលបំណងដើម្បីឱ្យសមត្ថកិច្ចជួយពន្លឿនការជួយសង្គ្រោះ។ លោកឧត្តមសេនីយ៍ទោ Surachet Hakphan បន្តថា ទង្វើនេះជាបទល្មើសព្រហ្មទណ្ឌ ដឹងថាមិនមានអំពើល្មើសកើតឡើង ហើយប្តឹងដល់មន្ត្រីស៊ើបអង្កេត ឬមន្ត្រីមានសមត្ថកិច្ចដែលមានអំណាចស៊ើបអង្កេតករណីព្រហ្មទណ្ឌថា មានបទល្មើស គឺត្រូវមានទោសជាប់ពន្ធនាគារ ៣ឆ្នាំ ឬពិន័យជាប្រាក់ពី ៦ពាន់បាត ហើយនឹងត្រូវនាំខ្លួនទៅកាត់ទោសនៅស្នងការដ្ឋាននគរបាលខេត្តស្រះកែវ(ថៃ)។

ចំណែកជនរងគ្រោះ បានសារភាពថា នាងបង្កើតរឿងនេះឡើងព្រោះបារម្ភខ្លាចថា ខ្លួននឹងមិនទទួលបានជំនួយសង្គ្រោះជាបន្ទាន់ ពីព្រោះចង់ត្រឡប់ទៅថៃវិញ ដោយសារនៅក្នុងកន្លែងធ្វើការងាររបស់នាងនោះ ជាតំបន់ហាមឃាត់មិនអាចចេញទៅក្រៅបាន ដែលមានលក្ខណៈហាក់ដូចត្រូវបានបង្ខាំង និងបង្ខំឱ្យធ្វើការធ្ងន់ធ្ងរ។ នាងបានបន្ថែមថា នៅមានជនជាតិថៃរាប់ពាន់នាក់ទៀតដែលរត់ពន្ធមកធ្វើការនៅទីនោះ ទាំងមជ្ឈមណ្ឌលហៅទូរស័ព្ទ (Call center) ទាំងគេហទំព័រល្បែងស៊ីសងតាមអ៊ីនធឺណិតនានា ហើយគោលដៅរបស់ពួកគេគឺ បោកប្រាស់ប្រជាជនថៃដោយក្រុមចៅកែជាជនជាតិចិន៕ បកប្រែ៖ សំអាន ប្រភព៖ Thai PBS

## អភិបាលរងខេត្តព្រះសីហនុ៖ ស្ត្រីជនជាតិថៃបានសារភាពនិងសុំទោសចំពោះប្រឌិតករណីយកសរីរាង្គ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 19/03/2022 - 12:26

អភិបាលរងខេត្តព្រះសីហនុ លោក ឡុង ឌីម៉ង់ បានបញ្ជាក់ប្រាប់វិទ្យុបារាំងអន្តរជាតិនៅរសៀលនេះថា ស្ត្រីជនជាតិថៃមួយរូបបានសារភាពថា នាងបានប្រឌិតករណីប្លមយកឈាម និងវះយកសរីរាង្គនៅខេត្តព្រះសីហនុ ក្នុងគោលបំណងអោយនគរបាលថៃជួយអោយនាងបានទៅប្រទេសថៃវិញ ក្រោយពីលួចឆ្លងដែនចូលមកធ្វើការនៅប្រទេសកម្ពុជាដោយខុសច្បាប់។ បើតាមលោកអភិបាលរងខេត្តព្រះសីហនុ ស្ត្រីជនជាតិថៃនោះ បានសារភាពទទួលកំហុស និងសុំទោសជាសារធារណៈ នៅក្នុងសន្និសារព័ត៌មានរួមរវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលភូមិន្ទថៃ នៅទីក្រុងបាំងកក នៅថ្ងៃសុក្រទី១៨ មីនា ម្សិលមិញនេះ។ ចំពោះលោកអភិបាលរងខេត្តព្រះសីហនុ លោកពិតជាសោកស្តាយខ្លាំងណាស់ ដែលស្ត្រីរូបនោះបានសម្លុយកេរ្តិ៍ឈ្មោះកម្ពុជាយ៉ាងដូច្នេះ។

តាមទោសនៃច្បាប់នៅប្រទេសថៃ នារីខាងលើត្រូវបានចោទប្រកាន់ ដាក់ពន្ធធនាគារ ចំនួនបីឆ្នាំ ពីបទរាយការព័ត៌មានក្លែងក្លាយ។ គួរជម្រាបថា នៅដើមខែមីនានេះ កាសែតអនឡាញថៃបានចុះផ្សាយថាស្ត្រីជនជាតិថៃខាងលើត្រូវបានគេល្បួងមកធ្វើការងារខុសច្បាប់នៅប្រទេសកម្ពុជា ក្នុងខេត្តព្រះសីហនុ ប្រុងនឹងក្លាយជាជនរងគ្រោះដោយសារការវះយកសរីរាង្គ ដោយក្រុមបងតូចបងធំជាជនជាតិចិន សម្រាប់លក់នៅក្នុងទីផ្សារងងឹត ប៉ុន្តែនាងត្រូវបានរត់គេចខ្លួនដោយត្រដាបត្រដួស៕

# ថ្ងៃទី២២ ខែ មីនា ឆ្នាំ២០២២

## ជំនួបពិសេសទ្វេភាគី៖ សម្តេចតេជោ ហ៊ុន សែន ស្នើជប៉ុនបង្កើនកូតាទទួលយកពលករ និងកម្មសិក្សាការីកម្ពុជាបន្ថែមទៀត

http://freshnewsasia.com/ 2022-03-20 09:53pm

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងជំនួបជាមួយលោក គីស៊ីដា ហ្វ៊ូមីអូ នាយករដ្ឋមន្ត្រីជប៉ុន នៅល្ងាចថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២នេះ បានស្នើឲ្យជប៉ុនបង្កើនកូតា ក្នុងការទទួលយកពលករ និងកម្មសិក្សាការីកម្ពុជាបន្ថែមទៀត។ សំណើនេះត្រូវបានសម្តេចតេជោ ហ៊ុន សែន លើកឡើងនៅពេលដែលលោកនាយករដ្ឋមន្ត្រីជប៉ុន បំពេញទស្សនកិច្ចផ្លូវការក្នុងប្រទេសកម្ពុជា តាមការអញ្ជើញរបស់សម្តេច។ លោកនឹងបំពេញទស្សនកិច្ចនៅកម្ពុជា រយៈពេលពីរថ្ងៃ។ ក្រោយជំនួបទ្វេភាគីសម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មានរួមគ្នាយ៉ាងដូច្នេះថា «**ខ្ញុំក៏បានស្នើជប៉ុនបង្កើនកូតាក្នុងការទទួលយកកម្មសិក្សាការី និងពលករជំនាញកម្ពុជា។ ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុនសង្ឃឹមថា ពេលស្ថានភាពជំងឺកូវីដបានល្អប្រសើរពេលករជំនាញ និងកម្មសិក្សាការីជាច្រើនថែមទៀត ជាបន្តបន្ទាប់**»។

បន្ថែមពីនេះ ក្នុងសេចក្តីថ្លែងការណ៍រួម ក៏បានបញ្ជាក់ដែរថា នាយករដ្ឋមន្ត្រីទាំងពីរ បានឯកភាពបង្កើនការផ្លាស់ប្តូរក្រុមបញ្ញវន្ត រវាងរដ្ឋាភិបាលជប៉ុន ធនាគារខួរក្បាលជប៉ុន វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) និងវិទ្យាស្ថានកម្ពុជាសម្រាប់កិច្ចសហប្រតិបត្តិការ និងសន្តិភាព (CICP)។ នាយករដ្ឋមន្ត្រីទាំងពីរ បានចែករំលែកទស្សនៈថា នឹងបន្តកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍធនធានមនុស្ស សម្រាប់ប្រព័ន្ធរដ្ឋបាលកម្ពុជា។ ជាមួយគ្នានេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានស្វាគមន៍ការសម្រេចចិត្តរបស់ជប៉ុនក្នុងការទទួលយកពលករជំនាញ និងកម្មសិក្សាការីបច្ចេកទេសឡើងវិញ ចាប់ពីថ្ងៃទី០១ មីនា ២០២២។ ដោយឡែក នាយករដ្ឋមន្ត្រី គីស៊ីដា បានបញ្ជាក់ពីការរំពឹង

ទុកថា ពលករជំនាញ និងកម្មសិក្សាការីបច្ចេកទេសកម្ពុជាជាច្រើននឹងធ្វើដំណើរមកប្រទេសជប៉ុនជាបន្តបន្ទាប់ នៅពេលស្ថានភាពកូវីដ-១៩ ធូរស្បើយ។

គួរជម្រាបថា គិតត្រឹមឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ឱកាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋចំនួនជាង ១ ,៣០១,៦០៩ នាក់ (ស្រី ៥២៨,៧៩៩នាក់) ក្នុងនោះ ប្រទេសថៃមានចំនួន ១,២២០,១៩៧ នាក់ ប្រទេសកូរ៉េមានចំនួន ៤ ៥,៨៦០នាក់ ប្រទេសម៉ាឡេស៊ីមានចំនួន ២៣,០២៧នាក់ ប្រទេសជប៉ុនមានចំនួន ១១,៨៥៣នាក់ ប្រទេសសិង្ហបុរីមានចំនួន ៨២១នាក់ ហុងកុងមានចំនួន ២០២នាក់ និងអារ៉ាប់ប៊ីសាអូឌីតចំនួន ៤៣នាក់។ បើតាមការប៉ាន់ប្រមាណពីការប្រាក់បញ្ញើ ដែលបងប្អូនពលករបានផ្ញើជូនក្រុមគ្រួសារ ក្នុងមួយឆ្នាំៗ ប្រហែល២,៨ ប៊ីលានដុល្លារអាមេរិក ដែលតាមរយៈទឹកប្រាក់ទាំងនេះ បានចូលរួមចំណែកជំរុញដល់កំណើន សេដ្ឋកិច្ចជាតិ ហើយជីវភាពរស់នៅរបស់ក្រុមគ្រួសារពលករកាន់តែប្រសើរឡើងផងដែរ៕

## សម្តេចតេជោ ហ៊ុន សែន
## ប្រាប់ឲ្យរដ្ឋមន្ត្រីសុខាភិបាលដាក់ការដូរក្រលៀន ជាការព្យាបាលស្របច្បាប់នៅកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២១ មីនា ២០២២ដោយ Dy Bunnara

មានប្រសាសន៍នៅក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ ជាផ្លូវការមន្ទីរពេទ្យមិត្តភាព កម្ពុជា-ចិន ព្រះកុសុមៈ (ពេទ្យលោកសង្ឃ) ដែលជាមន្ទីរពេទ្យបំពាក់បរិក្ខារវេជ្ជសាស្ត្របម្រើការព្យាបាលដ៏ទំនើប នាព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ ដោយជំរុញឲ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង ប្រកាសដាក់ការដូរក្រលៀន ជាការព្យាបាលស្របច្បាប់នៅកម្ពុជា ពីព្រោះបើមិនមាននៅកម្ពុជាទេ ក៏ប្រជាពលរដ្ឋត្រូវចេញទៅព្យាបាលនៅខាងក្រៅបរទេសដែរ។ បើតាមសម្តេចតេជោ ហ៊ុន សែន កន្លងមកប្រជាពលរដ្ឋ ដែលមានបញ្ហាក្រលៀន បានចេញទៅព្យាបាលនៅក្រៅប្រទេស ដូច្នេះបើទោះបីជាមិនព្យាបាលក៏ពលរដ្ឋចេញទៅព្យាបាលនៅប្រទេសក្រៅដែរ ដែលគួរតែគិតគូរដាក់ការព្យាបាលនេះ ឲ្យក្លាយទៅជាការព្យាបាលស្របច្បាប់នៅប្រទេសកម្ពុជា។

សម្តេចតេជោបានរំលឹកកាលគ្រាកន្លងមក មានអ្នកដែលកើតជំងឺខូចក្រលៀនបានទៅព្យាបាល ហើយសាច់ញាតិស្ម័គ្រចិត្តបរិច្ចាកក្រលៀនឲ្យ ប៉ុន្តែនៅពេលនោះ ត្រូវបានសមត្ថកិច្ចទៅចាប់តែម្តង ដោយអះអាងថា ជាការជួញដូរសរីរាង្គ។ សម្តេចបញ្ជាក់ថា នៅពេលនោះ បើកុំតែមានការអន្តរាគមន៍ទាន់ពេល គឺត្រូវស្លាប់ទាំង២នាក់តែម្តង។ ជាមួយគ្នានោះ សម្តេចបានស្នើឲ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដាក់ការព្យាបាលដូរក្រលៀននេះទៅជាស្របច្បាប់តែម្តង ហើយត្រូវផ្សព្វផ្សាយជាផ្លូវការ ដើម្បីឲ្យប្រជាពលរដ្ឋបានដឹង។

បើតាមលោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានបញ្ជាក់ថា ការព្យាបាលដូរក្រលៀននេះ នៅកម្ពុជាមានច្បាប់រួចហើយ ប៉ុន្តែមិនបានផ្សព្វផ្សាយ។ ក្នុងឱកាសនោះ សម្តេចជំរុញឲ្យផ្សព្វផ្សាយច្បាប់នេះឲ្យបានទូលំទូលាយ។ ប្រមុខរដ្ឋាភិបាលបានបញ្ជាក់ថា កន្លងមកសម្តេចបានជួយមនុស្សមិនជាង១០នាក់ទេ ដើម្បីចេញទៅក្រៅដើម្បីព្យាបាលការដូរក្រលៀននេះ៕ អត្ថបទ៖ កោះកែវ

## ត្រឹម១ថ្ងៃ ពលករជាង៥០០នាក់មកពីថៃចូលកម្ពុជាវិញ រកឃើញកូវីដ៤នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២០ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ១៦:០៧

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ខណៈបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខិតជិតមកដល់នេះ នៅក្នុងភូមិសាស្រ្តខេត្តបន្ទាយមានជ័យ គ្រាន់តែរយៈពេល១ថ្ងៃ គឺនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២នេះ មានចំនួន៥០៤នាក់ (ស្រី១២២នាក់ កុមារចំនួន៤៧នាក់) ក្នុងនោះរកឃើញវិជ្ជមានកូវីដ-១៩ចំនួន៤នាក់ ។

លោកវរសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅថ្លែងថា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២នោះក្រុមការងារទទួលពលករខ្មែរត្រឡប់ពីប្រទេសថៃចូលតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ មានចំនួន២៨០នាក់(ស្រី១៤៥នាក់ កុមារ៣៧នាក់) និងរកឃើញអ្នកវិជ្ជមានកូវីដ-១៩ ចំនួន៤នាក់(ស្រី៣នាក់)។

រីឯវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ថ្លែងថា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ ប៉ុស្តិ៍សង្កែ និងច្រកព្រំដែនម៉ាឡៃបានទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាមានចំនួន១៩៧នាក់(ស្រី៩៥នាក់ កុមារ៣នាក់)។

ចំណែកលោក វ៉ាន់ ដាវ៉ាន់ ប្រធានគណៈកម្មការច្រកតំបន់ព្រំដែនបឹងត្រកួនថ្លែងថា នៅថ្ងៃជាមួយគ្នានោះក្រុមការងារបានទទួលពលករខ្មែរចំនួន២៧នាក់(ស្រី១២នាក់) ពួកគាត់ត្រឡប់មកពីប្រទេសថៃចូលមកកម្ពុជាវិញដើម្បីមកជួបជុំក្រុមគ្រួសារនាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខាងមុខនេះ ៕

## ពលករខ្មែរនៅថៃមួយចំនួនបន្តរស់នៅលំបាកដោយសារវិបត្តិជំងឺកូវីដ១៩អូសបន្លាយពេល

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី2022-03-20

ពលករខ្មែរមួយចំនួនដែលធ្វើការនៅប្រទេសថៃបន្តមានជីវភាពលំបាក ដោយសារគ្មានការងារធ្វើទៀងទាត់។ អំឡុងបុណ្យឆ្នាំប្រពៃណីខ្មែរខាងមុខនេះ ពួកគេនឹងមិនបានទៅលេងស្រុកកំណើតនោះទេ ព្រោះគ្មានប្រាក់ធ្វើដំណើរទៅកម្ពុជា។ ពលករខ្មែរធ្វើការនៅប្រទេសថៃលើកឡើងថា ជីវភាពរបស់ពួកគេជួបការលំបាកខ្លាំងនៅរយៈពេល២ខែចុងក្រោយនេះ ដោយសារការរាតត្បាតជំងឺកូវីដ១៩ បានផ្ទុះឡើងជាថ្មីនៅប្រទេសថៃ។

ប្រជាពលរដ្ឋមានស្រុកកំណើតនៅខេត្តឧត្តរមានជ័យម្នាក់ លោកស្រី ភី រិទ្ធ ប្រាប់វិទ្យុអាស៊ីសេរីនៅព្រឹកថ្ងៃទី២០ មីនា ថា លោកស្រីមិនបានធ្វើការងារជាប់លាប់ប្រមាណ២ខែមកហើយ ដោយសារផ្ទុះការរាតត្បាតជំងឺកូវីដ១៩ នៅតំបន់ដែលលោកស្រីធ្វើការ។ ស្ត្រីវ័យ៥១ឆ្នាំដែលធ្វើការរោងចក្រផលិតជីនៅខេត្តអយុធ្យា (Ayutthaya ) រូបនេះបន្តថា សព្វថ្ងៃនេះលោកស្រីធ្វើការបាន២ថ្ងៃក្នុងមួយខែ និងបានប្រាក់ឈ្នួលចំនួន៣០០បាតស្មើនឹងជាង៩ដុល្លារប៉ុណ្ណោះ។ បញ្ហានេះបានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារលោកស្រី ហើយលោកស្រីបានខ្ចីប្រាក់ពីថៅកែអស់ជាង៥ពាន់បាត(៥.០០០) ឬស្មើនឹងប្រមាណ១៦០ដុល្លារហើយ ដើម្បីទិញស្បៀងអាហារហូបចុកប្រចាំថ្ងៃ៖ «ឆ្នាំនេះដូចវាយ៉ាប់តែហ្មងដូចថា ជីវភាពលូតទៅមុខមិនរួចក្រោយមិនរួច ចិត្តខ្ញុំចង់ទៅជួបប្ដីជួបកូនចង់ងាប់ហើយ។ ខ្ញុំមកចោលកូនតាំងពីកូននៅតូចឥឡូវឡើងពេញកម្លោះបាត់ហើយមិនទាន់បានជួបផង ចាប់ពីកូវីដមកហ្នឹង។ វាអារឿងការងារអត់មានហ្មងជីវភាពវាយ៉ាប់ទៅ ចាប់តាំងពីទំនិញឡើងថ្លៃមកវាអត់ទិញមកសាងឱ្យខ្មែរយើងធ្វើទៀតអីចឹង។ នៅច្រើនណាស់ខ្មែរយើងម៉ាជួរខេត្តនេះបើរាប់រៀបវិញមិនអស់កន្លែងនៅទេ»។ លោកស្រីបន្តថា នៅតំបន់លោកស្រីធ្វើការមានពលករខ្មែរប្រមាណ២ពាន់នាក់ស្នាក់នៅ ហើយពួកគាត់អត់ការងារធ្វើដូចគ្នា។ ក្នុងនោះមានពលករខ្លះបានទៅស៊ីឈ្នួលឱ្យធ្វើការតាមផ្ទះឱ្យជនជាតិថៃបានប្រាក់ឈ្នួលបន្តិចបន្តួចដើម្បីប្រាក់ដោះស្រាយជីវភាពប្រចាំថ្ងៃ។

ស្រដៀងគ្នានេះដែរ ពលករធ្វើការនៅប្រទេសថៃម្នាក់ទៀត លោក ជឿន ស៊ីណោត រៀបរាប់ថា លោកមិនបានធ្វើការងារជាប់លាប់រយៈពេលជាង២ខែមកហើយ ដោយសារការរាតត្បាតជំងឺកូវីដ១៩ឆ្លងចូលក្នុងសហគមន៍។ ពលករនៅចំការមៀនវ័យ៣០ឆ្នាំរូបនេះបន្តថា នៅកន្លែងលោកធ្វើការក្នុងខេត្តច័ន្ទបូរី (Chanbori) មានពលករខ្មែរប្រមាណ១០គ្រួសារ រកប្រាក់មិនបានផ្ញើទៅឱ្យឪពុកម្ដាយនៅកម្ពុជានោះទេ ពោលគឺពួកលោកធ្វើការបានប្រាក់ឈ្នួលប្រមាណ ៤ពាន់បាត ឬស្មើនឹង១២៥ដុល្លារសម្រាប់ដោះស្រាយជីវភាពនៅក្នុងប្រទេសថៃប៉ុណ្ណោះ៖ «មិនដឹងធ្វើម៉េចបើយើងចេញទៅផ្ទះក៏វាមិនកើតអីចឹង ចេញទៅក៏វាអត់លុយអត់អីលំបាកចេញណាស់។ សុខចិត្តនៅនេះតេះៗឱ្យបានធូរចិត្តចាំទៅផ្ទះ បើទៅផ្ទះមានអីធ្វើ ខ្ញុំនៅជាមួយម៉ែមួយអីដែរហ្នឹង ហើយមួយផ្ទះប្រាំប្រាំមួយនាក់ណោះ។ នៅណេះយើងមានថៅកែអីចឹងយើងអាចខ្ចីគេខ្លះចាយតិចៗ បើយើងនៅខ្មែរយើងមានថៅកែមានអីណាមានដីមានអីដូចគេណា។ លំបាកណាស់យើងសម្រាកអីចឹងលំបាកដែរបើអត់មានការងារធ្វើចេះតែចង់ទៅធ្វើទៅព្រោះខ្ញុំត្រូវការចាយវាយច្រើនផង ទឹកដោះគោកូនដល់ទៅ២នាក់ណោះ»។

ដោយឡែកពលករធ្វើការសំណង់នៅទីក្រុងបាងកកឯណោះវិញពួកគេក៏មានជីវភាពខ្វះខាតដែរ ដោយសារការរាតត្បាតជំងឺកូវីដ១៩។ លោកស្រី ជឿន ស្រីម៉ិច ថ្លែងថា នៅកន្លែងធ្វើការរបស់លោកស្រីមានពលករខ្មែរជិត ១០០នាក់អត់ការងារធ្វើជាង១សប្ដាហ៍ហើយ ដោយសារមានពលករខ្លះបានឆ្លងជំងឺកូវីដ១៩។លោកស្រីបន្តថា នៅថ្ងៃទី២០ មីនា ខាងអង្គការសង់ត្រាល់បានផ្ដល់ស្បៀងអាហារមួយចំនួនជូនដល់ពួកលោកស្រី ក្រោយពីពួកគាត់បានស្នើសុំ។ ក្រុមពលករទាំងនេះថ្លែងថា ពួកគាត់នឹងមិនបានទៅលេងបុណ្យចូលឆ្នាំប្រពៃណីខ្មែរនៅពេលខាងមុខនោះទេ ព្រោះជីវភាពខ្វះខាត ហើយគ្មានប្រាក់ធ្វើដំណើរឆ្លងដែនទៅកម្ពុជា។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ដើម្បីសុំអត្ថាធិប្បាយជុំវិញទុក្ខលំបាករបស់ពលករទាំងនោះទេនៅថ្ងៃទី២០ មីនា។ ប៉ុន្តែ ហ្វេសប៊ុកស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកកបានបង្ហោះសារពីការចុះជួបសំណេះសំណាលនិងសួរសុខទុក្ខពលករខ្មែរដែលស្នាក់នៅ និងធ្វើការនៅខេត្តឈុនបុរី (Chunbori) ជាប់ទីក្រុងបាងកកកាលពីថ្ងៃទី២៣ មករា។ មន្ត្រីស្ថានទូតបានអប់រំពន្យល់ណែនាំអំពីច្បាប់ការពារសិទ្ធិពលករ និងសិទ្ធិទទួលបានអត្ថប្រយោជន៍ផ្សេងៗចំពោះពលករដែលធ្វើការងារស្របច្បាប់ និងណែនាំឱ្យពួកគាត់ចេះវិធីបង្ការកុំឱ្យឆ្លងជំងឺកូវីដ១៩។

ជុំវិញរឿងនេះ មន្ត្រីសិទ្ធិការងារនៃអង្គការសង់ត្រាល់ (Central) ប្រចាំប្រទេសថៃ លោក លឹង សុផុន សង្កេតឃើញថា ជីវភាពរបស់ពលករអំឡុងពេលនេះលំបាកគ្រប់ទីកន្លែង ហើយពលករមួយចំនួនចាប់ផ្ដើមធុញទ្រាន់នឹងស្ថានភាពអូសបន្លាយវិបត្តិជំងឺកូវីដ១៩ ដែលធ្វើឱ្យពួកគាត់ខកខានទៅលេងកម្ពុជាអស់រយៈពេលជាង២ឆ្នាំហើយ។ លោកបន្តថា រយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ មានពលករច្រើននាក់បានធ្វើដំណើរទាំងប្រថុយប្រថានត្រឡប់ទៅកម្ពុជាវិញ ដោយសារពួកគាត់មិនអាចអត់ទ្រាំនឹងការលំបាកនៅប្រទេសថៃបន្តទៅទៀតបាន៖ «ជាក់ស្ដែងនៅតាមមិនថាឡើយកន្លែងខ្ញុំនៅទេសូម្បីទេ កន្លែងដទៃផ្សេងៗដែលខ្ញុំចុះទៅហ្នឹងឃើញថា ពលករមានការឆ្លងជំងឺហើយមានការលំបាកក្នុងការរស់នៅ។ ខ្ញុំចង់បានមន្ត្រីពាក់ព័ន្ធនឹងពលករខ្មែរនៅថៃហ្នឹងជួយរកវិធានការណាមួយសម្រាលទុក្ខលំបាករបស់ពួកគាត់នៅពេលដែលពួកគាត់ប្រឈមនឹងបញ្ហាបច្ចុប្បន្នហើយយើង ដឹងហើយបញ្ហាប្រឈមរបស់ពួកគាត់មានអីខ្លះហ្នឹងខ្ញុំជឿថា មន្ត្រីស្ថានទូតនិងមន្ត្រីពាក់ព័ន្ធហ្នឹងខ្ញុំជឿថាពួកគាត់យល់ដឹងថា ក្រុមពលករគាត់មានបញ្ហាអី»។

លោក លឹង សុផុន បន្ថែមទៀតថា សព្វថ្ងៃនេះមានពលករខ្មែររាប់ម៉ឺននាក់អស់សុពលភាពទិដ្ឋាការនិងឯកសារធ្វើការងារស្របច្បាប់ ហើយពួកគាត់មិនបានបន្តសុពលឯកសារទាំងនោះឡើយ ដោយសារគ្មានប្រាក់បណ្ដាលមកពីអត់ការងារធ្វើទៀងទាត់អស់ជាច្រើនខែមកហើយ។ លោកជឿជាក់ថា ដើម្បីសម្រួលដល់ពលករទាំងនោះ មាន

តែរដ្ឋាភិបាលនិងស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃជួយអន្តរាគមន៍ទៅអាជ្ញាធរថៃដើម្បីសម្រួលឱ្យពួកគាត់បន្តស្នាក់នៅប្រទេសថៃដោយមិនមានការចាប់ចងអំឡុងពេលនេះ។ របាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការងារស្របច្បាប់និងមិនស្របច្បាប់ជិត២លាននាក់ធ្វើការងារនៅប្រទេសថៃ៕

## ពលកររាប់រយនាក់ សម្រុកចេញ ពីស្រុកថៃចូលមកស្រុកខ្មែរ តាមច្រករបៀងដើម្បីចូលរួមបុណ្យចូលឆ្នាំខ្មែរខាងមុខ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២១ មីនា ២០២២ដោយ deth leng

ក្នុងភូមិសាស្ត្រប៉ុស្តិ៍សង្កែ ក្នុងចំណុចកំពង់បងសល់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ក្នុង១ថ្ងៃៗមានពលករ រាប់រយនាក់ទាំងក្មេង ចាស់ ប្រុស ស្រី នាំគ្នាសម្រុកចេញពីស្រុកថៃចូលមកស្រុកខ្មែរ តាមច្រករបៀងនេះ ដើម្បីមកចូលរួមបុណ្យចូលឆ្នាំខ្មែរខាងមុខ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានឱ្យដឹងនៅថ្ងៃទី ២១នេះថា លោកបានឲ្យចុះ សហការជាមួយ កម្លាំងប៉ុស្តិ៍ស្ពានម៉ាឡៃ កម្លាំងយោធាត្រួតពិនិត្យពលកររាប់រយនាក់ នាំគ្នាសម្រុកចេញពីស្រុកថៃចូលមកស្រុកខ្មែរ តាមច្រករបៀង ដើម្បីមកចូលរួមបុណ្យចូលឆ្នាំខ្មែរខាងមុខ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនបានពលករបានចំនួន ១៩៧នាក់ ស្រី៩៥នាក់ កុមារ៣នាក់ វិលត្រឡប់ពីប្រទេសថៃ តាមភូមិសាស្ត្រប៉ុស្តិ៍ចំបក់នេះ។ លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា ពលករទាំង ១៩៧នាក់ បានប្រគល់ទៅឲ្យក្រុមគ្រូពេទ្យមន្ទីរពេទ្យបង្អែកម៉ាឡៃសន្តិភាពពិនិត្យ និងធ្វើតេស្តរកមេរោគកូវីដ-១៩ ក្រោយពីធ្វើតេស្តរហ័សរួចទាំង១៩៧នាក់ នេះអវិជ្ជមានទាំងអស់។ ក្នុងនោះបានធ្វើការណែនាំដល់ពលករទាំង ១៩៧ នាក់នោះស្តីពីការឆ្លងរាលដាលរបស់ កូវីដ១៩ រួចធ្វើកិច្ចសន្យាកុំឱ្យវិលទៅប្រទេសថៃទៅរកការងារធ្វើដោយខុសច្បាប់បន្តទៀតនិងឲ្យវិញត្រឡប់ទៅភូមិកំណើតរៀងខ្លួន។

កម្លាំងប៉ុស្តិ៍ចំបក់ នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកប៉ុស្តិ៍ចំបក់នៃវរសេនាតូចលេខ៨១៥ បានសហការជាមួយកម្លាំងផ្នែកសឹករងស្រុកម៉ាឡៃ និងកម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំបឹងបេងធ្វើការត្រួតពិនិត្យ ប្រជាពលរដ្ឋថៃ រថយន្តថៃដឹកដែលបានទំនិញឆ្លងកាត់ចេញចូលនៅច្រកទ្វារតំបន់ម៉ាឡៃ ដើម្បីវិធីបង្កាការពារការរាលដាលនៃជំងឺកូវីដ១៩ នៅច្រកទ្វារតំបន់ម៉ាឡៃ ស្រុកម៉ាឡៃផងដែរ៕ អត្ថបទ៖ វ៉ាន់ ណាង

# ថ្ងៃទី២៣ ខែ មីនា ឆ្នាំ២០២២

## នារីថៃម្នាក់ ប្រឌិតរឿងបន្លំឈ្មោះកម្ពុជា ត្រូវតុលាការខេត្តស្រះកែវ កាត់ទោសដាក់គុក ៦ខែ

https://kohsantepheapdaily.com.kh/ ២១ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ១៧:៥០

ទីក្រុងបាងកក ៖ ករណីស្ត្រីជនជាតិថៃម្នាក់ បានប្រឌិតរឿងក្លែងក្លាយដែលថា ក្រុមជនជាតិចិន ចាប់បង្ខាំងបូមឈាម និងប៉ុនប៉ងវះយកសរីរាង្គ នៅខេត្តព្រះសីហនុ ប្រទេសកម្ពុជានោះ ត្រូវបានតុលាការខេត្តស្រះកែវ កាត់ទោសឲ្យជាប់ពន្ធនាគារ រយៈពេល៦ខែ ដោយមិនមានការលើកលែងទោសឡើយ នេះបើយោងតាមសារព័ត៌មានថៃ khaosod ចុះផ្សាយកាលពីថ្ងៃទី២០ មីនា ២០២២ ។

សូមជម្រាបថា នៅក្នុងសន្និសីទកាសែតមួយ កាលពីថ្ងៃទី១៨ មីនា ២០២២ នាង Areeya Komkratok អាយុ២៥ឆ្នាំ បានសារភាពទទួលស្គាល់កំហុស និងធ្វើការសុំទោសជាសាធារណៈ ចំពោះមុខមន្ត្រីនគរបាលថៃ និងមន្ត្រីកម្ពុជា ។ នាង អារីយ៉ា បានសារភាពកំហុសថា នាងបានប្រឌិតរឿងទាំងមូល ដោយសារតែនាងចង់ត្រឡប់ទៅ

ប្រទេសថៃវិញ ជាបន្ទាន់ ។ នាង អារីយ៉ា ធ្វើការជាអ្នកគ្រប់គ្រងអនឡាញ រួមនឹងជនជាតិថៃ ៧នាក់ផ្សេងទៀត ដែលត្រូវបានគេល្បួងឲ្យមកធ្វើការដោយខុសច្បាប់នៅកម្ពុជា ត្រូវបានជួយសង្គ្រោះ និងនាំត្រឡប់ទៅប្រទេសថៃវិញ តាមខេត្តស្រះកែវ កាលពីថ្ងៃទី៩ មីនា ។

ស្នងការរងនគរបាលថៃ លោកឧត្តមសេនីយ៍ Roy Ingkapairote បានបញ្ជាក់ថា អារីយ៉ា ប្រឌិតព័ត៌មានក្លែងក្លាយ ដោយសារតែនាងចង់បានជំនួយបន្ទាន់ ដើម្បីត្រឡប់ទៅប្រទេសថៃវិញ ។ លោកបានថ្លែងបន្តថា ការផ្តល់ព័ត៌មានមិនពិតបានប៉ះពាល់ដល់ទំនាក់ទំនងល្អ រវាងកម្ពុជា និងថៃ ។ ការភូតកុហកនេះ វាមិនត្រឹមតែប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរបស់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ វាប៉ះពាល់ដល់មន្ត្រីថៃ ដែលអាចត្រូវបានគេមើលឃើញថា ជាការធ្វេសប្រហែសក្នុងការជួយជនជាតិថៃរបស់ខ្លួនទៀត ប៉ុន្តែទីបំផុត មន្ត្រីសមត្ថកិច្ចទាំង២ប្រទេសបានសហការគ្នា ស៊ើបអង្កេតរហូតអាចបញ្ជាក់ការពិតទាំងអស់ ។ ថ្មីៗនេះ ស្នងការដ្ឋាននគរបាលខេត្តស្រះកែវ បាននាំខ្លួននាង អារីយ៉ា ទៅឲ្យមន្ត្រីស៊ើបអង្កេត ។ ហើយមន្ត្រីនគរបាលប៉ុស្តិ៍អារញ្ញ ក៏បានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តស្រះកែវ កាលពីថ្ងៃទី១៩ ខែមីនា មុននឹងតុលាការសាលាដំបូងខេត្ត សម្រេចផ្តន្ទាទោសនាង អារីយ៉ា ឲ្យជាប់ពន្ធនាគារ ៦ខែ ដោយមិនមានការលើកលែងទោស ។

ជុំវិញរឿងប្រឌិតរបស់នាង អារីយ៉ា រូបនេះ ត្រូវបានសារព័ត៌មានថៃមួយចំនួន យកទៅចុះផ្សាយកាលពីថ្ងៃទី១១ មីនា ដោយដកស្រង់សម្ដីរបស់ស្ត្រីជនជាតិថៃម្នាក់នោះថា ត្រូវគេល្បួងទៅធ្វើការខុសច្បាប់ទៅប្រទេសកម្ពុជា។ នាងថា ត្រូវជនជាតិចិន វាយដំ ចាប់ឃុំខ្លួន និងបង្អត់អាហារទុកឱ្យស្រេកឃ្លាន បន្ទាប់ពីបដិសេធមិនព្រមធ្វើការ ។ ស្ត្រីរូបនោះបន្តថា ត្រូវគេបញ្ជូនពីតំបន់មួយ ទៅតំបន់មួយទៀត ហើយប្រាប់ឱ្យទាក់ទងទៅគ្រួសារនាងនៅប្រទេសថៃ ដើម្បីជំរិតទារយកប្រាក់ ជាថ្នូរនឹងការដោះលែងនាង ។ នៅក្នុងអំឡុងពេលឃុំខ្លួនក្នុងបន្ទប់នោះ នាងអះអាងថា ត្រូវគេឆក់ចរន្តអគ្គិសនី និងមានឧបករណ៍វះកាត់ជាច្រើន បន្ទាប់មកក្រុមឧក្រិដ្ឋជនចិន បានបូមឈាមនាង៣ទៅ៤កំប្លោក ហើយធ្ងន់ធ្ងរជាងនេះ គេប្រុងនឹងយកនាងទៅវះកាត់ដើម្បីយកសរីរាង្គខាងក្នុង ប៉ុន្តែនាងរត់គេចខ្លួន ។ នាងថែមទាំងបង្កើតគណនីហ្វេសប៊ុកក្លែងក្លាយ ក្នុងគោលបំណងទាមទារជំនួយបន្ទាន់ពីមន្ត្រីថៃ ។ បន្ទាប់មក សមត្ថកិច្ចបានជួយសង្គ្រោះ និងបញ្ជូនទៅមន្ទីរពេទ្យមួយ នៅក្រុងប៉ោយប៉ែត ដើម្បីព្យាបាលរហូតដល់នាងមានកម្លាំងឡើងវិញ ។ ត្រូវបានអាជ្ញាធរថៃនៅព្រំដែន បានសម្របសម្រួលជាមួយមន្ត្រីកម្ពុជា បញ្ជូនរូបនាង និងជនជាតិ៨ទៀត ទៅប្រទេសវិញ ដោយសុវត្ថិភាព តាមស្ពានមិត្តភាពកម្ពុជា-ថៃ ក្នុងខេត្តស្រះកែវ កាលពីថ្ងៃទី៩ មីនា កន្លងទៅនេះ ។

## រដ្ឋាភិបាលកម្ពុជាផ្តល់បណ្ណការងារ ដល់ពលករជំនាញប្រទេសឆែកផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈជាង១០០នាក់

https://kohsantepheapdaily.com.kh/ ភ្នំពេញ២២ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ១៥:១២

រាជធានីភ្នំពេញ ៖ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ប័ណ្ណការងារដល់ពលករជំនាញរបស់ប្រទេសឆែក ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈជាង១០០នាក់ គិតមកដល់ពេលបច្ចុប្បន្ន ។ នេះបើតាមការបញ្ជាក់របស់រដ្ឋមន្ត្រីក្រសួងការងារ ។ ក្នុងជំនួបពិភាក្សាការងារផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការផ្នែកបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) របស់កម្ពុជាទាំងលើការបណ្តុះបណ្តាលសមត្ថភាព សិស្ស-និស្សិតរួមនឹងការបំពាក់សម្ភារបរិក្ខានានា ជាការជួយលើកកម្ពស់ទៅលើការបណ្តុះបណ្តាលផ្នែកនេះ ឲ្យស្របតាមការវិវឌ្ឍយ៉ាងរហ័សនៃបច្ចេកវិទ្យារបស់ពិភពលោកជាមួយលោក Martin Vávra (ម៉ាទីន វ៉ាវ៉ា) ឯកអគ្គរដ្ឋទូតឆែកប្រចាំកម្ពុជា នាព្រឹកថ្ងៃទី២២ ខែមីនានេះ នៅទីស្តីការក្រសួងឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានលើកឡើងថា ក្នុង

កិច្ចការងារការទូតរបស់លោកទូត ពិតជាបានធ្វើឲ្យទំនាក់ទំនងរវាងប្រជាជន និងប្រជាជនក៏ដូចជា រដ្ឋាភិបាលប្រទេសយើងទាំងពីរកម្ពុជា-ឆែក មានភាពស្និទស្នាល បង្កើនកិច្ចសហប្រតិបត្តិការទេសយើងទាំងពីរធ្លាប់មានទំនាក់ទំនងការទូតជាមួយគ្នាជាយូរលង់ណាស់មកហើយ ។

ឯកឧត្តមក៏បានអរគុណដល់រដ្ឋាភិបាលឆែក ដែលបានផ្ដល់ជំនួយជួយដល់កម្ពុជា នាពេលកន្លងមកជំនួយអស់ទាំងនេះបានរួមចំណែកឲ្យកម្ពុជាបន្តការអភិវឌ្ឍប្រទេសរបស់ខ្លួនឲ្យមានការរីកចម្រើនបន្តទៅមុខទៀត ។ ឯកឧត្តមរដ្ឋមន្ត្រីបានឲ្យដឹងថា អ្នកជំនាញការរបស់ឆែកក៏បានមកបំពេញកិច្ចការងារនៅក្នុងប្រទេសកម្ពុជា ដែលគិតមកដល់ពេលនេះ ក្រសួងការងារបានផ្ដល់នូវបណ្ណការងារដល់ពលករជំនាញ ក៏ដូចជាអ្នកជំនាញការរបស់ឆែកប្រមាណជាង១០០នាក់មកហើយ ដោយពួកគេនឹងទទួលបានសិទ្ធគាំពារនានា ដូចពលរដ្ឋកម្ពុជាដែរ»។ ឯកឧត្តមរដ្ឋមន្ត្រី ស្វាគមន៍ដល់អ្នកជំនាញការទាំងនេះដែលបានមកបំពេញការងារនៅក្នុងប្រទេសកម្ពុជា ហើយក៏ចាត់ទុកថាជាកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រជាជនផងដែរ ។ ជាមួយគ្នានោះដែរ ឯកឧត្តមរដ្ឋមន្ត្រី បញ្ជាក់ថា កន្លងមករាជរដ្ឋាភិបាលកម្ពុជា ក៏មានកិច្ចសហប្រតិបត្តិកា រជាមួយអង្គការភីន ឬ PIN (People In Need) ដែលជាអង្គការមិនមែនរដ្ឋាភិបាល និងមិនរកប្រាក់ចំណេញនៃប្រទេសឆែក ដែលអនុវត្តលើគ ម្រោងជំនួយមនុស្សធម៌, គម្រោងអភិវឌ្ឍន៍រយៈពេលវែង, កម្មវិធីអប់រំ, និងកម្មវិធីសិទ្ធិ មនុស្សនៅតាមតំ បន់ដែលមានវិបត្តិនៅទូទាំងសកលលោក និងបានចូលមកកម្ពុជា ពីឆ្នាំ ២០០៨ ។

ចំណែកលោកទូតឆែកប្រចាំកម្ពុជា ក៏បានវាយតម្លៃខ្ពស់ចំពោះ ទំនាក់ទំនងការទូតរបស់ប្រទេសទាំងពីរ ហើយរដ្ឋាភិបាលឆែកបានផ្ដល់នូវជំនួយក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ជាបន្តបន្ទាប់ ។ ដោយឡែកចំពោះសកម្មភាពកិច្ចសហប្រតិបត្តិលើការបណ្តុះបណ្តាលផ្នែកបច្ចេកទេស និងវិជ្ជាជីវៈនេះទៀតសោត លោកទូត ចង់ឲ្យគម្រោងនេះមាននិរន្តរ៍ភាព និងឯកឧត្តមទូត ចង់បានការបញ្ជាក់បន្ថែមពីឯកឧត្តមរដ្ឋមន្ត្រីថា តើក្រសួងចង់ឲ្យរដ្ឋាភិបាលឆែកបន្តជួយលើផ្នែកTVET នេះក្នុងកម្រិតណាបន្តទៀត ។

ក្នុងជំនួបនោះដែរ ឯកឧត្តមអ៊ិត សំហេង ចង់ឲ្យមានដំណើរទស្សនកិច្ចរវាងគ្រូ និងគ្រូរបស់ប្រទេសយើងទៅវិញទៅមក ដើម្បីផ្លាស់ប្តូរនូវបទពិសោធន៍ ចែករំលែកនូវចំណេះដឹងក៏ដូចជាកម្មវិធីសិក្សា លើការបណ្តុះបណ្តាលផ្នែកធនធានមនុស្សនេះ ឲ្យកាន់តែប្រសើរ និងដើរឲ្យទាន់នូវការរីកចម្រើនបច្ចេកវិទ្យារបស់ពិភពលោក ។ ឆ្លើយតបទៅនឹងសំណើ របស់ឯកឧត្តមរដ្ឋមន្ត្រី ឲ្យមានការរៀបចំ ទស្សនកិច្ចសិក្សារវាងគ្រូ និងគ្រូរបស់ប្រទេសទាំងពីរ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកនូវចំណេះដឹងផងនោះ លោកទូតរីករាយនូវសំណើនេះ និងសូមឲ្យខាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបន្តធ្វើកិច្ចការនេះជាមួយស្ថានទូត ដើម្បីដាក់ស្នើសុំទៅ រដ្ឋាភិបាលឆែកឲ្យមាន កិច្ចសហប្រតិបត្តិការលើកិច្ចការងារទាំងនេះឲ្យបានកាន់តែលឿន៕

## សមត្ថកិច្ចបង្កើនសកម្មភាព ត្រៀមទប់ស្កាត់ កូវីដ ខណៈពលករខ្មែរមកពីថៃ សម្រុកមកលេងស្រុកកំណើតមុនចូលឆ្នាំខ្មែរ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២២ មីនា ២០២២ដោយ deth leng

ស្នងការនគរបាលខេត្តបន្ទាយមានជ័យលោក សិទ្ធិ ឡោះ បានបញ្ជាឱ្យកម្លាំងនគរបាលតាមព្រំដែន ត្រៀមបង្ការទប់ស្កាត់ការឆ្លងជំងឺកូវីដ១៩ ខណៈដែលពលករខ្មែររាប់រយនាក់ក្នុង១ថ្ងៃៗ បានធ្វើដំណើរមកពីប្រទេសថៃត្រឡប់ចូលស្រុកកំណើតវិញតាមច្រករបៀងផ្សេងៗ នៅមុនពេលចូលឆ្នាំខ្មែរ។ នៅយប់ថ្ងៃទី ២១ ខែមីនា កម្លាំងការពារព្រំដែនម៉ាឡៃ បានឃាត់ពលករខ្មែរឬ ចំនួន ១១៧ នាក់។ បើតាមលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះសព្វថ្ងៃនេះ ជំងឺកូវីដ១៩ កំពុងរាតត្បាតក្នុងប្រទេសកម្ពុជា ដូច្នេះគ្រប់អង្គភាពនគរបាលទាំងអស់ ត្រូវត្រៀមសម្រាប់

អន្តរាគមន៍ ដោះស្រាយទប់ស្កាត់ នូវការចម្លងមេរោគកូវីដ១៩ ពីពលករខ្មែរ នៅប្រទេសថៃ ជិតចូលឆ្នាំ គាត់វិលមកស្រុកខ្មែរដើម្បីចូលរួមបុណ្យចូលឆ្នាំ ខ្មែរនៅពេលខាងមុខនេះ។

លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ត្រូវត្រួតពិនិត្យស្រាវជ្រាវរកឲ្យឃើញពលករខ្មែរណាដែលសង្ស័យថា មានផ្ទុកជំងឺកូវីដ-១៩ និងអ្នកប៉ះពាល់ដោយផ្ទាល់ ដោយប្រយោល ដើម្បីប្រគល់ជូនក្រុមការងារសុខាភិបាលធ្វើតេស្តរហ័ស។ ត្រូវពង្រឹងកម្លាំងទប់ស្កាត់បទល្មើស គ្រប់ប្រភេទតាមខ្សែបន្ទាត់ព្រំដែន ពលករខ្មែរ រួមទាំងជនបរទេសឆ្លងដែន ចេញ-ចូល ដោយខុសច្បាប់ត្រូវឃាត់ធ្វើចត្តាឡីស័ក ។ ក្នុងករណីជនបរទេសមកពីថៃមិនទាន់ចូលដល់កម្ពុជានោះ ត្រូវឲ្យត្រឡប់ទៅវិញតាមផ្លូវដើម ដោយសហការជាមួយកម្លាំងសមត្ថកិច្ចចម្រុះ និងក្រុមការងារសុខាភិបាល៕ អត្ថបទ៖ វ៉ាន់ ណាង

## សមត្ថកិច្ចថៃ ចាប់ពលករខ្មែរ ២២៨ នាក់ បញ្ជូនមកកម្ពុជាវិញ

https://www.gntimes.com/ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២

ខេត្តបាត់ដំបង៖ ដោយសាតែការប្រថុយប្រថានតាមជនជាមេខ្យល់ បាននាំឲ្យប្រជាពលរដ្ឋខ្មែរជួបផលលំបាកគ្រប់ពេល ខណៈដែលពួកគេចូលក្នុងប្រទេសថៃរកការងារធ្វើដោយខុសច្បាប់ហើយក៏ត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូនមកកម្ពុជាវិញជាបន្តបន្ទាប់ ។ ជាក់ស្តែងពលករខ្មែរ ២២៨ នាក់ទៀតហើយត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូនមកកម្ពុជាវិញ នៅថ្ងៃទី ១៨ ខែ មីនា នេះ ក្រោយពួកគេលួចចូលទៅរកការងារធ្វើដោយខុសច្បាប់ក្នុងប្រទេសថៃ ។

លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩ បានឲ្យដឹងថា ពលករខ្មែរដែលភាគីថៃបញ្ជូនមកនាពេលនេះ លោកបានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យទៅទទួលពួកគេនៅចំណុចច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ លោកបន្តថា បន្ទាប់ពីសមត្ថកិច្ចធ្វើការសាកសួរកត់ឈ្មោះចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួចមក សមត្ថកិច្ចបានប្រគល់ឲ្យក្រុមគ្រូពេទ្យដើម្បីពិនិត្យលើសុខភាព ។ ក្រុមគ្រូពេទ្យបានបញ្ជាក់ឲ្យដឹងថា ពលករខ្មែរដែលមានសរុប ២២៨ នាក់ ក្នុងនោះស្រី ៩៣នាក់ ក្មេង ៤២នាក់ (ស្រី ២១នាក់) ក្រោយពីក្រុមគ្រូពេទ្យធ្វើតេស្តរហ័សជាលទ្ធផលវិជ្ជមានកូវីដ-១៩ ចំនួន ២៣នាក់ ស្រី ១១នាក់ ក្មេង ២នាក់ (ស្រី ១នាក់) បានបញ្ជូនទៅព្យាបាលនៅមណ្ឌលស្រុកសំពៅលូន ។ ដោយឡែកពលករ ២៧នាក់ ស្រី ១១នាក់ ក្មេង ៥នាក់ (ស្រី ៣នាក់) បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ ៩ ស្រុកសំពៅលូន ខេត្តបាតដំបង ។ ចំណែកពលករដែលមានកាតចាក់វ៉ាក់សាំង ១៧៨ នាក់ ស្រី ៧០ នាក់ក្មេង ៣៥នាក់ (ស្រី ១៧ នាក់) ក្នុងនោះបានចាក់វ៉ាក់សាំងឲ្យក្មេងចាប់ពីអាយុ៥ ឆ្នាំដល់ ១៨ ឆ្នាំ ចំនួន ៣០នាក់ ស្រី ១៨នាក់ ក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕ ដោយ៖ សួន សុខហៃ

# ថ្ងៃទី២៤ ខែ មីនា ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង ជំរុញឲ្យអាជ្ញាធរមូលដ្ឋាន ត្រូវបំផុសឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងការការពារ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

https://cen.com.kh/ Posted ByPen Srey NeatMarch 23, 2022

ព្រៃវែង៖ ស្តីពី ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព បើគ្មានការចូលរួមពីប្រជាពលរដ្ឋសហការជាមួយសមត្ថកិច្ចនោះទេ សមត្ថកិច្ចក៏មិនអាចអនុវត្តគោលការណ៍នេះប្រកបដោយជោគជ័យបានដែរ ដូច្នេះហើយបានជា សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំមន្ត្រីរាជការ កងកម្លាំងទាំងអស់បង្កើនការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឲ្យបានល្អប្រសើរគ្រប់មូលដ្ឋាន ជាពិសេស ត្រូវបំផុសឲ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងការអនុវត្តគោលនយោបាយ «ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព» ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពលួច ឆក់ ប្លន់ ល្បែងស៊ីសងខុសច្បាប់ ក្រុមក្មេងទំនើងគ្រប់មូលដ្ឋាន។ ការជំរុញបែបនេះរបស់ សម្តេចក្រឡាហោម ស ខេង ធ្វើឡើង ក្នុងឱកាសសម្តេចអញ្ជើញបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រៃវែង នាថ្ងៃ២២ ខែមីនា ឆ្នាំ ២០២២។

ជាមួយនឹងការជំរុញនេះ សម្តេចក្រឡាហោម ក៏បានកោតសរសើរ និងការវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំមន្ត្រីរាជការ បុគ្គលិក កងកម្លាំង មានសមត្ថកិច្ចនានា និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានគ្រប់លំដាប់ថ្នាក់នៃខេត្តព្រៃវែង និងខេត្តផ្សេងទៀត ដែលបានខិតខំប្រឹងប្រែង រួមគ្នាយ៉ាងសកម្មក្នុងការបំពេញតួនាទី ភារកិច្ចប្រកបដោយស្មារតី ទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបាននូវសមិទ្ធផលក្នុងការធានាថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ ការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលសំដៅ លើកកម្ពស់ជីវភាពរស់នៅ និងបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

សម្តេចក្រឡាហោម ស ខេង ក៏បានជំរុញផងដែរថា រដ្ឋបាលខេត្ត អាជ្ញាធរមូលដ្ឋាន ត្រូវបន្តខិតខំចូលរួមក្នុងការដោះស្រាយជីវភាពរបស់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ពីវិបត្តិ នៃជំងឺកូវីដ១៩ ការដោះស្រាយក្តីកង្វល់ សំណើ សំណូមពរ និងបញ្ហាប្រឈមនានានៅមូលដ្ឋាន ជាពិសេស ការចូលរួមចាក់វ៉ាក់សាំង ទប់ស្កាត់ប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ, ដោយធ្វើយ៉ាងណា ត្រូវបំផុសឲ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងការអនុវត្តគោលនយោបាយ «ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព» ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាព លួច ឆក់ ប្លន់ អំពើហិង្សា ល្បែងស៊ីសងខុសច្បាប់ និងក្រុមក្មេងទំនើងគ្រប់មូលដ្ឋាន៕ រក្សាសិទ្ធិដោយ ៖ ពិសិដ្ឋ CEN

## សកម្មភាពនៃការលួចឆ្លងដែនរបស់ ពលករខ្មែរនៅតែមាន,ខណៈការវិលត្រឡប់ហាក់មានសន្ទុះច្រើនជាងមុនបន្តិច

http://nokorwatnews.com/ 23/03/2022

ខេត្តបាត់ដំបង ៖ ក្នុងបរិបទជំងឺកូវីដ-១៩ កំពុងរីករាលដាលអាជ្ញាធរតាមព្រំដែនរឹតបន្តឹងការឆ្លងដែនយ៉ាងណាក៏ដោយក៏សកម្មភាពលួចធ្លាក់ឆ្លងដែនខុសច្បាប់នៅតែកើតមាន។ ជាក់ស្តែងនៅតាមព្រំដែនខេត្តបាត់ដំបងជាប់ជាមួយប្រទេសថៃ នៅតែមានប្រជាពលរដ្ឋចេញចូល ដោយខុសច្បាប់ និងលួចឆ្លងដែនចូលប្រទេសថៃជាដដែល។ សកម្មភាពខុសច្បាប់ទាំងនេះត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកវិញជារឿយៗ។

បើតាមរបាយការណ៍របស់សមត្ថកិច្ចបានឲ្យដឹងថា ក្នុងរយៈពេលពេញ១ខែកុម្ភៈ ឆ្នាំ២០២២ សមត្ថកិច្ចថៃបានចាប់បញ្ជូនពលករខ្មែរជាង ៥ពាន់នាក់មកវិញ តាមច្រកព្រំដែននានាក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ខណៈសកម្មភាពបណ្តាញមេខ្យល់នាំមនុស្សឆ្លងដែនចេញចូលខុសច្បាប់ និងប្រជាពលរដ្ឋលបលួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃនៅតែបន្តកើតមាន។ របាយការណ៍របស់គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តបាត់ដំបង ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ ឱ្យដឹងថា អាជ្ញាធរនិងកងកម្លាំងចម្រុះការពារព្រំដែន បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋ ដែលបម្រុងឆ្លងដែនខុសច្បាប់ ចំនួន២លើក មនុស្ស១១នាក់ និងសមត្ថកិច្ចថៃ បានចាប់បញ្ជូនមកវិញចំនួន១៦០លើក មនុស្ស៥៦៩៦នាក់។ អាជ្ញាធរមានសមត្ថកិច្ចទាំងភាគីថៃ ក៏ដូចកម្ពុជាបានព្យាយាមសម្របសម្រួលឲ្យមានការចេញចូលដោយស្របច្បាប់ ។ ប៉ុន្តែជនខិលខូចជាពិសេសពលរដ្ឋដែលមិនមានឯកសារគ្រប់គ្រាន់នៅតែបន្តលួចឆ្លងដែនខុសច្បាប់។ ទីបំផុតប្រជាពលរដ្ឋនោះត្រូវអាជ្ញាធរថៃចាប់បានហើយបញ្ជូនប្រគល់មកឲ្យភាគីកម្ពុជាវិញជារឿយៗផងដែរ ។ ជនខិលខូចក៏ដូចជាប្រជាពលរដ្ឋ ដែលមិនមានឯកសារគ្រប់គ្រាន់នៅតែបន្តព្យាយាមលួចឆ្លង ដែនបំពានច្បាប់បង្កឲ្យមានបញ្ហាឈឺក្បាលជាញឹកញាប់ដល់សមត្ថកិច្ច។

របាយការណ៍ដដែលបន្ថែមថា ចំពោះសភាពការណ៍ ប្រជាពលរដ្ឋចេញ-ចូលឆ្លងកាត់ព្រំដែន មានអ្នកដំណើរឆ្លងកាត់ច្រកព្រំដែន អន្តរជាតិដូង ច្រកព្រំដែនអន្តរជាតិភ្នំដី និងច្រកទ្វារតំបន់ទាំងបី (មាន ច្រកអូរអន្លក់(សួនស៊ុ) អូររំដួល និងច្រក (៤០០) ទាំងចេញ និងចូល សរុបចំនួនជិត១ម៉ឺន៦ពាន់នាក់។

លោក ណាត ចាន់រ៉េត ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន ស៊ួនស៊ុ (អូរអន្លក់) ស្រុកកំរៀងបានឱ្យដឹងថា នៅតាមច្រកនេះ រំហូរពលករខ្មែរវិល ត្រឡប់មកពីប្រទេសថៃ ក្នុងមួយរយៈពេល ចុងក្រោយនេះ មិនទៀងទាត់ឡើយ ខណៈវិធានការសុខាភិបាលនៅច្រកព្រំដែនត្រូវបានកែសម្រួល និងរឹតបន្តឹង។ យ៉ាងណាក៏ដោយលោកកត់សម្គាល់ថា នៅក្នុងរយៈពេលពីរបីថ្ងៃកន្លងមកនេះហាក់ដូចជាមានចរន្តនៃការវិលត្រឡប់របស់ពលករខ្មែរកើនឡើងជាងសព្វមួយដង។

របាយាការណ៍ បានបញ្ជាក់ថា រដ្ឋបាលខេត្តបាត់ដំបង បានដាក់ចេញទិសដៅការងារបន្តដោយ បង្កើនសកម្មភាពល្បាតត្រួតពិនិត្យតាមបន្ទាត់ព្រំដែន ដោយរក្សាឲ្យខាងតែបាននូវបូរណភាពទឹកដី និង ទប់ស្កាត់ពលរដ្ឋឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។ លើកកម្ពស់អនុវត្តស្មារតី នៃកិច្ចប្រជុំទ្វេភាគី រវាងរដ្ឋ បាលខេត្តបាត់ដំបង និងខេត្តចាន់បុរី និងរវាងខេត្តបាត់ដំបង និងខេត្តស្រះកែវ ដើម្បីសម្រួលដល់ពលករ ទៅធ្វើការនៅខេត្តចាន់បុរី។ រដ្ឋបាលខេត្ត បានប្តេជ្ញាជំរុញសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឲ្យកាន់តែខ្លាំងក្លាថែមទៀត ដោយយកចិត្តទុកដាក់ទប់ស្កាត់និងបង្ក្រាបឲ្យមានប្រសិទ្ធភាពក្នុងសកម្មភាពជួញដូរពលករឆ្លងដែន និងចំណាកស្រុកខុសច្បាប់៕

## នៅព្រឹកថ្ងៃអង្គារ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/22/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១១និង៣០នាទី នាថ្ងៃអង្គារ ៥រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍

គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង បានចំនួន០២លើក សរុបចំនួន៩៣នាក់ (ស្រី៤០នាក់ ក្មេង១២នាក់ ក្មេងស្រី០៧នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក)។ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺវិជ្ជមាន ចំនួន០២នាក់ (ស្រី) ក្រុមគ្រូពេទ្យបានបញ្ជូនអ្នកវិជ្ជមានទៅកាន់មណ្ឌលព្យាបាលកូវីដ-១៩ ស្ថិតក្នុងភូមិកណ្តាលឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន៧៦នាក់ ស្រី៣១នាក់ ក្មេង១០នាក់ ក្មេងស្រី០៦នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្នែនអត់ចេញ ចំនួន១៥នាក់ ស្រី០៧នាក់ ក្មេង០២នាក់ ក្មេងស្រីម្នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ក្នុងខែកុម្ភៈ សមត្ថកិច្ចថៃ
## ចាប់បញ្ជូនពលករខ្មែរជាង ៥ពាន់នាក់មកវិញ តាមច្រកខេត្តបាត់ដំបង

https://btv.com.kh/ 03/22/2022 02:03 PM

បាត់ដំបង៖ ក្នុងរយៈពេលពេញមួយខែកុម្ភៈ ឆ្នាំ២០២២ សមត្ថកិច្ចថៃ បានចាប់បញ្ជូនពលករខ្មែរជាង ៥ពាន់នាក់មកវិញ តាមច្រកព្រំដែននានាក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ខណៈសកម្មភាពបណ្តាញមេខ្យល់នាំមនុស្សឆ្លងដែនចេញចូលខុសច្បាប់ និងប្រជាពលរដ្ឋលបលួចឆ្លងដែនខុសច្បាប់ ចូលប្រទេសថៃនៅតែបន្តកើតមាន។

របាយការណ៍របស់គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តបាត់ដំបង ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ បាន ឱ្យដឹងថា អាជ្ញាធរនិងកងកម្លាំងចម្រុះការពារព្រំដែន បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋ ដែលបម្រុងឆ្លងដែនខុសច្បាប់ ចំនួន២លើក មនុស្ស១១នាក់ និងសមត្ថកិច្ចថៃ បានចាប់បញ្ជូនមកវិញ ចំនួន១៦០លើកមនុស្ស៥៦៩៦នាក់។ របាយការណ៍ បានឱ្យដឹងបន្ថែមថា ការល្បាតតាមព្រំដែន វរសេនាតូចនគរបាលការពារព្រំដែន គោកសហការជាមួយកងទ័ពភាគីថៃ និងផ្នែកសឹករងវរសេនាតូច នៃតំបន់ប្រតិបត្តិការសឹករងបាត់ដំបង កងការពារព្រំដែនលេខ៥០២ និង ៥០៤ ចំណែកការងារទំនាក់ទំនងព្រំដែន បានជួបប្រជុំជាមួយភាគីថៃ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការល្អ និងផ្លាស់ប្តូរព័ត៌មានចំនួន១១លើក។ ចំពោះសភាពការណ៍ប្រជាពលរដ្ឋចេញ-ចូលឆ្លងកាត់ព្រំដែន មានអ្នកដំណើរឆ្លងកាត់ច្រកព្រំដែន អន្តរជាតិដូង ច្រកព្រំដែនអន្តរជាតិភ្នំដី និងច្រកទ្វារតំបន់ទាំងបី (មាន ច្រកអូរអន្លក់ (ស្ទួនស៊ុ) អូរវិជ្ជុល និងច្រក (៤០០) ទាំងចេញ និងចូល សរុបចំនួនជិត១ម៉ឺន៦ពាន់នាក់។

លោក ណាត ចាន់រ៉េត ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន ស្ទួនស៊ុ (អូរអន្លក់) ស្រុកកំរៀង បានឱ្យដឹងថា នៅតាមច្រកនេះ រំហូរពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ ក្នុងមួយរយៈពេល ចុងក្រោយនេះ មិនទៀងទាត់ឡើយ ខណៈវិធានការសុខាភិបាលនៅច្រកព្រំដែនត្រូវបានកែសម្រួល និងរឹតបន្តឹង។ របាយាការណ៍ បានបញ្ជាក់ថា រដ្ឋបាលខេត្តបាត់ដំបង បានដាក់ចេញទិសដៅការងារបន្តដោយ បង្កើនសកម្មភាពល្បាតត្រួតពិនិត្យតាមបន្ទាត់ព្រំដែន ដោយរក្សាឲ្យខាងតែបាននូវបូរណភាពទឹកដី និង ទប់ស្កាត់ពលរដ្ឋឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ។

លើកកម្ពស់អនុវត្តស្មារតី នៃកិច្ចប្រជុំទ្វេភាគី រវាងរដ្ឋ បាលខេត្តបាត់ដំបង និងខេត្តចាន់បុរី និងរវាងខេត្តបាត់ដំបង និងខេត្តស្រះកែវ ដើម្បីសម្រួលដល់ពលករ ទៅធ្វើការនៅខេត្តចាន់បុរី។ រដ្ឋបាលខេត្ត បានប្តេជ្ញាជំរុញសកម្មភាព ប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឲ្យកាន់តែខ្លាំងក្លាថែមទៀត ដោយយកចិត្តទុកដាក់ទប់ស្កាត់ និងបង្ក្រាបឲ្យមាន ប្រសិទ្ធភាពក្នុងសកម្មភាព ជួញដូរពលករឆ្លងដែន និងចំណាកស្រុកខុសច្បាប់៕ អត្ថបទ៖ នឿត សុភក្ត្រ

## ពលករខ្មែរនៅថៃ ចាប់ផ្តើមធ្វើដំណើរចូលមកស្រុកដើម្បីចូលរួមពិធីបុណ្យចូលឆ្នាំខ្មែរ

https://www.kampucheathmey.com/ ថ្ងៃពុធ ២៣ មីនា ២០២២ដោយ deth leng

ពលករខ្មែរ ដែលទៅបម្រើការងារនៅប្រទេសថៃ ចាប់ផ្តើមធ្វើដំណើរចូលមកស្រុកវិញ មុនពេលពិធីបុណ្យចូលឆ្នាំខ្មែរចូលមកដល់នាពាក់កណ្តាលខែមេសា ឆាប់ៗខាងមុខនេះ។ ចំនួនពលករដែលធ្វើដំណើរចូលមកបានកើនឡើងប្រមាណ ៤០០ ទៅ ៥០០ នាក់ក្នុងមួយថ្ងៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងតាមព្រំដែនខេត្តឧត្តរមានជ័យ។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានប្រាប់កម្ពុជាថ្មីនៅថ្ងៃទី ២៣ ខែមីនានេះថា "ជាធម្មតារៀងរាល់ឆ្នាំ គឺជិតចូលឆ្នាំខ្មែរ ពួកគាត់មកចឹងហើយមួយថ្ងៃប្រមាណ ៧០០ ទៅ ៨០០ នាក់ នៅប៉ុន្មានថ្ងៃនេះពួកគាត់ចូលមកមួយថ្ងៃ ប្រមាណ ៤០០ ទៅ ៥០០ នាក់ ខណៈដែលអាជ្ញាធរបានប្រកាន់យកវិធានការសុខាភិបាលតាមការណែនាំរបស់រាជរដ្ឋាភិបាលដើម្បីទប់ស្កាត់ជំងឺកូវីដ១៩"។

លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ស្ថានភាពហូរពលករខ្មែរចូលមកតាមព្រំដែនខេត្តឧត្តរមានជ័យមានការកើនឡើងនៅប៉ុន្មានថ្ងៃនេះ។ លោកប្រាប់ថា នៅថ្ងៃ ២២ ខែមីនា ចំនួន ២៣០ នាក់ រីឯថ្ងៃ ២១ ចំនួន ៥២៩ នាក់ គឺប្រែប្រួលចុះឡើងទៅតាមថ្ងៃនីមួយៗ ហើយអាជ្ញាធរបានត្រួតពិនិត្យតាមវិធានការសុខាភិបាល ដោយពិនិត្យមើលការចាក់វ៉ាក់សាំង និងស្ថានភាពរបស់ពួកគាត់។ ដោយឡែកសម្រាប់អ្នកមិនទាន់ចាក់វ៉ាក់សាំង គឺតម្រូវឱ្យធ្វើចត្តាឡីស័ក ១៤ ថ្ងៃ។ លោក ប៉ែន កុសល្យឱ្យដឹងថា ដើមឡើយមានការធ្វើតេស្ត ប៉ុន្តែឥឡូវនេះ គឺមិនមានទេ ដោយគ្រាន់តែពិនិត្យទៅលើស្ថានភាពរបស់ពួកគាត់ថា ល្អប្រសើរមិនមានការធ្វើតេស្តទេ។ ប៉ុន្តែបើស្ថានភាពគាត់មានបញ្ហា ដូចជាផ្តាសាយ គឺយើងត្រូវពិនិត្យធ្វើតេស្តទាំងអស់ ហើយអត្តសញ្ញាណ ទីកន្លែងកំណើតអាជ្ញាធរបានចុះក្នុងបញ្ជិការ និងរាយការប្រាប់ទៅអាជ្ញាធរដែនសត្តកិច្ច ដែលជាទីកន្លែងពួកគាត់រស់នៅ៕

## ពលករខ្មែរ សម្រុកចេញមកមុនពេលចូលឆ្នាំ ត្រូវទាហានថៃឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃពុធ ២៣ មីនា ២០២២ដោយ Sorn Phanith

ពលករខ្មែរមួយចំនួនធំ ដែលធ្វើការនៅក្នុងប្រទេសថៃ កំពុងសម្រុកចេញមកប្រទេសកម្ពុជាជាបណ្តើរៗ ក្នុងគោលបំណងមកលេងក្នុងថ្ងៃចូលឆ្នាំខ្មែរ ដែលនេះជាបញ្ហាមួយ ដូចជាខ្លះត្រូវតម្រួតថៃឃាត់ខ្លួន ឯខ្លះទៀតបាននាំមកជាមួយនូវពេគសញ្ញាកូវីដ ឬអូមីក្រុងផងដែរ។ ជាក់ស្តែងនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១១ និង ២០ នាទីថ្ងៃត្រង់ កម្លាំងតម្រួតការពារព្រំដែនថៃលេខ ១២ ដែលឈរជើងត្រង់ចំណុចភូមិណូនស៊ូង ឃុំណូនម៉ាកម៉ុន ស្រុកគោកខ្សូង ខេត្តស្រះកែវ បានឃាត់រថយន្តចំនួន ២ គ្រឿង បន្ទាប់ពីមានការសង្ស័យ។ រថយន្តទាំងពីរនោះ ម៉ាក តូយូតា វីហ្គូ ដូចគ្នា ពណ៌ខ្មៅ ១ គ្រឿង និងពណ៌ស ១ គ្រឿង បើកបរដោយជនជាតិថៃ ប្រុសម្នាក់ ស្រីម្នាក់ ដោយក្នុងរថយន្តទាំងពីរគ្រឿងនេះ សមត្ថកិច្ចថៃបានរកឃើញពលករខ្មែរសរុបចំនួន ៨ នាក់ ក្នុងនោះមនុស្សធំ ៤ នាក់ និងក្មេង ៤ នាក់ ។

ក្រោយពីបានសាកសួរអ្នកបើកបរបានសារភាពថា គេបានស៊ីឈ្នួលដឹកពលករទាំងអស់នេះ ក្នុងតម្លៃខ្ពស់ ដោយទិសដៅចេញពីខេត្តសមុទ្រប្រាកាន មកកាន់ព្រំដែនកម្ពុជា។ ដោយឡែកសម្រាប់ពលករខ្មែរបាននិយាយថា ពួកគេចង់វិលទៅស្រុកកំណើតឲ្យទាន់មុនពេលចូលឆ្នាំ ដោយសារតែគ្មានច្បាប់នេះហើយទើបពួកគេសុខចិត្តចំណាយម៉ៅរថយន្តមកតែម្តង។ បច្ចុប្បន្នដោយសារតែគ្មានច្បាប់អនុញ្ញាតសមត្ថកិច្ចបានបញ្ជូនទាំងអ្នកបើកបរទាំងពលករនិងមធ្យោបាយធ្វើដំណើរទៅកាន់អធិការដ្ឋានតម្រួតស្រុកគោកខ្សូងដើម្បីអនុវត្តតាមផ្លូវច្បាប់៕**សោនិយមវត្ត**

## ថ្ងៃទី២៥ ខែ មីនា ឆ្នាំ២០២២

## នាយករដ្ឋមន្ត្រីកម្ពុជា ស្នើរដ្ឋាភិបាលកូរ៉េទទួលយកពលករខ្មែរទៅធ្វើការបន្ថែមទៀតនៅឆ្នាំនេះ

https://www.postkhmer.com/national/ មុំ គន្ធា | Publication date 24 March 2022 | 09:37 ICT

**កណ្តាលៈ** លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើឱ្យរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ បង្កើនចំនួននៃការទទួលយកពលករខ្មែរទៅធ្វើការបន្ថែមទៀត នៅឆ្នាំ ២០២២ នេះ ខណៈដែលពលករកម្ពុជា ប្រមាណជា ៤៥ ០០០ នាក់បាននិងកំពុងធ្វើការនៅប្រទេសកូរ៉េទៅហើយនោះ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើបែបនេះនាព្រឹកថ្ងៃទី ២៣ ខែមីនា ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវជាតិលេខ ២១ ដែលមានប្រវែងជិត ៦៤ គីឡូម៉ែត្រតភ្ជាប់ពីរង្វង់មូលក្រុងតាខ្មៅ រហូតដល់ច្រកទ្វារអន្តរជាតិកម្ពុជា-វៀតណាម (ជ្រៃធំ-ឡុងប៊ិញ)។ លោកលើកឡើងថា ការនាំចេញពាណិជ្ជកម្មកម្ពុជាក្នុងរយៈពេល ២ ខែ ដើមឆ្នាំ ២០២២ នេះ មានកំណើនជាង ៣០% នៃការនាំចេញសរុបទូទៅ។ ប៉ុន្តែដោយឡែកសម្រាប់ប្រទេសកូរ៉េខាងត្បូង មានការកើនឡើង ៣៣% នៃការនាំចេញពីកម្ពុជាទៅកាន់ប្រទេសនេះ។ លោក ហ៊ុន សែន ថ្លែងថា៖ «ដូចនេះចំណុចនេះជាចំណុចដែល យើងកំពុងតែអនុវត្តដោយខាងប្រទេសកម្ពុជាបានឱ្យរួចហើយនូវសច្ចាប័នពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ។ ខ្ញុំក៏បានប្រាប់ទាំងប្រធានសភា ទាំងប្រធានាធិបតីកូរ៉េខាងត្បូងថា សុំឱ្យពួកគាត់បំពេញនីតិវិធីផ្ទៃក្នុងឱ្យបានឆាប់ ដើម្បីយើងអាចចាប់ផ្តើមជំរុញពាណិជ្ជកម្មរវាងកម្ពុជា-កូរ៉េ ស្របគ្នាជាមួយនឹងការចូលជាធរមាននូវកិច្ចព្រមព្រៀងអាសិប (ASEP)។ នេះជាផលប្រយោជន៍ដែលចេញមកពីកិច្ចសហប្រតិបត្តិការ»។

បើតាមលោកនាយករដ្ឋមន្ត្រី ប្រជាពលរដ្ឋកម្ពុជាដែលកំពុងធ្វើការនៅប្រទេសកូរ៉េខាងត្បូងមានប្រមាណជា ៤៥ ០០០ នាក់។ លោកមានប្រសាសន៍ថា៖ «ខ្ញុំបានស្នើសុំឱ្យផ្តល់កូតាសម្រាប់ពលករកម្ពុជាទៅធ្វើការប្រទេសកូរ៉េបន្ថែមទៀត ដែលយើងមិនមែនត្រឹមតែយកប្រាក់កាសមកដោះស្រាយជីវភាពនោះទេ ប៉ុន្តែក៏អាចនាំមកផងដែរ នូវបច្ចេកទេសនានាពាក់ព័ន្ធនឹងការអភិវឌ្ឍប្រទេសជាតិរបស់យើងផងដែរ»។

នាឱកាសនោះដែរ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជា លោក Park Heung-Kyeong បានលើកឡើងដែរថា ទំនាក់ទំនងមិត្តភាពដ៏ល្អរវាងកម្ពុជា និងកូរ៉េ បានចូលរួមចំណែកយ៉ាងធំក្នុងការបង្កើតការងារក្នុងការប្រមូលរូបិយប័ណ្ណអន្តរជាតិ សម្រាប់ប្រទេសកម្ពុជាផងដែរ តាមរយៈការនាំចេញកម្លាំងពលកម្ម ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ។ លោកថ្លែងថា៖ «បច្ចុប្បន្ននេះ មានពលករកម្ពុជាប្រមាណជា ៤៥ ០០០ នាក់ កំពុងតែបម្រើការងារក្នុងវិស័យឧស្សាហកម្មកូរ៉េប្រកបដោយភាពស្មោះត្រង់ និងទទួលបានការទទួលស្គាល់សមត្ថភាពពីនិយោជករបស់ពួកគេផងដែរ»។ លោក Park Heung-Kyeong ថ្លែងដែរថា ការផ្លាស់ប្តូរប្រជាជនរវាងប្រទេសទាំង ២ ក៏មានសកម្មភាពយ៉ាងសកម្មផងដែរ មុនពេលមានការផ្ទុះឡើងនូវការរីករាលដាលនៃមេរោគកូវីដ ១៩ ហើយក្នុងនោះចំនួនភ្ញៀវទេសចរទេសចរណ៍ទេសចរទៅវិញទៅមករវាងប្រទេសទាំង ២ ប្រចាំឆ្នាំមានចំនួនរហូតដល់ ៣០ ម៉ឺននាក់។ ប្រទេសកម្ពុជា គឺជាប្រទេសលំដាប់ខ្ពស់ និងជាប្រទេសដែលមានពលករខិតខំធ្វើការងារ អត់ធ្មត់ល្អជាងគេក្នុង

ចំណោម ១៦ ប្រទេសផ្សេងទៀត ហើយប្រទេសកូរ៉េចាត់ទុកប្រទេសកម្ពុជា គឺជាប្រទេសដៃគូសហប្រតិបត្តិការមិនអាចខ្វះបាននៅពេលបច្ចុប្បន្ន និងអនាគត។ នេះបើតាមការបញ្ជាក់របស់លោក គីម វ៉ុនសុក ប្រធានការិយាល័យអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងការងារកូរ៉េតំបន់សេអ៊ូល។

ការលើកឡើងដូចនេះ ក្នុងជំនួបជាមួយមន្ត្រីនៃការិយាល័យអនុព័ន្ធការងារនៃស្ថានទូត-កម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០២២ ដើម្បីពិភាក្សាការងារពលករប្រចាំតំបន់ និងជាពិសេស ការសហការក្នុងការបើកវគ្គបណ្តុះបណ្តាលពលករផ្លាស់ប្តូរការងារផងដែរ។ លោក គីម វ៉ុនសុក និងក្រុមការងារ មានការសប្បាយរីករាយសហការជាមួយស្ថានទូតកម្ពុជា ក្នុងការរៀបចំបើកវគ្គបណ្តុះបណ្តាលខ្លីដល់ពលករកម្ពុជាបន្ថែមទៀត ដើម្បីឱ្យទទួលបានចំណេះដឹងឱ្យកាន់តែទូលំទូលាយបន្ថែមទៀតក្នុងអំឡុងពេលបម្រើការងារនៅសាធារណរដ្ឋកូរ៉េ។ ជាការឆ្លើយតប ការិយាល័យអនុព័ន្ធការងារនៃស្ថានទូតកម្ពុជា ពិតជាមានសេចក្តីសោមនស្ស និងចូលរួមសហការជាមួយភាគីកូរ៉េបន្ថែមទៀត ដើម្បីឱ្យប្រជាពលករខ្មែរទទួលបានចំណេះដឹងឱ្យកាន់តែច្រើនបន្ថែមទៀតអំឡុងពេលមកបម្រើការងារនៅសាធារណរដ្ឋកូរ៉េ។

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង ថ្លែងកាលពីខែកុម្ភៈ ថា គិតត្រឹមឆ្នាំ ២០២១ រាជរដ្ឋាភិបាលបានផ្តល់ឱកាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋបានចំនួនជាង ១,៣ លាននាក់។ លោក អ៊ិត សំហេង បន្ថែមថា៖ «បើតាមការប៉ាន់ប្រមាណពីការប្រាក់បញ្ញើដែលបងប្អូនពលករបានផ្ញើជូនក្រុមគ្រួសារក្នុង ១ ឆ្នាំៗ ប្រហែល ២,៨ ប៊ីលានដុល្លារអាមេរិក ដែលតាមរយៈទឹកប្រាក់ទាំងនេះបានចូលរួមចំណែកជំរុញដល់កំណើនសេដ្ឋកិច្ចជាតិ ហើយជីវភាពរស់នៅរបស់ក្រុមគ្រួសារពលករកាន់តែប្រសើរឡើងផងដែរ»។ លោកថា កម្ពុជាបន្តពង្រឹងកិច្ចសហការជាមួយប្រទេសជាដៃគូ រួមមាន ថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន ហុងកុង សិង្ហបុរី និងប្រទេសមួយចំនួនទៀតដើម្បីផ្តល់ឱកាសការងារជូនពលករ ការពារសិទ្ធិ និងផលប្រយោជន៍ពលករដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ បង្កលក្ខណសម្បត្តិឱ្យបងប្អូនទទួលបានរបបគាំពារសង្គមទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់មកវិញ។

តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករខ្មែរដែលកំពុងធ្វើការនៅក្រៅប្រទេស រួមមាន ប្រទេសថៃចំនួន ១ ២២០ ១៩៧ នាក់ កូរ៉េ ៤ ៥ ៨៦៦ នាក់ ម៉ាឡេស៊ី ២៣ ០២៧ នាក់ ជប៉ុន ១១ ៤៥៣ នាក់ សិង្ហបុរី៨២១ នាក់ ហុងកុង ២០២ នាក់ និងប្រទេសអារ៉ាប៊ីសាអ៊ូឌីត ៤៣ នាក់៕

## សម្តេច ស ខេង អំពាវនាវពលរដ្ឋ មុននៅធ្វើការ នៅក្រៅប្រទេស ត្រូវសួរព័ត៌មានអាជ្ញាធរជាមុនសិន ជៀសវាងចាញ់បោកមេខ្យល់

https://dap-news.com/national/ ByKD102Posted on March 24, 2022

**ភ្នំពេញ៖** **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរ មុនសម្រេចចិត្តទៅធ្វើការងារនៅប្រទេសថៃ ឬប្រទេសផ្សេងៗទៀត ត្រូវសួរព័ត៌មានអាជ្ញាធរក្នុងមូលដ្ឋានឲ្យច្បាស់លាស់ជាមុនសិន ដើម្បីជៀសវាងការចាញ់បោកមេខ្យល់ ព្រោះកន្លងទៅ មានពលរដ្ឋខ្មែរ ចាញ់បោកមេខ្យល់ជាច្រើននាក់។**

ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់នូវសមិទ្ធផលនានា នៅខេត្តបាត់ដំបង នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ សម្តេច ស ខេង បានសង្កេតឃើញថា នាពេលកន្លងមកមានករណីជួញដូរមនុស្ស មានការលួងលោមនាំទៅក្រៅប្រទេស។ សម្តេច ក៏បានរំលឹកថា កន្លងទៅ មានស្ត្រីខ្មែរម្នាក់ បានចាញ់បោកគេដោយរៀប គូស្រករនៅប្រទេសកូរ៉េ ក្រោយមក សមត្ថកិច្ចកម្ពុជា សហការជាមួយក្រសួងមហាផ្ទៃកូរ៉េ បានអន្តរាគមន៍ស្ត្រីខ្មែរម្នាក់នោះ មកកម្ពុជាវិញ។

សម្តេច មានប្រសាសន៍ថា «សូមកុំជឿគេផ្តេសផ្តាស កាលណាគេមកសួរយើងថា ធ្វើការនេះ ធ្វើការនោះ ហើយធ្វើការនៅថៃស្រួលណាស់ មានប្រាក់ចំណេញ យើងត្រូវសួរព័ត៌មានឲ្យច្បាស់សិន បើយើងមិនដឹងទេ អាជ្ញាធរយើងនៅហ្នឹងកន្លែង ត្រូវសួរនាំសិន»។ លើសពីនេះ សម្តេច ស ខេង ក៏បានលើកឡើងទៀតថា នាពេលកន្លងទៅ ក៏មានប្រជាពលរដ្ឋខ្មែរ ចាញ់បោកមេខ្យល់យ៉ាងច្រើន ដោយមេខ្យល់ទាំងនោះ ធ្វើការលួងលោមឲ្យទៅ ធ្វើការងារនៅក្រៅប្រទេស ដូច្នេះ ត្រូវមានការប្រុងប្រយ័ត្នចំពោះបញ្ហាទាំងនេះ៕

## លោកស្រី ជូ ប៊ុនអេង៖ កម្ពុជាកំពុងសហការស្រង់ស្ថិតិពលករចំណាកស្រុកនៅថៃ

https://www.postkhmer.com/national/ ឡុង គីមម៉ារីតា | Publication date 23 March 2022 | 10:26 ICT

**ភ្នំពេញ៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) បានឱ្យដឹងថា កម្ពុជា និងថៃកំពុងបន្តសហការគ្នា ដើម្បីស្រង់ទិន្នន័យពលករចំណាកស្រុកនៅប្រទេសថៃ ខណៈលោកស្រីបារម្ភពីចំនួនអ្នករស់នៅមិនស្របច្បាប់ក្នុងប្រទេសនេះអាចនឹងមានការកើនឡើង បើទោះជាចំនួនអ្នកឆ្លងដែនខុសច្បាប់មានការធ្លាក់ចុះក្តី។ លោកស្រី ជូ ប៊ុនអេង បានអះអាងប្រាប់កាសែតភ្នំពេញ-ប៉ុស្តិ៍កាលពីថ្ងៃទី ២០ មីនា យ៉ាងដូច្នេះថា៖ «ពាក់ព័ន្ធនឹងតួលេខខ្ញុំចង់និយាយបន្តិចមកដល់ពេលនេះយើងកំពុងគិតគូរនឹងការងារទិន្នន័យហ្នឹងខ្លាំងណាស់ ព្រោះដូចនិយាយអ៊ីចឹង យើងកំពុងតែស្ថិតក្នុងស្ថានភាពប្រទេសជិតខាងនៅបិទច្រកព្រំដែន មិនចង់ឱ្យមានទំនាក់ទំនងគ្នាចុះឡើងៗទេ។ បើទោះបីជាមានការជ្រើសរើសការងារ ក៏យើងឃើញថា នៅប្រទេសថៃយើងកំពុងជជែកគ្នាដែលយើងចាំបាច់ត្រូវការសហការគ្នាដើម្បីស្វែងរកទិន្នន័យឱ្យបានជាក់លាក់»។ លោកស្រីបានបន្តថា ចំពោះកិច្ចសហការជាមួយភាគីថៃក្នុងពេលនេះ ក៏ព្រោះសព្វថ្ងៃ ទិន្នន័យដែលកំពុងប្រើប្រាស់គឺអាស្រ័យទៅតាមការរាយការណ៍ពីខាងភាគីថៃ ខណៈប្រជាពលរដ្ឋខ្មែរចូលទៅប្រទេសថៃដោយមិនមានច្បាប់ទម្លាប់មានការធ្លាក់ចុះ។ ប៉ុន្តែលោកស្រីថា ចំនួនការរស់នៅដោយខុសច្បាប់អាចមានការកើនឡើង ព្រោះពលរដ្ឋដែលកំពុងមានភាពស្របច្បាប់ កំពុងបន្តរស់នៅដោយខុសច្បាប់នៅទីនោះ។

លោកស្រីបានបញ្ជាក់ថា៖ «បើទោះបីជាពីមុនយើងបានដឹងថាគាត់ទទួលបានភាពស្របច្បាប់ តែភាពស្របច្បាប់ទាំងនោះអាចអស់សុពលភាពទៅហើយ ដោយសារតែ ២ ឆ្នាំបន្តមកហើយ។ អ៊ីចឹងឥឡូវនេះយើងកំពុងគិតពីវិធានការបន្តសម្រាប់ការគ្រប់គ្រងទិន្នន័យទាំងនោះ»។ បើតាមលោកស្រី ជូ ប៊ុនអេង ចំពោះការធ្វើចំណាកស្រុកទាំងប្រថុយប្រថានក្នុងពេលបច្ចុប្បន្ននេះគឺមិនមានការកើនឡើងនោះឡើយក្នុងអំឡុងពេលផ្ទុះជំងឺកូវីដ ១៩ ដោយគេដឹងថា មានពលករចំណាកស្រុកជិត ៣០ ម៉ឺននាក់បានវិលត្រឡប់មកប្រទេសវិញ រីឯអ្នកវិលត្រឡប់ទៅប្រទេសថៃវិញគឺមានចំនួនតិចតួចបំផុត។ លោកស្រីបានបញ្ជាក់បន្ថែមថា៖ «ក្នុងអំឡុងពេលនេះអ្នកដែលទៅដោយខុសច្បាប់ពីកម្ពុជាយើង គឺមានមិនច្រើននោះទេ ហើយបើទៅក៏មិនត្រូវបានគេទទួលធ្វើការដែរ ហើយត្រូវបានគេចាប់បញ្ជូនត្រឡប់មកវិញដែរ។ អ៊ីចឹងអ្វីដែលច្រើននោះ (ពលករខុសច្បាប់) គឺអ្នកដែលនៅទីនោះមិនទាន់មក បានន័យថា គេអាចប៉ាន់ប្រមាណថានៅ ក៏មិនតិចជាង ១ លាននាក់ដែរ»។

លោក យុន ថារ៉ូ អ្នកគ្រប់គ្រងកម្មវិធីការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សរបស់អង្គការសង់ត្រាល់បានលើកឡើងថា ប្រសិនបើមានការសហការធ្វើជំរឿនទិន្នន័យថ្មីរវាងប្រទេសទាំង ២ គឺជារឿងមួយដែលល្អ។ លោកបន្តថា ចំពោះតួលេខដែលប្រើប្រាស់កន្លងមកចំពោះពលករចំណាកស្រុក គឺតែងមានភាពប្រទាំងប្រទើសគ្នា ហើយមិនមានភាពច្បាស់លាស់ទៅនឹងដង់ស៊ីតេស្ថិតិនៃពលករខ្មែរដែលកំពុងធ្វើការងារ និងរស់នៅក្នុងប្រទេសថៃទេ។ លោកបានបញ្ជាក់ថា៖ «ខ្ញុំគិតថា នេះគឺជារឿងមួយដែលល្អដើម្បីឱ្យយើងច្បាស់លាស់អំពីស្ថិតិជាក់ស្តែងនៃពលករខ្មែរដែលកំពុងធ្វើការងារនៅក្នុងវិស័យនានារួមទាំងប្រជាពលរដ្ឋខ្មែរដែលកំពុងធ្វើការ និងរស់នៅ

ប្រទេសថៃ»។ ជាមួយនឹងការគាំទ្រនេះ លោក យុន ថារ៉ូ មើលឃើញថា ការងារនេះគឺហាក់មានភាពស្មុគស្មាញ និងត្រូវការការប្រមូលទិន្នន័យ និងព័ត៌មានដែលទាមទារឱ្យមានការចូលរួមសហការជាមួយដៃគូពាក់ព័ន្ធ ជាពិសេសគឺភាគីថៃ ដើម្បីសម្របសម្រួលឱ្យមានការស្រង់ទិន្នន័យឱ្យបានច្បាស់លាស់នៅតាមគ្រឹះស្ថាន និងសហគ្រាសនានានៅក្នុងប្រទេសថៃ៕

## នៅយប់ថ្ងៃពុធ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/24/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង២០និង០០នាទី នាថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្ដិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្ដិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបចំនួន៤៦នាក់ ស្រី១៦នាក់ ក្មេង០៩នាក់ ក្មេងស្រី០៥នាក់។

ក្រោយពីទទួលបាន កម្លាំងយើងធ្វើការសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចប្រគល់បងប្អូនឲ្យក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើការពិនិត្យសុខភាព និងស្វែនប័ណ្ណចាក់វ៉ាក់សាំងនៅនឹងប៉ុស្ដិ៍ ជាលទ្ធផល មានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវទាំងអស់គ្នា។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញទាំងអស់។

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/03/24/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តនតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញាមេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្ដិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១៥៩នាក់, ស្រី៥៩នាក់ និងក្មេង១០នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវីដ-១៩រួចរាល់ ក្រុមគ្រូពេទ្យ

បានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ ចំនួនម្នាក់ (ស្រី)។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន១៤៣នាក់ (ស្រី៥៤នាក់, ក្មេង១០នាក់) ចំណែកពលករចំនួន១៥នាក់ (ស្រី៣នាក់) ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួន៥នាក់ (ស្រី៥នាក់) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## មន្ត្រីជាន់ខ្ពស់ក្រសួងសង្គមកិច្ចៈ អំពើជួញដូរមនុស្សកំពុងកើតឡើង គ្រប់ទីកន្លែង ក្នុងរូបភាពជាឧក្រិដ្ឋកម្មឆ្លងដែន និងក្នុងប្រទេស ដែលមានអង្គការចាត់តាំង

http://freshnewsasia.com/ 2022-03-24 12:11pm

**(ព្រះសីហនុ)៖** លោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានឱ្យដឹងថា អំពើជួញដូរមនុស្សបាននឹងកំពុងកើតឡើងគ្រប់ទីកន្លែងក្នុងរូបភាពភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន និងក្នុងប្រទេស ដែលមានអង្គការចាត់តាំង ហើយឧក្រិដ្ឋកម្មនេះបានជះឥទ្ធិពលជាអវិជ្ជមានដល់បុគ្គល គ្រួសារ និងសហគមន៍ ជាពិសេសទាំងនៅថ្នាក់ជាតិ តំបន់ និងពិភពលោក។ ការឱ្យដឹងបែបនេះ របស់លោក ញ៉ឹក វណ្ណារ៉ា បានធ្វើឡើងក្នុងពិធីបើកសិក្ខាសាលាស្តីពី «នីតិវិធីនៃដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស» នៅខេត្តព្រះសីហនុ នៅព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២នេះ ដោយមានការចូលរួមពីសំណាក់លោកស្រី ប៉ែន វិចសុី អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល, ថ្នាក់ដឹកនាំក្រសួងសង្គមកិច្ច, តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អភិបាលរងខេត្តព្រះសីហនុ និងលោក ផូនី ផុសណេត ប្រធានអង្គការរតនៈអ៊ីជើណេសិនណល។ តាងនាមលោករដ្ឋមន្ត្រី វង សូត, លោក ញ៉ឹក វណ្ណារ៉ា បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដើម្បីការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ហើយដែលនាំឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មីគួរជាទីមោទនៈបំផុត។ ការអនុវត្តយុទ្ធសាស្រ្តចតុកោណ បានផ្តល់ផលជាការផ្លាស់ប្តូរស៊ីជម្រៅនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាពប្រជាជន ឱ្យកាន់តែប្រសើរឡើង ទាំងខាងសម្ភារៈ និងស្មារតី តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការបង្កើតការងារជូនប្រជាជន ការធានាសមធម៌សង្គម និការងពង្រឹងប្រសិទ្ធភាពនៃអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ។

មន្ត្រីជាន់ខ្ពស់រូបនេះ បានបន្តថា ការផ្តោតនៃយុទ្ធសាស្រ្តចតុកោណក្នុងដំណាក់កាលទី៤ បានតម្កល់ការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ នៅលើគេ រួមមាន ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។ ដំណើរការសម្របសម្រួលជាប់លាប់ និងយ៉ាងល្អ ដើម្បីផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាផ្នែកមួយនៃយន្តការគាំពារសង្គមដែលប្រសើរឡើង។ ដោយយោងតាមពិធីសារ ប៉ាឡឺម៉ូ (Palermo បានបញ្ជាក់ថា សកម្មភាពប្រកបដោយប្រសិទ្ធភាពក្នុងការទប់ ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ទាមទារឱ្យមានវិធីសាស្រ្តអន្តរជាតិដ៏ទូលំទូលាយមួយនៅក្នុងប្រទេសដើម ប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ។ វិធីសាស្រ្តនេះចាំបាច់ត្រូវរួមបញ្ចូលវិធានការទប់ស្កាត់ការជួញដូរមនុស្សបែបនេះ ដោយការផ្តន្ទាទោសជនប្រព្រឹត្តបទល្មើស។ ជាមួយគ្នានេះដែរ លោក ញ៉ឹក វណ្ណារ៉ា បានលើកឡើងថា ដើម្បីឱ្យរាជរដ្ឋាភិបាលកម្ពុជា អាចផ្តល់ការស្តារនីតិសម្បទា ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស វាជាការសំខាន់ណាស់ដែលជនរងគ្រោះទាំងនេះត្រូវបានកំណត់អត្តសញ្ញាណប្រកបដោយប្រសិទ្ធភាព និងផ្តល់ការគាំទ្រដោយមិនបង្អង់យូរ។ ការកំណត់អត្តសញ្ញាណជនរងគ្រោះច្បាស់លាស់ អាចឱ្យមន្ត្រីរដ្ឋាភិបាលយល់អំពីស្ថានភាព និងតម្រូវការរបស់ជនរងគ្រោះ ដើម្បីបង្កើត និងអនុវត្តការឆ្លើយតបសមស្រប។ តាមរយៈការសម្របសម្រួលពីមន្ត្រីនគរបាលយុត្តិធម៌ក្នុងការប្រមូលព័ត៌មានលម្អិតច្បាស់លាស់ ការកំណត់អត្តសញ្ញាណជនរងគ្រោះក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការលុបបំបាត់អំពើជួញដូរមនុស្សផងដែរ។ ប្រសិនបើការកំណត់អត្តសញ្ញាណជនរងគ្រោះមិនអាចធ្វើបាន ឬមិនអាចអនុវត្តបានត្រឹមត្រូវ ជនរងគ្រោះនឹង

រងនូវការឈឺចាប់បន្ថែមទៀត ដោយសារតែគាត់នឹងមិនទទួលបានការគាំទ្រគ្រប់គ្រាន់ ឬសន្តិសុខផ្លូវកាយ និងផ្លូវចិត្ត។ លើសពីនេះ ឱកាសនៃការចាប់ខ្លួនជនល្មើសអាចនឹងត្រូវបាត់បង់ ដែលជាហេតុធ្វើឱ្យជនល្មើសប្រព្រឹត្តបទឧក្រិដ្ឋលើមនុស្សផ្សេងទៀត។

បើតាមមន្ត្រីជាន់ខ្ពស់រូបនេះ បានបញ្ជាក់ថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសេនាធិការជូនរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ ឧបត្ថម្ភរាល់សេចក្តីត្រូវការចាំបាច់ របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រសួងបានរៀបចំតាក់តែងច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្ត ដើម្បីការពារ ទប់ស្កាត់ នូវអំពើជួញដូរមនុស្ស។ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវកិច្ចការពារ សិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទាមទារឱ្យមានកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធរវាងក្រសួង ស្ថាប័ន អាជ្ញាធរ អង្គការដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិពាក់ព័ន្ធ រួមគ្នាដើម្បីរៀបចំនីតិវិធីនៃដំណើរការមាតុភូមិនិវត្តន៍ ក្នុងគោលបំណងសម្របសម្រួល និងផ្តល់ព័ត៌មានលម្អិតនៃការបញ្ជូនជនរងគ្រោះ និងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ដើម្បីទទួលបានសេវាចាំបាច់សមស្របទៅតាមតម្រូវការជាក់ស្តែង និងទាន់ពេលវេលាដោយផ្អែកលើវ៉ៃ យេនឌ័រ មុននឹងឈានទៅទទួលបានការដោះស្រាយតាមផ្លូវច្បាប់ ការផ្តល់សេវាស្តារនីតិសម្បទា និងសេវាសង្គមដទៃទៀត។

រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងខិតខំប្រឹងប្រែងបង្កើត រៀបចំចងក្រង ផ្សព្វផ្សាយ និងអនុវត្តគោលនយោ បាយយុទ្ធសាស្ត្រ ផែនការ កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងយន្តការនានាសំដៅប្រយុទ្ធប្រឆាំង និងកាត់បន្ថយឱ្យបានជាអតិបរមានូវអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ អនុតំបន់ តំបន់ និងលើពិភពលោក។

លោកបានគូសបញ្ជាក់ថា ដោយឡែក ក្រសួងសង្គមកិច្ច ដែលបានទទួលអណត្តិពីរាជរដ្ឋាភិបាល ក្នុងការការពារ និងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ ក្រសួងបានបំពេញការងារយ៉ាងសកម្ម និងសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការងារកសាងគោលនយោបាយ ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការបង្កើនភាពជាដៃគូ។ នាឱកាសនោះដែរ លោករដ្ឋលេខាធិការ សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃនាយកដ្ឋានប្រឆាំងប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិពាក់ព័ន្ធ ជាពិសេសអង្គការតេនះអ៊ីនធើណេសិនណលដែលបានគាំទ្រថវិកា និងបច្ចេកទេស ដើម្បីរៀបចំតាក់តែងនូវនីតិវិធីនេះឡើង។

នីតិវិធីណែនាំនេះ មានគោលបំណងផ្តល់ព័ត៌មានលម្អិតអំពីបែបបទនៃការបញ្ជូនជនរង និងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សមកកាន់ប្រទេសកម្ពុជាវិញ និងគាំទ្រតួនាទី ភារកិច្ច និងនីតិវិធីច្បាស់លាស់រវាងអន្តរក្រសួង ស្ថាប័ន ដើម្បីធានាបានថាជនរងគ្រោះ និងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សទទួលបាននូវសេវាសមស្រប និងទាន់ពេលវេលា ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពការងារ និងកិច្ចសហការរួមគ្នា ដោយប្រកាន់ខ្ជាប់នូវកិច្ចការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងមានវិសាលភាពគ្របដណ្តប់ករណីជនរងគ្រោះ និងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណបឋមនៅក្នុងប្រទេសគោលដៅ ដែលធ្វើមាតុភូមិនិវត្តន៍តាមច្រកទ្វារអាកាសយានដ្ឋានជាតិ និងអន្តរជាតិ៕

# អាជ្ញាធរនិងសមត្ថកិច្ចស្រុកម៉ាឡៃ
# និងស្រុកថ្មពួកជួបជាមួយភាគីថៃ ដើម្បីពង្រឹងសន្តិសុខតាមព្រំដែន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៤ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ១០:៥៩

ខេត្តបន្ទាយមានជ័យ៖ ដើម្បីរឹតចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង លោក ស្វាយ ជា អភិបាលស្រុកម៉ាឡៃ នៅវេលាម៉ោង០៨និង៣០នាទីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ ២០២២ បានដឹកនាំកម្លាំងនគរបាលប៉ុស្តិ៍ការពារព្រំដែនខ្លាងាប់ នៃវរសេនាតូចការពារពញរំដែនលេខ៨១៥ ចំនួន០៤នាក់ និងកងកម្លាំងពាក់ព័ន្ធ ជួបប្រជុំពិភាក្សាជាមួយទាហានឈុតខ្មៅថៃអនុសេនាធំ ១៣.០៣ និងទាហានឈុតប៉ារ៉ាថៃ ដឹកនាំដោយលោកវរសេនីយ៍ឯក គិទិ ប្រាក់ភិតផៃសាន មេបញ្ជាការទាហានឈុតប៉ារ៉ាថៃ នៅមាត់អូរព្រំដែនខាងថៃចំណុចប៉ុស្តិ៍(អ.៤៦) ស្ថិតក្នុងភូមិខៅណយ ឃុំខ្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ទល់មុខប៉ុស្តិ៍ខ្លាងាប់ភូមិទួលពង្រ ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

តាមការបញ្ជាក់ឲ្យដឹងពីលោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ ៨១៥ បានឲ្យដឹងថា នៅក្នុងកិច្ចជំនួបប្រជុំពិភាក្សានេះ ក្នុងគោលបំណងទី១-គឺដើម្បីរឹតចំណង សាមគ្គីភាពនិងមានកិច្ចសហប្រតិបត្តិការល្អជាមួយគ្នា ដើម្បីធ្វើឲ្យព្រំដែនមានសុខសន្តិភាព ស្ថេរភាព សហប្រតិបត្តិការនិងការអភិវឌ្ឍ។ ទី២/-ផ្តល់ពត៌មានទៅវិញទៅមកនិង ទី៣/-រួមគ្នាទប់ស្កាត់រាល់បទ ល្មើសឆ្លងដែនគ្រប់ប្រភេទ ។

នៅថ្ងៃដដែលនេះផងដែរ វេលាម៉ោង០៩:០០នាទីព្រឹក កម្លាំងការពារព្រំដែនប៉ុស្តិ៍ប្រាសាទត្បែង នៃវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ប៊ុន គឹមហេង នាយរងប៉ុស្តិ៍ បានសហការជាមួយកម្លាំងយោធា វរៈសេនាតូចលេខ២០១ ចំនួន០៥នាក់ ដឹកនាំដោយលោក អនុសេនីយ៍ឯក ហេង វ៉ា មេបញ្ជាការគ៣ បានជួបប្រជុំពិភាក្សាការងារជាមួយភាគីថៃ ចំនួន០៤នាក់ ដឹកនាំដោយលោក វរសេនីយ៍ត្រី ថាន់ណាក់ ម៉ាក់ថាយ៉ុមម៉ាក់ មេកង លេខ១២.០១ នៅចំណុចប៉ុស្តិ៍លេខ៣ថៃ ក្នុងទឹកដីថៃ។ ខ្លឹមសារនៃកិច្ចពិភាក្សានេះ គឺសហការគ្នាទប់ស្កាត់រាល់បទល្មើសគ្រប់ប្រភេទនៅតាមបន្ទាត់ព្រំដែន និងទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់នៅថ្ងៃដដែល ក្រោមបរិយាកាសរីករាយនិងស្និទ្ធស្នាលក្រៃលែង៕

## ថ្ងៃទី២៨ ខែ មីនា ឆ្នាំ២០២២

# មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ
# ប្រាប់ឲ្យអាជ្ញាធរមូលដ្ឋានត្រូវទទួលខុសត្រូវ បង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៤ មីនា ២០២២ដោយ sopheak khoun

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងប្រាប់មេឃុំ-ចៅសង្កាត់ គប្បីប្រឹងប្រែងយកចិត្តទុដាក់ទប់ស្កាត់ និងបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស គ្រាបន្តរកឃើញបង្ក្រាបជិត ៤០០ករណី សម្រាប់ឆ្នាំ ២០២១។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឲ្យដឹងនៅថ្ងៃទី ២៤ ខែមីនានេះថា គ្រប់អាជ្ញាធរមូលដ្ឋាន ត្រូវបន្តចូលរួមតាមដាន កំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សឲ្យបានល្អប្រសើរ និងប្រមូលទិន្នន័យជាក់លាស់ ពីករណីបទល្មើសទាំងនេះ ចៀសវាងមជ្ឈដ្ឋានបរទេសអង្គការ ចោទប្រកាន់ថា ព្រងើយកន្តើយមិនយកចិត្តទុកដាក់។ លោកស្រី ជូ ប៊ុនអេង បានអះអាងនៅក្នុងវគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើ ជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របនៅខេត្តកោះកុងថា រាល់ការកំណត់អត្តសញ្ញាណ គឺមានសារៈ

សំខាន់ផ្តែកទៅលើច្បាប់កំណើត លើប្រតិបត្តិការបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់រូបភាព ដែលក្រុមជនល្មើសបានប្រព្រឹត្ត។

លោកស្រីអនុអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កត់សម្គាល់ទៀតថា ជាក់ស្តែង រាល់រៀងឆ្នាំអាជ្ញាធរសមត្ថកិច្ចជំនាញ បង្ក្រាបជាច្រើនរយករណី ភាគច្រើនជនរងគ្រោះត្រូវបានបញ្ជូនមកពីក្រៅប្រទេស និងមួយចំនួនទៀតកំណត់អត្តសញ្ញាណ បាននៅក្នុងប្រទេសផ្ទាល់។ ដូច្នេះគប្បី ទាមទារឲ្យអាជ្ញាធរសមត្ថកិច្ចមូលដ្ឋានទាំងអស់ បង្កើនការយកចិត្តទុកដាក់ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស ឲ្យបានទាន់ពេលវេលា គ្រាឆ្នាំ ២០២១កន្លងទៅ បន្តរកឃើញបង្ក្រាប ៣៥៩ករណី បើធៀបនឹងឆ្នាំ ២០២០ កើនឡើងគុណនឹង ២ដង។

យោងតាមរបាយការណ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្ហាញថា បន្ទាប់ពីរិះរកមធ្យោ បាយសង្គ្រោះស្ត្រី និងកុមារ ដែលរងគ្រោះដោយអំពើជួញដូរមនុស្ស គឺពួកគេសុទ្ធតែទទួលបានសេវាគាំពារ រហូតដល់ចប់នីតិវិធីនៃការអនុវត្តច្បាប់ រួមមាន៖ សេវាព្យាបាលសុខភាព សេវាសង្គមកិច្ច និងផ្តល់ស្បៀងអាហារស្នាក់នៅ ជាដើម។

លោកស្រី មិថុនា ភូថង អភិបាលខេត្តកោះកុង លើកឡើងថា ស្ត្រី និងកុមារ ដែលធ្វើចំណាកស្រុករកការងារធ្វើឆ្ងាយពីគ្រួសារ បង្កជាហានិភ័យដាច់ផុត ពីបណ្តាញសុវត្ថិភាពរបស់ពួកគេ ដែលពេលនោះងាយប្រឈមនឹងអំពើជួញដូរផ្លូវភេទ កម្លាំងពលកម្ម រៀបការផ្ទុយឆន្ទៈ ព្រមទាំងការកេងប្រវ័ញ្ចផ្សេងទៀតផងដែរ។ លោកស្រីអភិបាលខេត្ត ចាត់ទុកវគ្គសិក្សានៅថ្ងៃនេះ ដល់ក្រុមមន្ត្រីរដ្ឋបាល និងកម្លាំងប្រដាប់អាវុធមកពីស្រុកថ្មបាំង និងស្រុកកោះកុងថា ជាយន្តការពង្រឹងសមត្ថភាព ដល់អាជ្ញាធរមន្ត្រីសមត្ថកិច្ច ដើម្បីអនុវត្តបង្ក្រាបទប់ស្កាត់ ប្រកបដោយប្រសិទ្ធភាពខ្ពស់ អំពីរបៀបកំណត់អត្តសញ្ញាណជនងាយរងគ្រោះ ក្នុងមូលដ្ឋាន។ ទន្ទឹមនោះ លោកស្រី មិថុនា ភូថង ជំរុញឲ្យអាជ្ញាធរសមត្ថកិច្ចជំនាញ ក្នុងមូលដ្ឋាន បង្កើនយកចិត្តទុកដាក់ បង្ក្រាបបទល្មើសអំពើជួញដូរមនុស្សឲ្យបានទាន់ពេលវេលា ប្រសិនបើដឹងវាបម្រុងកើតមានពេលណាមួយ ដើម្បីឆ្លើយតបនឹងគោលនយោបាយ រាជរដ្ឋាភិបាលកម្ពុជា។

គួរជម្រាបថា ក្រុមអាជ្ញាធររដ្ឋបាល និងកងកម្លាំងសមត្ថកិច្ច មកពីស្រុកថ្មបាំង និងស្រុកកោះកុង ប្រមាណជា ៥០នាក់ បានទទួលវគ្គបណ្តុះបណ្តាល ពីការកំណតើអត្តសញ្ញាណជនរងគ្រោះ ដោយសារតែអំពើជួញដូរមនុស្សនេះចំនួន ២ថ្ងៃ៕ អត្ថបទ៖ សិរីវឌ្ឍនៈ

## លោកជំទាវ ជូ ប៊ុនអេង ៖
## បណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណ ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស

https://cen.com.kh/ Posted ByPen Srey NeatMarch 25, 2022

ខេត្តកោះកុង លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពក្នុងពិធី បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណ ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ជាមួយរដ្ឋបាលខេត្តកោះកុង ដោយមានកិច្ចសហការ ជាមួយអង្គការ អាស៊ានអាក់ (Asian Act) នៅថ្ងៃទី២៤-២៥ ខែមីនា ឆ្នាំ២០២២ ។ វគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សនេះផងដែរ ធ្វើឡើងក្នុងគោលបំណង ដើម្បីឱ្យអ្នកមានភារកិច្ច កំណត់អត្តសញ្ញាណជនរងគ្រោះយល់បានច្បាស់ ពីនីតិវិធី និងអាចប្រើប្រាស់ បែបបទដែលពាក់ព័ន្ធ ក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ យល់ដឹងអំពីច្បាប់ និងអាចសន្និដ្ឋានជាបឋម ដោយភាពប្រាកដប្រជា ដើម្បីទទួលបានលទ្ធផល និង

ព័ត៌មានគ្រលប់ស្តីពី ការប្រើប្រាស់បទដ្ឋាននានា ភាពប្រឈម និងចំនុចខ្វះខាតនៃការ ណែនាំក្នុងការអនុវត្ត ដើម្បីកែលម្អ បង្កើនប្រសិទ្ធភាពការងារ ក្នុងការផ្តល់ សេវាបឋមជូនដល់ជនរងគ្រោះ ។

លោកជំទាវ មិថុនា ភូថង អភិបាល នៃគណៈអភិបាលខេត្តកោះកុង បានធ្វើសេចក្តីរាយការណ៍ខ្លី ស្តីអំពីស្ថានភាពរបស់រដ្ឋបាលខេត្តកោះកុង ។ លោកជំទាវ អភិបាលខេត្តបានថ្លែងបញ្ជាក់បន្ថែម វត្តមានរបស់លោក លោកស្រី ពិតជាបានបង្ហាញឱ្យឃើញពីកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួត ជាមួយមន្ត្រីអនុវត្តផ្ទាល់នៅថ្នាក់ខេត្ត ក្រុង/ស្រុក ឃុំ/សង្កាត់ និងនៅតាមមូលដ្ឋាន ដើម្បីអនុវត្តភារកិច្ច ប្រកបដោយការទទួលខុសត្រូវ និងរួមសហការគ្នាឆ្ពោះទៅកាន់គោលដៅរួមតែមួយគឺដើម្បីសេចក្តីសុខ និងភាពរីកចម្រើនរបស់មនុស្សជាតិ ។

អញ្ជើញមានមតិចាប់អារម្មណ៍ ក្នុងពិធីបើកវគ្គនេះលោកជំទាវ ជូ ប៊ុនអេង បានគូសបញ្ជាក់ថាវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ មានគោលដៅជំរុញអនុវត្តគោលការណ៍ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់ អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលប្រកាស ដាក់ឲប្រើប្រាស់ពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីឱ្យជនរងគ្រោះទទួលបានសេវាបឋម ចាំបាច់ បន្ទាន់ និងអាចបន្តជួយគាំទ្រផ្តល់កិច្ចការពារ តាមរយៈសេវាបញ្ជូន ទៅគោលដៅ ផ្តល់សេវា ជាក់លាក់ ។ ម្យ៉ាងទៀតវគ្គបណ្តុះបណ្តាលដែលមានរយៈពេល២ថ្ងៃនេះ នឹងផ្តល់ឱ្យលោក លោកស្រី ដែលជាសិក្ខាកាម មានការយល់ដឹងកាន់តែច្បាស់អំពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយ អំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប" ដែលជាកត្តាមួយយ៉ាងសំខាន់ ក្នុងការអនុវត្តការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាពេលខាងមុខកាន់តែមានប្រសិទ្ធិភាព និងប្រសិទ្ធិផល និងសំនូមពរសិក្ខាកាមទាំងអស់ ចូលរួមផ្តល់មតិយោបល់ ឲ្យបានផុលផុសទៅលើខ្លឹមសារនៃមេរៀនគោលការណ៍ណែនាំនេះផងដែរ ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## ពលករខ្មែរប្រមាណ ៣០០ ទៅ ៥០០ នាក់ ក្នុង ១ ថ្ងៃ បានធ្វើដំណើរចូលតាមច្រកព្រំដែនអូរស្មាច់ មកលេងបុណ្យចូលឆ្នាំ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២៥ មីនា ២០២២ដោយ deth leng

លោក ឌី វ៉ាដូ អភិបាលរង និងជាអ្នកនាំពាក្យខេត្តឧត្តរមានជ័យ មានប្រសាសន៍ឱ្យដឹងនៅព្រឹកថ្ងៃទី ២៥ ខែមីនានេះថា បច្ចុប្បមានពលករខ្មែរ ដែលកំពុងបម្រើការងារ និងស្នាក់នៅប្រទេសថៃប្រមាណ ៣០០ នាក់ ទៅ ៥០០ នាក់ បានធ្វើដំណើរមកលេងស្រុក។ បងប្អូនពលករបាននាំគ្នាសម្រុកចេញពីប្រទេសថៃចូលតាមច្រកព្រំដែនអន្តរជាតិអូរស្មាច់ខេត្តឧត្តរមានជ័យដើម្បីមកលេងស្រុក និងចូលរួមពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិដែលនឹងឈានចូលមកដល់នៅពាក់កណ្តាលខែក្រោយនេះ។ អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យបានបន្តថា ចាប់តាំងពីដើមឆ្នាំ ២០២២ រហូតមកដល់ពេលនេះចំនួនបងប្អូនពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ តាមច្រកអូស្មាច់មានការកើនឡើងជាបន្តបន្ទាប់ដោយក្នុង១ថ្ងៃ គិតជាមធ្យមមានប្រមាណ៣០០នាក់ និងមានថ្ងៃខ្លះកើនឡើងដល់៥០០នាក់ ក៏មានដែរ។ លោកបានបន្តទៀតថា ការសម្រុកធ្វើដំណើរចេញពីប្រទេសថៃចូលមកកម្ពុជារបស់បងប្អូនពលករខ្មែរនេះ គឺដោយសារពួកគាត់នឹករលឹកស្រុកកំណើត ដែលពួកគាត់ខកខានមកលេងរយៈពេល២ឆ្នាំមកហើយ និងមួយទៀតដើម្បីមកចូលរួមពិធីបុណ្យចូលឆ្នាំខ្មែរនាពេលខាងមុខផងដែរ ព្រោះរដ្ឋាភិបាលបានផ្អាកប្រារព្ធពិធីនេះ២ឆ្នាំ ដោយសារការរាតត្បាតជំងឺកូវីដ១៩។

អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យបានបន្ថែមទៀតថាបច្ចុប្បន្ននេះតាមការណែនាំរបស់ក្រសួងសុខាភិបាលពលករខ្មែរធ្វើដំណើរមកពីថៃ ដែលបានចាក់វ៉ាក់សាំងបានចំនួន២ដូសហើយមិនត្រូវបានធ្វើតេស្តរកជំងឺកូវីដ១៩ទៀតទេនិងតម្រូវឱ្យពួកគាត់ធ្វើដំណើរទៅស្រុកកំណើតតែម្តង។ ប៉ុន្តែចំពោះពលករណាដែលចាក់វ៉ាក់សាំងមិនបាន

គ្រប់ដូសឬមិនទាន់បានចាក់វ៉ាក់សាំងត្រូវអនុវត្តតាមគោលការណ៍ដដែលគឺត្រូវធ្វើតេស្តរកជំងឺកូវីដ១៩។អ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យបានបញ្ជាក់ថា បើលទ្ធផលតេស្តអវិជ្ជមានត្រូវបន្តធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃតែបើលទ្ធផលតេស្តវិជ្ជមានកូវីដ១៩ ត្រូវបញ្ជូនទៅព្យាបាលខណៈបច្ចុប្បន្នមានពលករកំពុងស្នាក់នៅមណ្ឌលចត្តាឡីស័កនៅពហុកីឡដ្ឋានក្រុងសំរោង និងកន្លែងព្យាបាលនៅស្រុកអន្លង់វែងមានប្រមាណ៣៦១នាក់៕ អត្ថបទ៖ សំអឿន

## អគ្គស្នងការដ្ឋាននគរបាលជាតិ ច្រានចោលទាំងស្រុងនូវ ខ្លឹមសារសម្ភាសន៍ របស់ភរិយាលោក រ៉ាត់ វ័ន្នមុន្នី ដែលញុះញង់ឲ្យមានការរើសអើង និងមួលបង្កាច់រដ្ឋាភិបាល

http://freshnewsasia.com/ 2022-03-26 10:05am

**(ភ្នំពេញ)៖** អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២នេះ បានច្រានចោលទាំងស្រុងនូវ ខ្លឹមសារសម្ភាសន៍របស់ភរិយាលោក រ៉ាត់ វ័ន្នមុន្នី តាមវិទ្យុបរទេសមួយ ដែលបានវាយប្រហារតាម បែបអគតិបង្ករការញុះញង់ឲ្យមានការរើសអើង និងមួលបង្កាច់ការពិត ធ្វើឲ្យប៉ះពាល់ដល់កិត្តិយសកិត្យានុភាព និងសេចក្តីថ្លៃថ្នូរ របស់រាជរដ្ឋាភិបាលកម្ពុជា។ តាមសេចក្តីប្រកាសដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅថ្ងៃនេះ អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានចាត់ទុកថា ខ្លឹមសារសម្ភាសន៍របស់ស្ត្រីឈ្មោះ ឡុង គឹមហ៊ាង គឺជាការបញ្ចេញកំហឹងសងសឹកទាំងងងឹតងងុល ពិសេសការពោលពាក្យតាមបែបអគតិមានទស្សនៈចង្អៀតចង្អល់ ស្អប់ខ្ពើម និងប្រមាថជាតិកំណើតរបស់ខ្លួន ដែលជាសម្តីបំផ្លើសផ្ទុយពីការពិត ព្រោះថាបើសម្តីទាំងនេះជាការពិតនោះ ម្ល៉េះសមស្តី ឡុង គឹមហ៊ាង និងស្វាមីឈ្មោះ រ៉ាត់ វ័ន្នមុន្នី មិនអាចមានសេរីភាពចាកចេញពីប្រទេសកម្ពុជាបានឡើយ។

សេចក្តីប្រកាសរបស់ អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានលើកឡើងថា៖ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ កន្លងទៅថ្មីៗនេះ មានវិទ្យុបរទេសនិយាយភាសាខ្មែរមួយ បានធ្វើការផ្សព្វផ្សាយកិច្ចសម្ភាសជាមួយស្ត្រីឈ្មោះ ឡុង គឹមហ៊ាង ដែលមានខ្លឹមសារវាយប្រហារតាម បែបអគតិបង្ករការញុះញុងឲ្យមានការរើសអើង និងមួលបង្កាច់ការពិត ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស កិត្យានុភាព និងសេចក្តីថ្លៃថ្នូររបស់ព្រះរាជាណាចក្រកម្ពុជា។ អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជាក់ជូនសាធារណៈមតិជាតិ-អន្តរជាតិ បានជ្រាបថា៖ ស្ត្រីឈ្មោះ ឡុង គឹមហ៊ាង គឺជាភរិយារបស់ឈ្មោះ រ៉ាត់ វ័ន្នមុន្នី ដែលបុរសរូបនេះ ធ្លាប់បានធ្វើសកម្មភាពលួងលោមជនរងគ្រោះ០២នាក់ម្តាយ និងកូនស្រី ឲ្យថតជាខ្សែវីដេអូឯកសារ ដោយកុហកថា ជាខ្សែវីដេអូ និយាយអំពីការរីកចម្រើនរបស់ប្រទេសកម្ពុជាក្រោយរបបខ្មែរក្រហម និងសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ។ ប៉ុន្តែតាមការពិតខ្សែវីដេអូដែលថតនេះ ត្រូវបានផ្សព្វផ្សាយតាមបណ្តាញសង្គម មានចំណងជើងថា «ម្តាយខ្ញុំលក់ខ្ញុំ» ដែលមានខ្លឹមសារធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយសប្រពៃណីជាតិ និងសេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរ។ ផ្អែកតាមបណ្តឹងជនរងគ្រោះ០២នាក់ម្តាយ និងកូនស្រី សមត្ថកិច្ចបានបើកការស្រាវជ្រាវស៊ើបអង្កេត ដោយប្រមូលភស្តុតាងជាច្រើន កសាងសំណុំរឿងបញ្ជូនទៅតុលាការ ហើយត្រូវបានតុលាការចេញដីកាចាប់ខ្លួន និងបើកសវនការផ្តន្ទាទោសបុរសឈ្មោះ រ៉ាត់ វ័ន្នមុន្នី ដាក់ពន្ធនាគារកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ កំណត់រយៈពេល ០២ឆ្នាំ ពីបទ **«ញុះញង់ឲ្យមានការរើសអើង»**។

អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានបន្ថែមថា ក្នុងអំឡុងពេលស្រាវជ្រាវចាប់ខ្លួន និងអនុវត្តទោសលើបុគ្គលឈ្មោះ រ៉ាត់ វ័ន្នមុន្នី នោះស្ត្រីឈ្មោះ ឡុង គឹមហ៊ាង ត្រូវជាភរិយាគ្មានវត្តមានក្នុងប្រទេសកម្ពុជាឡើយ។ ដោយឡែកតាមព័ត៌មានដែលសមត្ថកិច្ចទទួលបានជនឈ្មោះ រ៉ាត់ វ័ន្នមុន្នី នេះបានចាកចេញពីប្រទេសកម្ពុជាទៅរស់នៅក្រៅប្រទេសបន្ទាប់ពីអនុវត្តទោសរួច។ ការផ្តល់កិច្ចសម្ភាសន៍របស់ស្ត្រីឈ្មោះ ឡុង គឹមហ៊ាង គឺមានចេតនាយ៉ាងច្បាស់ក្នុងការបំភាន់មតិ ជាតិ-អន្តរជាតិ ឲ្យមានការយល់ច្រលំចំពោះនយោបាយគ្រប់គ្រង ដឹកនាំរបស់

រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបង្ហាញឲ្យឃើញអំពីសារជាតិពុតត្បុត ញុះញង់ឲ្យប្រជាពលរដ្ឋខ្មែរបញ្ឈប់ការគាំទ្ររាជរដ្ឋាភិបាល។ ចំពោះការផ្តន្ទាទោសបុគ្គលឈ្មោះ វ៉ាត់ វ៉ត្ថមុន្នី គឺជាការអនុវត្តនូវគោលការណ៍ច្បាប់នៃប្រទេស នីតិរដ្ឋ ព្រោះបុគ្គលរូបនេះបានប្រព្រឹត្តល្មើសទៅនឹងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

«ដូច្នេះខ្លឹមសារសម្ភាសន៍របស់ស្ត្រីឈ្មោះ ឡុង គីមហ៊ាង គឺជាការបញ្ចេញកំហឹងសងសឹកទាំងងងិតងងុល ពិសេសការពោលពាក្យតាមបែបអគតិ មានទស្សនៈចង្អៀតចង្អល់ ស្អប់ខ្ពើម និងប្រមាថជាតិកំណើតរបស់ខ្លួន ដែលជាសម្តីបំផ្លើសផ្ទុយពីការពិត ព្រោះថាបើសម្តីទាំងនេះជាការពិតនោះ ម៉្លេះសមស្តី ឡុង គីមហ៊ាង និងស្វាមីឈ្មោះ វ៉ាត់ វ៉ត្ថមុន្នី មិនអាចមានសេរីភាពចាកចេញពីប្រទេសកម្ពុជាបានឡើយ»។ នេះបើតាមអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ។ អ្នកនាំពាក្យនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏បានបដិសេធច្រានចោលទាំងស្រុងនូវ ខ្លឹមសារសម្ភាសន៍រវាងវិទ្យុបរទេសនិយាយភាសាខ្មែរជាមួយស្ត្រីឈ្មោះ ឡុង គីមហ៊ាង និងចាត់ទុកថា កិច្ច សម្ភាសន៍នេះ គឺជាការរៀបចំវេទិកាក្នុងគោលបំណងទុច្ចរិត បង្កើតឲ្យមានការភាន់ច្រលំ និងញុះញង់បង្កឲ្យ មានការរើសអើងចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងបំណងកេងចំណេញនយោបាយ និងបង្កអស្ថិរភាពក្នុង ប្រទេសកម្ពុជា។ តាមរយៈការបំភ្លឺជូនខាងលើ អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិសង្ឃឹមថា សាធារណជនក៏ដូចជាសាធារណៈមតិជាតិ-អន្តរជាតិ ធ្វើការពិចារណាចំពោះហេតុផល និងវិនិច្ឆ័យគ្រប់ជ្រុងជ្រោយ ដោយពុំមានការភ័ន្តច្រលំ ជឿលង់ តាមខ្លឹមសារមួលបង្កាច់បែបអគតិ ដែលស្ត្រីឈ្មោះ ឡុង គីមហ៊ាង បានសម្ភាសន៍នោះឡើយ៕

## ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០២២

### នាយករដ្ឋមន្ត្រីកម្ពុជា ៖
### អ្នកកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលតាមព្រំដែនមានប្រមាណជាង១ពាន់នាក់

https://kohsantepheapdaily.com.kh/ ភ្នំពេញ២៨ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ១០:១៥

រាជធានីភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានលើកឡើងថា អ្នកដែលមិនបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ មកពីថៃ ជាង១០០០នាក់បានកំពុងធ្វើចត្តាឡីស័កនៅតាមព្រំដែនកម្ពុជា-ថៃ ។ សម្តេចតេជោ បានថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារមជ្ឈមណ្ឌលត្រចៀក ច្រមុះ បំពង់ក នៃមន្ទីរពេទ្យព្រះអង្គឌួង នាព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ថា នៅក្នុងប្រទេសជិតខាងអត្រាអ្នកឆ្លងជំងឺកូវីដ១៩ មានចំនួនកើនជាក់ស្តែងនៅក្នុងប្រទេសថៃមានអ្នកឆ្លងមានរហូតដល់៣ម៉ឺននាក់ ក្នុងមួយថ្ងៃ ក្នុងពេលកម្ពុជាកំពុងធ្លាក់ចុះអ្នកឆ្លងជំងឺនេះ ។ សម្តេចបញ្ជាក់ថា ៖«យើងកំពុងធ្វើការគ្រប់គ្រងយ៉ាងម៉ត់ចត់ នៅតាមច្រកព្រំដែនកម្ពុជា ថៃ ហើយអ្នកដែលមិនទាន់បានចាក់វ៉ាក់សាំងគ្រប់គ្រាន់ ដែលធ្វើដំណើរពីប្រទេសថៃមក យើងត្រូវឲ្យពួកគាត់ធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ដែលមកដល់ពេលនេះនៅសល់ប្រមាណជាង១០០០នាក់ នៅក្នុងមណ្ឌលចត្តាឡីស័កនានា នៅព្រំដែនកម្ពុជា-ថៃ»។

សម្តេចក៏បានលើកឡើងថា ចំពោះអ្នកធ្វើចត្តាឡីស័កនៅតាមព្រំដែននេះដែរ មានរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីម្នាក់ បានតាមដានយ៉ាងយកចិត្តទុកដាក់ ចំពោះករណីអ្នកធ្វើចត្តាឡីស័ក នៅតាមព្រំដែនកម្ពុជា- ថៃ ដោយផ្ញើមកសម្តេចផ្ទាល់ផងដែរ។ ជាមួយនោះដែរ សម្តេចក៏បានលើកឡើងថា ចំពោះអ្នកដែលមកពីក្រៅប្រទេសទាំងឡាយ ដែលមកតាមព្រលានយន្តហោះ គឺសម្តេចបានអនុញ្ញាតឲ្យលើកលែងទាំងការធ្វើចត្តាឡីស័កការធ្វើតេស្តការតម្រូវវិញ្ញាបណ្ណបត្រ៧២ម៉ោងក៏ត្រូវការដែរ។ អីញ៉ឹងពេលមកដល់ស៊ុវីសាក៏មិនចាំសុំកន្លែងណាទេ គឺផ្តល់ឲ្យតែម្តង។

សម្តេចបន្តថា ការធ្វើបែបនេះ ដើម្បីសម្រួលដល់អ្នកធុរៈកិច្ច អ្នកការទូត អ្នកទេសចរណ៍មកកម្ពុជា ។ តែយើងមិនអាចមើលស្រាលចំពោះអ្វីដែលបានកំពុងកើតនៅក្នុងប្រទេសរបស់យើងនោះទេ ។ សម្តេចថា ៖«យើងធូរស្រាលក៏តែយើងនៅតែប្រឹងប្រែងតាមដានពិនិត្យបញ្ហានេះ និងតាមដានបញ្ហានេះឲ្យជាប់» ៕

## នៅរសៀលថ្ងៃសៅរ៍ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/26/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅរសៀលថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុ៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៤នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង បានចំនួន០២លើក សរុបចំនួន២១នាក់ ស្រី០៩នាក់ ក្មេងស្រី០១នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺអវិជ្ជមាន និងមានប័ណ្ណចាក់វ៉ាក់សាំងស្តែនចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## នៅព្រឹកថ្ងៃសៅរ៍ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/26/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង០០នាទី នាថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៤នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំ

សិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង បានចំនួន០២លើក សរុបចំនួន១៣៧នាក់ ស្រី៦០នាក់ ក្មេង១៥នាក់ ក្មេងស្រី០៨នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) តែមិនមាន។ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺអវិជ្ជមាន។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន១៣១នាក់ ស្រី៥៦នាក់ ក្មេង១៤នាក់ ក្មេងស្រី០៨នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្ដែនអត់ចេញ ចំនួន០៦នាក់ ស្រី០៤នាក់ ក្មេងប្រុសម្នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្ហា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ប៉ូលិសជាន់ខ្ពស់ថៃទទួលបន្ទុក
## ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សត្រូវបានរំពឹងនឹងមកទីក្រុងភ្នំពេញក្នុងសប្តាហ៍នេះ

https://www.khmertimeskh.com/ March 28, 2022

ឧត្តមសេនីយ៍ទោ Surachat ដែលទទួលបន្ទុកប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស គ្រោងនឹងមកទីក្រុងភ្នំពេញនៅចុងសប្តាហ៍នេះ ដើម្បីពិភាក្សាអំពីការបញ្ជូនជនជាតិថៃ ដែលត្រូវបានប្រមូលផ្តុំដោយអាជ្ញាធរមូលដ្ឋាន។ ការបញ្ជូនជនជាតិថៃត្រឡប់ទៅវិញនេះមិនត្រូវបានគេរំពឹងថា នឹងធ្វើដំណើរតាមផ្លូវគោក ឬតាមផ្លូវអាកាសទេ ប៉ុន្តែតាមកប៉ាល់។ ប៉ូលីសភូមិន្ទថៃ (RTP) ត្រូវបានដកស្រង់ដោយ Bangkok Post បាននិយាយថា ជនជាតិថៃ ដែលធ្វើការជាអ្នកបោកប្រាស់តាមទូរស័ព្ទនៅកម្ពុជា ហើយអ្នកខ្លះដែលត្រូវបានគេបង្ខំអោយធ្វើការនេះ អាចត្រូវបានបញ្ជូនទៅវិញតាមកប៉ាល់។ ប្រភពបាននិយាយថា គំនិតនៃការបញ្ជូនទៅវិញតាមកប៉ាល់ត្រូវបានស្នើឡើងដោយអគ្គស្នងការនគរបាលជាតិ ឧត្តមសេនីយ៍ទោ Surachate Hakparn ហើយត្រូវបានអនុម័តដោយនាយករដ្ឋមន្ត្រី Prayut Chan-o-cha ។

ប្រភពបាននិយាយទៀតថា ជំនួយការមេប៉ូលីសបានជួបលោកឧត្តមសេនីយ Prayut និងពិភាក្សាអំពីផែនការនាំជនជាតិថៃត្រឡប់មកវិញតាមកប៉ាល់ ប៉ុន្តែនៅមិនទាន់ច្បាស់ថា តើប្រតិបត្តិការនេះនឹងត្រូវបានធ្វើឡើងដោយរបៀបណាទេ។ គេប៉ាន់ប្រមាណថា មានជនជាតិថៃចន្លោះពី ៣.០០០ ទៅ ៤.០០០ នាក់ កំពុងធ្វើការដោយខុសច្បាប់នៅកម្ពុជា។ អ្នកដែលត្រូវបានបញ្ជូនទៅវិញ នឹងត្រូវចាត់ទុកថា ជាជនរងគ្រោះនៃការជួញដូរមនុស្ស។ ទោះយ៉ាងណាក៏ដោយ ទន្ទឹមនឹងនោះ ពួកគេអាចប្រឈមមុខនឹងចំណាត់ការផ្លូវច្បាប់ចំពោះការបំពានច្បាប់អន្តោប្រវេសន៍ ដោយចាកចេញពីប្រទេសដោយខុសច្បាប់មកកម្ពុជា។

ជាមួយគ្នានេះ ប្រភពពីការិយាល័យអន្តោប្រវេសន៍ បាននិយាយថា មិនមែនជនជាតិថៃទាំងអស់ ត្រូវបានគេបោកប្រាស់ និងបង្ខំឱ្យធ្វើការនៅទីនោះនោះទេ។ជាក់ស្តែង ជនជាតិថៃជាង៩០%បានទៅប្រទេសកម្ពុជាដោយព្រមព្រៀងគ្នាហើយយល់ព្រមធ្វើការឱ្យក្រុមជនពាលទាំងនោះ។ ប្រភពបាននិយាយថា វាមិនត្រូវនោះទេក្នុងការចាត់ទុកជនជាតិថៃទាំងអស់ដែលធ្វើការអោយក្រុមជនពាលជាជនរងគ្រោះដោយសារការជួញដូរមនុស្ស។ ម្យ៉ាងទៀត ការរៀបចំបញ្ជូនទៅវិញអាចជារឿងលំបាក ដោយសារក្រុមជនពាលនៅតែបន្តប៉ុនប៉ងចាប់ខ្លួនពួកគេទាំងនោះ។ ប្រភពដដែលបន្តថា មេក្រុមជនពាលខ្លះជាជនជាតិចិន ហើយជឿថាមានសកម្មភាព និងបណ្តាញច្រើននៅក្នុងប្រទេសកម្ពុជា។ កាលពីពេលថ្មីៗនេះ ជនជាតិថៃចំនួន ៥៩នាក់ និងជនជាតិចិន ២នាក់ ត្រូវបានឃុំខ្លួនកំឡុងពេលវាយ

ធ្លាក់ដោយប៉ូលីសថៃ និងកម្ពុជា ពីបទឆបោកតាមទូរស័ព្ទនៅខេត្តព្រះសីហនុ ក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមអ្នកជាប់ឃុំនោះ មា ២៨នាក់ ត្រូវបានចាត់ទុកថា ជាជនសង្ស័យ និង៥នាក់ ត្រូវបានបញ្ឆោតឱ្យធ្វើការនេះ ហើយអ្នកនៅសេសសល់កំពុងត្រូវបានស៊ើបអង្កេតនៅឡើយ នេះបើយោងតាមក្រុមប៉ូលីស Cyber Taskforce ( PCT )។

## នៅរសៀលថ្ងៃអាទិត្យ អាជ្ញាធរស្រុកសំពៅលូន បន្តទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/27/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅរសៀលថ្ងៃអាទិត្យ ១០រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន ០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករង សំពៅលូនចំនួន០៤នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធា វរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបងចំនួន០២លើក សរុបចំនួន៧៥នាក់ ស្រី២៣នាក់ ក្មេង១៩នាក់ ក្មេងស្រី០៧នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺអវិជ្ជមាន និងមានប័ណ្ណចាក់វ៉ាក់សាំងស្លែនចេញត្រឹមត្រូវទាំងអស់ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## កម្ពុជានឹងមានមជ្ឈមណ្ឌលសម្រាប់ប្រយុទ្ធប្រឆាំងបទល្មើសលើកុមារជាលើកដំបូង

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៨ មីនា ២០២២ដោយ Sokhom Khon

កម្ពុជានឹងមានមជ្ឈមណ្ឌលថ្មីសម្រាប់ប្រយុទ្ធប្រឆាំងបទល្មើសលើកុមារ និងផ្តល់ការថែទាំដល់ជនរងគ្រោះជាលើកដំបូងដើម្បីជួយដល់កុមាររងគ្រោះ ក៏ដូចជាចាប់ជនសង្ស័យឱ្យបានទាន់ពេលវេលា ។

ថ្លែងនៅក្នុងជំនួបពិភាក្សាការងារជាមួយនាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ កាលពីចុងសប្តាហ៍កន្លងទៅនេះ លោក James Neeson នាយកប្រតិបត្តិ នៃអង្គភាពការពារកុមារ CPUបានឱ្យដឹងថា គម្រោងសាងសង់មជ្ឈមណ្ឌលថ្មីរបស់អង្គការមូលនិធិកុមារកម្ពុជា នឹងចំណាយទឹកប្រាក់២០លានដុល្លារអូស្ត្រាលី មានទីតាំងតាមបណ្តោយផ្លូវជាតិលេខ២ ហើយមជ្ឈមណ្ឌលនេះសម្រាប់បម្រើការរួមមាន បន្ទប់សម្រាប់វគ្គបណ្តុះបណ្តាល សិក្ខាសាលា,បន្ទប់ស្នាក់នៅសម្រាប់ថែទាំជនរងគ្រោះ, បន្ទប់សម្រាប់ប្រឹក្សាផ្នែកច្បាប់,បន្ទប់ធ្វើកោសល្យវិច័យ ពេទ្យចិត្តសាស្ត្រ, បន្ទប់ព័ត៌មានវិទ្យា សម្រាប់ទទួលព័ត៌មាន និងទំនាក់ទំនងជាមួយស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងមានអ្នកជំនាញធ្វើកោសល្យវិច័យគ្រឿងអេឡិចត្រូនិច ដែលអាចទាញយកឯកសារ ឬរូបភាពចេញពីកុំព្យូទ័រ ទូរស័ព្ទដៃរបស់ជនរងគ្រោះឬជនសង្ស័យបាន និងមានបន្ទប់ស្នាក់នៅសម្រាប់កម្លាំងនគរបាល ប្រចាំការបំពេញភារកិច្ច និងចុះប្រតិបត្តិការ២៤/២៤ម៉ោង។ លោក James Neeson បានបន្តថា គម្រោងសាងសង់នេះតាម

ផែនការត្រូវសាងសង់រួចនៅដើមឆ្នាំ២០២៤ តែអាចដំណើរការជាបណ្ដើរៗនៅចុងឆ្នាំ២០២៣ ។ លោក James Neeson បានបន្តទៀតថា មជ្ឈមណ្ឌលនេះកើតឡើងដំបូងគេនៅកម្ពុជា ដែលបង្ហាញអន្តរជាតិឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាដល់ប្រជាពលរដ្ឋ ពិសេសជួយដល់កុមាររងគ្រោះ ដែលកិច្ចសហប្រតិបត្តិការនេះមានរយៈពេល១០ឆ្នាំទៅមុខទៀត ។

លោកស្រីនាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ បានគាំទ្រលើគម្រោងសាងសង់មជ្ឈមណ្ឌលថ្មីនេះ ដែលមានបន្ទប់បម្រើតាមជំនាញផ្សេងៗដើម្បីជួយដល់កុមាររងគ្រោះទាន់ពេលវេលានិងចាប់ជនសង្ស័យដោយមានជំនាញធ្វើកោសល្យវិច័យរកភស្តុតាងដាក់បន្ទុកលើជនសង្ស័យ។ លោកស្រីនាយឧត្តមសេនីយ៍បានវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងសហការល្អរវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា ជាមួយអង្គការមូលនិធិកុមារកម្ពុជា (CPU )។ នៅក្នុងជំនួបនោះ ភាគីទាំងពីរក៏បានពិភាក្សាទៅលើការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គការ ( CPU ) និងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការស៊ើបអង្កេតបង្ក្រាបបទល្មើសប្រឆាំងនឹងកុមារ និងការបណ្ដុះបណ្ដាលជំនាញដល់មន្ត្រីនគរបាលជាតិកម្ពុជាផងដែរ៕ អត្ថបទ៖ សំអឿន

## ថ្ងៃទី៣០ ខែ មីនា ឆ្នាំ២០២២

## ពលករខ្មែរជាង ១០០នាក់បន្ថែមទៀតត្រូវសមត្ថកិច្ចថៃចាប់បញ្ជូនមកកាន់ស្រុកកំណើត

http://nokorwatnews.com/ 29/03/2022

ខេត្តបាត់ដំបង ៖ ពលករខ្មែរប្រុសស្រីជាង ១០០នាក់ ត្រូវសមត្ថកិច្ចថៃចាប់បញ្ជូនត្រឡប់មកស្រុកកំណើតវិញក្រោយរកឃើញថាពួកគេលួចឆ្លងដែនដោយគ្មានច្បាប់អនុញ្ញាត។

សមត្ថកិច្ចបានឲ្យដឹងថា ការបញ្ជូនពលករខ្មែរឱ្យមកស្រុកកំណើតវិញគឺនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២នេះ ដោយកម្លាំងប៉ុស្តិ៍គីឡូ១៣ សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន កម្លាំងយោធាវរសេនាតូចលេខ៥៣៣ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកត្រង់ភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ បន្ទាប់ពីសាកសួរកត់ឈ្មោះរួចឃើញថា ពលករខ្មែរដែលទទួលត្រឡប់មកស្រុកកំណើតនាថ្ងៃនេះសរុបមានចំនួន ១៤០នាក់ ក្នុងនោះ ស្រី ៥៦នាក់ និងក្មេង១៦នាក់ត្រូវបានក្រុមគ្រូពេទ្យធ្វើតេស្តរហ័ស ជាលទ្ធផល វិជ្ជមានកូវីដ-១៩ ចំនួន០២នាក់ ស្រី០១នាក់ត្រូវបានបញ្ជូនទៅព្យាបាលនៅមណ្ឌលស្រុកសំពៅលូន ដោយឡែកពលករចំនួន ១៩នាក់ ស្រី០៦នាក់ ក្មេង០៣នាក់ មានកាតចាក់វ៉ាក់សាំងតែស្ដែនអត់ចេញត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័កនៅស្រុកសំពៅលូន ។ ហើយចំពោះពលករដែលទទួលបានកាតចាក់វ៉ាក់សាំងចំនួន ១១៩នាក់ ស្រី ៤៩នាក់ និងក្មេង ១៥នាក់ត្រូវបានក្រុមគ្រូពេទ្យធ្វើការអប់រំណែនាំអំពីវិធានការ ការពារ ការឆ្លងជំងឺកូវីដ-១៩ រួចអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## ឃាត់បានពលករខ្មែរត្រឡប់ពីថៃចូលមកកម្ពុជា

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៩ ខែ មីនា ឆ្នាំ ២០២២ ម៉ោង ០៩:០៤

ខេត្តបន្ទាយមានជ័យ ពលករខ្មែរនៅតែបន្តចូលមកកម្ពុជាវិញមានចំនួនជិត៣០២នាក់ ក្នុងនោះ រកឃើញវិជ្ជមានកូវីដ.១៩ ចំនួន៥នាក់ គិតត្រឹមថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ តាមច្រកចំនួន៣កន្លែង ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ទោ ម៉ាន់ ជី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាក្រុមការងារទទួលពលករខ្មែរបានប្រាប់ថាក្រុមការងារទទួលពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ មាន

ចំនួន២០៧នាក់ (ស្រី១០៣នាក់ កុមារ២៥នាក់ស្រី១២នាក់) រកឃើញវិជ្ជមានកូវីដ.១៩មានចំនួន៥នាក់ (ស្រី៤នាក់) ហើយមានពលករដែលមានឯកសារចាក់វ៉ាក់សាំងដូសទី២ និងទី៣មានចំនួន១៧៣នាក់ (ស្រី៨៤នាក់)។ ដោយឡែក នៅច្រកសង្កែ ស្រុកម៉ាឡៃ ក្រុមការបានទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃមានចំនួន៧១នាក់ (ស្រី២៦នាក់កុមារ១៦នាក់) និងច្រកបឹងត្រកួនស្រុកថ្មពួក ទទួលពលករខ្មែរដែលត្រឡប់ពីថៃចូលមកកម្ពុជាវិញមាន១៤នាក់ (ស្រី៦នាក់ក្មេង៣នាក់)។ លោកវរសេនីយ៍ទោ ម៉ាន់ ធី បានបញ្ជាក់ថា ចំពោះពលករខ្មែរដែលត្រឡប់ពីប្រទេសថៃដែលមកកម្ពុជាវិញដែលត្រូវបានក្រុមការងារទទួលមាន១.ច្រកអូរបីជាន់ស្រុកអូរជ្រៅ ២.ច្រកសង្កែស្រុកម៉ាឡៃ ៣.ច្រកបឹងត្រកួន ស្រុកថ្មពួក ហើយពលករខ្មែរដែលមានឯកសារចាក់វ៉ាក់សាំងដូសទី២ និងទី៣ក្រោយត្រួតពិនិត្យសុខភាពហើយអោយត្រឡប់ស្រុកកំណើតវិញ និងអ្នកដែលគ្មានឯកសារចាក់វ៉ាក់សាំងត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃនៅមណ្ឌលក្រុងប៉ោយប៉ែត និងអ្នកដែលរកឃើញវិជ្ជមានកូវីដ.១៩ ត្រូវបានបញ្ជូនព្យាបាលនៅមណ្ឌលក្រុងសិរីសោភ័ណ៕

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារ
## ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ ខេត្តសៀមរាប

https://www.khmertimeskh.com/ កែវ រចនា / Khmer Times March 29, 2022

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់រដ្ឋបាលខេត្តសៀមរាប បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២១ ក្នុងបំណងដើម្បីបង្ហាញលទ្ធផលការងារ និងរៀបចំផែនការការងារនៅឆ្នាំបន្ទាប់។

ក្នុងពិធីនាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា ក្នុងការអនុវត្ត បង្ការ ទប់ស្កាត់ការបង្ក្រាបបទល្មើសនានាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើហិង្សាទាក់ទង់និងយេនឌ័រ ការផ្តន្ទាទោសជនល្មើស ការការពារជនរងគ្រោះ ការពង្រឹងសមត្ថភាពក្រុមការងារពាក់ព័ន្ធ និងកិច្ចសហប្រត្តិបត្តិការក្នុងរយៈពេល១ឆ្នាំមកនេះ ដើម្បីតាមដាន ត្រួតពិនិត្យ វាយតម្លៃលើលទ្ធផលការងារកន្លងមក។ លោកស្រីបន្ថែមថា កិច្ចប្រជុំនេះ នឹងមានក្រុមពិភាក្សា ដោយផ្តោតលើ ពីការអនុវត្តតួនាទី ភារកិច្ច បញ្ហាប្រឈម នៅក្នុងដំណើរការអនុវត្តការងាររបស់ក្រុមការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្នាក់ក្រុង ស្រុក ព្រមទាំងកិច្ចគាំពារ និងលើកកម្ពស់សុខុមាលភាព ជីវភាពរបស់ពលរដ្ឋបានវិលត្រឡប់ពីធ្វើការក្រៅប្រទេស ក្នុងវិបត្តិកូវិដ១៩ និង កិច្ចគាំពារកុមារ ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើកុមារតាមអនឡាញ , ព្រមទាំងការទប់ស្កាត់អំពើជួញដូរមនុស្ស និង អំពើហិង្សា ទាក់ទងនឹងយេនឌ័រផងដែរ។

មានប្រសាសន៍បើកកិច្ចប្រជុំនោះ លោក អ៊ាន យុន ក៏បានសម្តែងនូវការកោតសរសើរដោយស្មោះ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ លោក លោកស្រី ស្ថាប័នរដ្ឋ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ សំខាន់លេខាធិការដ្ឋាន គ.ខ.ប.ជ ដែលបានរួមគ្នាកន្លងមក ក្នុងកិច្ចសហប្រតិបត្តិការលើការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១ ឲ្យទទួលបានលទ្ធផលគួរជាទីមោទន ទោះស្ថិតនៅក្នុងកាលៈទេសៈនៃវិបត្តិជំងឺកូវីដ-១៩ យ៉ាងណាក៏ដោយ។ លោកសង្ឃឹមជឿជាក់ថានៅឆ្នាំ២០២២នេះ គណៈកម្មាធិការខេត្ត ដែលមានលេខាធិការដ្ឋាន ដែលជាសេនាធិការដឹកនាំសម្របសម្រួលនឹងបន្តអនុវត្តទៅតាមតួនាទី ភារកិច្ច ឲ្យសម្រេចបានជោគជ័យតាមផែនការដែលបានគ្រោងក្នុងកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍ខេត្ត៕

# CPU បង្ហាញគម្រោងសង់មជ្ឈមណ្ឌល
# មានតម្លៃ ២០ លានដុល្លារអូស្ត្រាលី ជួយកុមាររងគ្រោះពីការបំពានផ្លូវភេទ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 29 March 2022 | 09:14 ICT

**ភ្នំពេញៈ** អង្គភាពការពារកុមារ (CPU) បង្ហាញគម្រោងសាងសង់មជ្ឈមណ្ឌលថ្មីមួយនៅចុងឆ្នាំ ២០២៣ ខាងមុខក្នុងទំហំទឹកប្រាក់ប្រមាណ ២០ លានដុល្លារអូស្ត្រាលី សម្រាប់ជួយដល់កុមាររងគ្រោះពីការរំលោភបំពានផ្លូវភេទ និងមានបំពាក់ដោយទីតាំងជំនាញបច្ចេកទេសផ្សេងៗជាច្រើនទៀតសម្រាប់តាមចាប់ជនសង្ស័យលើករណីនេះ។ នេះបើតាមអគ្គស្នងការនគរបាលជាតិ។ ការបង្ហាញពីគម្រោងសាងសង់មជ្ឈមណ្ឌលថ្មីនេះធ្វើឡើងអំឡុងពេល លោក James McCabe នាយកប្រតិបត្តិ CPU បានជួបប្រជុំជាមួយលោកស្រី យក់ សុខា អគ្គស្នងការរងនគរបាលជាតិ កាលពីថ្ងៃទី ២៥ មីនា ដើម្បីប្រគល់ជូននូវរបាយការណ៍ប្រចាំឆ្នាំ និងរៀបរាប់អំពីគម្រោងរបស់ CPU សម្រាប់ ៥ ឆ្នាំខាងមុខនេះ ដែលនឹងមានការបង្កើននូវសេវាកម្ម និងការព្យាបាលជូនជនរងគ្រោះនៃបទល្មើសរំលោភផ្លូវភេទ រួមទាំងការបង្កើននូវសេវាកម្មគាំទ្រ និងសេវាកម្មស៊ើបអង្កេត។ កិច្ចប្រជុំនេះមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គភាព CPU និងអគ្គស្នងការដ្ឋាននគរបាលជាតិក្នុងការស៊ើបអង្កេតបង្ក្រាបបទល្មើសប្រឆាំងនឹងកុមារ និងការបណ្តុះបណ្តាលជំនាញដល់មន្ត្រីនគរបាលជាតិកម្ពុជាផងដែរ។ នេះបើតាមអគ្គស្នងការនគរបាលជាតិ។

យោងតាមរបាយការណ៍របស់ CPU ជម្រាបជូនលោកស្រី យក់ សុខា អំពីគម្រោងសាងសង់មជ្ឈមណ្ឌលថ្មីគឺមានទឹកប្រាក់ប្រមាណ ២០ លានដុល្លារអូស្ត្រាលី ដែលមានទីតាំងតាមបណ្តោយផ្លូវជាតិលេខ ២។ មជ្ឈមណ្ឌលនេះជាទីតាំងសម្រាប់បម្រើការងារផ្សេងៗ រួមមានបន្ទប់សម្រាប់វគ្គបណ្តុះបណ្តាល សិក្ខាសាលា បន្ទប់ស្នាក់នៅសម្រាប់ថែទាំជនរងគ្រោះ បន្ទប់សម្រាប់ប្រឹក្សាផ្នែកច្បាប់ បន្ទប់ធ្វើកោសល្យវិច្ច័យ ពេទ្យចិត្តសាស្ត្រ បន្ទប់ព័ត៌មានវិទ្យា សម្រាប់ទទួលព័ត៌មាន និងទំនាក់ទំនងជាមួយស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងមានអ្នកជំនាញធ្វើកោសល្យវិច័យគ្រឿងអេឡិចត្រូនិកដែលអាចទាញយកឯកសារ ឬរូបភាពចេញពីកុំព្យូទ័រ ទូរស័ព្ទដៃរបស់ជនរងគ្រោះ ឬជនសង្ស័យ។ ក្រៅពីនេះក៏មានបន្ទប់ស្នាក់នៅសម្រាប់កម្លាំងនគរបាលប្រចាំការបំពេញភារកិច្ច និង ចុះប្រតិបត្តិការ ២៤ ម៉ោងលើ ២៤ ម៉ោងផងដែរ។

លោក James McCabe បានឱ្យដឹងថា គម្រោងសាងសង់នេះតាមផែនការត្រូវសាងសង់រួចនៅដើមឆ្នាំ ២០២៤ តែអាចដំណើរការជាបណ្តើរៗនៅចុងឆ្នាំ ២០២៣។ មជ្ឈមណ្ឌលនេះ កើតឡើងដំបូងគេនៅកម្ពុជា ដែលបង្ហាញអន្តរជាតិឱ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាដល់ប្រជាពលរដ្ឋពិសេសជួយដល់កុមាររងគ្រោះ ដែលកិច្ចសហប្រតិបត្តិការនេះមានរយៈពេល ១០ ឆ្នាំទៅមុខទៀត។

លោកស្រី យក់ សុខា បានគាំទ្រលើគម្រោងសាងសង់មជ្ឈមណ្ឌលថ្មីនេះ ដែលមានបន្ទប់បម្រើតាមជំនាញផ្សេងៗ សម្រាប់ជួយដល់កុមាររងគ្រោះទាន់ពេលវេលា និងចាប់ជនសង្ស័យដោយមានជំនាញធ្វើកោសល្យវិច័យរកភ័ស្តុតាងដាក់បន្ទុកលើជនសង្ស័យ។ លោកស្រីបានវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងសហការល្អរវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជាជាមួយ CPU។

អង្គភាព CPU បានថ្លែង អបអរសាទរទៅដល់រាជរដ្ឋាភិបាល កម្ពុជា និងនគរបាលជាតិកម្ពុជាចំពោះកិច្ចការដ៏ល្អប្រសើរក្នុងឆ្នាំ ២០២១ ក្នុងការស៊ើបអង្កេតទៅលើរាល់បទល្មើសលើកុមារ។ ខណៈអត្រាឃាត់ខ្លួន ៨៥% ក្នុងករណីសរុបចំនួន ៣១៣ ករណី គឺជាសមិទ្ធផលដ៏អស្ចារ្យ ហើយក៏បង្ហាញពីភាពប្តេជ្ញា និងការខិតខំប្រឹងប្រែងក្នុងការប្រឆាំងបទល្មើសលើកុមារ។ CPU បានបង្ហាញការប្តេជ្ញាក្នុងការផ្តល់ជូននូវសេវាកម្មល្អបំផុតជូនទៅដល់រាល់កុមារដែលបានរងគ្រោះពីបទល្មើស និងផ្តល់ជូននូវសេវាកម្មគាំទ្រ និងសេវាកម្មស៊ើបអង្កេតដែលល្អបំផុត។

លោក Jamesថ្លែងថា៖ «កិច្ចការ និងបេសកកម្មស៊ើបអង្កេតជាច្រើនត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០២១ ដែលនាំមកនូវលទ្ធផលដ៏ល្អប្រសើរ ហើយ CPU មានភាពរីករាយក្នុងការបន្តកិច្ចសហប្រតិបត្តិការជាមួយនគរបាលជាតិកម្ពុជា ដើម្បីទទួលបាននូវលទ្ធផលល្អប្រសើរទាំងនេះបន្តទៅមុខទៀត»៕

# ថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០២២

## ករណីវិជ្ជមានកូវីដ-១៩ក្នុងចំណោមពលករខ្មែរ ត្រឡប់ពីថៃមានថយចុះ ខណៈវិធានការនៅតែបន្តរឹតបន្តឹង

https://btv.com.kh/ 03/30/2022 09:03 AM

បាត់ដំបង៖ ពលករខ្មែរដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលតាមច្រកខេត្តបាត់ដំបងជាបន្តបន្ទាប់ ខណៈករណីរកឃើញវិជ្ជមានជំងឺកូវីដ-១៩ ក្នុងចំណោមពលករទាំងនោះ មានការថយចុះ ស្របពេលវិធានការសុខាភិបាលនៅច្រកព្រំដែននៅតែបន្តរឹតបន្តឹង។

លោកណាត ចាន់រ៉េត ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន ស៊ួនស៊ុ(អូរអន្លក់) ស្រុកកំរៀង បានថ្លែងឱ្យដឹងថា ដើម្បីទប់ស្កាត់ការចម្លងមេរោគកូវីដ-១៩ បំប្លែងថ្មីប្រភេទអូមីក្រុង វិធានការសុខាភិបាល នៅច្រកព្រំដែនត្រូវបានរឹតបន្តឹងដោយគ្មានការធ្វេសប្រហែសឡើយ ខណៈករណីវិជ្ជមានកូវីដ-១៩ក្នុងចំណោមពលករមានការថយចុះជាបន្តបន្ទាប់។ លោកបន្តថា បច្ចុប្បន្ននេះវិធានការសុខាភិបាលនៅច្រកព្រំដែនត្រូវបានកែសម្រួលដោយអ្នកដែលបានកាតចាក់វ៉ាក់សាំងចាប់ពី ២ដូសឡើងទៅត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញរៀងៗខ្លួនដោយពុំឆ្លងកាត់ការធ្វើតេស្តរហ័សឡើយ៕

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 30/03/2022 Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃពុធ ១៣ រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២២ ដោយអនុវត្តនតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងឃោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ ទៅទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១៩៣នាក់, ស្រី៧១នាក់ និងក្មេង២៥នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺវិជ្ជមានកូវីដ-១៩ ចំនួន៤នាក់ ស្រី២នាក់ ក្មេងម្នាក់ (ស្រី)។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន១៧៤នាក់ (ស្រី៦៥នាក់, ក្មេង២០នាក់) ចំណែកពលករចំនួន១៥នាក់ (ស្រី៤នាក់ ក្មេង៤នាក់) ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោ

យក្មេងចាប់ពីអាយុ ៥ឆ្នាំ ដល់ ១៨ឆ្នាំ ចំនួន៨នាក់ (ស្រី៤នាក់) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## នៅព្រឹកថ្ងៃពុធ អាជ្ញាធរស្រុកសំពៅលូន បន្តទទួល ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/03/30/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង០០នាទី នាថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៤នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ពៅ-ចំរើន (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង បានចំនួន០១លើក សរុបចំនួន១២៣នាក់ ស្រី៥៣នាក់ ក្មេង១៤នាក់ ក្មេងស្រី០៦នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីត្រួតពិនិត្យសម្ភារៈហាមឃាត់ (ចំពោះអ្នកត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក) តែមិនមាន។ រួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផល គឺអវិជ្ជមាន។ បន្ទាប់មកក្រុមគ្រូពេទ្យបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន១១៩នាក់ ស្រី៤៩នាក់ ក្មេង១៤នាក់ ក្មេងស្រី០៦នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ)។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្តែនអត់ចេញ ចំនួន០៤នាក់ (ស្រី) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កចំណុចរោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្ហោ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។